# ថ្ងៃទី០២ ខែ មិថុនា ឆ្នាំ២០២៣

# សម្តេចតេជោ ៖ ត្រូវធ្វើឲ្យកុមារយល់ដឹងវិធីរាយការណ៍ ចំពោះការរំលោភបំពានគ្រប់រូបភាព

https://dap-news.com/national/2023/05/31/336104/ ByPH104Posted on May 31, 2023

ភ្នំពេញ ៖ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា និងជាប្រធានកិត្តិយសក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ បានធ្វើការណែនាំដល់ភាគី ពាក់ព័ន្ធទាំងអស់ ត្រូវធ្វើយ៉ាងណាឲ្យកុមារ អាចយល់ដឹងអំពីវិធីរាយការណ៍ ដល់អាជ្ញាធរ ឬមនុស្សពេញវ័យជាអ្នកថែទាំពួកគេ ចំពោះការលោកបំពានគ្រប់រូបភាព ។ យោងតាមសារលិខិត របស់រាជរដ្ឋាភិបាល ក្នុងឱកាសខួបលើកទី៧៤ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី២២ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០២៣ សម្តេចតេជោបានថ្លែងថា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ត្រូវបន្តការសម្របសម្រួល និងពង្រឹងការអនុវត្តលិខិត បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការពារកុមារជាអន្តរក្រសួង ស្ថាប័នដៃគូអភិវឌ្ឍ សង្គមស៊ីវិល ប្រកបដោយប្រសិទ្ធភាព ជាពិសេសលើអនក្ខរកម្មបច្ចេកវិទ្យាពត៌មាន និងជំរុញលើកកម្ពស់ប្រជាជនកម្ពុជា ឲ្យក្លាយជាប្រជាជនឌីជីថលមានសុវត្ថិភាព និងឧត្តមប្រយោជន៍។

សម្តេចតេជោបន្តថា ក្រសួង ស្ថាប័ន គ្រប់ភាគីពាក់ព័ន្ធ រួមទាំងអាជ្ញាធរមាន សមត្ថកិច្ច មាតាបិតា អាណាព្យាបាល សហគមន៍ និងកុមារត្រូវសហការ ស្វែងរកដំណោះស្រាយ និងបង្កើតយុទ្ធសាស្ត្រផ្លាស់ប្តូរ ឥរិយាបទសង្គម តាមរយៈការទូន្មានប្រៀនប្រដៅបែបវិជ្ជមានចំពោះកុមារ និងត្រូវរួមគ្នាដោះស្រាយ ទប់ស្កាត់ការកេងប្រវ័ញ្ច និងរំលោភបំពានលើកុមារគ្រប់រូបភាពតាមប្រព័ន្ធអនឡាញឲ្យបានសមស្របនិងទាន់ពេលវេលា។

សម្តេចតេជោគូសបញ្ជាក់ថា «លើកកម្ពស់ការយល់ដឹងអំពីសុវត្ថិភាពតាមប្រព័ន្ធអនឡាញ និងភាពជាពលរដ្ឋឌីជីថលនិងពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការពារជនរងគ្រោះ ឲ្យមានប្រសិទ្ធភាព ។ ក្រសួង ស្ថាប័ន អាជ្ញាធរមូលដ្ឋាន សហគមន៍ និងពលរដ្ឋគ្រប់រូប ត្រូវចូលរួមអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ជាពិសេសចាត់វិធានការការពារកុមារពីអំពើហិង្សាគ្រប់រូបភាព អប់រំកុមារពីរបៀបការពារ ប្រឆាំងនឹងការរំលោភបំពាន ការបៀតបៀនផ្លូវភេទ តាមគ្រប់រូបភាព ការសម្លុតគំរាម កំហែងគ្រប់បែបយ៉ាង និងត្រូវធ្វើឲ្យកុមារអាចយល់ដឹង អំពីវិធីរាយការណ៍ដល់អាជ្ញាធរ ឬមនុស្សពេញវ័យដែលជាអ្នកថែទាំពួកគេ ចំពោះការលោកបំពានតាមគ្រប់រូបភាព»។

សម្តេចនាយករដ្ឋមន្ត្រី បានលើកឡើងទៀតថា ត្រូវបង្កើនកិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័ន អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ ក្នុងការបង្ការ ទប់ស្កាត់ អន្តរាគមន៍ និងផ្តល់សេវាឆ្លើយតបឲ្យបានសមស្រប និងទាន់ពេលវេលា ដើម្បីរួមចំណែកទប់ស្កាត់ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ កុមារតាមប្រព័ន្ធអនឡាញ និងលុបបំបាត់ពលកម្មកុមារនៅកម្ពុជា៕

## ជប៉ុន ផ្តល់៦៣ម៉ឺនដុល្លារ សម្រាប់លុបបំបាត់ អំពើហិង្សាលើកុមារ តាមសាលារៀន

https://dap-news.com/national/2023/05/30/335895/ ByPH104Posted on May 30, 2023

ភ្នំពេញ ៖ រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាប្រមាណ ៦៣៧,៨៣៨ ដុល្លារ សម្រាប់គម្រោងលុបបំបាត់អំពើហិង្សាលើកុមារ នៅតាមសាលារៀន ក្នុងខេត្តកំពង់ចាម។

ក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណង សម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន នាថ្ងៃទី២៩ ឧសភា លោក អ៊ូអិណុ អាត់ស៊ូស៊ី ឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា បានថ្លែងថា «រដ្ឋាភិបាលជប៉ុន ផ្តល់ថវិកាប្រមាណ ៦៣៧,៨៣៨ ដុល្លារអាមេរិក សម្រាប់គម្រោង ដែលអនុវត្តដោយអង្គការ Save the Children Japan (SCJ)។ នៅក្នុងឆ្នាំទី២ នៃគម្រោងនេះ ដោយបន្តសកម្មភាព ពីឆ្នាំទី១ មកអង្គការ មានគោលបំណងលុបបំបាត់ អំពើហិង្សា លើកុមារ ដូចជាការដាក់ទណ្ឌកម្មលើរាងកាយ ការធ្វើបាប និងការប្រើប្រាស់ភាសា រំលោភបំពាន នៅក្នុងសាលារៀនរដ្ឋចំនួន៤៣ នៅក្នុងខេត្តកំពង់ចាម»។

លោកបន្តថា ដើម្បីរក្សាបានមុខងារប្រកប ដោយប្រសិទ្ធភាព នៃប្រព័ន្ធការពារកុមាររួមទាំងយន្តការ សម្រាប់ការរាយការណ៍នៅតាមសាលារៀន និងតំបន់ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំទី១ នៃគម្រោង អង្គការនឹងអនុវត្តសកម្មភាព លើកកម្ពស់ការយល់ដឹង និងចូលរួមក្នុងការបង្កើតប្រព័ន្ធ និងការតស៊ូមតិផ្នែក គោលនយោបាយ ដោយមានការសហការពីភាគីពាក់ព័ន្ធ ក្នុងសាលារៀនរួមមាន ៖ កុមារ និងមន្ត្រីរដ្ឋាភិបាលកម្ពុជា ទាំងថ្នាក់ជាតិនិងថ្នាក់ខេត្ត ។ តាមរយៈគម្រោងនេះ លោកទូត សង្ឃឹមថា កុមារនៅកម្ពុជានឹងអាចសិក្សាក្នុងបរិស្ថាន គ្មានអំពើហិង្សាដែលមានសុវត្ថិភាព និងមានលក្ខណៈបរិយាបន្នជាង មុនដែលនឹងនាំឲ្យមានភាពប្រសើរឡើងនូវការលូតលាស់ប្រកបដោយសុខភាពល្អ និងសុខុមាលភាពរបស់កុមារ។

សូមរំលឹកថា រដ្ឋាភិបាលជប៉ុន បាននិងកំពុងផ្តល់ជំនួយឥតសំណង ដល់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ចាប់តាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រគម្រោង អភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរបស់ពួកគេ ដែលត្រូវបានអនុវត្តក្នុងប្រទេស ឬតំបន់កំពុងអភិវឌ្ឍន៍។ ក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ ស្ថានទូតជ

ប៉ុនបាន ផ្តល់ជំនួយជាង១៤០គម្រោងនៅកម្ពុជា តាមរយៈកម្មវិធីនេះ។ គម្រោងទាំងនេះ បានចូលរួមចំណែក ដោយផ្ទាល់ក្នុងការកែលម្អ គុណភាពជីវិតរបស់ប្រជាជនកម្ពុជា ៕

## ឃាត់ខ្លួនជនជាតិបង់ក្លាដែសច្រើននាក់ ដែលលួចឆ្លងដែនពីកម្ពុជាទៅថៃ

https://kohsantepheapdaily.com.kh/article/1746920.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram បន្ទាយមានជ័យ៣១ ខែ ឧសភា ឆ្នាំ ២០២៣ ម៉ោង ១៣:៤១

ខេត្តបន្ទាយមានជ័យ ៖ បុរសជនជាតិបង់ក្លាដែសចំនួន១១នាក់ ដែលលួចឆ្លងដែនពីកម្ពុជាចូលទៅប្រទេសថៃ កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣ នៅចំណុចព្រំដែន ស្ថិតក្នុងភូមិបន្ទាយទី២ ឃុំអូរសំព័រ ស្រុកម៉ាឡៃ ត្រូវបានឃាត់ខ្លួន ។

លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការនគរបាលរការពារព្រំដែនគោកលេខ៨១៥ បានប្រាប់ថា ការឃាត់ខ្លួនជនជាតិបង់ក្លាដែសនេះ ត្រូវបានអនុវត្តដោយកម្លាំងនគរបាលការពារព្រំដែនគោកលេខ៨១៥ សហការជាមួយកម្លាំងយោធាតំបន់ប្រតិបត្តិការសឹករងស្រុកម៉ាឡៃ និងកម្លាំងអធិការដ្ឋាននគរបាលស្រុកម៉ាឡៃ ដែលចេញល្បាតតាមព្រំដែន បានប្រទះឃើញជនជាតិបង់ក្លាដែសចំនួន១១នាក់សុទ្ធតែជាបុរស មានស្ពាយបាឡូគ្រប់គ្នា ។ ពួកគេមានបំណងលួចឆ្លងដែនពីកម្ពុជាឆ្ពោះទៅប្រទេសថៃតាមច្រករបៀងខុសច្បាប់ ។ ក្រោយពេលឃាត់ខ្លួន ក៏បាននាំយកមកទីបញ្ជាការរការពារព្រំដែនគោកលេខ៨១៥ ដើម្បីធ្វើការសាកសួរ ។ លោកបានបញ្ជាក់ថា ក្រោយកម្លាំងចម្រុះឃាត់ខ្លួន និងបាននាំមកសាកសួរ បានបង្ហាញថា ពួកគេទាំង១១នាក់មានលិខិតឆ្លងដែន (ប៉ាស្ព័រ) ទាំង១១នាក់ តែមិនដឹងថា មូលហេតុអ្វីនាំគ្នាមកលួចឆ្លងដែនល្មើសច្បាប់នៅតាមបន្ទាត់ព្រំដែនស្រុកម៉ាឡៃនោះទេ? ។ ក្រោយសាកសួរហើយ រៀបចំនីតិវិធីប្រគល់ជូនអធិការដ្ឋាននគរបាលស្រុកម៉ាឡៃ ដើម្បីអនុវត្តនីតិវិធីបន្ត ។

លោកវរសេនីយ៍ឯក បេន សំអាត អធិការនគរបាលស្រុកម៉ាឡៃបានប្រាប់ថា ជនជាតិបង់ក្លាដែសចំនួន១១នាក់ ដែលមានបំណងលួចឆ្លងដែនចេញពីកម្ពុជាចូលទៅប្រទេសថៃ ក្រោយសាកសួរបានឱ្យដឹងថា ពួកគេមកតាម រយៈមេខ្យល់ជូនដាក់ព្រំដែនកម្ពុជា ហើយឆ្លងដែនចូលទៅមេខ្យល់ថៃរង់ចាំទទួលនៅអូរព្រំដែន តែកម្លាំងចម្រុះល្បាតឃើញទាន់ ក៏បានឃាត់ខ្លួនពួកគេតែម្តង ៕

# រាជរដ្ឋាភិបាលកម្ពុជា
# ចេញសារាចរស្ដីពីការរៀបចំខួបលើកទី៧៤ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី២២ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៣

http://nokorwatnews.com/archives/1006108 01/06/2023

ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣ បានចេញសារាចរស្តីពីការរៀបចំខួបលើកទី៧៤ ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី២២ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៣។ នៅក្នុងសារាចររបស់រាជរដ្ឋាភិបាល បានបញ្ជាក់ថា អស់រយៈពេល៣ឆ្នាំមកហើយ ដែលកម្ពុជា បានអាកខានរៀបចំទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី២២ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជា ដោយសារតែការឆ្លងរីករាលដាលជំងឺកូវីដ១៩។

ខួបលើកទី៧៤ ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី២២ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៣ ត្រូវបានប្រារព្ធធ្វើឡើងក្រោមប្រធានបទ «យើងរួមគ្នាថែរក្សាការពារ និងអភិវឌ្ឍកុមារគ្រប់រូបក្រោមម្លប់សន្តិភាពក្នុងយុគ្គសម័យឌីជីថល» និង «យុត្តិធម៌សង្គមសម្រាប់គ្រប់គ្នាបញ្ចប់ពលកម្មកុមារ»។ ការប្រារព្ធទិវាកុមារអន្តរជាតិ១មិថុនា គឺជាការបង្ហាញនូវឆន្ទៈនិងការប្តេជ្ញាចិត្តយ៉ាងមុះមុតរបស់ រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកស្ទួយសុខុមាលភាព សិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារកម្ពុជា ដែលកម្ពុជា បានផ្តល់សច្ចាប័នលើលិខិតុបករណ៍អន្តរជាតិនិងមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជា ច្បាប់កំពូលរបស់ជាតិ លើសពីនេះផងដែរក៏សូមរំលឹកនូវព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនៃរបបវិនាសកម្មរបស់ ពួកហ្វាសស៊ីសអ៊ីត្លែរ ដែលបានកាប់សម្លាប់ស្ត្រីនិងកុមារនៅភូមិលីឌីសែនៃប្រទេសឆេកូស្លូវ៉ាគី និងនៅភូមិអូរាឌូនៃប្រទេសបារាំង ក្នុងអំឡុងឆ្នាំ១៩៤២-១៩៤៤ នៃសង្គ្រាមលោកលើកទី២ ព្រមទាំងរួមគ្នាទប់ស្កាត់អំពើហិង្សា ថែរក្សាសន្តិភាពពិភពលោក និងជំរុញការអនុវត្តសិទ្ធិកុមារនៅលើសកលលោក។

ការប្រារព្ធទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា គឺជាការបង្កើនចលនាពិភពលោកប្រឆាំង ពលកម្មកុមារ ដែលបានស្តែងឱ្យឃើញតាមរយៈការផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ ១៨២ ស្តីពីការហាមប្រាមនិងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និង អនុសញ្ញាលេខ១៣៨ ស្តីពីអាយុអប្បបរមាសម្រាប់ចូលធ្វើការដោយប្រទេសជាច្រើនលើពិភពលោក សំដៅ ទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរ ដូចជា ទាសករកុមារ ការជួញដូរកុមារ ពេស្យាចារកុមារ និងការប្រើកុមារក្នុងជម្លោះប្រដាប់អាវុធ និងក្នុងស្ថានភាពគ្រោះថ្នាក់ការងារផ្សេងៗ។

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ១០ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ២២នាក់

https://freshnewsasia.com/index.php/en/localnews/293636-2023-06-01-03-38-26.html 2023-06-01 10:38am

(ភ្នំពេញ)៖ គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី៣០ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ១០ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ២២នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣ រួមមាន៖

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៩១៦ករណី មានមនុស្ស ២,៣១៥នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៨៦៧សំណើ និងបិទសំណុំរឿង ២៩៤សំណើ (រកឃើញមនុស្ស ១,៣២៨នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣៥នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៤៩ករណី។

# ថ្ងៃទី០៥ ខែ មិថុនា ឆ្នាំ២០២៣

## សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន
## ផ្តល់អនុសាសន៍ ៨ចំណុច ក្នុងឱកាសខួបលើកទី៧៤ ទិវាកុមារអន្តរជាតិ ១មិថុនា និងខួបលើកទី២១ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជា

http://nokorwatnews.com/archives/1006164 03/06/2023

ភ្នំពេញ ៖ សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច តំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីក្នុងពិធីអបអរសាទរខួបលើកទី៧៤ ទិវាកុមារអន្តរជាតិ និងទិវាកុមារកម្ពុជា ១មិថុនា ក្រោមប្រធានបទ «យើងរួមគ្នាថែរក្សា ការពារ និងអភិវឌ្ឍន៍កុមារ គ្រប់រូប ក្រោមម្លប់សន្តិភាពក្នុងយុគសម័យឌីជីថល» និងខួបលើកទី២២ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា ក្រោមប្រធានបទ «យុត្តិធម៌សង្គមសម្រាប់គ្រប់គ្នា ដើម្បីបញ្ចប់ពលកម្មកុមារ» ដែលពិធីបានរៀបចំឡើងនៅសាលមហោស្រពនៃមជ្ឈមណ្ឌលសន្និបាត

និងពិពណ៌កោះពេជ្រ នាព្រឹក ថ្ងៃព្រហស្បតិ៍ ១៣កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣ ។

ថ្ងៃក្នុងឱកាសនោះ សម្តេចកិត្តិសង្គហបណ្ឌិត បានពាំនាំនូវការផ្តាំផ្ញើរសាកសួរសុខទុក្ខពីសំណាក់សម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ជូនដល់អង្គពិធី ដោយក្តីនឹករលឹក និងការគិតគូរសុខទុក្ខប្រជាពលរដ្ឋនៅទូទាំងប្រទេស ។ សម្តេចកិត្តិសង្គហបណ្ឌិតបានបន្តទៀតថា រាជរដ្ឋាភិបាលបានអនុវត្តយ៉ាងពេញលេញ និងមានចក្ខុវិស័យច្បាស់លាស់ក្នុងការលើកកម្ពស់សិទ្ធិ និងឧត្តមប្រយោជន៍ របស់កុមារ ដោយធ្វើយ៉ាងណាឱ្យកុមារ ក្រុមគ្រួសារ និងសហគមន៍ទទួលបាននូវគុណភាព គុណតម្លៃ និងគុណធម៌នៃការរស់នៅ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ សមភាព និងសុវត្ថិភាពស្របតាមរដ្ឋធម្មនុញ្ញ និងគោលការណ៍នីតិរដ្ឋ ព្រមទាំងចូលរួមយ៉ាងសកម្មស្មើភាពគ្នាក្នុងតម្លាភាពសង្គម ព្រមទាំងជំរុញឱ្យមានការអភិវឌ្ឍគ្រប់វិស័យនិងគ្រប់កម្រិត។ ក្នុងន័យនេះ យើងមានបេសកកម្មរួមគ្នាមួយគឺការចូលរួមពីគ្រប់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការជាតិ អន្តរជាតិ គ្រួសារ សហគមន៍ រួមទាំងកុមារ ដើម្បីធ្វើឱ្យការអនុវត្តច្បាប់ ផែនការយុទ្ធសាស្ត្រជាតិ គោលនយោបាយ បទដ្ឋាន គតិយុត្ត និងកម្មវិធីនានា សម្រេចបានប្រកប ដោយប្រសិទ្ធភាព និងប្រសិទ្ធផល ព្រមទាំងបន្តយកចិត្តទុកដាក់លើកកម្ពស់ការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិកុមារ និងច្បាប់អន្តរជាតិពាក់ព័ន្ធ។

ដើម្បីចាត់វិធានការឱ្យកាន់តែមានប្រសិទ្ធភាព និងនិរន្តរភាពចំពោះការអភិវឌ្ឍសិទ្ធិកុមារ ក៏ដូចជាសារាចរលេខ០៦សរ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ក្នុងនាម រាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមផ្តល់នូវអនុសាសន៍មួយចំនួន ដូចតទៅៈ

១. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ត្រូវបន្តសម្របសម្រួលជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ សង្គមស៊ីវិល លើការអនុវត្ត អនុសញ្ញាស្តីពីសិទ្ធិកុមារ ដោយបន្តធ្វើការផ្សព្វផ្សាយនិងពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការការពារ កុមារប្រកបដោយប្រសិទ្ធភាព ជាពិសេសគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩ រួមទាំងសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជំរុញការអនុម័តច្បាប់ស្តីពីកិច្ចការពារកុមារនៃព្រះរាជាណាចក្រកម្ពុជា។

២. ក្រសួង ស្ថាប័ន គ្រប់ភាគីពាក់ព័ន្ធ រួមទាំងអាជ្ញាធរមានសមត្ថកិច្ច មាតាបិតា អាណាព្យាបាល និងសហគមន៍ ត្រូវសហការ ស្វែងរកដំណោះស្រាយ បង្កើតយុទ្ធសាស្ត្រផ្លាស់ប្តូរឥរិយាបទសង្គមតាមរយៈការអប់រំ ទូន្មានប្រៀនប្រដៅបែបវិជ្ជមានចំពោះកុមារ និងត្រូវរួមគ្នាបង្ការ ការពារ និងអន្តរាគមន៍អំពើហិង្សាលើកុមារគ្រប់រូបភាពឱ្យបានសមស្រប ទាន់ពេលវេលា ជាពិសេសពង្រឹងការ

អនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ដើម្បីសម្រេចបាន តាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងផែនការសកម្មភាពរបស់អាស៊ានស្តីពីអំពើហិង្សា លើកុមារ។

៣. ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល ត្រូវយកចិត្តទុកដាក់បង្កើននូវការចូលរួមរបស់កុមារនិងយុវជនឲ្យបានគ្រប់កម្រិត ជាពិសេសរាល់ ពេលរៀបចំច្បាប់ គោលនយោបាយ លិខិតបទ ដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធដល់ការរស់រានមាន ជីវិត តម្រូវការ បញ្ហាប្រឈម និងការព្រួយបារម្ភណ៍របស់ពួកគាត់។

៤. ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល ត្រូវចូលរួមចាត់វិធានការការពារ កុមារពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដោយធ្វើការផ្សព្វផ្សាយដល់យុវជននិងកុមារ មាតាបិតា និងអ្នកថែទាំកុមារ រួមទាំងកម្លាំងសេវាសង្គមអំពីសុវត្ថិភាព កុមារតាមប្រព័ន្ធអនឡាញ ឲ្យយល់ដឹង ពីទម្រង់ហានិភ័យនៃប្រព័ន្ធអនឡាញ ចេះកំណត់មុខងារសុវត្ថិភាពនិងឯកជនភាព ព្រមទាំងវិធី រាយការណ៍ និងការប្រើប្រាស់ថ្នាលកម្មវិធីប្រកបដោយសុវត្ថិភាព។

៥. ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបន្តអនុវត្តអនុសញ្ញាស្នូលនៃអង្គការអន្តរជាតិខាងការងារ ដើម្បីលុបបំបាត់គ្រប់ទម្រង់នៃពលកម្មកុមារ រួមមានការលើកកម្ពស់ការយល់ដឹង ការបណ្តុះបណ្តា ល ការផ្សព្វផ្សាយ និងពង្រឹងវិធានការអធិការកិច្ចក្នុងការដកហូតកុមារពីទម្រង់ពលកម្ម។

៦. គ្រប់ស្ថានីយវិទ្យុ ទូរទស្សន៍របស់រដ្ឋ និងឯកជន ព្រមទាំងប្រព័ន្ធផ្សព្វផ្សាយសង្គមនានា បន្តជួយផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីការការពារកុមារពីការជួញដូរ ការកេងប្រវ័ញ្ចគ្រប់ទម្រង់ អំពើហិង្សា និងការរំលោភបំពានកុមារតាមប្រព័ន្ធអនឡាញ ជាពិសេសពង្រឹងគុណភាពនៃការ ផលិតកម្មវិធីសម្រាប់កុមារប្រកបដោយខ្លឹមសារអប់រំ ដើម្បីបង្ការទប់ស្កាត់កុំឱ្យកុមារក្លាយជាជនរង គ្រោះ។

៧. ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល ត្រូវអនុវត្តសារាចរលេខ០៦សរ ចុះ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការអនុវត្តអនុសាសន៍របស់ គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការ សហប្រជាជាតិ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

៨. ចំពោះក្មួយៗកុមារ និងយុវជន ត្រូវបង្កើនស្វ័យសិក្សាក្នុងយុគសម័យឌីជីថល មានមូល ដ្ឋានគ្រឹះរឹងមាំ មានគុណសម្បត្តិនិងឥរិយាបថវិជ្ជមាន មានចំណេះដឹងទូលំទូលាយលើបំណិនត្រិះ រិះពិចារណា, បំណិនផ្នែកនវានុវត្តន៍និងចេះដោះស្រាយបញ្ហា, បំណិនផ្នែកកំព្យូទ័រ, បំណិនផ្នែក ជ្រើសរើសជំនាញ, បំណិន ផ្នែកសហការនិងធ្វើការងារជាក្រុម, បំណិនផ្នែកយល់ដឹងពីវប្បធម៌ផ្សេ ងៗ, បំណិនសិក្សាដោយខ្លួនឯងពេញមួយជីវិត, និងបំណិនផ្នែកភាពជាអ្នកដឹកនាំ ជាពិសេសត្រៀម

ខ្លួនសម្រាប់ទីផ្សារការងារក្នុងយុគសម័យឌីជីថលនេះ។ ទន្ទឹមនេះដែរ កុមារនិងយុវជន ត្រូវចេះស្វែងរកព័ត៌មានឲ្យបានត្រឹមត្រូវលើអ៊ីនធឺណិត ចេះប្រើប្រាស់និងចែករំលែកព័ត៌មានតាមប្រព័ន្ធអនឡាញ យល់ដឹងពីសុវត្ថិភាពនៃបច្ចេកវិទ្យា និងបង្កើតមាតិកាឌីជីថល ព្រមទាំងចែករំលែកប្រកបដោយក្រមសីលធម៌។

ជាចុងក្រោយ សម្តេចកិត្តិសង្គហបណ្ឌិត បាននាំយកថវិការបស់សម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិតចំនួន ៧៣.១៦០.០០រៀល ឧបត្ថម្ភកម្មវិធី រួមមាន៖

១. កុមារា កុមារី សិស្ស និស្សិត ចំនួន ២.៣៥៣នាក់ ក្នុងម្នាក់ៗ ថវិកា ២ម៉ឺនរៀល

២. លោកគ្រូ អ្នកគ្រូ បុគ្គលិកថែទាំកុមារ ចំនួន ៣០២នាក់ ក្នុងម្នាក់ៗ ថវិកា ៥ម៉ឺនរៀល

៣. ឧបត្ថម្ភក្រុមសិល្បៈ ១លានរៀល

៤. គណៈកម្មការរៀបចំកម្មវិធី ១០លានរៀល ៕

## ប្រតិបត្តិការពិភពលោក Global Chain ចាប់បានបណ្តាញជួញដូរមនុស្ស ២១២នាក់

https://www.rfi.fr/km//20230601-?ref=tgi ចុះផ្សាយនៅថ្ងៃ៖ 01/06/2023 - 17:39

ប្រតិបត្តិការពិភពលោក ប្រឆាំងនឹងបណ្តាញជួញដូរមនុស្ស សហដឹកនាំដោយក្រុមប៉ូលិស Interpol Frontex និង Europol ចាប់បានជនសង្ស័យចំនួន២១២នាក់ និងកំណត់អត្តសញ្ញាណជនរងគ្រោះបាន១៤២៦នាក់ នៅក្នុង៤៤ប្រទេស។ ជនរងគ្រោះ ដែលខ្លះជាក្មេងមិនទាន់ពេញវ័យ ត្រូវបានបណ្តាញជួញដូរមនុស្សចាប់បង្ខំឱ្យរកស៊ីលក់ខ្លួន ធ្វើការជាទម្ងន់ ដើរសុំទាន លួចឆក់ ឬរកស៊ីខុសច្បាប់ ។

ប្រតិបត្តិការGlobal Chain មានទិសដៅចាប់ក្រុមឧក្រិដ្ឋជនរកស៊ីជួញដូរទាក់មនុស្សមកពី អាហ្វ្រិក អាស៊ី អាមេរិកខាងត្បូង និងតំបន់បាល់កង់ឬអ៊ុយក្រែន និងផ្តល់ការការពារដល់ជនរងគ្រោះដែលធ្លាក់ជានុយរបស់បណ្តាញជួញដូរមនុស្ស។ នេះបើតាមសេចក្តីថ្លែងការណ៍របស់ប៉ូលិសអឺរ៉ុបអាំងទែរប៉ូល។ ដឹកនាំដោយអូទ្រីសនិងរ៉ូម៉ានី ប្រតិបត្តិការមានប្រើកម្លាំងជានាយប៉ូលិស គយ ឆ្មាំព្រំដែន ចំនួន១៣០០០នាក់ ចេញធ្វើអន្តរាគមផ្ទាល់កន្លែងចំនួន២៥៤០០ដង និងឆែកមនុស្សចំនួន១,៦លាននាក់ នៅតាមច្រកព្រំដែន តាមផ្លូវ តាមស្ថានីយ៍រថភ្លើងឬអាកាសយានដ្ឋាន។ នៅទីបំផុត ពីថ្ងៃទី៨ដល់១៥ឧសភា ២០២៣ អាជ្ញាធរប៊ុលហ្គារី ចាប់ខ្លួនគេរវជនសង្ស័យម្នាក់ជាប់បញ្ជីInterpol តាំងពីឆ្នាំ ២០១៥មក ដែលប្រើលិខិតឆ្លងដែនក្លែងក្លាយ។

របាយការណ៍របស់Interpolដដែលបានលម្អិតអំពីប្រតិបត្តិការចាប់ក្រុមជួញដូរមនុស្ស ៦នាក់ នៅស៊ែរប៊ី ដែលបង្ខំឱ្យស្ត្រី១០នាក់រកស៊ីលក់ខ្លួន ១១ករណីនៅម៉ាសេដ្វានខាងជើង ៧ករណីនៅកូឡុំប៊ី ជាបណ្តាញផ្លូវភេទក្មេងមិនទាន់ពេញវ័យ។ នៅរ៉ូម៉ានី ការបំបែកបណ្តាញជួញដូរមនុស្សឱ្យមកធ្វើការដោយបង្ខំ អាចជួយជនរងគ្រោះបាន៨នាក់ និងការចាប់ខ្លួនបួនករណី ព្រមទាំងជួយរំដោះក្មេងពីការដើរសុំទានបាន៥នាក់ នៅក្នុងប្រទេសស៊ុយអែត។ ក្រុមឧក្រិដ្ឋជនចូលចិត្តទាក់ក្មេងព្រោះងាយយកចំណេញ និងងាយប្រើ។ នេះបើតាមសេចក្តីថ្លែងការណ៍របស់អគ្គនាយកInterpol ដោយពន្យល់ថា ប្រតិបត្តិការGlobal Chain បានអនុញ្ញាតឱ្យប៉ូលិសអាចរែករកឃើញដានសម្រាប់ប្រយុទ្ធប្រឆាំងនឹងបណ្តាញរបស់ក្រុមជួញដូរមនុស្ស។ ក្រៅអំពីប្រទេសនៅអឺរ៉ុប ប្រតិបត្តិការ Global Chain ក៏មានចូលរួមដោយប្រទេសផ្សេងទៀតដូចជាអ៊ីស្លង់ អង់គ្លេសសហរដ្ឋអាមេរិក ម៉ារ៉ុក ប្រេស៊ីល នីហ្សេរីយ៉ា ហ្វីលីពីន បង់ក្លាដែស និងវៀតណាម។

## ប្រទេសថៃអនុញ្ញាតឱ្យពលករបរទេស រួមទាំងពលករខ្មែរបន្តស្នាក់នៅ និងធ្វើការរហូតដល់រដ្ឋាភិបាលថ្មីត្រូវបានបង្កើត

https://www.khmertimeskh.com/501301077// Khmer Times June 2, 2023

យោងតាមរបាយការណ៍របស់ Bangkok Post គណៈរដ្ឋមន្ត្រីថៃ បានអនុម័តលើការបន្តកិច្ចសន្យាការងារ ដែលនឹងអនុញ្ញាតឱ្យពលករចំណាកស្រុកជាង ២០០,០០០ នាក់បន្តធ្វើការងាររហូតដល់រដ្ឋាភិបាលថ្មីចូលកាន់តំណែង។

លោកឧបនាយករដ្ឋមន្ត្រី Wissanu Krea-ngam បានអោយដឹងថា គណៈរដ្ឋមន្ត្រីបានផ្តល់ភ្លើងខៀវឱ្យពលករពីប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ាបន្តធ្វើការងារ។ លោក Wissanu បាននិយាយថា មុននេះគណៈរដ្ឋមន្ត្រីថៃ បានច្រានចោលសំណើរបស់ក្រសួងការងារសម្រាប់ការពន្យារពេលនេះ ដោយបារម្ភថា វានឹងបង្កើតបន្ទុកនៃការទទួលខុសត្រូវសម្រាប់រដ្ឋាភិបាលថ្មី។ ប៉ុន្តែគណៈរដ្ឋមន្ត្រីបានផ្លាស់ប្តូរចិត្ត និងបានអនុម័តលើការពន្យារពេលនេះ ដោយសារភាពមិនច្បាស់លាស់ដែលបន្តកើតមានលើការបង្កើតរដ្ឋាភិបាលដែលអាចប៉ះពាល់ដល់ពលកម្មការងារ។

លោក Wissanu បាននិយាយថា ប្រសិនបើការពន្យារពេលនេះមិនត្រូវបានអនុម័តនោះទេ ពលករចំណាកស្រុកនឹងត្រូវត្រឡប់ទៅផ្ទះវិញ ហើយរង់ចាំរហូតដល់រដ្ឋាភិបាលឡើងកាន់អំណាច ទើបពួកគេអាចត្រឡប់មកធ្វើការនៅប្រទេសថៃវិញបាន។ លោកបានទទូចថា ការបន្តកិច្ចសន្យានេះមានសុពលភាពដរាបណារដ្ឋាភិបាលបច្ចុប្បន្ននៅតែបន្តកាន់តំណែង។ វិធានការនេះនឹងត្រូវបានពិនិត្យឡើងវិញនៅពេលរដ្ឋាភិបាលថ្មីឡើងកាន់តំណែង។ លោកបានបន្តថា "ប្រសិនបើសុពលភាព

ការងាររបស់ពលករចំណាកស្រុកមិនត្រូវបានបន្តទេ នគរបាលនឹងធ្វើការបង្ក្រាប ហើយម្ចាស់អាជីវកម្មនឹងភ័យខ្លាចក្នុងការជួលពលករចំណាកស្រុក”។

## ប្រធានអន្តោប្រវេសន៍ថៃថា ជនសង្ស័យជនជាតិចិន ដែលចាប់ខ្លួន បានលាងលុយ ២,៥ ពាន់លានបាត ពីការឆបោកតាមទូរស័ព្ទ ធ្វើសកម្មភាពនៅកម្ពុជា

https://dap-news.com/international/2023/06/02/336630/ ByPH104Posted on June 2, 2023

បរទេស ៖ ការិយាល័យអន្តោប្រវេសន៍ថៃ បានប្រកាសពីការចាប់ខ្លួនបាន អ្នកលាងលុយកខ្វក់ តាមប្រព័ន្ធទូរស័ព្ទជនជាតិចិនម្នាក់ និងជនសង្ស័យគ្រឿងញៀនម្នាក់ទៀតមកពីប្រទេសកូរ៉េខាងត្បូង ។ ការតាមចាប់ខ្លួនជនជាតិឈ្មោះ Xu Wei អាយុ ៤០ឆ្នាំ និងឈ្មោះ Kim Junbeom អាយុ ២៦ ឆ្នាំត្រូវបានប្រកាសនៅក្នុងសន្និសីទសារព័ត៌មាននៅសណ្ឋាគារ Briton Grand ក្នុងទីក្រុង Pattaya កាលពីថ្ងៃពុធ។

យោងតាមសារព័ត៌មានថៃ បាងកក ប៉ុស្តិ៍ ចេញផ្សាយនៅថ្ងៃទី១ ខែសភា ឆ្នាំ២០២៣ បានឱ្យដឹងថា ស្នងការ នៃការិយាល័យអន្តោប្រវេសន៍ លោកឧត្តមសេនីយ៍ Pakphumpipat Sajjaphan បានប្រាប់សន្និសីទសារព័ត៌មានថា ជនសង្ស័យទាំងពីរនាក់ ត្រូវបានចោទប្រកាន់ថា ជាសមាជិកនៃក្រុមឧក្រិដ្ឋជនឆ្លងដែន ហើយត្រូវបានចាប់ខ្លួនតាមដីការបស់ប៉ូលិស អាំងទែរប៉ូល ។

ប្រធានផ្នែកអន្តោប្រវេសន៍ថៃ បាននិយាយថា លោក Wei ត្រូវបានចោទប្រកាន់ពីបទលាងលុយកខ្វក់ចំនួន ២,៥ពាន់លានបាត តាមការឆបោកតាមទូរស័ព្ទ ដែលធ្វើប្រតិបត្តិការក្នុងប្រទេសកម្ពុជា។ លោកបាននិយាយថា ការិយាល័យបានពិនិត្យ ហើយបានរកឃើញថា Wei បានចូលប្រទេសថៃ កាលពីថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០២០ ជាមួយនឹងទិដ្ឋាការទេសចរណ៍ ហើយបានលាក់ខ្លួននៅខុនដូមួយក្នុងទីក្រុងប៉ាតាយ៉ា ជាកន្លែង ដែលគាត់ត្រូវបានចាប់ខ្លួន។ កាលបរិច្ឆេទនៃការចាប់ខ្លួនមិនត្រូវបានផ្តល់ឱ្យទេ ។

ប្រធានផ្នែកអន្តោប្រវេសន៍បាននិយាយទៀតថា លោក Wei ត្រូវបានចាប់ខ្លួនតាមដីកាចាប់ខ្លួននៅក្នុងប្រទេសចិន ហើយទិដ្ឋាការរបស់គាត់ត្រូវបានបញ្ចប់។ Wei ត្រូវបានគេសង្ស័យថាបានលាងលុយឱ្យក្រុមក្មេងទំនើងទៅជា bitcoins និងបានផ្ញើប្រាក់ឌីជីថលត្រឡប់ទៅប្រទេសចិនដើម្បីទិញមាសនិងអចលនទ្រព្យផ្សេងទៀត។ ប្រែសម្រួលៈ ណៃ តុលា

# ថ្ងៃទី០៦ ខែ មិថុនា ឆ្នាំ២០២៣

## សមត្ថកិច្ចកម្ពុជា បន្តទទួលបានបណ្ដឹង ២ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ២នាក់

https://freshnewsasia.com/index.php/en/localnews/293782-2023-06-02-08-21-29.html 2023-06-02 03:21pm

*(ភ្នំពេញ)៖ គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី៣១ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១ ខែមិថុនា ឆ្នាំ ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០២ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០២នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន* Fresh News*។ បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣ រួមមាន៖*

*១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្ដេចក្រឡាហោម សរុប ៩១៦ករណី មានមនុស្ស ២,១៩៨នាក់*

*២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៨៦៩សំណើ និងបិទសំណុំរឿង ២៩៥សំណើ (រកឃើញមនុស្ស ១,៣៣៧នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣៥នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)*

*៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៤៧ករណី៕*

## សម្ដេចតេជោ ហ៊ុន សែន ៖ នយោបាយរបស់អ្នកជាប់ឆ្នោតថ្មី របស់ប្រទេសថៃមួយរូប មិនទាន់នឹងបានធ្វើជានាយករដ្ឋមន្ត្រីថៃផង បែរជាចេញសារគំរាមបណ្ដេញពលករខ្មែរ ពលករឡាវ និងពលករមីយ៉ាន់ម៉ា ចេញពីប្រទេសខ្លួន

https://cen.com.kh/archives/665411.html Posted ByPen Srey NeatJune 3, 2023

*កណ្ដាល៖ នៅថ្ងៃសៅរ៍នេះ សម្ដេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា នយោបាយរបស់អ្នកជាប់ឆ្នោតថ្មីរបស់ប្រទេសថៃមួយរូប មិនទាន់នឹងបានធ្វើជានាយករដ្ឋមន្ត្រីថៃផង បែរជាចេញសារគំរាមបណ្ដេញពលករខ្មែរ ពលករឡាវ និងពលករមីយ៉ាន់ម៉ា ចេញពីប្រទេសខ្លួនទៅហើយ ខណៈនយោបាយបែបនេះ អាចនឹងធ្វើឲ្យរោងចក្រ សហគ្រាសរបស់ថៃមួយចំនួនដួលរលំផងដែរ។*

*ក្នុងឱកាសជួបសំណេះសំណាលជាមួយកម្មករនិយោជិតសរុបជិត២ម៉ឺននាក់ មកពីរោងចក្រសហគ្រាសនានានៅខេត្តកណ្ដាល កំពង់ស្ពឺ និងកំពង់ឆ្នាំង នាព្រឹកថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៣ សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានប្រតិកម្មលើគោលនយោបាយរបស់ប្រធាន*

គណបក្សឈ្នះឆ្នោតនៅប្រទេសថៃ ដែលចង់បណ្តេញពលករខ្មែរ និងពលករឡាវចេញពីប្រទេសថៃ ដោយសម្តេចបានផ្តាំទៅអ្នកនយោបាយទាំងនោះសូមមើលឱ្យឆ្ងាយពីប្រទេសថៃ ព្រោះការបណ្តេញពលករបរទេសចេញនេះ នឹងប៉ះពាល់ដល់ច្រវាក់ផលិតកម្មរបស់ថៃខ្លួនឯងទៅវិញទេ។ សម្តេចតេជោបានថ្លែងថា មិនទាន់បានអីផង អ្នកនយោបាយនៅប្រទេសថៃបានគំរាមបណ្តេញចេញនូវពលករខ្មែរ និងពលករឡាវទៅហើយ។ ខ្ញុំមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់អ្នកទេ ខ្ញុំគ្រាន់តែសង្ឃឹមថាអ្នកនឹងមើលឱ្យឆ្ងាយទៅហួសពីប្រទេសថៃ។

សម្តេចតេជោនាយករដ្ឋមន្ត្រី បានផ្តាំទៅក្រុមអ្នកនយោបាយឈ្នះឆ្នោត នៅប្រទេសថៃថា នយោបាយបណ្តេញពលករបរទេសចេញនេះ អាចនឹងបង្កគ្រោះថ្នាក់ដល់សេដ្ឋកិច្ចថៃ មិនគ្រាន់តែគ្រោះថ្នាក់ដល់ជីវភាពពលករខ្មែរ និងពលករឡាវប៉ុណ្ណោះទេ តែនឹងធ្វើឱ្យប៉ះពាល់ដល់ខ្សែច្រវាក់ផលិតកម្ម នៅតាមសហគ្រាសក្នុងប្រទេសថៃ ដែលកំពុងត្រូវការកម្លាំងពលកម្មជាចាំបាច់។ នយោបាយនេះប្រហែលជាមិនទទួលបានការគាំទ្រពីប្រទេសជិតខាង ដូចជា ប្រទេសឡាវ មីយ៉ាន់ម៉ា ក៏ដូចជាកម្ពុជានោះទេ។ អ្នកនយោបាយថៃគួរតែប្រុងប្រយ័ត្នចំពោះការដាក់ចេញ និងអនុវត្តនយោបាយរបស់ខ្លួននេះ។

សម្តេចតេជោ ហ៊ុន សែន បានបញ្ជាទៅកាន់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធដទៃទៀត ត្រូវបង្កើនការយកចិត្តទុកដាក់ និងដោះស្រាយបញ្ហាប្រឈមនានា របស់ពលករខ្មែរនៅប្រទេសថៃ ដោយសម្តេចតេជោក៏បានរំឭកពីអនុសាសន៍ទី១០ ក្នុងចំណោមអនុសាសន៍គោលទាំង១០ចំណុច ដែលមានការពាក់ព័ន្ធនឹងពលករខ្មែរនៅក្រៅប្រទេស។/ រក្សាសិទ្ធដោយ ៖ សុទ្ធលី

## អ្នកសុំទានខ្មែរចំណាកស្រុកខុសច្បាប់ ត្រូវចាប់ខ្លួននៅប៉ាតាយ៉ា

https://www.khmertimeskh.com/501301386//?p=1301386 June 3, 2023

មន្ត្រីនគរបាលជាង ៩០នាក់មកពីប៉ុស្តិ៍ Banglamung និង Pattaya បានរួមសហគ្នាដើម្បីបំបែកក្រុមក្មេងទំនើងដែលពាក់ព័ន្ធនឹងសកម្មភាពសុំទាននិងល្បែងស៊ីសងខុសច្បាប់។ ប្រតិបត្តិការនេះធ្វើឡើងនៅព្រឹកថ្ងៃទី២៧ ឧសភា ។ ជាដំបូង អាជ្ញាធរបានមានគោលដៅលើផ្ទះមួយខ្នងដែលមានទីតាំងស្ថិតនៅសង្កាត់ Sukhumvit Soi 7និងក្នុងសង្កាត់រង Nongprue។ នៅពេលនគរបាលបានចូលទៅដល់ គេបានឃើញផ្ទះពីរខ្នងប្រក់ដំបូលស័ង្កសីដែលមានរបងបិទជិត។ នៅពេលចូលដល់ក្នុងផ្ទះភ្លាម គេបានប្រទះនឹងស្ត្រីខ្មែរម្នាក់ដែលត្រូវនឹងការប្រកាសស្វែងរកចាប់ខ្លួន។ ភ្លាមៗនោះ មន្ត្រីនគរបាលបានបង្ហាញដីកាចាប់ខ្លួន និងផ្តល់រូបថតមួយសន្លឹក ដើម្បីបញ្ជាក់ពីអត្តសញ្ញាណរបស់គា

ត់។ នៅក្នុងផ្ទះទីមួយ ពួកគេក៏បានប្រទះឃើញកូនក្មេងចំនួនប្រាំនាក់ផងដែរ ដែលមានអាយុចន្លោះពី១ ទៅ ៨ឆ្នាំ។

ចំណែកផ្ទះទី២ មន្ត្រីក៏ប្រទះឃើញបុរសជនជាតិខ្មែរម្នាក់ និងស្ត្រីម្នាក់ និងកូន២នាក់ ។ ពុំមានឯកសារបញ្ជាក់អត្តសញ្ញាណផ្ទាល់ខ្លួនណាមួយ ត្រូវបានគេរកឃើញក្នុងពេលឆែកឆេរនោះទេ ទើបសមត្ថកិច្ចនាំខ្លួនជនទាំងអស់ទៅកាន់ប៉ុស្តិ៍នគរបាលBanglamung។ នៅទីតាំងទី២ ផ្ទះមួយកន្លែងឈ្មោះ Pornpimol ស្ថិតក្នុងសង្កាត់Soi Naklua 14 អាជ្ញាធរបានរកឃើញចំណុចគួរឱ្យកត់សម្គាល់ផ្សេងទៀត ។ ពួកគេបានរកឃើញមនុស្សពេញវ័យខ្មែរមួយក្រុមរួមនឹងកុមារចំនួន ១១ នាក់អាយុទើបកើតដល់អាយុ ៨ ឆ្នាំ រស់នៅជាមួយគ្នា។ ក្នុងចំណោមការរកឃើញរបស់ពួកគេ មានវត្ថុដែលជាធម្មតាទាក់ទងនឹងការសុំទានដូចជា ផ្តិល និងកាក់។ គេមិនបានរកឃើញឯកសារអត្តសញ្ញាណផ្ទាល់ខ្លួននៅទីតាំងនេះទេ។

ក្រោយពីបង្ហាញដីកាចាប់ខ្លួនសមត្ថកិច្ចបាននាំខ្លួនមនុស្សប្រុស២នាក់ ស្រី៣នាក់ទៅឃុំខ្លួន។ បុគ្គលម្នាក់បានប្រាប់អត្តសញ្ញាណខ្លួនឯងត្រឹមតែឈ្មោះ អូ អាយុ ២៧ ឆ្នាំ បានអះអាងថាធ្វើការនៅសណ្ឋាគារមួយដែលមិនទាមទារឯកសារអ្វីឡើយ។ គាត់ក៏បានសារភាពថា បុគ្គលមួយចំនួនមកពីក្រុមសុំទានបានចូលរួមលេងល្បែងបៀរក្នុងគោលបំណងកម្សាន្ត ដោយភ្នាល់លុយដែលពួកគេរកបានពីការសុំទាន។ ការស៊ើបអង្កេតបឋមបានបង្ហាញថា ក្រុមអ្នកសុំទានទាំងនេះបានចូលទីក្រុងដោយខុសច្បាប់ ដោយប្រើមធ្យោបាយផ្សេងៗ និងដាក់គោលដៅលើកុមារនៅតំបន់ដែលមានអ្នកទេសចរធ្វើដំណើរច្រើនដើម្បីសុំប្រាក់ ឬសុំការអាណិតអាសូរពីអ្នកស្រុក និងអ្នកទេសចរ។ ប្រាក់ចំណូលប្រចាំថ្ងៃរបស់ពួកគេមានចាប់ពី ៣០០ ទៅ ១,០០០បាត។

ដើម្បីដោះស្រាយស្ថានការណ៍នេះ មន្ត្រីបានសហការជាមួយការិយាល័យអភិវឌ្ឍន៍សង្គម និងសន្តិសុខប្រជាជនខេត្តឈុនបុរី និងមណ្ឌលកុមារខេត្ត ដើម្បីធ្វើការពិនិត្យបុគ្គល កត់ត្រាប្រវត្តិផ្ទាល់ខ្លួន និងស៊ើបអង្កេតបណ្តាញ និងទំនាក់ទំនងក្នុងចំណោមមនុស្សពេញវ័យដែលអះអាងថាជាឪពុកម្តាយរបស់កុមារទាំងនោះ។ ក្នុងករណីមិនមានទំនាក់ទំនងស្របច្បាប់ណាមួយទេ អាជ្ញាធរគ្រោងនឹងបន្តការចោទប្រកាន់ពីបទជួញដូរមនុស្ស។ ការស៊ើបអង្កេតបន្ថែមទៀតនឹងត្រូវបានអនុវត្តដើម្បីប្រមូលភស្តុតាងសម្រាប់ការចោទប្រកាន់បន្ថែម។ Pattaya Mail

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ៤ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៥នាក់

https://freshnewsasia.com/index.php/en/localnews/294073-2023-06-05-04-57-28.html 2023-06-05 11:57am

(ភ្នំពេញ)៖ គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី០៣ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៤ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០៥នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៣ រួមមាន៖

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៩២១ករណី មានមនុស្ស ២,៣២២នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៨៧១សំណើ និងបិទសំណុំរឿង ២៩៤សំណើ (រកឃើញមនុស្ស ១,៣៤១នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣៥នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៥០ករណី៕

## កម្ពុជា-អូស្ត្រាលី ឯកភាពគ្នាទប់ស្កាត់ការបោកប្រាស់ទាក់ទាញពលករកម្ពុជា ឱ្យទៅធ្វើការនៅអូស្ត្រាលីផ្នែកកសិកម្ម និងនេសាទ

https://freshnewsasia.com/index.php/en/localnews/294104-2023-06-05-08-15-38.html 2023-06-05 03:15pm

(ភ្នំពេញ)៖ ភាគីកម្ពុជា និងភាគីអូស្ត្រាលី បានឯកភាពសហការទប់ស្កាត់ការបោកប្រាស់ទាក់ទាញពលករពីកម្ពុជា ឱ្យទៅធ្វើការនៅប្រទេសអូស្ត្រាលីផ្នែកកសិកម្ម និងនេសាទ ខណៈប្រទេសទាំងពីរមិនទាន់មានកិច្ចព្រមព្រៀង ឬអនុស្សរណៈយោគយល់គ្នាលើការបញ្ជូន-ទទួលពលករកម្ពុជាធ្វើការនៅប្រទេសអូស្ត្រាលីនោះឡើយ។ ការឯកភាពនេះធ្វើឡើងក្នុងជំនួបពិភាក្សាការងាររវាងលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយលោក ចាស្ទីន ខេវីន វ៉ៃអាត់ (Justin Kevin Whyatt) ឯកអគ្គរដ្ឋទូតអូស្ត្រាលីថ្មីប្រចាំកម្ពុជា នាព្រឹកថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣ នៅទីស្តីការក្រសួងការងារ។ លោករដ្ឋមន្ត្រី អ៊ិត សំហេង និងឯកអគ្គរដ្ឋទូតអូស្ត្រាលី បានឯកភាពលើកិច្ចសហការទប់ស្កាត់ការបោកប្រាស់ទាក់ទាញពលករពីកម្ពុជា ឱ្យទៅធ្វើការនៅប្រទេសអូស្ត្រាលី ផ្នែកកសិកម្មនិង នេសាទ។

គួររំលឹកថា កន្លងមក ក្រសួងការងារបានចេញសេចក្ដីជូនដំណឹងរួចហើយ អំពាវនាវសូមឱ្យប្រជាពលរដ្ឋប្រុងប្រយ័ត្នអំពើឆបោក ដែលជនទុច្ចរិតជានាផ្ដល់ឱកាសការងារនៅប្រទេសអូស្ត្រាលី ដោយឱ្យប្រជាពលរដ្ឋបង់ប្រាក់ជាមុន ដែលរហូតមកដល់ពេលនេះ កម្ពុជានិងអូស្ត្រាលីមិនទាន់មានកិច្ចសហប្រតិបត្តិការលើការបញ្ជូនពលករកម្ពុជាឱ្យទៅធ្វើការនៅប្រទេសអូស្ត្រាលីនៅឡើយទេ។ លោករដ្ឋមន្ត្រី អ៊ិត សំហេង បានក្រើនរំលឹក និងអំពាវនាវសាជាថ្មីដល់ប្រជាពលរដ្ឋកម្ពុជាសូមកុំចាញ់បោកពួកមេខ្យល់ទាំងនោះ ហើយសូមចូលរួមសហការផ្ដល់ព័ត៌មានដល់ក្រសួងការងារ ប្រសិនបើមានភ្នាក់ងារជ្រើសរើសណាមួយធ្វើការជ្រើសរើស និងបញ្ជូនពលករធ្វើការនៅប្រទេសអូស្ត្រាលី៕

# ថ្ងៃទី០៧ ខែ មិថុនា ឆ្នាំ២០២៣

## ថៃបន្តកិច្ចសន្យាជាមួយពលករចំណាកស្រុកជាង ២០០.០០០នាក់

https://www.information.gov.kh/articles/106486 AKP ភ្នំពេញថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៣

សេចក្ដីសម្រេចមួយកាលពីពេលថ្មីៗនេះរបស់គណៈរដ្ឋមន្ត្រីថៃ ក្នុងការបន្តកិច្ចសន្យាការងារសម្រាប់ពលករចំណាកស្រុកជាង ២០០.០០០នាក់ បានបន្ធូរបន្ថយការព្រួយបារម្ភអំពីកង្វះកម្លាំងពលកម្មក្នុងស្រុក។

លោក ប៉ូច អារ៉ាមវឌ្ឍនានុន្ត (Poj Aramwattananont) អនុប្រធានសភាពាណិជ្ជកម្មថៃ និងជាប្រធានគណៈកម្មាធិការអភិវឌ្ឍការងារ និងជំនាញបាននិយាយថា ដោយផ្អែកទៅលើកិច្ចពិភាក្សាដែលបានធ្វើឡើងជាមួយសភា និងសហព័ន្ធឧស្សាហកម្មថៃ (FTI) គណៈរដ្ឋមន្ត្រីថៃបានអនុម័តទៅលើអនុស្សរណៈនៃការយោគយល់គ្នាមួយ ស្ដីពីពលករបរទេសមកពីប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា; ព្រមទាំងកិច្ចព្រមព្រៀងស្ដីពីពលករបរទេសមកពីប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម។ការអនុម័តនេះ គឺផ្អែកទៅលើដំណោះស្រាយមួយរបស់គណៈរដ្ឋមន្ត្រីចាប់ពីថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២២ និងមួយទៀតចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៣។ យោងតាមអ្នកនាំពាក្យរដ្ឋាភិបាលថៃ លោក អានុចា ប៊ូរ៉ាប៉ាឆៃស្រី (Anucha Burapachaisri) បានឱ្យដឹងថា ការអនុវត្តនេះ គឺមានបំណងពង្រឹងសន្តិសុខសេដ្ឋកិច្ច។ ការបន្ថែមនេះអនុវត្តចំពោះពលករចំណាកស្រុកដែលបានទៅប្រទេសថៃក្រោម MoU ទាក់ទងនឹងការងារដែលចុះហត្ថលេខាដោយរដ្ឋាភិបាល។

ទោះជាយ៉ាងណាក៏ដោយ លោក អានុចា បាននិយាយថា គណៈរដ្ឋមន្ត្រីបានផ្លាស់ប្ដូរគំនិតរបស់ខ្លួន ហើយបានអនុម័តលើការបន្តកិច្ចសន្យានាពេលនេះ ខណៈដែលភាពមិនប្រាកដប្រជានៃ

ការបង្កើតរដ្ឋាភិបាលកំពុងគំរាមកំហែងដល់ការបន្សល់ទុកនូវចន្លោះទំនេរដ៏ធំមួយ។ គណៈរដ្ឋមន្ត្រីពីមុនបានច្រានចោលសំណើរបស់ក្រសួងសម្រាប់ការពន្យារពេលកិច្ចសន្យានេះ ដោយបារម្ភថាវានឹងបង្កើតបន្ទុកនៃការទទួលខុសត្រូវដល់រដ្ឋាភិបាលថ្មី។ បើតាមឧបនាយករដ្ឋមន្ត្រីថៃ លោក វិស្សានុ គ្រាង៉ាម (Wissanu Krea-ngam) បានឱ្យដឹងថា បើគ្មានការពន្យាពេលកិច្ចសន្យានេះទេ ពលករចំណាកស្រុកត្រូវត្រឡប់ទៅផ្ទះវិញ ហើយរង់ចាំរហូតដល់មានរដ្ឋាភិបាលថ្មីចូលកាន់អំណាចទើបពួកគេអាចត្រឡប់ទៅធ្វើការនៅប្រទេសថៃវិញបាន៕ (ប្រភព VNA បកប្រែដោយលោក យា ចិន្តាខន្តី)

## សង្គមស៊ីវិលទទូចឲ្យក្រសួងមហាផ្ទៃស្វែងរកអ្នកនៅពីក្រោយខ្នងករណីជួញដូរមនុស្ស

https://www.rfa.org/khmer/news/human-rights/ngos-urged-interior-ministry-to-find-leaders-behind-human-trafficking-case-06042023084850.html ដោយ សេក បណ្ឌិត2023.06.04

មន្ត្រីអង្គការសង្គមស៊ីវិល នៅតែទទូចឲ្យក្រសួងមហាផ្ទៃមានវិធានការតឹងរ៉ឹង ក្នុងការស្វែងរកអ្នកនៅពីក្រោយខ្នង នៃការប្រព្រឹត្តបទល្មើសជួញដូរមនុស្ស។ ការលើកឡើងនេះ នៅបន្ទាប់ពីសមត្ថកិច្ចបានជួយសង្គ្រោះជនបរទេសចំនួន២២នាក់បន្ថែមទៀត។ មន្ត្រីអង្គការសង្គមស៊ីវិល នៅតែព្រួយបារម្ភអំពីករណីជួញដូរមនុស្សនៅកម្ពុជា ខណៈដែលក្រសួងមហាផ្ទៃ នៅតែទទួលពាក្យបណ្ដឹងឲ្យជួយសង្គ្រោះជនបរទេសស្ទើរជារៀងរាល់ថ្ងៃ ដែលអ្នកនោះ ជាជនរងគ្រោះក្នុងអំពើជួញដូរមនុស្ស ។ ប្រធានសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា(ADHOC) លោក នី សុខា ប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី២ ឧសភា ថា ទិន្នន័យដែលបង្ហាញពីចំនួនការជួញដូរមនុស្សនៅកម្ពុជា នៅតែស្ថិតនៅក្នុងចំនួនច្រើនគួរឲ្យព្រួយបារម្ភ។ លោកយល់ថា អំពើពុករលួយអាចជាឫសគល់ នៃការជួញដូរមនុស្ស ដែលធ្វើឲ្យអ្នកប្រព្រឹត្តបទល្មើសនេះ មិនខ្លាចច្បាប់។ លោក នី សុខា សង្ស័យថា អ្នកប្រព្រឹត្តការជួញដូរមនុស្សនេះ មិនមែនជាជនសាមញ្ញ គ្មានអ្នកកាងនៅពីក្រោយអាចមកធ្វើបាននោះទេ ពោលអ្នកដែលហ៊ានធ្វើរឿងនេះសុទ្ធតែអ្នកមានខ្សែបណ្ដាញមានឥទ្ធិពលជាដើម។

គិតត្រឹមថ្ងៃទី១ ខែមិថុនា សំណើក្នុងបញ្ជីតាមដានរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស ខេង មានចំនួន ជិត១ពាន់ករណី(៩១៦) ក្នុងនោះមានមនុស្សជាង២ពាន់នាក់(២.១៩៨ )។ ក្រសួងមហាផ្ទៃបញ្ជាក់ថា ការស្រាវជ្រាវបឋមមានចំនួនជិត៩រយសំណើ(៨៦៩ ) និងបិទសំណុំរឿងជិត ៣រយសំណើ(២៩៥ )។ ក្នុងនោះ សមត្ថកិច្ច រកឃើញមនុស្សជាង១ពាន់ ( ១.៣៣៧)នាក់ និងឃាត់ខ្លួនជនសង្ស័យជាងមួយរយនាក់(១៣៥) បិទទីតាំងក្រុមហ៊ុនចំនួន៥ និងផ្អាកដំណើរការក្រុមហ៊ុនមួយចំនួនដើម្បីបន្តការស៊ើបអង្កេត។ រីឯប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត មានចំនួន ៤៧ ករណី។ នៅថ្ងៃទី២ មិថុនា ក្រសួងមហាផ្ទៃ ក៏ទទួលបានពាក្យបណ្ដឹងឲ្យជួយសង្គ្រោះជនបរទេស២នាក់ទៀតដែរ។

អ្នកនាំពាក្យក្រសួងមហាផ្ទៃលោក ខៀវ សុភ័គ មានប្រសាសន៍ថា កាលពីថ្ងៃទី៣០ និង៣១ ឧសភា សមត្ថកិច្ចបានទទួលសំណើចំនួន១០ ដែលស្នើឲ្យជួយសង្គ្រោះជនបរទេសចំនួន២២នាក់ ហើយ សមត្ថកិច្ច បានជួយសង្គ្រោះរួចហើយ។ លោក ខៀវ សុភ័គ រំពឹងកម្ពុជានឹងអាចរួចផុតពីចំណាត់ថ្នាក់ ទាប ដែលជាប្រទេសមានបទល្មើសជួញដូរមនុស្សច្រើនជាងគេ ក្រោយពីក្រសួងមហាផ្ទៃបានបើក យុទ្ធនាការដើម្បីជួយសង្គ្រោះជនរងគ្រោះពីអំពើជួញដូរ។ លោកបញ្ជាក់ថា កាលពីផ្ដើមយុទ្ធនាការ ដំបូង មានសំណើយ៉ាងហោចណាស់ ១០ក្នុងមួយថ្ងៃ ក៏ប៉ុន្តែថ្មីៗនេះសំណើជួយសង្គ្រោះជនរងគ្រោះ នោះ គឺថមថយ ហើយថ្ងៃខ្លះពុំមានសំណើនោះទេ។ លោកស្នើឲ្យជនរងគ្រោះ ឬសាច់ញាតិ ទាក់ទង ទៅហ្វេសប៊ុក (Facebook) លោក ស ខេង ដើម្បីរាយការណ៍ និងទទួលបានការជួយសង្គ្រោះទាន់ ពេលវេលា។

កាលពីខែកក្កដា ឆ្នាំ២០២២ កន្លងទៅ ការផ្សព្វផ្សាយរបស់ស្ថាប័នព័ត៌មានអន្តរជាតិអាល់ហ្សា ហ្សេរ៉ា (Al Jazeera) បានបង្ហាញថា បណ្ដាញក្រុមហ៊ុនឆបោកចិនបើកអាជីវកម្មចាប់ជម្រិតមនុស្ស បង្ខំឱ្យធ្វើការខុសច្បាប់នៅកម្ពុជា ដំណើរការទៅបានដោយសេរី គឺដោយសារតែក្រុមហ៊ុនទាំងនោះ បានសហការ និងទទួលបានការជួយជ្រោមជ្រែងពីក្រុមមនុស្សអ្នកមានលុយមានអំណាច នៃបក្ស ពួកលោក ហ៊ុន សែន។ សារព័ត៌មានអន្តរជាតិនេះបានលាតត្រដាងថា មនុស្សស្និទ្ធនឹងលោក ហ៊ុន សែន ព្រមទាំងមន្ត្រីក្នុងជួររដ្ឋាភិបាលមួយចំនួនទៀតសុទ្ធតែមានអគារដូចជា នៅខេត្តព្រះសីហនុ ខេត្តពោធិ៍សាត់ សម្រាប់ផ្តល់ឱ្យជនជាតិចិនបង្ខាំងមនុស្ស ដើម្បីបង្ខំឱ្យធ្វើការឆបោកមនុស្សនៅតំបន់ អាស៊ីដែលមានទំហំទឹកប្រាក់រាប់ពាន់លានដុល្លារ។

រីឯអគារដែលក្រុមជួញដូរមនុស្សនោះប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស តែងតែជាអគារធំៗ មានកាមេរ៉ាសុវត្ថិភាពគ្រប់ជ្រុង និងមានរបងខ្ពស់ៗផុតពីភ្នែកមនុស្ស ដែលមិនអាចមើលឃើញផ្នែក ខាងក្នុងដោយភ្នែកទទេ ហើយមានសន្តិសុខយាមកាមតឹងរ៉ឹង ដែលមិនមានសកម្មភាពចេញចូលក្នុង បរិវេណនោះដោយងាយស្រួលនោះទេ។

ក្រសួងការបរទេសសហរដ្ឋអាមេរិកក៏រកឃើញថា កម្ពុជាដើរថយក្រោយ និងគ្មានឆន្ទៈក្នុងការ លុបបំបាត់ការជួញដូរមនុស្សដោយសារបញ្ហាអំពើពុករលួយជាប្រព័ន្ធ ដែលបានរារាំងដល់ការអនុ វត្តច្បាប់លើក្រុមឧក្រិដ្ឋជន ដែលប្រព្រឹត្តនូវការជួញដូរមនុស្សនៅកម្ពុជា។ របាយការណ៍ស្ដីពីការ ជួញដូរមនុស្សឆ្នាំ២០២២ របស់ក្រសួងការបរទេសអាមេរិកបានទម្លាក់ចំណាត់ថ្នាក់កម្ពុជាកម្រិតទី៣ ដែលមានន័យថា អាក្រក់បំផុត និងពុំធ្លាប់មានចាប់តាំងពីឆ្នាំ២០១៩ មក៕

## កម្ពុជាកំពុងសហការជាមួយថៃជុំវិញការព្រួយបារម្ភអំពីការបណ្តេញពលករបរទេស

https://khmer.voanews.com/a/cambodia-discusses-with-thailand-over-concerns-of-cambodian-migrants-expelled/7123235.html ០៥ មិថុនា ២០២៣លាស់ លីបលីប

*ភ្នំពេញ៖ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានណែនាំទៅក្រសួងការងារកម្ពុជាឱ្យយកចិត្តទុកដាក់លើគោលនយោបាយថៃ ដែលលោកថា ចង់បណ្តេញពលករកម្ពុជា និងឡាវចេញពីប្រទេស ដែលជាគោលនយោបាយរបស់រដ្ឋាភិបាលថៃថ្មី។ មន្ត្រីជាន់ខ្ពស់នៃក្រសួងការងារកម្ពុជាឱ្យដឹងថា ក្រសួងកំពុងសហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាលថៃលើបញ្ហានេះ។*

*នៅក្នុងពិធីសំណេះសំណាលជាមួយកម្មករក្នុងខេត្តកណ្តាល កាលពីថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៣ លោក ហ៊ុន សែន ថ្លែងថា បើទោះបីថៃមិនទាន់ប្រកាសបេក្ខភាពនាយករដ្ឋមន្ត្រីជាផ្លូវការក៏ដោយ ប៉ុន្តែមានការគំរាមបណ្តេញពលករកម្ពុជា និងឡាវចេញពីប្រទេសថៃ។ លោកបន្តថា គោលនយោបាយនេះមិនត្រឹមតែប៉ះពាល់ពលករកម្ពុជាដែលកំពុងធ្វើការនៅទីនោះទេ ប៉ុន្តែវាថែមទាំងអាចបង្កនូវការខូតខាតដល់ក្រុមហ៊ុនថៃ ដែលកំពុងប្រើប្រាស់កម្លាំងពលកម្មបរទេស។ លោកថ្លែងថា៖ «មិនទាន់បានអីផង នៅក្នុងប្រទេសថៃ បានគំរាមបណ្តេញចេញនូវកម្មករកម្ពុជា និងកម្មករឡាវទៅហើយ។ ខ្ញុំគ្រាន់តែផ្តាំទៅថា អ្នកឈ្នះឆ្នោតក្នុងប្រទេសថៃ ខ្ញុំមិនជ្រៀតជ្រែកនយោបាយរបស់អ្នកទេ ក៏ប៉ុន្តែសង្ឃឹមថា អ្នកនឹងមើលឱ្យឆ្ងាយជាងប្រទេសថៃ ហើយអ្នកជាអ្នកឈ្នះឆ្នោត ក៏ប៉ុន្តែមិនប្រាកដថា អ្នកក្លាយទៅជានាយករដ្ឋមន្ត្រី និងបង្កើតរដ្ឋាភិបាលបានទេ។ ប៉ុន្តែអ្នកបានដាក់ចេញនូវនយោបាយមួយ ដែលវាបង្កនូវគ្រោះថ្នាក់ មិនមែនគ្រាន់តែសេដ្ឋកិច្ច គ្រាន់តែពលករកម្ពុជា និងពលករឡាវទេ តែវាខូតខាតសហគ្រាសរបស់ថៃ ដែលកំពុងប្រើប្រាស់ពលករទៅពីកម្ពុជា មកពីឡាវ ហើយមកពីមីយ៉ាម៉ាផងដែរ»។ លោក ហ៊ុន សែន បញ្ជាក់ថា បើនោះជាគោលនយោបាយថៃមែន វានឹងមិនទទួលបានការគាំទ្រពីប្រទេសជិតខាង ដូចជាកម្ពុជា និងឡាវឡើយ។*

*មន្ត្រីជាន់ខ្ពស់នៃក្រសួងការងារកម្ពុជាអះអាងថា ក្រសួងកំពុងតាមដានយ៉ាងយកចិត្តទុកដាក់ និងសហការជាមួយក្រសួងការងារថៃ និងអាជ្ញាធរពាក់ព័ន្ធ។ លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ ប្រាប់វីអូអេតាមប្រព័ន្ធទំនាក់ទំនងតេឡេក្រាមជាអក្សរ នៅថ្ងៃចន្ទថា៖ «រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងសហការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលថៃ។ អ្វីដែលជាផែនការ ឬគោលនយោបាយរបស់ថៃ គឺក្រសួងកំពុងតាមដានយ៉ាងយកចិត្តទុកដាក់ជាមួយស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ និងសហការជាមួយក្រសួងការងារថៃ និងអាជ្ញាធរពាក់ព័ន្ធថៃ។ ប៉ុន្តែរហូតមកដល់ពេលនេះ គោលនយោបាយរបស់ថៃមិនទាន់មានអ្វីប្រែប្រួលនោះទេ»។ បើតាមលោក ហេង សួរ គិតត្រឹមខែឧសភា ឆ្នាំ២០២៣ ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃមានប្រមាណ១លាន២សែននាក់ ក្នុងនោះស្ត្រីមានជិត៥០ម៉ឺននាក់។*

វីអូអេមិនទាន់អាចសុំការបញ្ជាក់ពីស្ថានទូតថៃប្រចាំនៅកម្ពុជាតាមសារអ៊ីម៉ែលបាននៅឡើយទេ។

ប្រទេសថៃទើបតែបញ្ចប់ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិថ្មីរបស់ខ្លួន កាលពីពាក់កណ្តាលខែឧសភា ឆ្នាំ២០២៣។ គណបក្ស Move Forward ទទួលបានសំឡេងគាំទ្រច្រើនជាងគេ ដោយទទួលបានសំឡេង១៥១អាសនៈក្នុងចំណោមអាសនៈចំនួន៥០០នៅក្នុងសភាជាន់ទាប។ គណបក្ស Pheu Thai ដែលដឹកនាំដោយកូនស្រីរបស់អតីតនាយករដ្ឋមន្ត្រី Thaksin Shinawatra ទទួលបាន១៤១អាសនៈ។ ការប្រកាសនាយករដ្ឋមន្ត្រីថៃជាផ្លូវការនឹងធ្វើឡើងក្នុងរយៈពេល៦០ថ្ងៃបន្ទាប់ពីការបោះឆ្នោត ដែលត្រូវការ៣៧៦សំឡេង ទើបអាចបង្កើតរដ្ឋាភិបាលបាន។

លោក ឌី ថេហូយ៉ា ប្រធានកម្មវិធីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងទេសន្តរប្រវេសន៍នៃអង្គការសង់ត្រាល់ (CENTRAL) ប្រាប់វីអូអេនៅថ្ងៃចន្ទថា លោកមិនទាន់ជឿថា ប្រទេសថៃអនុវត្តគោលនយោបាយដូចអ្វីដែលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកឡើងទេ ព្រោះថា ប្រទេសថៃក៏នៅត្រូវការកម្លាំងពលកម្មពីបរទេស ដែលរួមមានកម្ពុជា ឡាវ វៀតណាម និងភូមា។ ប៉ុន្តែលោកថា បើសិនជាប្រទេសថៃបញ្ជូនពលករកម្ពុជាមកវិញមែន នោះរដ្ឋាភិបាលកម្ពុជាជាអ្នកទទួលខុសត្រូវ ដោយបង្កើតការងារក្នុងស្រុកឱ្យបានច្រើន។ លោកថ្លែងថា៖ «ប៉ុន្តែយ៉ាងណាក្តី បើសិនជាមានការបញ្ជូន[ពលករកម្ពុជា]មកវិញ អ៊ីចឹងមែនក៏ជាភារកិច្ចរបស់រដ្ឋាភិបាលកម្ពុជាត្រូវទទួលខុសត្រូវប្រជាពលរដ្ឋខ្លួនឯង តាមរយៈការបង្កើតការងារក្នុងស្រុកឱ្យគាត់ [ពលរដ្ឋ] ធ្វើ ដើម្បីទទួលបានប្រាក់ចំណូល និងជាផ្នែកមួយក្នុងការចូលរួមចំណែកសេដ្ឋកិច្ចជាតិដែរ»។

បើតាមលោក ឌី ថេហូយ៉ា ពលករខ្មែរដែលកំពុងរស់នៅនិងធ្វើការក្នុងប្រទេសថៃមានចំនួនជាង២លាន២សែននាក់។ ក្នុងនោះពលករខ្មែរដែលប្រើប្រាស់ឯកសារហួសសុពលភាពមានប្រមាណ៣០ទៅ៤០ភាគរយ ដែលកើតឡើង ដោយសារបញ្ហាកូវីដ១៩ និងការស្នើសុំឯកសារនៅមានភាពស្មុគស្មាញ។ លោកជំរុញឱ្យរដ្ឋាភិបាលកម្ពុជានិងថៃគួរតែធ្វើគោលនយោបាយមួយ ដោយតម្រូវឱ្យថៅកែថៃជាអ្នករៀបចំឯកសារ និងចេញថ្លៃឯកសារនោះសម្រាប់ពលករខ្មែរ។ បន្ថែមពីនេះលោកក៏ជំរុញឱ្យរដ្ឋាភិបាលកម្ពុជាកំណត់តម្លៃទាបបំផុតរាល់ការធ្វើឯកសារចេញពីកម្ពុជា និងត្រូវបង្កភាពងាយស្រួលក្នុងការធ្វើឯកសារទាំងនោះផងដែរ៕

## ក្រសួងការងារ អំពាវនាវដល់ប្រជាពលរដ្ឋឱ្យមានការប្រុងប្រយ័ត្នខ្ពស់ ចំពោះរាល់ការផ្សព្វផ្សាយអំពីការជ្រើសរើស និងបញ្ជូនពលករខ្មែរទៅប្រទេសអូស្ត្រាលី

https://freshnewsasia.com/index.php/en/localnews/294264-2023-06-06-09-09-07.html 2023-06-06 04:09pm

*(ភ្នំពេញ)៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៣នេះ បានអំពាវនាវដល់ប្រជាពលរដ្ឋ ឱ្យមានការប្រុងប្រយ័ត្នខ្ពស់ ចំពោះរាល់ការផ្សព្វផ្សាយអំពីការជ្រើសរើស និងបញ្ជូនពលករខ្មែរទៅប្រទេសអូស្ត្រាលី។ ការអំពាវនាវនេះ បានធ្វើឡើងបន្ទាប់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានទទួលព័ត៌មានថា មានជនខិលខូចមួយចំនួនបានធ្វើសកម្មភាពផ្សព្វផ្សាយជ្រើសរើស និងប្រមូលថវិកាពីប្រជាពលរដ្ឋ ដោយធានាអះអាងថា អាចបញ្ជូនទៅធ្វើការនៅប្រទេសអូស្ត្រាលីបាន។*

*ក្រសួងសូមបញ្ជាក់ថា មកដល់ពេលនេះ រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអូស្ត្រាលីពុំមានកិច្ចសហប្រតិបត្តិការលើការបញ្ជូនពលករ កម្ពុជាទៅធ្វើការនៅប្រទេសអូស្ត្រាលីឡើយ។ ក្រសួងសូមអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋ ឱ្យមានការប្រុងប្រយ័ត្នខ្ពស់ ចំពោះរាល់ការផ្សព្វផ្សាយអំពីការជ្រើសរើស និងបញ្ជូនពលករខ្មែរទៅប្រទេសអូស្ត្រាលី។*

*ទន្ទឹមនេះ យោងតាមអនុក្រឹត្យលេខ១៩០អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រង លើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន រាល់ការបញ្ជូនពលករទៅធ្វើ ការនៅបរទេស ត្រូវមានការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្នុងន័យនេះ ការបញ្ជូនពលករ ទៅធ្វើការនៅប្រទេសដែលគ្មានកិច្ចប្រតិបត្តិការលើការបញ្ជូនពលករជាមួយកម្ពុជា និងដោយគ្មានការអនុញ្ញាតពី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាទង្វើឆបោក និងអាចជាបទល្មើសនៃការជួញដូរមនុស្ស៕*

# ថ្ងៃទី០៨ ខែ មិថុនា ឆ្នាំ២០២៣

## កម្ពុជា-អូស្ត្រាលី រហូតមកដល់ពេលនេះ ពុំមានកិច្ចសហប្រតិបត្តិការលើការបញ្ជូនពលករកម្ពុជា ទៅធ្វើការនៅប្រទេសអូស្ត្រាលីទេ

https://www.information.gov.kh/articles/106560 AKP ភ្នំពេញ ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៣

*ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបញ្ជាក់ថា មកដល់ពេលនេះ រាជរដ្ឋា ភិបាលកម្ពុជា និងរដ្ឋាភិបាលអូស្ត្រាលី ពុំមានកិច្ចសហប្រតិបត្តិការលើការបញ្ជូនពលករ កម្ពុជាទៅធ្វើការនៅប្រទេសអូស្ត្រាលីឡើយ។*

យោងតាមជូនដំណឹងរបស់ក្រសួងការងារនៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៣ បានឱ្យដឹង ថា កាលពីពេលថ្មីៗនេះ ក្រសួងបានទទួលព័ត៌មានថាមានជនខិលខូចមួយចំនួនបានធ្វើ សកម្មភាពផ្សព្វផ្សាយជ្រើសរើស និងប្រមូលថវិកា ពីប្រជាពលរដ្ឋ ដោយជានាអះអាងថា អាចបញ្ជូនទៅធ្វើការនៅប្រទេសអូស្ត្រាលីបាន។ ក្រសួងការងារសូមបញ្ជាក់ថា " មកដល់ពេលនេះ រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាល អូស្ត្រាលី ពុំមានកិច្ចសហប្រតិបត្តិការលើការបញ្ជូនពលករកម្ពុជាទៅធ្វើការនៅប្រទេស អូស្ត្រាលីឡើយ"។

ជាមួយគ្នានោះដែរ ក្រសួងសូមអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋឱ្យមានការប្រុង ប្រយ័ត្នខ្ពស់ចំពោះរាល់ការផ្សព្វផ្សាយអំពីការជ្រើសរើស និងបញ្ជូនពលករខ្មែរទៅប្រទេស អូស្ត្រាលី។ ទន្ទឹមនេះ យោងតាមអនុក្រឹត្យលេខ១៩០អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រង លើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើស រើសឯកជន រាល់ការបញ្ជូនពលករទៅធ្វើការនៅបរទេស ត្រូវមានការអនុញ្ញាតពីក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្នុងន័យនេះ ការបញ្ជូនពលករ ទៅធ្វើការនៅប្រទេស ដែលគ្មានកិច្ចប្រតិបត្តិការលើការបញ្ជូនពលករជាមួយកម្ពុជា និងដោយគ្មានការអនុញ្ញាតពី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាទង្វើឆបោក និងអាចជាបទល្មើស នៃការជួញដូរមនុស្ស។ដោយៈប៊ុនរិទ្ធ សម្រួលផ្សាយដោយ៖ ធូ កុសល

## បង្ក្រាបទីតាំងម៉ាស្សាមួយកន្លែង
## រួចចាប់ខ្លួននារីវ័យក្មេងជាច្រើននាក់ និងមេការម្នាក់ផ្អើលក្នុងបុរី

https://kohsantepheapdaily.com.kh/article/1751364.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ភ្នំពេញ០៧ ខែ មិថុនា ឆ្នាំ ២០២៣ ម៉ោង ០៩:៣៥

រាជធានីភ្នំពេញ ៖ បើតាមសេចក្តីរាយការណ៍បានឱ្យដឹងថា ទីតាំងកន្ទែងម៉ាស្សាបង្កប់ទៅដោយសេវាបំរើកម្សាន្តមួយកន្ទែង ត្រូវមន្ត្រីផ្នែកជំនាញនាយកដ្ឋានប្រឆាំងការជួយដូរមនុស្សអនីតិជនចុះសហការជាមួយកម្លាំងអជ្ញាធរខណ្ឌបង្រ្កាប និងឃាត់ខ្លួននារីៗធ្វើការសេវាបំរើកម្សាន្តចំនួន៥នាក់ និងមេការម្នាក់ បង្កឲ្យមានការភ្ញាក់ផ្អើលកាលពីវេលាម៉ោង១០និង៣៥នាទីយប់ ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៣ នៅចំណុចបុរីញ៉ូវថោន ស្ថិតក្នុងសង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ។

សេចក្តីរាយការណ៍បន្តថា ទីតាំងម៉ាស្សាខាងលើនេះមានយីហោ «ម៉ាកស្រីកា» ផ្ទះលេខ No CO2.St.112KD ក្នុងនោះមានស្ត្រីបំរើសេវាកម្សាន្តចំនួន៥នាក់ ជាអនីតិជន២នាក់ និង៣នាក់ទៀតគ្រប់អាយុ រួមនឹងមេការម្នាក់ទៀត ត្រូវបានបញ្ជូនទៅកាន់ផ្នែកជំនាញ។ ចំណែកវត្ថុតាងដែលត្រូវ

ដកហូតបានរួមមាន ៖ ម៉ូតូមួយគ្រឿងម៉ាកឌូដេ ពណ៌ក្រហម ពាក់ស្លាកលេខ ភ្នំពេញ1KE-4685 ព្រមទាំងទូរស័ព្ទដៃមួយចំនួនផងដែរ។

តាមប្រភពព័ត៌មានបានអោយដឹងថា នៅមុនពេលកើតហេតុ ដោយមានការរាយការណ៍ផ្តល់ព័ត៌មានពីប្រជាពលរដ្ឋរស់នៅក្នុងបុរីខាងលើ ប្តឹងទៅខាងអជ្ញាធរសមត្ថកិច្ចមូលដ្ឋាន បន្ទាប់សមត្ថកិច្ចក៏រាយការណ៍បន្តទៅកាន់ផ្នែកជំនាញនាយកដ្ឋានប្រឆាំងការជួយដូរមនុស្ស និងការពារអនីតិជនតែម្តង។ ប្រភពដដែលបន្តថា លុះនៅវេលាម៉ោងកើតហេតុខាងលើ មន្ត្រីផ្នែកជំនាញក៏ដឹកនាំកម្លាំងចុះទៅសហការជាមួយកម្លាំងផ្នែកជំនាញខណ្ឌពោធិ៍សែនជ័យ និងអជ្ញាធរភូមិ ឃុំ សង្កាត់ អោយចូលរួមអន្តរាគមន៍បង្រ្កាបទីតាំងម៉ាស្សានោះ។ បន្ទាប់ពីធ្វើការសួរនាំទៅលើនារីបំរើសេវាកម្សាន្តទាំង៥នាក់នោះទៅ ទើបដឹងថា មាននារី២នាក់ជាអនិតិជន។ ហើយនៅទីតាំងនោះផងដែរ នៅពេលឆែកឆេរ គឺរកឃើញស្រោមអនាម័យដែលប្រើប្រាស់រួចជាច្រើនស្រោមវេចខ្ចប់ទុកក្នុងថង់ខ្មៅមួយហើយក៏ត្រូវបានផ្នែកជំនាញប្រមូលទុកជាភស្តុតាង ដើម្បីកសាងសំណុំរឿងផងដែរ។

ក្រោយពេលកើតហេតុ នារីបំរើសេវាកម្សាន្តទាំង៥នាក់ និងមេការម្នាក់ ត្រូវឃាត់ខ្លួនបញ្ជូនទៅកាន់ផ្នែកជំនាញនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីចាត់ការទៅនីតិវិធីបន្ត ចំណែកទីតាំងផ្ទះម៉ាស្សាខាងលើវិញ ក៏ត្រូវបានបិទទ្វារសោផ្អាកជាបណ្តោះអាសន្ន៕

## សាលាឧទ្ធរណ៍ ជម្រះបណ្ដឹងឧទ្ធរណ៍ស្ត្រីជាប់ចោទម្នាក់ ជាប់គុក ១៦ ឆ្នាំ ពាក់ព័ន្ធនឹងការលក់ដូរមនុស្ស ទៅម៉ាឡេស៊ី

https://cen.com.kh/archives/666491.html Posted ByPen Srey NeatJune 7, 2023

ភ្នំពេញ : សាលាឧទ្ធរណ៍រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០២៣ នេះ បានបើកសវនាការជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍របស់ស្ត្រីជាប់ចោទម្នាក់ ដែលត្រូវតុលាការថ្នាក់ក្រោម ដាក់គុកកំណត់ ១៦ ឆ្នាំ ជាប់ពាក់ព័ន្ធនឹងការជួញដូរ និងលក់ដូរស្ត្រីខ្មែរចំនួន ៧ នាក់ ប្រទេសម៉ាឡេស៊ី ប្រព្រឹត្តនៅ រាជធានីភ្នំពេញ នៅអំឡុងខែមិថុនា ឆ្នាំ ២០១៦ ។

លោក ឌុច សុខសារិន ជាប្រធានចៅក្រមប្រឹក្សាជំនុំជម្រះ នៃតុលាការឧទ្ធរណ៍ បានថ្លែងឲ្យដឹងថា: ជនជាប់ចោទមានឈ្មោះ អ៊ុំ រ៉ាដែន ភេទស្រី អាយុ៣៥ឆ្នាំ (កើតថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៨១ ) ។ នៅក្នុងសំណុំរឿងនេះ ស្ត្រីជាប់ចោទឈ្មោះ អ៊ុំ រ៉ាដែន ត្រូវបានសាលាដំបូងខេត្តរាជធានីភ្នំពេញ កាលពីថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៩ ផ្តន្ទាទោស ដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ និង បង្គាប់ឱ្យសង ជម្ងឺចិត្តដល់ជនរងគ្រោះ ២០ លានរៀល ក្រោមការចោទប្រកាន់ពីបទ : នាំចេញដោយមិនស្របច្បាប់

សម្រាប់ឆ្លងដែន និង អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន តាមបញ្ញត្តិមាត្រា ១១ នៃ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ ។

ស្ត្រីជាប់ចោទ បាន ប្តឹងឧទ្ធរណ៍ តែសាលាឧទ្ធរណ៍រាជធានីភ្នំពេញ ។ ស្ត្រីជាប់ចោទ ឈ្មោះ អ៊ុំ ហ៉ដែន ត្រូវបានចាប់ឃាត់ខ្លួន កាលពីថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ ។ នៅក្នុងសំណុំរឿងនេះ សាលាឧទ្ធរណ៍ រាជធានីភ្នំពេញបនឹងប្រកាសដីកា នៅចុងខែមិថុនា ខាងមុខ នេះ ៕ រក្សាសិទ្ធដោយ ៖ ចន្ទា ភា

## សមត្ថកិច្ចកម្ពុជា បន្តទទួលបានបណ្តឹង ២ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ២៤នាក់

https://freshnewsasia.com/index.php/en/localnews/294381-2023-06-07-08-35-19.html 2023-06-07 03:35pm

(ភ្នំពេញ)៖ គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី០៥ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០២ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ២៤នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣ រួមមាន៖

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៩២១ករណី មានមនុស្ស ២,៣២២នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៨៧៧សំណើ និងបិទសំណុំរឿង ២៩៩សំណើ (រកឃើញមនុស្ស ១,៣៤២នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣៥នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៤៤ករណី៕

## លោក Marcos សន្យាពង្រឹងទំនាក់ទំនង ជាមួយបណ្តាប្រទេស ដែលជាម្ចាស់ផ្ទះពលករហ្វីលីពីនជិតពីរលាននាក់

https://freshnewsasia.com/index.php/en/internationalnews/294422-2023-06-07-12-22-25.html 2023-06-07 07:22pm

(ម៉ានីល)៖ ប្រធានាធិបតីហ្វីលីពីន លោក Ferdinand Marcos Jr. បានប្រកាសកាលពីថ្ងៃពុធថា រដ្ឋបាលរបស់លោកនឹងធ្វើការដើម្បីពង្រឹងទំនាក់ទំនង ជាមួយប្រទេសដែលទទួលពលករហ្វីលីពីនចំណាកស្រុក ដើម្បីធានាសុវត្ថិភាព និងសុខុមាលភាពរបស់ពួកគេ។ នេះបើយោងតាមការចេញ

ផ្សាយដោយ សារព័ត៌មាន AFP នៅថ្ងៃពុធ ទី០៧ ខែមិថុនា ឆ្នាំ២០២៣។ ពលករចំណាកស្រុកជិតពីរលាននាក់ គឺជាកត្តាជំរុញដ៏សំខាន់នៃសេដ្ឋកិច្ចហ្វីលីពីន និងជាប្រភពដ៏សំខាន់ នៃទុនបម្រុងរូបិយប័ណ្ណបរទេសរបស់ប្រទេស។

លោក Marcos បាននិយាយថា ប្រជាជនហ្វីលីពីននៅក្រៅប្រទេសកំពុង «ជំរុញម៉ាស៊ីននៃវឌ្ឍនភាព» នៅក្នុងប្រទេសហ្វីលីពីន។ ពួកគេបានផ្ញើប្រាក់ផ្ទេរប្រាក់ផ្ទាល់ខ្លួនប្រហែល ៣៦ពាន់លានដុល្លារកាលពីឆ្នាំមុន ស្មើនឹង ៨.៩ ភាគរយនៃផលិតផលក្នុងស្រុកសរុបរបស់ប្រទេសនេះបើយោងតាមទិន្នន័យរបស់ធនាគារកណ្តាល។ លោក Marcos បាននិយាយនៅក្នុងសារជាវីដេអូ ដែលចាក់ផ្សាយនៅថ្ងៃទិវាពលករចំណាកស្រុកនៅប្រទេសហ្វីលីពីនថា «យើងយល់ពីបញ្ហាប្រឈមដែលអ្នកបានជួបប្រទះនៅឆ្ងាយពីមនុស្សជាទីស្រលាញ់របស់អ្នក សម្របខ្លួនទៅនឹងវប្បធម៌ថ្មី និងការយកឈ្នះលើឧបសគ្គនានា»។ លោកសង្កត់ធ្ងន់ថា «នោះហើយជាមូលហេតុដែលរដ្ឋបាលនេះ នឹងបន្តពង្រឹងទំនាក់ទំនងកាន់តែរឹងមាំ ជាមួយប្រទេសដែលជាម្ចាស់ផ្ទះពលករចំណាកស្រុករបស់យើង ជានាសុវត្ថិភាព សុខុមាលភាព និងសុខុមាលភាព»។

គួរបញ្ជាក់ថា ស្ទើរតែមួយភាគបួននៃប្រជាជនហ្វីលីពីននៅក្រៅប្រទេស ឬនៅធ្វើការក្រៅប្រទេស និងរស់នៅក្នុងប្រទេសអារ៉ាប៊ីសាអូឌីត បន្ទាប់មកគឺប្រទេសអារ៉ាប់រួម ហុងកុង គូវ៉ែត សិង្ហបុរី និងកាតា៕

## ថៃថាគ្មានបក្សនយោបាយណាមួយមានគោលនយោបាយបញ្ជូនពលករចំណាកស្រុកដែលអះអាងដោយនាយករដ្ឋមន្ត្រីកម្ពុជាឡើយ

https://www.rfi.fr/km//20230607-?ref=tgi ចុះផ្សាយនៅថ្ងៃ៖ 07/06/2023

គ្មានគណបក្សនយោបាយណាមួយនៅថៃ រៀបរាប់ពីគោលនយោបាយបញ្ជូនពលករចំណាកស្រុកត្រឡប់ទៅវិញទេ ដូច្នេះការថ្លែងរបស់នាយករដ្ឋមន្ត្រីកម្ពុជា ដែលថាបក្សឈ្នះឆ្នោតថ្មីរបស់ថៃមានគម្រោងបណ្តេញពលករកម្ពុជាចេញពីប្រទេសថៃនោះ គឺជាការអះអាងមួយដែលមិនត្រឹមត្រូវឡើយ។ នេះបើតាមកាសែតបាងកកប៉ុស្តិ៍របស់ថៃបានចុះផ្សាយ។ ការចុះផ្សាយនេះ គឺបន្ទាប់ការលើកឡើងរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីពេលថ្មីៗនេះដែលថាគោលនយោបាយរបស់ប្រធានគណបក្សឈ្នះឆ្នោតនៅថៃ ចង់បណ្តេញពលករខ្មែរ និងពលករឡាវចេញពីប្រទេសថៃ។

កាសែតបាងកកប៉ុស្តិ៍របស់ថៃបានផ្សាយថា ការថ្លែងរបស់នាយករដ្ឋមន្ត្រីកម្ពុជា ដែលថាបក្សឈ្នះឆ្នោតថ្មីរបស់ថៃ មានគម្រោងបណ្តេញពលករកម្ពុជាចេញពីប្រទេសថៃនោះ គឺជាការអះអាង

មួយដែលមិនត្រឹមត្រូវឡើយ។ យោងតាមអត្ថបទព័ត៌មានមួយចុះកាលពីថ្ងៃទី៦មិថុនា គេមិនច្បាស់ថា ការសន្និដ្ឋានរបស់លោកហ៊ុន សែននេះ ធ្វើឡើងដោយរបៀបណាឡើយ ក៏ប៉ុន្តែកាលពីយុទ្ធនាការបោះឆ្នោត១៤ ឧសភា មិនមានគណបក្សនយោបាយរបស់ថៃណាមួយ បានរៀបរាប់ពីគោលនយោបាយបញ្ជូនពលករចំណាកស្រុកត្រឡប់ទៅវិញទេ។

បើតាមកាសែតបាងកកប៉ុស្តិ៍ ផ្ទុយទៅវិញសេដ្ឋកិច្ចរបស់ថៃដែលកំពុងតែត្រូវបានស្តារឡើងវិញ កំពុងបន្តជួបកង្វះខាតនៃកម្លាំងពលកម្មនេះ ក្នុងវិស័យទេសចរណ៍ និងសំណង់។ ក្រៅពីនេះរដ្ឋបាលខេត្តមួយធ្វើការងារពាក់ព័ន្ធនឹងពលករចំណាកស្រុករបស់ថៃថ្មីៗនេះ ក៏ទើបតែត្រូវបានពន្យារតទៅទៀត ដើម្បីជានាឲ្យបាននូវការបន្តគោលនយោបាយនេះអំឡុងពេលបោះឆ្នោតរហូតដល់ការរៀបចំរដ្ឋាភិបាលថ្មី នាពេលខាងមុខ។

សូមបញ្ជាក់ថា ការចុះផ្សាយរបស់កាសែតបាងកកប៉ុស្តិ៍របស់ថៃនេះ គឺបន្ទាប់ពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីថ្ងៃទី០៣មិថុនា ក្នុងពិធីជួបសំណេះសំណាលជាមួយកម្មករ លោកបានប្រតិកម្មទៅលើគោលនយោបាយ របស់ប្រធានគណបក្សឈ្នះឆ្នោតនៅប្រទេសថៃ ដែលចង់បណ្តេញពលករខ្មែរ និងពលករឡាវចេញពីប្រទេសថៃ។ នៅពេលនោះដែរលោក ហ៊ុន សែន ក៏បានផ្តាំទៅអ្នកនយោបាយទាំងនោះសូមមើលឲ្យឆ្ងាយពីប្រទេសថៃ ព្រោះការបណ្តេញពលករបរទេសចេញ នឹងប៉ះពាល់ដល់ច្រវាក់ផលិតកម្មរបស់ថៃខ្លួនឯងទៅវិញទេ។

លោក ហ៊ុន សែន បញ្ជាក់ថា នយោបាយនេះប្រហែលជាមិនទទួលបានការគាំទ្រពីប្រទេសជិតខាង ដូចជា ប្រទេសឡាវ មីយ៉ាន់ម៉ា ក៏ដូចជាកម្ពុជា។ អ្នកនយោបាយថៃគួរតែប្រុងប្រយ័ត្នចំពោះការដាក់ចេញ និងអនុវត្តនយោបាយរបស់ខ្លួននេះ។ បញ្ហានេះលោក ហ៊ុន សែន បានបញ្ជាទៅកាន់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងស្ថាប័ន និងភាគីពាក់ព័ន្ធដទៃទៀត ត្រូវបង្កើនការយកចិត្តទុកដាក់ និងដោះស្រាយបញ្ហាប្រឈមនានារបស់ពលករខ្មែរនៅប្រទេសថៃផងដែរ។

សូមជម្រាបជូនថា បច្ចុប្បន្នពលករកម្ពុជាដែលកំពុងបម្រើការងារនៅប្រទេសថៃមានប្រមាណ ១.២លាននាក់ ក្នុងចំណោមពលករនៅក្រៅប្រទេស ១.៣លាននាក់៕

# ថ្ងៃទី០៩ ខែ មិថុនា ឆ្នាំ២០២៣

## សម្តេចតេជោបញ្ជាក់ កម្មករខ្មែរធ្វើការនៅថៃមិនត្រូវបណ្តេញចេញទេ ផ្ទុយទៅវិញថៃម ទាំងសម្រួលយកចិត្តទុកដាក់ទៀត

https://kohsantepheapdaily.com.kh/article/1752202.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram កំពង់ឆ្នាំង០៨ ខែ មិថុនា ឆ្នាំ ២០២៣ ម៉ោង ០៩:៥២

ខេត្តកំពង់ឆ្នាំង ៖ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីបានគូសបញ្ជាក់ថា ករណីកម្មករខ្មែរកំពុងធ្វើការនៅក្នុងប្រទេសថៃ មិនត្រូវបានបណ្តេញចេញដូចអ្វីដែលលើកឡើងមុននោះទេ ផ្ទុយទៅថៃមទាំងជួយសម្រួលយកចិត្តទុកដាក់ ។

ថ្ងៃក្នុងពិធីសំណេះសំណាលជាមួយកម្មករ កម្មការិនីមកពីរោងចក្រសហគ្រាសចំនួន៥ ក្នុងស្រុកសាមគ្គីមានជ័យ និងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង នាព្រឹកថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៣ សម្តេចតេជោបានបញ្ជាក់ថា ៖«ខ្ញុំសូមអបអរសាទរជាមួយព័ត៌មានដែលទទួលបានពីរឿងកម្មករខ្មែរធ្វើការនៅថៃដែលពីមុនខ្ញុំបានកង្វល់ស្តីពីបក្សឆ្ពោះទៅមុខ ដែលលឺពាក្យថា មានបំណងបណ្តេញកម្មករខ្មែរ និងឡាវចេញពីថៃ ។ តែពីម្សិលមិញ(ថ្ងៃ៧ មិថុនា) បានបញ្ជាក់មិនមានការដេញចេញទេ ថៃមទាំងសម្រួលថែមទៀតផង» ។

សម្តេចតេជោ បានលើកឡើងថា នៅពេលទទួលបានព័ត៌មាននេះហើយសម្តេចតេជោ លើកឡើងថា កម្ពុជាលែងព្រួយបារម្ភទៀតហើយចំពោះការបណ្តេញចេញកម្មករកម្មការិនីកំពុងធ្វើការចេញពីប្រទេសថៃ ។ សម្តេចបញ្ជាក់ថា ៖«ខ្ញុំត្រូវតែឈឺឆ្អាលចំពោះរឿងនេះ ប្រសិនបើរឿងទាក់ទងនិងការបណ្តេញចេញ ឬបញ្ឈប់ការងារ ឬទាក់ទង និងអត្តប្រយោជន៍ចំពោះកម្មករកម្មការិនីនៅក្រៅប្រទេស» ។

ជាមួយគ្នានោះដែរ សម្តេចតេជោក៏បានអរគុណចំពោះបញ្ហារបស់គណបក្សនយោបាយក្រោយៗដែលឈ្នះឆ្នោត ។ ខ្ញុំមានការពេញចិត្តជាមួយនឹងការបកស្រាយថា នឹងមិនមានការបណ្តេញពលករខ្មែរចេញពីប្រទេសថៃនោះទេ ។ សម្តេចតេជោ ក៏បានសម្តែងក្តីសង្ឃឹមជឿជាក់ថា កិច្ចសហប្រតិបត្តិការទាក់ទិន និងកម្មករអន្តោប្រវេសន៍ដែលជាកិច្ចព្រមព្រៀងស្ថិតក្នុងក្របខណ្ឌសម្រុះសម្រួលអាស៊ានត្រូវបានការពារចំពោះកម្មករ ។

នៅក្នុងប្រទេសកម្ពុជាក៏មានកម្មករបរទេសកំពុងធ្វើការផងដែរ ដូច្នេះយើងក៏បានយកចិត្តទុកដាក់ការពារពួកគេផងដែរ ។ សម្តេចបានគូសបញ្ជាក់ថា ៖«ចំណុចទាំងនេះ គឺជាចំណុចដែលខ្ញុំសូមបញ្ជាក់ជូនឲ្យដឹងហើយឆ្លើយតប និងលើកទឹកចិត្តឲ្យដល់បក្សដែលមានសំឡេងឆ្នោត ខណៈខ្ញុំ

មិនទាន់បានបក្សមួយណាមានសំឡេងឆ្នោតច្រើននោះទេ ប៉ុន្តែយ៉ាងណាក៏ដោយយើងបានការបញ្ជាក់ពីគណបក្សនយោបាយមួយថា គ្មានបញ្ហាចំពោះរឿងកម្មករនេះទេ» ៕

## គណបក្សជាប់ឆ្នោតថៃ ចេញមុខបំភ្លឺ រឿងដែលថា ខ្លួនគ្រោងបណ្ដេញពលករខ្មែរ

https://www.kampucheathmey.com/global-news/523923 ថ្ងៃព្រហស្បតិ៍ ៨ មិថុនា ២០២៣ដោយ Sok Sovann

គណបក្សចលនាឆ្ពោះទៅមុខ បានបដិសេធទាំងស្រុង ចំពោះសេចក្ដីរាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយបរទេសដែលថា ខ្លួនមានគោលនយោបាយ បណ្ដេញពលករចំណាកស្រុកចេញពីប្រទេសថៃ ហើយបក្សក៏មិនដែលពិភាក្សាអំពីការធ្វើបែបនេះដែរ ។

គណបក្សបានបង្ហោះលើ Facebook ថា "គណបក្សចលនាឆ្ពោះទៅមុខ សូមបដិសេធយ៉ាងដាច់អហង្ការ នូវរបាយការណ៍ក្នុងប្រព័ន្ធផ្សព្វផ្សាយមួយចំនួន ដែលចោទប្រកាន់លើ គណបក្សដែលមានគោលនយោបាយធ្វើមាតុភូមិនិវត្តន៍ពលករចំណាកស្រុកមកពីប្រទេសជិតខាង"។ ស្របពេលជាមួយគ្នានោះ គណបក្សក៏បញ្ជាក់ជាថ្មីផងដែរ នូវផែនការរបស់ខ្លួន ក្នុងការធ្វើផ្ទុយពីនេះ ពោលគឺបក្សចង់បង្កលក្ខណៈកាន់តែងាយស្រួល ដល់ជនបរទេស ដែលទៅធ្វើការនៅប្រទេសថៃ និងពង្រីកសិទ្ធិទទួលបានការការពារការងារ សម្រាប់ពលករទាំងអស់ដោយមិនគិតពីសញ្ជាតិ។

យោងតាមគណបក្សនេះ, ពលករចំណាកស្រុកគឺមានសារសំខាន់ណាស់ សម្រាប់សេដ្ឋកិច្ចថៃ ជាពិសេសនៅក្នុងឧស្សាហកម្មដែលពឹងផ្អែកលើកម្លាំងពលកម្ម។ ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសថៃ នឹងមិនទទួលបានជោគជ័យឡើយ បើមិនមានពលករចំណាកស្រុក។ គណបក្សចលនាឆ្ពោះមុខ បន្ថែមទៀតថា គណបក្ស នឹងផ្ដោតលើការលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយដៃគូអាស៊ាន ដើម្បីធានាស្ថិរភាពសេដ្ឋកិច្ច និងលើកកម្ពស់សិទ្ធិនៅក្នុងតំបន់។ សេដ្ឋកិច្ចដែលរីកចម្រើននយោបាយស្ថិរភាព និងសន្តិមយុត្តិធម៌ក្នុងអាស៊ាន នឹងនាំមកនូវវិបុលភាពដល់តំបន់ទាំងមូល។ ការបញ្ជាក់របស់គណបក្សចលនាឆ្ពោះទៅមុខ ធ្វើឡើងបន្ទាប់ពី សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រតិកម្មលើគោលនយោបាយរបស់អ្នកនយោបាយថៃ ដែលមានបំណងដេញពលករខ្មែរចេញពីប្រទេស។

ក្នុងឱកាសជួបសំណេះសំណាលជាមួយកម្មករនិយោជិត ជិត២ម៉ឺននាក់ មកពីរោងចក្រសហគ្រាសនានានៅខេត្តកណ្ដាល កំពង់ស្ពឺ និងកំពង់ឆ្នាំង កាលពីព្រឹកថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៣ សម្ដេចមានប្រសាសន៍ថា ផែនការណាមួយរបស់ប្រទេសថៃ ក្នុងការបណ្ដេញពលករបរទេស ជា

*ពិសេសពលករខ្មែរ ឡាវ និងមីយ៉ាន់ម៉ា នឹងធ្វើឲ្យខូចសេដ្ឋកិច្ចប្រទេសដែលផ្គត់ផ្គង់កម្មករ ក៏ដូចជាប្រទេសថៃផងដែរ ព្រោះពួកគេពឹងផ្អែកខ្លាំងលើពលកម្មបរទេស៕ ប្រែសម្រួល៖* Vann Vann

## សម្តេចតេជោ ហ៊ុន សែន
## សាទរចំពោះព័ត៌មានថា ថៃមិនមានបំណងបណ្ដេញពលករកម្ពុជា ចេញពីប្រទេសរបស់ខ្លួន

https://www.kampucheathmey.com/local-news/523999 ថ្ងៃព្រហស្បតិ៍ ៨ មិថុនា ២០២៣ដោយ sopheak khoun

*សម្តេចតេជោ ហ៊ុន សែន បានសម្តែងការអបអរសាទរ នៅពេលដែលទទួលបានព័ត៌មានថា ប្រទេសថៃ មិនមានបំណងបណ្ដេញពលករកម្ពុជា ចេញពីប្រទេសរបស់ខ្លួន។ ការសម្តែងការអបអរសាទររបស់សម្តេចតេជោ ហ៊ុន សែន ខាងលើនេះ ធ្វើឡើងក្នុងពិធីជួបសំណេះសំណាលជាមួយកម្មករ-កម្មការិនីចំនួន ១៨,០០០នាក់ មកពីរោងចក្រសហគ្រាសចំនួន ៥ ក្នុងស្រុកសាមគ្គីមានជ័យ និងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង នៅព្រឹកថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ២០២៣នេះ។*

*សម្តេចតេជោ ហ៊ុន សែន ថ្លែងបែបនេះថា «ហើយខ្ញុំក៏សុំអបអរសាទរជាមួយនឹងព័ត៌មានដែលទទួលបានពីព្រះរាជាណាចក្រថៃ ដែលមុននេះខ្ញុំបានបង្ហាញពីកង្វល់ ស្តីអំពីបក្សឆ្ពោះទៅមុខនេះ ដែលមានបំណង ដែលលឺចេញជាពាក្យមកថា នឹងបណ្តេញកម្មករកឡាវ និងកម្មករកម្ពុជា ចេញពីប្រទេសថៃ ប៉ុន្តែម្សិលម៉្ងៃនេះ ម្សិលមិញនេះ ម្សិលម៉្ងៃគឺមានការនិយាយ តែម្សិលមិញមានការបញ្ជាក់យ៉ាងជាក់លាក់ថា គឺអត់មានទេ គេនឹងសម្រួលឲ្យថែមទៀតផង បើដូច្នេះគឺយើងលែងកង្វល់ជាមួយនឹងការចាកចេញរបស់កម្មករ-កម្មការនីរបស់យើង ដែលកំពុងធ្វើការក្នុងប្រទេសថៃ។»។*

*សម្តេចតេជោ ហ៊ុន សែន លើកឡើងដែរថា សម្តេច ត្រូវតែឈឺឆ្អាលចំពោះព័ត៌មានទាក់ទងនឹងការបណ្តេញចេញ ឬបញ្ឈប់ការងារ ឬក៏បាត់បង់អត្ថប្រយោជន៍ពលកររបស់កម្ពុជា ដែលធ្វើការងារនៅក្រៅប្រទេស។ សម្តេចតេជោ ហ៊ុន សែន ក៏បានថ្លែងអំណរគុណចំពោះការបញ្ជាក់របស់ភាគីថៃថា ពុំមានបំណងបណ្តេញពលករកម្ពុជា ចេញពីប្រទេសរបស់ខ្លួននោះ៕*

# ជនជាតិបង់ក្លាដែស ៣ នាក់ ស្វែងរកការជួយអន្តរាគមន៍ ដើម្បីជួយសម្រួលឱ្យពួកគាត់បាន ទទួលលិខិតឆ្លងដែនពីក្រុមហ៊ុនវិញ

https://www.postkhmer.com/national/2023-06-07-1835-250987.html អោម ប៊ុនធឿន | Publication date 07 June 2023 | 18:35 ICT

ភ្នំពេញៈ ជនជាតិបង់ក្លាដែស ៣ នាក់ ស្វែងរកការជួយអន្តរាគមន៍ពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីជួយសម្រួលឱ្យពួកគាត់បានទទួលលិខិតឆ្លងដែនពីក្រុមហ៊ុនឈ្មោះ BC BUILDERS INVESTMENT CO., LTD ដំណើរការនៅកម្ពុជា ដែលពួកគាត់មកបម្រើការងារ ប៉ុន្តែក្រុមហ៊ុនមិនបានបើកប្រាក់ឈ្នួលឱ្យតាមកិច្ចសន្យាធ្វើឱ្យពួកគាត់បង្ខំចិត្តលាឈប់ និងចាកចេញពីកន្លែងការងារ។

បុរសជាជនបរទេសទាំង ៣ នាក់នោះទី ១.ឈ្មោះ MOLIA MD TOWHID NEWAL កាន់លិខិតឆ្លងដែនលេខ EE0670794 ទី២.ឈ្មោះ HOSSAIN ALAM GR កាន់លិខិតឆ្លងដែនលេខ BB0707223 និងទី៣ឈ្មោះ KHAN MD DELWER កាន់លិខិតឆ្លងដែនលេខ BY0536974 ទាំង ៣ នាក់ជាជនជាតិបង់ក្លាដែស ស្នាក់នៅសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

លោក MOLIA MD TOWHID NEWWAL បានឱ្យដឹងថា រូបលោក និងក្រុមការងារ ២នាក់ទៀត បានចូលមកកម្ពុជាតាមជើងយន្តហោះមកពីប្រទេសបង់ក្លាដែស ដោយទទួលបានទិដ្ឋាការស្របច្បាប់ ពីអគ្គនាយកដ្ឋានអន្តោប្រវេសន៍កម្ពុជា និងចាប់ផ្តើមធ្វើការងារនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០២០ ក្នុងនាមកម្មករជំនាញ ដោយខែដំបូងក្នុងម្នាក់ទទួលបានប្រាក់ខែ ៣០០ ដុល្លារ អាមេរិក ប៉ុន្តែខែបន្ទាប់ ក្រុមហ៊ុនមិនបានផ្តល់ប្រាក់ខែឱ្យទេ។ លោកថា នៅពេលមានការតវ៉ា ក្រុមហ៊ុនបានសម្រួលឱ្យបន្តការងារ ដោយផ្តល់ថ្លៃហូបចុកពី ៥ទៅ១០ដុល្លារប៉ុណ្ណោះ។ បញ្ហានេះអូសបន្លាយរហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ អ្នកទាំង៣សម្រេចចិត្តឈប់ធ្វើការ និងចាកចេញពីក្រុមហ៊ុនដោយមានជាប់បណ្តាចេញចូលការងារចំនួន៣ខែ គឺខែមករា ដល់ខែមីនា ឆ្នាំ២០២១។ លោកបន្តថា ក្រុមហ៊ុន ប៊ីស៊ី ប៊ីលឌ័រ អ៊ិនវេសម៉ិន (ខេមបូឌា) ឯ.ក (BC BUILDERS INVESTMENT CO., LTD) ដែលមានលោក MOHAMMED JAHANGIA ជាអ្នកតំណាង មិនត្រឹមតែមិនបានបើកប្រាក់ឈ្នួលមកពួកលោកនោះទេ ហើយថែមទាំងព្យាយាមមិនសហការក្នុងការផ្តល់លិខិតឆ្លងដែនថែមទៀត ទោះបីមានការសម្របសម្រួលពីស្ថាប័នតុលាការក៏ដោយ។ លោកបញ្ជាក់ថា៖ «យើងស្នើទៅរដ្ឋាភិបាលកម្ពុជាឱ្យជួយដោះស្រាយបញ្ហារបស់ពួកយើងឱ្យបានឆាប់ ដើម្បីពួកយើងបានត្រឡប់ទៅប្រទេសកំណើតវិញ»។

តំណាងក្រុមហ៊ុន លោក ALAM MOHAMMED JAHANGIA បានថ្លែងការណ៍ថា ខ្លួនមិនទទួលស្គាល់ចំពោះការទាមទាររបស់កម្មករជំនាញទាំង៣នាក់នោះទេ ព្រោះពួកគាត់មិនបានធ្វើការឱ្យក្រុមហ៊ុនឡើយ។ អ្នកទាំង៣ធ្វើការ បានតែ៣ខែប៉ុណ្ណោះ ដោយចាប់ផ្តើមធ្វើការនៅថ្ងៃទី២១ ខែ

កុម្ភៈ ឆ្នាំ២០២០ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ ដែលប្រាក់ឈ្នួលអំឡុងពេលនោះខាងក្រុមហ៊ុនបានបើកប្រាក់ឈ្នួលជូនរួចហើយ។

នាយកដ្ឋានវិវាទការងារ នៃអគ្គនាយកដ្ឋានការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើការប្រជុំសម្របសម្រួល និងធ្វើការផ្សះផ្សា ករណីក្រុមហ៊ុនមិនទូទាត់ប្រាក់ឈ្នួលនេះជាច្រើនលើកច្រើនសា ប៉ុន្តែមិនមានលទ្ធផលសះជានឹងគ្នា។ នេះបើយោងតាមកំណត់ហេតុនៃការផ្សះផ្សាវិវាទបុគ្គល នៃអគ្គនាយកដ្ឋានការងារ។ នាយកដ្ឋានវិវាទការងារបញ្ជាក់ថា លោក MOLIA MD TOWHID NEWWAL នៅតែទាមទារឱ្យក្រុមហ៊ុនទូទាត់ប្រាក់ឈ្នួលដែលមិនបានបើក មានចំនួនសរុប ៤ ៣២០ ដុល្លារសហរដ្ឋអាមេរិក។ ដោយឡែកលោក ALAM MOHAMMED JAHANGIA តំណាងក្រុមហ៊ុននៅតែបញ្ជាក់ថា ក្រុមហ៊ុនបានទូទាត់ប្រាក់ឈ្នួលជូនកម្មកររួចហើយ តាមរយៈវិក្កយបត្របើកប្រាក់ឈ្នួលជាអំណះអំណាង។

លោក កែវ វណ្ណថន អ្នកនាំពាក្យអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ប្រាប់ភ្នំពេញប៉ុស្តិ៍នៅថ្ងៃទី៧ ខែមិថុនាថា ចំពោះជនបរទេសណាដែលបាត់លិខិតឆ្លងដែន ត្រូវដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាល រួចយកទៅស្នើសុំលិខិតឆ្លងដែនថ្មី ហើយត្រូវមកស្នើសុំទិដ្ឋាការចេញ(Exit Visa) នៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍។ ដោយឡែក ចំពោះករណីក្រុមហ៊ុនដកហូតលិខិតឆ្លងដែន គឺជាអំពើមិនស្របច្បាប់ ដូច្នេះស្នើសាមីជនបរទេសអាចដាក់ពាក្យបណ្តឹងទៅសមត្ថកិច្ចប្រសិនបើមានករណីដូច្នេះ៕

## កម្ពុជា-អូស្ត្រាលី បានពិភាក្សាគ្នាពីការបង្កើតតុលាការការងារនៅកម្ពុជា

https://www.postkhmer.com/national/2023-06-07-1055-250920.html ជា សុខនី | Publication date 07 June 2023 | 10:55 ICT

ភ្នំពេញៈ កាលពីថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០២៣ នៅទីស្តីការក្រសួងការងារ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងចាស្ទីន ខេវីន វ៉ៃយ៉ាត់ (Justin Kevin Whyatt) ឯកអគ្គរដ្ឋទូតអូស្ត្រាលីថ្មីប្រចាំកម្ពុជា បានពិភាក្សាគ្នាពីការបង្កើតតុលាការការងារ ដើម្បីជាការរួមចំណែកក្នុងការធ្វើឱ្យមានភាពប្រសើរក្នុងការដោះស្រាយទំនាស់ក្នុងការងារ។

លោក អ៊ិត សំហេង ថ្លែងថា៖ «ចំពោះការដោះស្រាយបញ្ហារបស់និយោជក និងកម្មករ-និយោជិត កម្ពុជាបានបង្កើតក្រុមប្រឹក្សាអាជ្ញាកណ្តាល ១ ហៅកាត់ថា AC រួចមកហើយ ដើម្បីសម្រួលការដោះស្រាយទំនាស់វិវាទក្រៅប្រព័ន្ធតុលាការ ហើយរាជរដ្ឋាភិបាលបានដាក់ឱ្យប្រើប្រាស់ច្បាប់ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការរួចមកហើយដែរ តែទោះជាយ៉ាងណា ការរៀបចំបង្កើត

តុលាការការងារនៅតែមានការយកចិត្តទុកដាក់ និងឈានទៅការបង្កើតឱ្យបាននៅពេលខាងមុខ»។ លោកស្រី អ៊ូ ទេពផល្លីន ប្រធានសហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា បានប្រាប់ឱ្យដឹងថា ស្ថានភាពប្រទេសកម្ពុជាសព្វថ្ងៃនេះ ជាទូទៅពល់ពេលមានវិវាទការងារកើតឡើង តែងតែដាក់ពាក្យបណ្ដឹងទៅតុលាការអាជ្ញាកណ្ដាល ហើយតុលាការនេះដោះស្រាយគ្រប់វិវាទ ដូច្នេះហើយបានជាកម្ពុជា មិនមានតុលាការតាមជំនាញនោះ។ លោកស្រី អ៊ូ ទេពផល្លីន បានថ្លែងថា៖ «ចំពោះតុលាការការងារ វាជាផ្នែកមួយដែលរដ្ឋត្រូវតែមានហើយ ក៏ប៉ុន្តែអ្វីដែលយើងយល់ មុននឹងឈានដល់តុលាការការងារ កម្មករក៏អាចប្រើប្រាស់នូវយន្តការក្រុមប្រឹក្សាអាជ្ញាធរកណ្ដាល ដើម្បីដោះស្រាយទាំងវិវាទរួម ទាំងវិវាទបុគ្គលផងដែរ»។ «តុលាការការងារហ្នឹង ក៏ត្រូវតែមានទម្រង់ស្រដៀងទៅនឹងក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដើម្បីធានាបានថា វិវាទដែលកម្មករបាននាំបណ្ដឹងទៅនោះ អាចទទួលបានយុត្តិធម៌»។

កាលពីខែមករា ឆ្នាំ ២០២២ ក្រសួងយុត្តិធម៌កម្ពុជា បានចេញសេចក្ដីសម្រេចចំនួន ២ ដាច់ដោយឡែកពីគ្នាស្ដីពីការបង្កើតគណៈកម្មការរៀបចំដំណើរការតុលាការជំនាញក្នុងនោះ រួមមានតុលាការពាណិជ្ជកម្ម និងតុលាការការងារ ដើម្បីដោះស្រាយភាពចាំបាច់នៃសំណុំរឿងពិសេសដាច់ដោយឡែកជុំវិញវិវាទការងារ និងពាណិជ្ជកម្ម ប៉ុន្តែរហូតមកដល់ពេលនេះ មិនទាន់មានចេញជាលទ្ធភាពដាក់ឱ្យដំណើរការនៅឡើយទេ។ លោក អ៊ិត សំហេង ក៏បានរំឭកផងដែរនូវទំនាក់ទំនងការទូតល្អរវាងកម្ពុជា-អូស្ត្រាលី ដោយបានប្រារព្ធខួបអនុស្សាវរីយ៍ ៧០ ឆ្នាំ។

## លោក ហ៊ុន សែន អរគុណបក្សប្រឆាំងថៃ ចំពោះការសន្យារក្សាជំហរមិនបណ្ដេញពលករខ្មែរចេញពីប្រទេសថៃ

https://www.rfi.fr/km//20230608-?ref=tgi ចុះផ្សាយនៅថ្ងៃ៖ 08/06/2023 - 08:14

លោក ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានថ្លែងអរគុណគណបក្ស ការក្លៃ ឬ «Move Forward» ដែលបានបញ្ជាក់អំពីគោលជំហរមិនបណ្ដេញពលករខ្មែរចេញពីប្រទេសថៃ ប្រសិនបើគណបក្សប្រឆាំងថៃនេះឡើងទៅកាន់អំណាច។ ក្នុងពិធីសំណេះសំណាលជាមួយកម្មករ-កម្មការិនីក្នុងខេត្តកំពង់ឆ្នាំង នៅថ្ងៃទី៨មិថុនានេះ លោក ហ៊ុន សែន នៅបន្តរក្សាភាពត្រឹមត្រូវ ដែលលោកបានបង្ហាញក្ដីបារម្ភជុំវិញបំណងបណ្ដេញពលករខ្មែរចេញពីប្រទេសថៃរបស់គណបក្សការក្លៃនេះ។

នៅចំពោះមុខកម្មករ-កម្មការិនីក្នុងខេត្តកំពង់ឆ្នាំងនៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានអបអរសាទរដំណឹង ស្ដីពីការបន្តរក្សាគោលនយោបាយគាំទ្រពលករអន្តោប្រវេសន៍នៅប្រទេសថៃរបស់គណបក្សប្រឆាំងគឺ គណបក្សការក្លៃ ឬ «Move Forward» ដែល

ជាគណបក្សទទួលបានសំឡេងបោះឆ្នោតជាតិច្រើនជាងគេ។ លោក ហ៊ុន សែន បានថ្លែងអរគុណគណបក្សការក្លៃ ដែលបានឆ្លើយតបក្តីបារម្ភរបស់លោកពាក់ព័ន្ធនឹង បំណងបណ្តេញចេញពលករចំណាកស្រុក នៅពេលគណបក្សប្រឆាំងថៃនេះឡើងកាន់អំណាច។ ជាក្តីបារម្ភ ដែលលោក ហ៊ុន សែន អះអាងថា លោកត្រូវតែហ៊ានលើកឡើង ហ៊ានឈឺឆ្អើល ក្នុងនាមជានាយករដ្ឋមន្ត្រី ដែលនោះគឺជារឿងដ៏ត្រឹមត្រូវ។

គួររំឭកថា លោក ហ៊ុន សែន ក្នុងវេទិកាសាធារណៈមួយកាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៣ ធ្លាប់បានប្រតិកម្មបង្ហាញការមិនគាំទ្រ ចំពោះគោលនយោបាយរបស់គណបក្សប្រឆាំងថៃគណបក្សការក្លៃ ឬ «Move Forward» ដែលចង់បណ្តេញពលករខ្មែរ និងពលករឡាវចេញពីប្រទេសថៃ។ ហើយលោក ហ៊ុន សែន ថែមទាំងបានព្រមានគណបក្សប្រឆាំងថៃពីគោលនយោបាយនេះ និងដាក់បញ្ហាឱ្យក្រសួងការងារ ក្រសួងស្ថាប័នរបស់កម្ពុជានិងភាគីពាក់ព័ន្ធដទៃទៀត ត្រៀមដើងព្រួលដោះស្រាយបញ្ហាប្រឈមរបស់ពលករខ្មែរនៅប្រទេសថៃ។ បច្ចុប្បន្ននេះ មានពលករខ្មែរប្រមាណ១.២លាននាក់កំពុងបម្រើការងារនៅប្រទេសថៃ ដែលជាចំនួនដ៏ច្រើនលើសលុប ក្នុងចំណោមពលករនៅក្រៅប្រទេសសរុបប្រមាណ ១.៣លាននាក់។

ជាការឆ្លើយតប គណបក្សការក្លៃ ឬ « Move Forward » នៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៣ បានចេញមកបដិសេធ និងបញ្ជាក់ថា រដ្ឋាភិបាលថៃ ក្រោមការដឹកនាំដោយគណបក្សប្រឆាំង ជំនួសលោក ប្រាយុទ្ធ ចាន់អូចារ នឹងមិនផ្លាស់ប្តូរគោលនយោបាយបញ្ជូនពលករចំណាកស្រុកចេញពីប្រទេសថៃឡើយ។ ផ្ទុយទៅវិញ គណបក្សការក្លៃ មានបំណងបង្កើតគោលនយោបាយសម្រួលដល់បរិយាកាសការងារពលករចំណាកស្រុកឱ្យកាន់តែមានភាពងាយស្រួលជាងមុន ផ្តល់ការការពារសមរម្យ និងធានាថា ពលករចំណាកស្រុកគ្រប់ជាតិសាសន៍នៅប្រទេសថៃ មិនទទួលរងការបង្ខិតបង្ខំ ឬកេងប្រវ័ញ្ចផ្សេងៗទៀត។

គួរជម្រាបបន្ថែមថា ថៃនឹងប្រកាសលទ្ធផលបោះឆ្នោតជ្រើសរើសនាយករដ្ឋមន្ត្រីថ្មីនៅខែកក្កដាខាងមុខនេះ ខណៈគណបក្ស ការក្លៃ ឬ « Move Forward» ជាគណបក្សប្រឆាំងទទួលសំឡេងគាំទ្រច្រើនជាងគេ៕

# ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០២៣

## លោក ហ៊ុន សែន
## អំពាវនាវកុំឱ្យមានការរើសអើងលើស្ត្រីដែលធ្វើការនៅតាមសេវាកម្សាន្ត

https://www.postkhmer.com/national/2023-06-09-0905-251065.html នាង សុគន្ធា | Publication date 09 June 2023 | 09:05 ICT

*កំពង់ឆ្នាំង: លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានអំពាវនាវជាសាធារណៈ កុំឱ្យមានការរើសអើងទៅដល់ស្ត្រីដែលធ្វើការនៅក្នុងសេវាកម្សាន្ត ដែលពួកគាត់មានការតស៊ូ ដើម្បីជីវភាពប្រចាំថ្ងៃ ខណៈដែលមន្ត្រីសហជីពក៏បានស្នើឱ្យអាជ្ញាធរមានវិធានការទៅលើអ្នកដែលរើសអើង ឬបៀតបៀនដល់ស្ត្រីទាំងនោះផងដែរ។ លោកបានលើកឡើងដូចនេះ កាលពីថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ២០២៣ ក្នុងពិធីជួបសំណេះសំណាលជាមួយកម្មករ-កម្មការិនីសរុបចំនួន ១៨ ០៩៥ នាក់ មកពីរោងចក្រសហគ្រាសចំនួន ៥ ក្នុងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។*

*លោកមានប្រសាសន៍ថា៖ «ខ្ញុំក៏សូមអំពាវនាវកុំឱ្យមានការរើសអើងចំពោះស្ត្រី ដែលបម្រើការងារនៅកន្លែងផ្តល់សេវាកម្សាន្តនានា។ សុំកុំរើសអើង ពួកគាត់ក៏ជាមនុស្សដូចយើងដែរ ហើយពេលខ្លះគាត់ធ្វើការនៅកន្លែងបម្រើសេវាកម្សាន្ត ប៉ុន្តែថ្ងៃពួកគាត់ពាក់អាវកាកបាទក្រហមបម្រើការងារសង្គម។ ដូចនេះ សុំកុំមើលថា អ្នកដែលធ្វើការងារនៅកន្លែងកម្សាន្តពេលយប់ សុទ្ធតែមិនល្អ គឺមិនមែនទេ ធ្វើអ៊ីចឹងគឺវាខុស»។*

*នាឱកាសនោះដែរ លោក ហ៊ុន សែន ក៏បានណែនាំដល់ភរិយាអភិបាលខេត្ត និងអភិបាលរងខេត្តជាស្ត្រីធ្វើជាប្រធានក្នុងការគ្រប់គ្រងដល់ស្ត្រីបម្រើការងារនៅតាមទីតាំងកម្សាន្តនេះតែម្តង ដើម្បីចូលរួមជួយដោះស្រាយទុក្ខលំបាកនានារបស់ពួកគាត់។ លោកបញ្ជាក់ថា៖ «អ៊ីចឹង! សុំកុំឱ្យមានការរើសអើង។ កែវក្មែករបស់យើងកុំសម្លឹងថា អ្នកចម្រៀង អ្នកសិល្បៈ ឬអ្នកផ្សេងៗថា ជាស្ត្រីមិនល្អ គឺមិនអ៊ីចឹងទេ តែដោយសារតែតម្រូវការជីវភាពឱ្យធ្វើអ៊ីចឹង»។*

*ជុំវិញការលើកឡើងរបស់លោក ហ៊ុន សែន នេះដែរ លោកស្រី អ៊ូ ទេពផល្លីន ប្រធានសហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា គាំទ្រទៅលើការអំពាវនាវកុំឱ្យមានការរើសអើងទៅលើស្ត្រីធ្វើការនៅសេវាកម្សាន្តនេះ។ ទន្ទឹមនឹងនេះដែរលោកស្រីក៏សំណូមពរដែរថា៖ «នៅពេលដែលមានអ្នកប្រព្រឹត្តអំពើហិង្សាឬមានសកម្មភាពអំពើណាមួយមិនសមរម្យតាមរយៈការរើសអើងលើស្ត្រីមានផ្ទៃពោះនៅកន្លែងធ្វើការ មិនឱ្យស្ត្រីប្រើប្រាស់សិទ្ធិខ្លួនឯងក្នុងនាមកម្មករចងក្រងសហជីព នោះគឺសុំឱ្យស្ថាប័នរដ្ឋ មិនត្រូវព្រងើយកន្តើយទេតែត្រូវមានវិធានការលើករណីនេះផងដែរ»។*

លោកស្រី អ៊ូ ទេពផល្លីន បានបញ្ជាក់ថា ពាក្យថា រើសអើង ឬមាក់ងាយមិនសំដៅលើតែការងារ និងមុខរបរទេ ព្រោះច្បាប់ការងារ ក៏មានចែងដែរហើយ តែអ្វីដែលខាងសហជីពចង់ឃើញនោះគឺអ្នកដែលប្រព្រឹត្តអំពើហិង្សា ឬការបៀតបៀនគឺមិនអាចលើកលែងបានឡើយ។ លោកស្រីបន្តថា៖ «ចំពោះអ្នក ឬនិយោជក ដែលរើសអើងស្ត្រី ដែលមានផ្ទៃពោះ ក៏មិនត្រូវអត់ឱនឱ្យដែរ»។

សូមរំឭកផងដែរថា ក្នុងមហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេសរបស់គណបក្សប្រជាជន នៅវិមាន ៧ មករា កាលពីថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០២៣ លោក ហ៊ុន សែន បានសម្រេចផ្តល់មេធាវីការពារផ្លូវច្បាប់ ចំពោះស្ត្រីបម្រើសេវាកម្សាន្តនៅទូទាំងប្រទេស ដើម្បីការពារសិទ្ធិស្ត្រី ដែលបម្រើការងារក្នុងវិស័យនេះខណៈដែលស្ត្រីមួយចំនួនតែងរងការបៀតបៀន៕

## ស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា ណែនាំឱ្យប្រយ័ត្នករណីឆបោកទិដ្ឋការ

https://www.kampucheathmey.com/local-news/524610 ថ្ងៃសុក្រ ៩ មិថុនា ២០២៣ដោយ Chan Sotheavy

ស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា មុននេះបន្តិច បានចេញសារជូនដំណឹងដល់សាធារណជន ឱ្យមានការប្រុងប្រយ័ត្ន បើសិនជាមានស្ថាប័ន ឬបុគ្គលណាម្នាក់ អះអាងថា អាចជួយសម្របសម្រួលទិដ្ឋាការ ក្រោមគម្រោងទិដ្ឋាការកសិកម្មអូស្ត្រាលីដែលបានគ្រោងទុក។ សេចក្តីជូនដំណឹងនេះ ធ្វើឡើងបន្ទាប់ពីស្ថានទូតទទួលបានព័ត៌មានថា មានស្ថាប័ន និងបុគ្គលមួយចំនួន អះអាងថាអាចជួយសម្របសម្រួលករណីខាងលើនេះ។ ករណីឆបោកទិដ្ឋការនេះ ធ្វើឡើងក្រោមរូបភាពបោកប្រាស់ជនរងគ្រោះ ដោយប្រាប់ថាអាចជួយសម្របសម្រួលទិដ្ឋាការ បាន សម្រាប់អ្នកដែលមានបំណងចង់ធ្វើការនៅប្រទេសអូស្ត្រាលី តាមរយៈទិដ្ឋាការ ETA ឬ Visitor ។ តែបើតាមស្ថានទូត គឺមិនមានការអនុញ្ញាតណាមួយ ឱ្យធ្វើការនៅប្រទេសអូស្ត្រាលីតាមរយៈទិដ្ឋាការទាំងពីរនេះឡើយ។

ស្ថានទូតអូស្ត្រាលី បញ្ជាក់ទៀតថា ការអនុញ្ញាតការធ្វើដំណើរតាមប្រព័ន្ធ ETA ឬទិដ្ឋាការ Visitor មិនមែនជាទិដ្ឋាការការងារទេ។ ហេតុនេះ ស្ថានទូតជូនជាដំណឹងថា នោះគឺជាករណីឆបោកទិដ្ឋការហើយ ប្រសិនបើជនណាម្នាក់មកប្រាប់លោកអ្នកថា អាចធ្វើការតាមទិដ្ឋការទាំងពីរខាងលើនេះបាន ព្រោះកម្មវិធីទិដ្ឋាការកសិកម្មអូស្ត្រាលី គឺលែងស្ថិតក្នុងដំណាក់កាលរៀបចំទៀតហើយ ហើយបច្ចុប្បន្ននេះ មិនមានប្រភេទទិដ្ឋាការកសិកម្មអ្វីទៀតនោះទេ។

ស្ថានទូតគូសបញ្ជាក់ដែរថា ស្ថានទូតក៏បានដឹងអំពីបុគ្គល ក៏ដូចជាភ្នាក់ងារ ដែលកំពុងព្យាយាមរៀបចំ ETAs/Visitor visas និងដើងហោះហើរទៅកាន់ប្រទេសអូស្ត្រាលី សម្រាប់មនុស្សធ្វើ

ការដោយខុសច្បាប់នេះផងដែរ និងស្នើឱ្យមានការប្រុងប្រយ័ត្នខ្ពស់ ចំពោះការក្លែងបន្លំថាអាចជួយសម្រួលទិដ្ឋាការប្រភេទនេះបាន។

## តើពលករចំណាកស្រុកកម្ពុជា ជួយសេដ្ឋកិច្ចថៃកម្រិតណា?

https://freshnewsasia.com/index.php/en/localnews/294496-2023-06-08-06-20-08.html 2023-06-08 01:20pm

(ភ្នំពេញ)៖ ពលករចំណាកស្រុក ជាគោលនយោបាយសេដ្ឋកិច្ចរបស់ប្រទេសជឿនលឿននានា នៅលើពិភពលោក ដែលគេត្រូវការកម្លាំងពលកម្ម ដើម្បីទ្រទ្រង់ដល់មូលដ្ឋានផលិតកម្មរបស់ប្រទេសនីមួយៗ។ តម្រូវការកម្លាំងពលកម្ម ដែលសំដៅដល់ការទាក់ទាញពលករពីប្រទេសនានា គឺប្រដូចនិងពាក្យចាស់ថា «ទំពក់វាទៅ ទើបញ្ញើវាមក» មានន័យថា មានអ្នកត្រូវការ ទើបមានអ្នកផ្គត់ផ្គត់ ដែលស្របទៅតាមទ្រឹស្តីនៃការអភិវឌ្ឍសេដ្ឋកិច្ច។

បច្ចុប្បន្នប្រទេសជឿនលឿនដូចជា ជប៉ុន កូរ៉េខាងត្បូង សឹង្ហបុរី ម៉ាឡេស៊ី រួមទាំងប្រទេសដែលមានអភិវឌ្ឍ កម្រិតមធ្យម ក៏ត្រូវការពលកម្មពីប្រទេសកំពុងអភិវឌ្ឍនានា ដូចជាពី វៀតណាម ហ្វីលីពីន កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។ ដោយឡែកប្រទេសដែលត្រូវការកម្លាំងពលកម្មច្រើនជាងគេនៅតំបន់អាស៊ានមានបួន រួមមាន ប៊្រុយណេ ម៉ាឡេស៊ី សឹង្ហបុរី និងប្រទេសថៃ។

អង្គការអន្តរជាតិខាងការងារ (ILO) បានប៉ាន់ស្មានចំនួនពលករចំណាកស្រុក នៅលើពិភពលោកមានចំនួន ១៦៤លាននាក់ ដែលតំណាងឱ្យ ជិត៥% នៃកម្លាំងពលកម្មសរុបរបស់ពិភពលោក ក្នុងនោះប្រមាណ ១២លាននាក់មកពីតំបន់អាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិក។

ប្រទេសកម្ពុជាវិញ បានផ្គត់ផ្គង់កម្លាំងពលកម្ម តាមរយៈគោលនយោបាយអភិវឌ្ឍពលករ ចំណាកស្រុក មានប្រមាណ ១.២លាននាក់ ភាគច្រើនបំផុតទៅប្រទេសថៃ។ តាមរយៈតួលេខនេះមានការលើកឡើងដោយ ក្រុមអ្នកនយោបាយថៃ អំពីរឿងការបញ្ជូនពលករចំណាកស្រុក ដែលកំពុងធ្វើការងារនៅប្រទេសថៃ ឱ្យត្រឡប់ទៅប្រទេសខ្លួនវិញ។ ពលករចំណាកស្រុកទាំងនោះ ភាគច្រើនមានមកពីប្រទេសកម្ពុជា ឡាវ និងប្រទេសភូមា ឬមីយ៉ាន់ម៉ា ដែលតាមការប៉ាន់ស្មានដោយ អង្គការទេសន្តប្រវេសន៍អន្តរជាតិ (IoM) រកឃើញថា មានចំនួនប្រមាណ ៥លាននាក់ ជាពលករចំណាកស្រុកសរុបកំពុងធ្វើការងារនៅប្រទេសថៃ នាពេលបច្ចុប្បន្នទាំងស្របច្បាប់ និងមិនស្របច្បាប់។

ថៃ៖ ចំណេញ ឬខាតខាងសេដ្ឋកិច្ច

ស្ថានភាពថៃនៅពេលនេះ ប្រឈមនឹងភាពខ្វះកម្លាំងពលកម្ម និងសេដ្ឋកិច្ចថៃមានបន្ទុកប្រជាពលរដ្ឋថៃចាស់កាន់តែមានចំនួនច្រើនៗ និន្នាការនេះ ធ្វើឱ្យសហគ្រាសថៃត្រូវពឹងខ្លាំងលើពលកម្មទាំងជំនាញ និងគ្មានជំនាញពីប្រទេសជិតខាង ដើម្បីអភិវឌ្ឍសហគ្រាស់ផលិតកម្មរបស់ខ្លួនៗ ត្រឹមឆ្នាំ ២០៣០ កម្លាំងពលកម្មថៃដែលពេញកម្លាំងអាចធ្វើការបានមានកំណើនប្រមាណ ០.៣% ប្រចាំឆ្នាំស្របពេល ដែលមនុស្សចាស់ជរាថៃ មានអត្រារហូតដល់៣០%ៗ បទពិសោធន៍កន្លងមក ពេលខ្វះកម្លាំងពលកម្ម សេដ្ឋកិច្ចថៃធ្លាក់ចុះៗ ជាក់ស្តែងនៅអំឡុងពេលកូវីដ នៅពេលដែលមានការបញ្ជូនពលករចំណាកទៅកាន់ប្រទេសសាម៉ីវិញ សេដ្ឋកិច្ចថៃធ្លាក់ចុះ ប្រមាណ០.៣% ដោយសារតែសកម្មភាពផលិតធ្លាក់ចុះ ជាពិសេសវិស័យសំណង់ សេវាកម្ម ផលិតកម្មចំណីអាហារ និងការវេចខ្ចប់ជាដើមៗ តួលេខពីរដ្ឋាភិបាលថៃបង្ហាញថា រៀងរាល់ឆ្នាំសហគ្រាសថៃ ជាមធ្យមត្រូវការកម្លាំងពលកម្មប្រមាណ ៤លាននាក់ ដើម្បីទ្រទ្រង់ដល់ផលិតកម្មថៃទាំងស្រុងៗ ហើយសភាពាណិជ្ជកម្មថៃធ្លាប់អះអាងថា នៅដំណាច់ឆ្នាំ២០២២ សហគ្រាស់ថៃត្រូវការកម្លាំងពលកម្មពីប្រទេសនានា យ៉ាងតិចបំផុត ៣លាននាក់ ប៉ុន្តែពលករធ្វើការស្របច្បាប់នៅថៃ មានប្រមាណ ២លាន៥សែននាក់ប៉ុណ្ណោះៗ បន្ថែមលើនេះ សម្ព័ន្ធសហគ្រាសថៃក៏បានអះអាងដែរថា កាលពីឆ្នាំ២០២២ សហគ្រាសថៃទាំងអស់ខ្វះកម្លាំងពលកម្មចន្លោះពី៥សែន ទៅ៨សែននាក់ៗ ដោយឈរលើមូលដ្ឋាននេះ ថៃបានរៀបចំបន្តឯកសារដល់ពលករចំណាកស្រុកនានា ឱ្យបន្តរការងារដល់ឆ្នាំ២០២៥ៗ

បទពិសោធន៍កម្ពុជា និងថៃ៖ ចំណេញទាំងអស់គ្នា

ទំនាក់ទំនងល្អរវាងរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលថៃ ដែលវត្តមានរបស់ពលករកម្ពុជា បានជួយដល់ការអភិវឌ្ឍឧស្សាហកម្មថៃ ហើយកម្ពុជាវិញក៏ទទួលបានលុយច្រើន ពីការផ្ញើរប្រាក់គាំទ្រដល់ជីវភាពគ្រួសារ របស់ពលករកម្ពុជាៗ កាលពីឆ្នាំ២០១៤ នៅពេលដែលនាយករដ្ឋមន្ត្រីថៃទើបឡើងកាន់អំណាច គឺនៅពេលនោះប្រមុខរាជរដ្ឋាភិបាលថៃ បានប្រកាសបណ្តេញចេញ ពលករដែលពុំមានឯកសារគ្រប់គ្រាន់ ចេញពីប្រទេសថៃៗ ហើយតួលេខនៅពេលនោះ គឺមានការបង្ហាញខុសៗគ្នាអំពីចំនួនពលករមិនស្របច្បាប់ ឬពុំមានឯកសារគ្រប់គ្រាន់ ក្នុងនោះតួលេខរដ្ឋាភិបាលកម្ពុជាប៉ាន់ស្មានថា មានចំនួន ៧០ម៉ឺននាក់ តែបើតាមអង្គការសង្គមស៊ីវិលវិញអះអាងថា មានចំនួនជាង១លាននាក់ ៗ ហើយកាលពីឆ្នាំ២០១៤នោះដែរ ថៃបានបញ្ជូនពលករខ្មែរមកវិញជាង ២សែននាក់ៗ

នៅពេលដែលថៃ បានបណ្ដេញពលករមិនស្របច្បាប់ នៅពេលនោះដែរក៏មានការតវ៉ា ពីសំណាក់ម្ចាស់សហគ្រាសផលិតកម្ម ឬឧស្សាហកម្មថៃ ថាខ្វះពលករ។ ហើយភាពខ្វះពលករនោះនឹងជះឥទ្ធិពលអាក្រក់ ដល់ដំណើរការផលិតកម្មរបស់ថៃដែរ។ ចំពេលពេលហ្នឹងក៏មានការស្រាវជ្រាវរកឃើញថា ពលករបរទេស ដែលកំពុងធ្វើការនៅប្រទេសថៃ បានជួយជំរុញផលិតភាពឧស្សាហកម្ម ដែលបានចូលរួមដល់ការកំណើនសេដ្ឋកិច្ចថៃ ១% ប្រចាំឆ្នាំ នេះបើយោងតាមការសិក្សាស្រាវជ្រាវ របស់វិទ្យាស្ថានសេដ្ឋកិច្ចរបស់ថៃ។

ដោយឡែកកម្ពុជាវិញក៏ចំណេញដែរ ។ បើយើងមើលតួលេខ អំពីប្រាក់ចំណូលចូលសេដ្ឋកិច្ចជាតិ គឺកម្ពុជាទទួលបាន ទឹកប្រាក់ពីពលករចំណាកស្រុកពីបរទេស សរុបយ៉ាងហោចណាស់ប្រមាណជាង ៣ពាន់លានដុល្លារក្នុងមួយឆ្នាំ បើយោងតាមក្រសួងការងារ។ ក្រៅពីនេះ ពលកកម្ពុជាអាចរៀនបទពិសោធន៍បច្ចេកទេស ឬកិច្ចការជំនាញផ្សេងៗ យកមកអនុវត្តន៍នៅប្រទេសកម្ពុជា។ បច្ចុប្បន្ន ពលករកម្ពុជាដែលកំពុងធ្វើការនៅក្រៅប្រទេសមានជាង ១លាន៣សែននាក់ ក្នុងនោះ១លាន២សែននាក់កំពុងធ្វើការងារ នៅប្រទេសថៃ៕ ដោយៈ អាន ស៊ីថាវ

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្ដឹង ០៣ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៤នាក់

https://freshnewsasia.com/index.php/en/localnews/294872-2023-06-11-08-15-21.html 2023-06-11 03:15pm

(ភ្នំពេញ)៖ គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី០៩ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៣ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០៤នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News។ បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣ រួមមាន៖

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្ដេចក្រឡាហោម សរុប ៩៣៩ករណី មានមនុស្ស ២,៤០១នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៨៩៤សំណើ និងបិទសំណុំរឿង ៣០២សំណើ (រកឃើញមនុស្ស ១,៣៧០នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣៧នាក់, បិទក្រុមហ៊ុន ៩ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៤១ករណី៕

# ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០២៣

## មកដឹងប្រាក់ខែពលករ កម្ពុជា និងប្រទេសផ្សេងទៀតដែលធ្វើការនៅ ថៃ

https://www.kampucheathmey.com/global-news/525775 ថ្ងៃចន្ទ ១២ មិថុនា ២០២៣ដោយ Sok Chivon

*គណៈកម្មាធិការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់សភាពាណិជ្ជកម្មថៃ (TCC) បានបង្ហើបប្រាប់ពីអំពីប្រាក់ខែរបស់ពលករកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ បន្ទាប់ពីគណបក្សចលនាឆ្ពោះទៅមុខ ដែលទើបជាប់ឆ្នោតថ្មីចេញមុខបំភ្លឺពាក់ព័ន្ធការបណ្ដេញពលករបរទេសទាំងនោះចេញពីប្រទេស ។ទាក់ទិននឹងបញ្ហានេះដែរ លោក* Tawatchai Setjinda *ប្រធាន* TCC *បានប្រាប់ថា ពលករកម្ពុជា និងប្រទេសផ្សេងទៀតដែលមកធ្វើការនៅក្នុងប្រទេសថៃ ទទួលបានប្រាក់ខែអប្បបរមាចន្លោះពី ៣០០ ទៅ ៤០០ ដុល្លារក្នុងមួយខែទៅតាមបណ្ដាខេត្តដែលពួកគេរស់នៅ និងធ្វើការ ។*

*ស្របពេលជាមួយគ្នានេះ គណបក្សចលនាឆ្ពោះទៅមុខដែលបានឈ្នះការបោះឆ្នោតសកលកាលពីថ្ងៃទី១៤ ខែឧសភាកន្លងទៅ ក៏បានសន្យាដែរថា រដ្ឋាភិបាលគ្រោងនឹងដំឡើងប្រាក់ឈ្នួលអប្បបរមាប្រចាំថ្ងៃដល់ពលករនៅទូទាំងប្រទេសឲ្យលើសពីនេះផងដែរក្នុងរយៈពេល ១០០ ថ្ងៃដំបូងនៃការកាន់តំណែង ។*

*លោក* Pita Limjaroenrat *ដែលជាមេដឹកនាំគណបក្សបានបញ្ជាក់ថា ពលករចំណាកស្រុកគឺមានសារសំខាន់ណាស់សម្រាប់សេដ្ឋកិច្ចថៃ ជាពិសេសនៅក្នុងឧស្សាហកម្មដែលពឹងផ្អែកលើកម្លាំងពលកម្ម ហើយការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសថៃ នឹងមិនទទួលបានជោគជ័យឡើយ ប្រសិនបើមិនមានពលករចំណាកស្រុកនោះ ។*

*គួរបញ្ជាក់ថា ប្រជាពលរដ្ឋកម្ពុជាប្រមាណ ១.៣ លាននាក់បានចេញទៅធ្វើការនៅបរទេស ហើយនៅក្នុងនោះមានពលករចំណាកស្រុកចំនួន ១.២ លាននាក់បានទៅធ្វើការនៅក្នុងប្រទេសថៃ ខណៈ ៤៩,០០០ នាក់នៅកូរ៉េខាងត្បូង, ២២,០០០ នាក់នៅម៉ាឡេស៊ី, ១៩,០០០ នាក់នៅជប៉ុន និងមួយចំនួនទៀតនៅសិង្ហបុរី, តំបន់រដ្ឋបាលពិសេសហុងកុងរបស់ចិន និងអារ៉ាប៊ីសាអូឌីតជាដើម ៕*

# ក្រសួងការបរទេសថៃ បញ្ជាក់ថា ថៃនៅតែបន្តជួលពលករបរទេស ដោយស្ថិតក្រោមអនុស្សរណៈកម្ពុជា-ឡាវ មានសិទ្ធទទួលសេវាកម្មសុខភាព និងសិទ្ធការពារការជួញដូរមនុស្ស

https://freshnewsasia.com/index.php/en/localnews/294947-2023-06-12-03-51-42.html 2023-06-12 10:51am

(ថៃ)៖ អ្នកស្រី កាញ្ចនា ផ័ត្រធូក អគ្គនាយក នៃអគ្គនាយកដ្ឋានសារព័ត៌មាន និងអ្នកនាំពាក្យនៃក្រសួងការបរទេសរបស់ថៃ បានលើកយកករណីមានការទទួលបានព័ត៌មានភាន់ច្រឡំពីការពិតនៅលើបណ្តាញសង្គមអនឡាញ កាលពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៣ ដែលមានការលេចឮថា នឹងមិនមានការជួលពលករពីកម្ពុជា និងឡាវបន្តទៀតឡើយ។ នេះបើតាមការចុះផ្សាយរបស់សារព័ត៌មានថៃ khaosod។

លោកស្រីបានបញ្ជាក់ថា នេះមិនមែនជារឿងពិតទេ ដោយអគ្គនាយកដ្ឋានស្វែងរកការងារនៃក្រសួងការងាររបស់ថៃ បានចេញមកបកស្រាយហើយថា យើងគ្រាន់តែកែប្រែដំណាក់កាលជួលពលករខ្មែរ និងឡាវបែបស្របច្បាប់ ដែលចូលមកធ្វើការតាមរយៈអនុស្សរណៈប៉ុណ្ណោះ ដើម្បីឲ្យម្ចាស់សហគ្រាស ឬថៅកែ អាចដាក់សំណើតម្រូវការពលករបរទេសទៅកាន់មន្ទីរស្វែងរកការងារខេត្ត ឬមន្ទីរស្វែងរកការងារទីក្រុងបាងកក តំបន់1-10 ដោយមិនចាំបាច់មកកាន់ទីស្នាក់ការកណ្តាល (អគ្គនាយកដ្ឋានស្វែងរកការងារ) ដើម្បីភាពងាយស្រួល និងឆាប់រហ័ស។ ប៉ុន្តែសម្រាប់ពលករពីប្រទេសមីយ៉ាន់ម៉ា តម្រូវឲ្យទាក់ទងតាមរយៈទីស្នាក់ការកណ្តាល (អគ្គនាយកដ្ឋានស្វែងរកការងារ) ដដែល។

អគ្គនាយក នៃអគ្គនាយកដ្ឋានសារព័ត៌មាន និងអ្នកនាំពាក្យ បានបន្ថែមអំពីរឿងផលប្រយោជន៍បន្ថែមផ្សេងៗ របស់ពលករបរទេសនៅក្នុងប្រទេសថៃថា ថៃថែមទាំងបានព្យាយាមអនុវត្តន៍វិធានការថៃទាំពលករបរទេស ដោយមិនមានការរើសអើងផងដែរ នាពេលកន្លងមក។ ពលករបរទេសអាចប្រើប្រាស់សេវាកម្មសុខភាព នៅក្នុងប្រទេសថៃបាន ជាពិសេសពលករបរទេសស្របច្បាប់ នឹងមានសិទ្ធប្រើប្រាស់សេវាកម្មបេឡាសន្តិសុខសង្គម និងបេឡាសុខភាពថែមទៀតផង។

លើសពីនេះទៅទៀត ថៃថែមទាំងបានជួយសង្គ្រោះពលករបរទេស និងការពារពួកគេកុំឲ្យក្លាយជាជនរងគ្រោះ ដោយសារអំពើជួញដូរមនុស្ស ឬការបង្ខិតបង្ខំធ្វើពលកម្ម ឬការប្រើប្រាស់ពលកម្មកុមារទៀតផងដែរ តាមរយៈការបង្កើតមជ្ឈមណ្ឌលផ្តល់សេវាកម្មជួយសង្គ្រោះពលករបរទេសនៅតាមបណ្តាខេត្តផ្សេងៗ ព្រមទាំងមានការចុះធ្វើអធិការកិច្ចជាប្រចាំ។ លើសពីនេះទៅទៀត ក៏មានការធ្វើវិសោធនកម្មច្បាប់ការពារពលករ ខាងវិស័យនេសាទ តាមសមុទ្រ ឆ្នាំ២០២២ ឲ្យស្របតាមស្តង់ដារអន្តរជាតិមួយកម្រិតទៀតផងដែរ។ សូម្បីតែក្នុងដំណាក់កាល នៃការរាតត្បាល នៃជំងឺកូវីដ១៩ កន្លងមក ថៃក៏បានជួយលើកទឹកចិត្តពលករបរទេស ឲ្យទទួលយកថ្នាំបង្ការ និងការត្រួតពិនិត្យប្រកបដោយសមភាពជាមួយជនជាតិថៃផងដែរ។

តាមរបាយការណ៍របស់ក្រសួងការងាររបស់ថៃ បានបញ្ជាក់ថា គិតត្រឹមត្រីមាសទី១ ឆ្នាំ ២០២៣ មានពលករបរទេសនៅក្នុងប្រទេសថៃ ចំនួន២,៧៤៣,៦៧៣នាក់ ស្មើនឹង៦.៩២% នៃចំនួនពលករសរុបនៅក្នុងប្រទេសថៃ។ ពួកគេដើរតួនាទីយ៉ាងសំខាន់ ក្នុងការរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមថៃ ជាពិសេសខាងវិស័យសំណង់ កសិកម្ម និងបសុសត្វ រួមទាំងអាជីវកម្មផ្តល់សេវាកម្មផ្សេងទៀតផងដែរ។

លោកស្រីអគ្គនាយកបានបញ្ជាក់ថា ថៃផ្តល់ការយកចិត្តទុកដាក់ទៅលើពលករបរទេស នៅក្នុងប្រទេសថៃ ជាពិសេសពលករដែលមកពីប្រទេសភូមិផងរបងជាមួយ ព្រោះពួកគេជាកម្លាំងចលករសំខាន់ ក្នុងការរួមចំណែកជំរុញ សេដ្ឋកិច្ចថៃ ជារៀងរហូតមក ដោយកន្លងមក ថៃតែងតែបានផ្តោតទៅលើការអភិវឌ្ឍស្តង់ដារ និងបទបញ្ញត្តិស្វែងរកការងារដើម្បីជួយសម្រួលភាពងាយស្រួលដល់ម្ចាស់សហគ្រាស ឬថៅកែរួមទាំងពលករជាបន្តបន្ទាប់ផងដែរ៕

# ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០២៣

## ប្តីប្រពន្ធខ្មែរត្រូវបានចាប់ខ្លួននៅប៉ាតាយ៉ា ប្រទេសថៃពីបទកេងប្រវ័ញ្ចលើកូនខ្លួនឯង

[https://www.khmertimeskh.com/501307149//](https://www.khmertimeskh.com/501307149//) Khmer Times June 13, 2023

នគរបាលប៉ាតាយ៉ាកំពុងចាត់វិធានការយ៉ាងម៉ឺងម៉ាត់ប្រឆាំងនឹងការកេងប្រវ័ញ្ច និងការជួញដូរកុមារ ដោយចាប់ផ្តើមប្រតិបត្តិការបោសសម្អាតជាលក្ខណៈទ្រង់ទ្រាយធំ ដើម្បីប្រយុទ្ធប្រឆាំងនឹងការកើនឡើងគួរឱ្យព្រួយបារម្ភនៃកុមារលក់ស្ករគ្រាប់ និងសុំទានតាមដងផ្លូវ។

កាលពីថ្ងៃទី១០ ខែមិថុនា នគរបាលបានចុះត្រួតពិនិត្យបន្ទប់ជួលមួយកន្លែងក្នុងភូមិ៧៣ ឃុំណងព្រឺ ក្នុងតំបន់ Banglamung បានរកឃើញស្ត្រីម្នាក់មានកូន៣នាក់ ស្រី២នាក់ អាយុ៨ឆ្នាំ និង៧ឆ្នាំ និងប្រុសអាយុ១ឆ្នាំម្នាក់។ ស្ត្រីនោះមានឈ្មោះ ចាន់ ឌី អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ បាននិយាយថា គាត់បានចូលប្រទេសថៃតាមច្រករបៀង ដោយបង់លុយចំនួន៣៣០០បាត ដើម្បីមកប៉ាតាយ៉ា។ ស្ត្រីនេះបានបន្តថា ខ្លួនបានអោយកូនទៅលក់ស្ករគ្រាប់ឱ្យភ្ញៀវទេសចរបរទេស និងសុំលុយផងដែរ ដោយបានប្រាប់ថា ក្នុងមួយថ្ងៃរកបានពី ៨០០ ទៅ១០០០ បាត ដើម្បីទិញទឹកដោះគោ ថ្នាំព្យាបាល និងសម្ភារចាំបាច់ និងផ្ញើលុយខ្លះទៅជួយគ្រួសារខ្លួននៅខ្មែរ។

នគរបាលក៏បានចាប់ខ្លួនប្តីរបស់ស្ត្រីនោះដែលមានឈ្មោះ ផៃ សាន អាយុ ៣១ ឆ្នាំ និងជាឪពុករបស់កូនទាំង ៣ នាក់ផងដែរ ខណៈដែលបានដើរលេងជាមួយមិត្តភក្តិនៅតំបន់ប៉ាតាយ៉ា។ អ្នកទាំងពីរប្រឈមមុខនឹងការចោទប្រកាន់ពីបទបង្ខិតបង្ខំ គំរាមកំហែង ល្បួងកុមារចូលរួមក្នុង

សកម្មភាពដូចជាសុំទាន ឬដើរត្រាច់ចរតាមផ្លូវដើម្បីកេងចំណេញដោយខុសច្បាប់។ លើសពីនេះ ពួកគេត្រូវបានចោទប្រកាន់ពីបទចូលប្រទេសដោយខុសច្បាប់ បំពានច្បាប់អន្តោប្រវេសន៍ និងសុំលុយ ឬទ្រព្យសម្បត្តិដោយខុសច្បាប់ពីអ្នកដទៃ។Pattaya Mail

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្ដឹង ០២ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៨នាក់

https://freshnewsasia.com/index.php/en/localnews/295261-2023-06-13-04-54-39.html 2023-06-13 11:54am

(ភ្នំពេញ)៖ គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១១ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០២ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០៨នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News។ បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ រួមមាន៖

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្ដេចក្រឡាហោម សរុប ៩៣៦ករណី មានមនុស្ស ២,៤០២នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៨៩៨សំណើ និងបិទសំណុំរឿង ៣០២សំណើ (រកឃើញមនុស្ស ១,៣៧៣នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣៧នាក់, បិទក្រុមហ៊ុន ៩ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣៨ករណី៕

## ក្រសួងការងារ គ្រោងបញ្ចប់ពលកម្មកុមារត្រឹមឆ្នាំ២០២៥

https://btv.com.kh/article/24685 2023/06/13 07:50:13 pm

ភ្នំពេញ៖លោកជំទាវ ស៊ើង សរសុចិត្តា រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជា អនុប្រធាន គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ បានអំពាវនាវដល់គ្រប់ភាគីពាក់ព័ន្ធចូលរួមអនុវត្ត គោលនយោបាយ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ ២០១៩-២០២៩ ជាពិសេសគឺការបញ្ចប់ពលកម្មកុមារនៅឆ្នាំ២០២៥។

នៅក្នុងពិធីអបអរសាទរខួបលើកទី៧៤ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី២២ទិវាពិភពលោក ប្រឆាំងពលកម្ម កុមារ១២មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០២៣ កាលពីថ្ងៃទី១២ មិថុនា ឆ្នាំ

២០២៣តទៅ លោកជំទាវរដ្ឋលេខាធិការ បានមានប្រសាសន៍ថា នាពេលកន្លងមក ក្រសួងបាន ធ្វើយុទ្ធនាការផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ ពលកម្មកុមារ នៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និង កសិឧស្សាហកម្ម ដោយមានការចូលរួមពីមន្ទីរការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈរាជធានីខេត្ត អាជ្ញាធរមូលដ្ឋាន និយោជក កម្មករនិយោជិត និងអង្គការសង្គមស៊ីវិល ព្រមទាំងបានជួប ផ្ទាល់ ជាមួយកុមារ និងក្រុមគ្រួសារកុមារនៅសហគមន៍ផលិតឥដ្ឋ ដើម្បីជំរុញកិច្ចសហការលើការផ្លាស់ប្តូរព័ត៌មាន និងការរាយការណ៍លើករណីសង្ស័យទាសភាពបំណុល ឬពលកម្មកុមារ ។

លោកជំទាវ ស៊ើង សរសុចិត្តា បានបន្តថា ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានផ្តោតការយកចិត្តទុកដាក់យ៉ាង ខ្លាំងក្នុងការដោះស្រាយនូវបញ្ហាប្រឈមនានាចំពោះកុមារ តាមរយៈបានដាក់ចេញ នូវគោលនយោបាយ ផែនការសកម្មភាពជាតិពាក់ព័ន្ធនឹងកុមារ និងការបង្កើតយន្តការជាច្រើននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីសម្របសម្រួល ពិនិត្យតាមដានវឌ្ឍនភាព និងបញ្ហាប្រឈមស្តីពីស្ថានភាពកុមារ នៅកម្ពុជាឱ្យកាន់ តែមានប្រសិទ្ធភាព។ ដើម្បីឆ្លើយតបការងារខាងលើនេះ លោកជំទាវ បានផ្តល់នូវអនុសាសន៍មួយចំនួន ដូចជា ត្រូវបន្តបណ្តុះបណ្តាលពង្រឹងសមត្ថភាពគ្រប់ភាគីពាក់ព័ន្ធ និងកៀរគរធនធានហិរញ្ញវត្ថុ និងស្វែងរកការ គាំទ្រពីសាធារណជនចូលរួមប្រឆាំងពលកម្មកុមារ និងពង្រឹងកិច្ចអន្តរាគមន៍ស្ទួល ដើម្បីសង្គ្រោះពលកម្មកុមារ និងហាមឃាត់ការងារដោយបង្ខំ និងបង្កើនកិច្ចសហការក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធក្នុង ការទប់ស្កាត់ ការប្រើប្រាស់ពលកម្មកុមារពីគ្រប់ទម្រង់៕ ដោយ ៖ បូរ៉ាវី

## អង្គការពលកម្មអន្តរជាតិ អំពាវនាវឲ្យមានសកម្មភាពបញ្ចប់ពលកម្មកុមារ

https://dap-news.com/international/2023/06/13/339446/ BySS107Posted on June 13, 2023

ហ្សឺណែវ៖ ក្នុងទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ អង្គការពលកម្មអន្តរជាតិ (ILO) បាន អំពាវនាវឲ្យមានសកម្មភាពបញ្ចប់ពលកម្មកុមារ នេះបើយោងតាមការចុះផ្សាយរបស់ទីភ្នាក់ងារសារព័ត៌មានចិនស៊ិនហួ។

កាលពីថ្ងៃចន្ទ អង្គការ ILO បានធ្វើកិច្ចប្រជុំថ្នាក់ខ្ពស់ក្រោមប្រធានបទ "យុត្តិធម៌សង្គមសម្រាប់ទាំងអស់គ្នា បញ្ចប់ពលកម្មកុមារ" ដែលជាព្រឹត្តិការណ៍ចំហៀងក្នុងសម័យប្រជុំនៃសន្និសីទការងារអន្តរជាតិ ដោយការពិភាក្សាផ្តោតលើការផ្សារភ្ជាប់គ្នារវាង យុត្តិធម៌សង្គម និងការលុបបំបាត់ពលកម្មកុមារ។ ក្រុមអ្នកពិភាក្សាតំណាងឱ្យកម្មករនិយោជិត និយោជក និងរដ្ឋាភិបាល បានសង្កត់ធ្ងន់លើភាពបន្ទាន់នៃការប្រយុទ្ធប្រឆាំង នឹងពលកម្មកុមារ និងបានពិភាក្សាអំពីវិធីដើម្បីបង្កើន យុត្តិធម៌ សង្គម។

*លោក Gilbert F. Houngbo អគ្គនាយកអង្គការ ILO បានឲ្យដឹងនៅក្នុងសុន្ទរកថាវីដេអូមួយថា "ជាលើកដំបូងក្នុងរយៈពេល ២០ឆ្នាំ ពលកម្មកុមារ កំពុងកើនឡើងក្នុងឱកាសនេះ។ លោកបានសង្កត់ធ្ងន់ថា "យើងត្រូវបង្កើនការប្រយុទ្ធរបស់យើង ប្រឆាំងនឹងពលកម្មកុមារ ដោយគាំទ្រដល់យុត្តិធម៌សង្គមកាន់តែច្រើន។ ប្រសិនបើយើងធ្វើបែបនេះ ការបញ្ចប់ពលកម្មកុមារ គឺមិនមែនគ្រាន់តែអាចធ្វើទៅបាននោះទេ។*

*អង្គការ ILO បានឲ្យដឹងថា ពិភពលោក មានការរីកចម្រើនជាលំដាប់ក្នុងការកាត់បន្ថយពលកម្មកុមារតាំងពីឆ្នាំ២០០០ ប៉ុន្តែក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ជម្លោះ វិបត្តិ និងជំងឺរាតត្បាតកូវីដ-១៩ បានធ្វើឱ្យគ្រួសារកាន់តែច្រើនធ្លាក់ចូលទៅក្នុងភាពក្រីក្រ និងបង្ខំកុមាររាប់លាននាក់បន្ថែមទៀតឱ្យទៅជាពលកម្មកុមារ។ សេចក្តីថ្លែងការណ៍បានបន្ថែមថា កំណើនសេដ្ឋកិច្ចមិនទាន់គ្រប់គ្រាន់ឬរួមបញ្ចូលគ្រប់គ្រាន់ ដើម្បីបន្ធូរបន្ថយសម្ពាធ ដែលគ្រួសារ និងសហគមន៍ជាច្រើនមានអារម្មណ៍។ វិធានការដើម្បីប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារ រួមមានការបង្កើត និងការអនុវត្តក្របខ័ណ្ឌច្បាប់ដ៏រឹងមាំមួយដោយផ្អែកលើស្តង់ដារការងារអន្តរជាតិ និងការសន្ទនាសង្គម ការផ្តល់សិទ្ធិជាសាកលដល់ការអប់រំប្រកបដោយគុណភាព និងការការពារសង្គម ព្រមទាំងវិធានការផ្ទាល់ ដើម្បីកាត់បន្ថយភាពក្រីក្រ វិសមភាព និង អសន្តិសុខសេដ្ឋកិច្ច និងលើកកម្ពស់ការងារសមរម្យ សម្រាប់កម្មករពេញវ័យ៕*

# ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០២៣

## បក្សចលនាឆ្ពោះទៅមុខ ថៃ ត្រៀមដំឡើងប្រាក់ខែដល់កម្មករ ៣ កម្រិតនេះ

https://www.kampucheathmey.com/global-news/526913 ថ្ងៃពុធ ១៤ មិថុនា ២០២៣ដោយ Sok Chivon

*នាយកមជ្ឈមណ្ឌលសិក្សាពាណិជ្ជកម្មអន្តរជាតិ នៃសាកលវិទ្យាល័យសភាពាណិជ្ជកម្មថៃ (UTCC) បានចេញមកប្រាប់ពីកម្រិត ឬជំនាញរបស់កម្មករ ទៅដល់គណបក្សចលនាឆ្ពោះទៅមុខ ដែលសន្យាត្រៀមនឹងដំឡើងប្រាក់ឈ្នួលអប្បបរមាប្រចាំថ្ងៃ នៅពេលឡើងកាន់តំណែង ។*

*លោក Att Pisarnvanich សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ UTCC បានឲ្យដឹងថា គោលការណ៍ដំឡើងប្រាក់ឈ្នួលអប្បបរមាប្រចាំថ្ងៃដល់ ១៣ ដុល្លារ ដែលស្នើឡើងដោយគណបក្សចលនាឆ្ពោះទៅមុខ របស់បេក្ខភាពនាយករដ្ឋមន្ត្រីថៃលោក Pita Limjaroenrat ដែលទើបជាប់ឆ្នោតថ្មី គួរតែត្រូវបានបែងចែកជា ៣ កម្រិតដូចខាងក្រោម៖*

កម្រិតទី១ ៖ សម្រាប់កសិករ ប្រាក់ឈ្នួលគួរកើនឡើងដល់ ១១.៥០ ដុល្លារក្នុងមួយថ្ងៃ (៣៤៥ ដុល្លារក្នុងមួយខែ)

កម្រិតទី២ ៖ សម្រាប់កម្មករឧស្សាហកម្ម ប្រាក់ឈ្នួលគួរកើនឡើងដល់ ១២.៣០ ដុល្លារក្នុងមួយថ្ងៃ (៣៦៩ ដុល្លារក្នុងមួយខែ)

កម្រិតទី៣ ៖ សម្រាប់អាជីវកម្មផ្នែកសេវាកម្មដូចជា បច្ចេកវិទ្យាព័ត៌មាន (IT), ហិរញ្ញវត្ថុ, ការកម្សាន្ត និងសំណង់ ប្រាក់ឈ្នួលគួរកើនឡើងដល់ ១៣ ដុល្លារក្នុងមួយថ្ងៃ (៣៩០ ដុល្លារក្នុងមួយខែ) អាស្រ័យលើកម្រិតជំនាញរបស់កម្មករ ។

ទោះយ៉ាងណាក៏ដោយ គោលការណ៍បង្កើនប្រាក់ឈ្នួលអប្បបរមាប្រចាំថ្ងៃរបស់គណបក្សចលនាឆ្ពោះទៅមុខ ក៏ពឹងផ្អែកលើភាពស្របគ្នាជាមួយនឹងវិធានការជំរុញសេដ្ឋកិច្ច និងតម្លៃប្រើប្រាស់ដូចជា ទឹក និងអគ្គិសនីជាដើម ខណៈបច្ចុប្បន្នពលករបរទេសដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ ទទួលបានប្រាក់ខែអប្បបរមាប្រមាណជា ៣០០ ដុល្លារក្នុងមួយខែ ។ដោយ ៖ ជីវ័ន្ត

## ពលករខ្មែររកការងារនៅថៃ ដែលមិនមានការងារធ្វើច្រើនរកត្រី និងសុំអង្គការសង់ត្រាល់ស្នាក់នៅ

https://www.rfa.org/khmer/news/human-rights/a-group-of-cambodian-workers-in-thailand-lose-jobs-and-stay-with-central-06122023211100.html ដោយ សេក បណ្ឌិត2023.06.12

ពលករខ្មែរមួយក្រុមដែលធ្វើដំណើរមកដល់ប្រទេសថៃ ដើម្បីរកការងារធ្វើតែគ្មានប្រាក់បន្តដំណើរបានសុំការិយាល័យអង្គការសង់ត្រាល់ (CENTRAL) ស្នាក់នៅបណ្ដោះអាសន្ន។ ក្រុមពលករថ្មីថ្មោងទាំងនោះក៏ធ្វៀតរកត្រីតាមបឹងប្រឡាយ នៅក្នុងប្រទេសថៃ ដើរបេះបន្លែ ធ្វើម្ហូបជួយសម្រួលជីវភាពបានខ្លះ។

ថ្ងៃចុងសប្ដាហ៍ ជាថ្ងៃពលករគ្រប់គ្នាសម្រាកពីការងារ ប៉ុន្តែ ពលរដ្ឋមួយក្រុមអ្នកខ្លះទើបចូលធ្វើការងារនៅប្រទេសថៃមួយសប្ដាហ៍ ឬពីរសប្ដាហ៍ និងអ្នកខ្លះទៀតរកមិនការងារមិនទាន់បានធ្វើនៅឡើយពួកគាត់យកមងសំណាញ់ ទៅរកត្រីតាមអូរប្រឡាយធម្មជាតិ នៅប្រទេសថៃ ដើម្បីបានត្រីធ្វើម្ហូប។ ពួកគាត់អ្នកខ្លះរកត្រី អ្នកខ្លះបេះបន្លែគ្រាន់បានដោះទាល់ក្នុងគ្រាខ្វះខាត និងមិនទាន់មានការងារធ្វើបែបនេះ។

ដៃកាន់ត្រីមួយចង មានត្រីអណ្ដែងនិងត្រីផ្ទក់នីន ដែលទើបដាក់មងបាន លោកស្រី ព្រំ ស្រីពៅ ទើបពីខេត្តប៉ៃលិនមករកការងារធ្វើនៅប្រទេសជាង១ខែមកហើយ។ លោកស្រីបានទើបចូលធ្វើការងារបានពីរបីថ្ងៃហើយ តែលោកស្រីមិនទាន់មានលទ្ធភាពមានប្រាក់ជួលបន្ទប់ស្នាក់នៅឡើយ

ទេ។ ស្ត្រីវ័យ២៨ឆ្នាំ រូបនេះទាំងនិយាយទាំងមុខញញឹមថា ពេលរកត្រីបានលោកស្រីសប្បាយចិត្ត ព្រោះបានត្រីធ្វើម្ហូប។ លោកស្រីសរសើរថា ត្រីដែលរកបានពីប្រឡាយនេះត្រីរសជាតិឆ្ងាញ់ជាងត្រីទិញនៅផ្សារ។

លោកស្រី ព្រំ ស្រីពៅ៖ «រកទៅយើងបានធូររួចមួយពេលៗ យកទៅស្ល ប្រឡាក់ហាលអី អ៊ីចឹង អត់ទាន់បានជួលបន្ទប់ទេ យើងអត់ទាន់មានលុយជួលគាត់ (អង្គការសង់ត្រាល់) ឱ្យនៅសិនអ៊ីចឹងណា ដល់ពេលយើងមានលុយអ៊ីចឹងទៅយើងសុំគាត់ទៅជួលបន្ទប់នៅកន្លែងផ្សេង»។ ពលកររកត្រីនៅទីនេះ អ្នកខ្លះដាក់មងអ្នកខ្លះបង់សំណាញ់ អ្នកខ្លះដាក់សន្ទូច។ ក្រៅពីអ្នករកត្រី ក៏មានពលករផ្សេងទៀតដើរបេះស្ពឹកបាសដុះតាមច្រាំងប្រឡាយ។

ពលករម្នាក់ទៀតលោក សាយ គុន កំពុងឱនងើបក្បែរច្រាំងប្រឡាយរាយមង។ លោក សាយ គុន ឱ្យដឹងថា លោកមកដល់ប្រទេសថៃ បានជាង១០ថ្ងៃ ពេលមកដល់ប្រទេសនេះ លោកអស់ប្រាក់ពីខ្លួន រហូតគ្មានប្រាក់ជួលបន្ទប់ និងប្រាក់សម្រាប់ចំណាយថ្លៃហូបចុកប្រចាំថ្ងៃ។ លោកឆ្លៀតមករកត្រីរៀងរាល់ថ្ងៃចុងសប្ដាហ៍ដែលសម្រាកពីការងារ។ លោកយល់ថា ការមករកការងារធ្វើនៅប្រទេសថៃ ទាល់តែប្រឹងសន្សំសំចៃ ទើបអាចសល់ប្រាក់ផ្ញើជូនឪពុកម្ដាយនៅស្រុកខ្មែរ។ លោក សាយ គុន៖ «មកតែថ្ងៃអាទិត្យតែថ្ងៃនេះថ្ងៃបុណ្យគេឈប់អ៊ីចឹងទៅបានមកថ្ងៃសៅរ៍ បានត្រីអណ្ដែង ត្រីផ្ទានីន ជួយកាត់បន្ថយយើងរៀងចាយវាយលើម្ហូបអីដែរ ដល់លុយសល់កាក់យើងទុក»។

ក្រុមពលកររកត្រី ទើបតែបានមួយសម្វស្រាប់តែមានពលករម្នាក់ឈ្លើងទាមដើង ពួកគាត់ម្នាក់ៗភ័យស្ទន់ស្ទោរត់ឡើងគោក លែងហ៊ានរកត្រីទៀត ហើយពួកគាត់ក៏នាំគ្នាសារមងទៅកន្លែងសម្រាកវិញគឺការិយាល័យអង្គការសង់ត្រាល់ ដែលអនុញ្ញាតឱ្យពលករខ្វះខាតទាំងនោះស្នាក់នៅបណ្ដោះអាសន្ន។ នៅទីនេះក្រុមពលករធ្វើបាយម្ហូបពិសាជុំគ្នា អង្គការសង់ត្រាល់ ក្រៅពីផ្ដល់កន្លែងស្នាក់នៅបណ្ដោះអាសន្ន ក៏មានផ្ដល់អង្ករផងដែរ។

ពលករម្នាក់ទៀត លោក ធី ពឿន អាយុ៣៨ឆ្នាំ មានស្រុកកំណើតនៅខេត្តប៉ៃលិន រៀបរាប់ថា ទម្រាំមកលោកធ្វើដំណើរមកដល់ប្រទេសថៃ គឺត្រូវចំណាយប្រាក់ទាំងថ្លៃឯកសារ និងថ្លៃធ្វើដំណើរអស់ជាង៣០០ដុល្លារ។ លោកថា ប្រសិនគ្មានផ្ដល់កន្លែងស្នាក់នៅបណ្ដោះអាសន្នពីអង្គការសង់ត្រាល់ទេ លោកនិងភរិយា មិនដឹងថាត្រូវទៅរស់នៅទីណាឡើយ។ លោក ធី ពឿន៖ «អត់ច្រើនដែរ ក្នុងម្នាក់ធ្វើប៉ាស្ព័រ(លិខិតឆ្លងដែន)អស់២១៥ដុល្លារ ហើយយើងជិះឡានគេនាំឱ្យយើងមកចូលទៀតអស់ម្នាក់ៗ៤ពាន់បាត គាត់(អង្គការសង់ត្រាល់) ជួយអង្ករជួយទឹក គាត់ជួយច្រើនម្ហូបភ្លើងទៀត បើអត់ស្គាល់កន្លែងគាត់យើងពិបាកយើងមកពីខ្មែរមកយើងដាច់លុយបិត»។

ការិយាល័យអង្គការសង់ត្រាល់ នៅប្រទេសថៃ អង្គការនេះជួលផ្ទះមួយកន្លែងក្នុងខេត្តឈុនបុរី (Chhon Bori) មានពីរបន្ទប់ និងកន្លែងទទួលភ្ញៀវ។ មួយបន្ទប់ជាកន្លែងរបស់បុគ្គលិកអង្គការប្រចាំទេសថៃបំពេញការងារ បន្ទប់ទំនេរមួយទៀតផ្តល់ឱ្យពលករដែលប្តី ឬប្រពន្ធពលករស្នាក់នៅចំណែកពលករផ្សេងទៀត គេងនៅកន្លែងទទួលភ្ញៀវ។

មន្ត្រីផ្នែកការពារសិទ្ធពលករចំណាកស្រុក នៃអង្គការសង់ត្រាល់ (CENTRAL) ប្រចាំនៅប្រទេសថៃ លោក លឹង សុផុន ឱ្យវិទ្យុអាស៊ីសេរីដឹងថា ក្រុមពលរដ្ឋដែលមកសុំការិយាល័យអង្គការរបស់លោកស្នាក់នៅពេលនេះមានចំនួន ៩នាក់។ លោកបន្តថា ពលករទាំងនេះមកដល់ប្រទេសថៃរកការងារធ្វើ តែមិនទាន់បានចូលធ្វើ ហើយក៏មានពលករខ្លះបាត់បង់ការងារ ដែលគ្មានប្រាក់ទៅស្រុកវិញ ឬរកការងារថ្មីមិនទាន់ទើបពួកគាត់មកសុំការិយាល័យអង្គការរបស់លោកស្នាក់នៅបណ្តោះអាសន្នសិន។ លោកបន្តថា នៅពេលកន្លែងស្នាក់នៅ ផ្តល់អង្គការឬម្ចាស់ឬបដល់ពលរដ្ឋ ក៏ទាក់ទងទៅមេការជនជាតិខ្មែរ ដែលធ្វើការងារតាមរោងចក្រនៅប្រទេសនេះ ដើម្បីជួយសម្រួលឬអាចជួយឱ្យពលករទាំងនោះបានចូលធ្វើការ។

លោក លឹង សុផុន៖ «អ្នកខ្លះនៅបន្ទប់តូចផង ហើយណាមួយគាត់មានប្រុសស្រីអ៊ីចឹងក៏ទៅដេកផ្ទះខ្ញុំផ្ទាល់ខ្លួនដែលខ្ញុំជួលផ្ទះមួយកន្លែងទៀត នៅពេលពួកគាត់រង់ចាំបានការងារធ្វើទៅ បានប្រាក់ខែទៅគាត់ក៏សម្រេចចិត្តដូរកន្លែងទៅកន្លែងម៉ឺណាជិតកន្លែងគាត់ធ្វើការ ដែលគាត់រស់នៅបាន។ ជួយគាត់ទិញអង្ករ ទិញសម្ភារៈហូបចុកយើងជួយគាត់តាមអ្វីដែលយើងអាចជួយបាន»។

ក្រសួងការងារឱ្យដឹងថា មានពលករ១លាន៣សែននាក់ កំពុងធ្វើការងារនៅប្រទេសថៃ ប៉ុន្តែអង្គការសង់ត្រាល់រកឃើញថា ពលករខ្មែរធ្វើការនៅប្រទេសនេះមានជាង២លាននាក់ បូករួមទាំងពលករគ្មានឯកសារគ្រប់គ្រាន់។ ក្រុមពលករខ្មែរទម្រាំអាចមកធ្វើការងារនៅប្រទេសថៃ គឺត្រូវចំណាយប្រាក់ច្រើនចាប់ពី៣០០ដុល្លារទៅ៥០០ដុល្លារ ឬច្រើនជាងនេះ ដើម្បីធ្វើឯកសារ និងត្រូវចំណាយមួយចំនួនទៀតសម្រាប់ការធ្វើដំណើរ ហើយប្រសិនបើពួកគាត់ឆ្លងដែនខុសច្បាប់ ត្រូវចំណាយប្រាក់ជិត២០០ដុល្លារ ទម្រាំអាចចូលប្រទេសថៃបាន។ អ្នកខ្លះមានឯកសារគ្រប់គ្រាន់ហើយតែមកដល់ប្រទេសថៃ រកការងារមិនបានធ្វើ ឬក៏ត្រូវអ្នកនាំឱ្យមកធ្វើការងារបោះបង់ចោល៕

## ពលករកម្ពុជាធ្វើការស្របច្បាប់ក្រៅប្រទេស១លាន៣សែននាក់ និងផ្ដល់ប្រាក់មកស្រុកប្រមាណ២ពាន់៧រយលានដុល្លារក្នុង១ឆ្នាំ

https://kohsantepheapdaily.com.kh/article/1755551.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ភ្នំពេញ១៤ ខែ មិថុនា ឆ្នាំ ២០២៣ ម៉ោង ១៤:១៧

*រាជធានីភ្នំពេញ ៖ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានគូសបញ្ជាក់ឲ្យដឹងថា គិតមកដល់បច្ចុប្បន្ននេះ កម្ពុជាបានបញ្ជូនពលករស្របច្បាប់ទៅធ្វើការនៅក្រៅប្រទេសចំនួន១លាន៣សែននាក់ ហើយពួកគេបានផ្ដាល់ប្រាក់ខែរបស់ខ្លួនមកស្រុកកំណើតប្រមាណ២ពាន់៧រយលានដុល្លារអាមេរិកក្នុងមួយឆ្នាំ ។*

*ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានលើកឡើងថា ក្នុងពិធីសំណេះសំណាលជាមួយកម្មករកម្មការិនីនៅក្នុងរាជធានីភ្នំពេញ នាព្រឹកថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ថា រាជរដ្ឋាភិបាលបានផ្ដល់ឱកាសការងារដល់បងប្អូនប្រជាពលរដ្ឋធ្វើការនៅក្រៅប្រទេសដោយអនុវត្តពលករទេសន្តប្រវេសន៍ដោយសុវត្ថិភាពគិតត្រឹមខែឧសភា ឆ្នាំ២០២៣ មានពលករចំនួនប្រមាណ១លាន៣សែននាក់ កំពុងធ្វើការនៅក្រៅប្រទេស ក្នុងនោះនៅប្រទេសថៃចំនួន១លាន២សែននាក់ កូរ៉េ៤ម៉ឺន៩ពាន់នាក់ ម៉ាឡេស៊ី២ម៉ឺន២ពាន់នាក់ ជប៉ុន១ម៉ឺន៩ពាន់នាក់ ។*

*ឯកឧត្តមរដ្ឋមន្ត្រីបានឲ្យដឹងថា ពលករដែលកំពុងធ្វើការនៅក្រៅប្រទេសសុទ្ធតែទទួលបានអត្ថប្រយោជន៍ផ្សេងៗតាមច្បាប់នៃប្រទេសនីមួយៗរួមទាំងប្រាក់ឈ្នួល និងរបបសន្តិសុខសង្គម ។ ពលករបានផ្ញើប្រាក់មកក្រុមគ្រួសារនៅស្រុកកំណើតពីគ្រប់ប្រទេសមានប្រមាណចំនួន២ពាន់៧រយលានដុល្លារអាមេរិក ។ ជាមួយគ្នានោះដែរ ឯកឧត្តមរដ្ឋមន្ត្រីបានលើកឡើងថា ពលករដែលធ្វើការនៅក្រៅប្រទេសសុទ្ធតែទទួលបានចំណេះជំនាញ និងជាធនធានមនុស្សដ៏មានតម្លៃនៅពេលមកប្រទេសវិញ ៕*

## សាលាឧទ្ធរណ៍ តម្កល់ទណ្ឌកម្ម ជនជាប់ចោទវៀតណាមប្រុស-ស្រី ២នាក់ ត្រូវជាប់គុក ម្នាក់ៗ ៨ ឆ្នាំ ដោយសារតែព្រួតគ្នាវាយ ស្ត្រីបំរើផ្ទះគេម្នាក់បណ្តាលឲ្យស្លាប់ ព្រោះខឹងនាងមិនព្រមទទួលភ្ញៀវ!

https://cen.com.kh/archives/668709.html Posted ByPen Srey Neat June 14, 2023

*ភ្នំពេញៈ ជនជាប់ចោទប្រុស-ស្រី ជនជាតិវៀតណាម ចំនួន២នាក់ កាលពីព្រឹកថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០២៣ ត្រូវបានសាលាឧទ្ធរណ៍ រាជធានីភ្នំពេញ ប្រកាសសាលដីកា តម្កល់ទោសពួកគេ ជាប់ពាក់ព័ន្ធនឹងការព្រួតគ្នា វាយ ធ្វើបាប នារីវៀតណាម បំរើផ្ទះគេម្នាក់ ដែលអ្នកបម្រើការងារ នៅ*

ក្នុងហាងម៉ាស្សារបស់ពួកគេ បណ្ដាលឲ្យស្លា.ប់ ពីព្រោះខឹងនឹងជនរងគ្រោះ មិនព្រមទទួលភ្ញៀវ រួចដឹកសពយកទៅវត្ត ដើម្បីបូជា ប្រព្រឹត្ត កាលពីថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១៨ នៅផ្ទះជួលលេខ ១៥៨ ផ្លូវលេខ៥៩៨ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

លោក អ៊ឹម វណ្ណៈ ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ បានថ្លែងឲ្យដឹងថា ជនជាប់ចោទទាំង២នាក់ មានឈ្មោះ ង្វៀង យ៉ាំងចូវ ភេទប្រុស អាយុ ២៨ ឆ្នាំ ជនជាតិវៀតណាម មុខរបរ មេការមើលខុសត្រូវនារីបំរើផ្លូវភេទ និងម្នាក់ទៀត ឈ្មោះ ង្វៀង ធីយុង ភេទស្រី អាយុ ៣៨ ឆ្នាំ ជនជាតិវៀតណាម ជាថៅកែ និង ម្ចាស់ហាង។ ចំណែកឯនារីរងគ្រោះត្រូវជាជនជាតិវៀតណាមដូចគ្នា មានអាយុ អាយុ ២៨ ឆ្នាំ ។ អ្នកទាំង៣នាក់ មានទីលំនៅ ផ្ទះជួលលេខ ១៥៨ ផ្លូវលេខ៥៩៨ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

លោកចៅក្រម បានថ្លែងថាៈ នៅក្នុងសំណុំរឿងក្តីនេះ ជនជាប់ចោទទាំង២នាក់ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៩ ដាក់ពន្ធនាគាកំណត់ ម្នាក់ៗ ០៨ ឆ្នាំ ពីបទៈ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណៈភាពនៃជនរងគ្រោះ ផ្ដើមគំនិតក្នុងអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណៈភាពនៃជនរងគ្រោះ ។ តែពួកគាត់បានប្តឹងឧទ្ធរណ៍ ។ ពួកគេ ត្រូវបានចាប់ឃាត់ខ្លួន កាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៨ នៅសង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ៕ រក្សាសិទ្ធដោយៈ ចន្ទា ភា

## ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ គឺជាបញ្ហាសកលដែលពិភពលោកកំពុងតែយកចិត្តទុកដាក់

https://btv.com.kh/article/24729 2023/06/14 02:35:43 pm

ភ្នំពេញ ៖ ឯកឧត្តម ស្រី សួន រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានអះអាងថា ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ គឺជាបញ្ហាសកលដែលពិភពលោកកំពុងតែយកចិត្តទុកដាក់ និងរួមគ្នាដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការរំលោភបំពានក្នុងបរិបទប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននេះ។ ការថ្លែងរបស់ឯកឧត្តម ស្រី សួន យ៉ាងដូច្នេះក្នុងពិធីបើកសិក្ខាសាលាស្តីពី "កិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ" នៅសាលាមជ្ឈមវិចិត្រសិល្បៈ ព្រឹកថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣នេះ។

ឯកឧត្តម ស្រី សួន រដ្ឋលេខាធិការ បានបន្តទៀតថា កម្ពុជា ក៏ជាប្រទេសមួយដែលបានបោះជំហានទៅមុខ ក្នុងការចូលរួមចំណែកសំដៅធ្វើឲ្យកាន់តែប្រសើរឡើងនូវការលើកកម្ពស់កិច្ចការពារ

កុមារ និងឧត្តមប្រយោជន៍របស់កុមារគ្រប់រូប។ ក្រោយពីព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ និងលើពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារ ស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ ព្រមទាំងពិធីសារបន្ថែម ស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះ ប្រដាប់អាវុធ នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០២ រួចមក រាជរដ្ឋាភិបាលកម្ពុជា បានបន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវបទដ្ឋានទាំងនោះ ដោយខិតខំដាក់បញ្ចូលខ្លឹមសារពាក់ព័ន្ធទៅក្នុងច្បាប់គោលនយោបាយ ផែនការនានា សំដៅពង្រឹងកិច្ចការពារកុមារពីភាពរងគ្រោះទាំងឡាយឲ្យកាន់តែល្អប្រសើរ។

ឯកឧត្តម រដ្ឋលេខាធិការ បានបញ្ជាក់ទៀតថា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សេដ្ឋកិច្ច វប្បធម៌ និងសង្គមជាតិ ត្រូវបានស្តារ និងអភិវឌ្ឍរហូតធ្វើឲ្យសម្រេចកំណើនសេដ្ឋកិច្ចគួរឲ្យកត់សម្គាល់ក្នុងពីរទសវត្សរ៍ចុងក្រោយនេះ ហើយប្រទេសនានាក្នុងតំបន់និងលើពិភពលោក ទទួលស្គាល់នូវជំហានរីកចម្រើនឈានឡើងយ៉ាងឆាប់រហ័សរបស់ព្រះរាជាណាចក្រកម្ពុជា ដោយបានបង្កើតនូវឱកាសជាច្រើនថែមទៀត ក្នុងការកសាងនិងអភិវឌ្ឍប្រទេស។

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ បានជំរុញឲ្យការវិភាជន៍ធនធានបន្ថែមដល់វិស័យអប់រំ សុខាភិបាល សង្គមកិច្ច និងវិស័យផ្សេងៗទៀត ដែលក្នុងនោះការអភិវឌ្ឍកុមារ គឺជាអាទិភាពមួយនៃការកសាងធនធានមនុស្សសម្រាប់ការអភិវឌ្ឍជាតិ និងសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព២០១៦-២០៣០។ ទន្ទឹមនឹងនេះ កម្ពុជាបានត្រៀមខ្លួនជាស្រេចក្នុងការចូលរួមក្នុងបដិវត្តឧស្សាហកម្ម ៤ចុច០ ដែលផ្តោតជាពិសេសលើវិស័យបច្ចេកវិទ្យា ដែលពិភពលោកកំពុងប្រើប្រាស់ជាមធ្យោបាយសម្រាប់វិស័យនយោបាយ សេដ្ឋកិច្ច វប្បធម៌ និងសង្គមកិច្ច យ៉ាងមានប្រសិទ្ធភាព។ ការរីកចម្រើនផ្នែកបច្ចេកវិទ្យាព័ត៌មាន បានកំចាត់នូវភាពអសកម្មជំរុញដល់ការរីកលូតលាស់ ការងារ នយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច ដែលធ្វើឱ្យកម្ពុជាមានទំនាក់ទំនងជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោកថែមទៀតផង ជាមួយគ្នានោះដែរ។

លោកជំទាវ ធឹង ស៊ីមន រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានលើកឡើងថា វគ្គបណ្តុះបណ្តាលនាពេលនេះ រៀបចំឡើងក្នុងគោលបំណងដើម្បីលើកកម្ពស់ការយល់ដឹងអំពីគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ និងកិច្ចការពារកុមារពីការរងប្រវ័ញ្ច និងការរំលោភ បំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ ដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៃសាលាមធ្យមវិចិត្រសិល្បៈ៕ អត្ថបទ ៖ រដ្ឋា

# ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០២៣

## ក្រសួងកិច្ចការនារី ប្រកាសលេខទូរស័ព្ទទាំង២៥ខេត្តក្រុង ដើម្បីពលរដ្ឋអាចរាយការណ៍ពេលឃើញអំពើហិង្សាលើស្ត្រី

https://www.kampucheathmey.com/local-news/526496 ថ្ងៃព្រហស្បតិ៍ ១៥ មិថុនា ២០២៣ដោយ អុន ស្រីមាន

ដើម្បីផ្តល់ភាពងាយស្រួល និងជួយដល់ស្ត្រី ក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សានានា ក្រសួងកិច្ចការនារី បានដាក់ខ្សែទូរស័ព្ទទាំង២៥ខេត្តក្រុង ដើម្បីងាយស្រួលដល់ជនរងគ្រោះ ព្រមទាំងអ្នកឃើញហេតុការណ៍ងាយស្រួលក្នុងការរាយការណ៍។ ក្រសួងកិច្ចការនារី បានណែនាំថា ប្រសិនជាមានភាពតានតឹង បញ្ហាស្មុគស្មាញ ឬ បញ្ហានានា គួរស្វែងរកការប្រឹក្សាផ្លូវចិត្តដើម្បីឱ្យសុខភាពផ្លូវចិត្តមានភាពប្រសើរឡើង ចៀសវាងការប្រព្រឹត្តអំពើហិង្សា។ ទន្ទឹមនឹងនេះ ក្រសួងក៏បានស្នើដល់ពលរដ្ឋ ឬ ជនរងគ្រោះ ឱ្យមានការរាយការណ៍ ឬ ជួបអំពើហិង្សាក្នុងគ្រួសារ ឬ បញ្ហាកើតលើស្ត្រី ក្មេងស្រីងាយរងគ្រោះ ដោយទាក់ទងតាមលេខទូរស័ព្ទខាងក្រោមនេះ៖

• ក្រសួងកិច្ចការនារី៖ ០១១ ២១៧ ១២៣ • ខេត្តបន្ទាយមានជ័យ៖ ០១២ ៥២៣ ៣៦៦/ ០៨៩ ៣៣៤ ៤៩២ • ខេត្តបាត់ដំបង៖ ០១០ ៨៩២ ៦០៤ ឬ ០១២ ៧៤២ ៧៣៣ • ខេត្តកំពង់ចាម៖ ០៨៥ ៧៦៩ ៣៨៣ ឬ ០៧៧ ៨៧៧ ៦៩៧ • ខេត្តកំពង់ឆ្នាំង៖ ០១២ ៩០៩ ៦៧២ / ០៨៧ ៦៥៦ ៥៣១ / ០៩២ ៩១៨ ២៥១ • ខេត្តកំពង់ស្ពឺ៖ ០១៦ ៤៩២ ៧៧៧ / ០១៦ ៧៩៨ ៨៩៨ • ខេត្តកំពង់ធំ៖ ០៩២ ៩២៣ ៦៩៣ / ០៩២ ៨១១ ៥៥០ • ខេត្តកំពត៖ ០៩៣ ៨៨៦ ៦២៦ / ០៧០ ៨៧៥ ៩៥៩ • ខេត្តកណ្ដាល៖ ០៩៦ ៣ ៦៣៦ ៧៧១ / ០៦៩ ៨២០ ៨៣០ • ខេត្តកែប៖ ០៧០ ៤៥៨ ២៦៤ / ០៩២ ៥៨២ ០៤០ • ខេត្តកោះកុង៖ ០១៦ ៥៤៨ ៩៦៥ / ០១៦ ៩២២ ៥៩១ • ខេត្តក្រចេះ៖ ០៩៧ ៨ ៨២០ ៣៦៣ / ០៨៨ ៤ ៧២៥ ៩៥៩ • ខេត្តមណ្ឌលគិរី៖ ០៨៩ ៩៩៨ ៨៧៧ / ០១៧ ៣២០ ៣៦២ • ខេត្តឧត្តរមានជ័យ៖ ០៨៨ ៦ ៤៤៤ ៧០៩ / ០៨៨ ៧ ៣២១ ២២១ • ខេត្តប៉ៃលិន៖ ០៨៨ ៧២១ ២២ ៨៨ / ០៩០ ៣៣៨ ៨១៨ • រាជធានីភ្នំពេញ៖ ០៩៥ ៦៩០ ៦០០ / ០៩៦ ៨៣៣ ៣៨៦៣ • អគ្គស្នងការនគរបាលជាតិ៖ ១២៨៨។

អំពើហិង្សានៅក្នុងគ្រួសារ លើស្ត្រី និងក្មេងស្រី មិនគួរកើតមានឡើយនៅក្នុងសង្គម។ ដូច្នេះចំពោះតួនាទីការពារ និងស្វែងរកជំនួយ ក៏មិនមែនជាតួនាទីរបស់ជនរងគ្រោះតែម្នាក់ឯង ដើម្បីរកជំនួយឡើយ គឺជាតួនាទីពលរដ្ឋគ្រប់រូបក្នុងការជួយដល់ស្ត្រី។ ជនរងគ្រោះ ក៏ត្រូវមានភាពក្លាហានក្នុងការតតាំង និងក្រោកឈរដោយខ្លួនឯងផងដែរ។ ប្រភព៖ ក្រសួងកិច្ចការនារី

## នគរបាលថៃចាប់ខ្លួនជនជាតិថៃម្នាក់ដែលធ្វើការអោយក្រុមឆបោកតាមទូរស័ព្ទនៅកម្ពុជា

https://www.khmertimeskh.com/501308631// Khmer Times June 15, 2023

មន្ត្រីក្រុមការងារឧក្រិដ្ឋកម្មតាមអ៊ីនធឺណិតនៅស្រុក Si Racha នៃខេត្ត Chon Buri ប្រទេសថៃ បានចាប់ខ្លួនបុរសម្នាក់ក្នុងខេត្ត Chiang Rai កាលពីថ្ងៃអង្គារ។ បុគ្គលនេះត្រូវបានគេចោទប្រកាន់ថាជាដៃស្តាំរបស់មេក្រុមឆបោកជនជាតិចិនម្នាក់នៅខេត្តកោះកុង។

ជនសង្ស័យមានឈ្មោះ Surachai Sae Jang មានស្រុកកំណើតនៅស្រុក Mae Fah Luang ក្នុងខេត្ត Chiang Rai ត្រូវបានចោទប្រកាន់ពីបទឆបោក ជាប់ពាក់ព័ន្ធក្រុមឧក្រិដ្ឋកម្ម និងការលាងលុយកខ្វក់។ ជនល្មើសបានទៅប្រទេសកម្ពុជាកាលពី២ឆ្នាំមុន ដើម្បីធ្វើការជាអ្នកបកប្រែភាសាថៃ-ចិន ប៉ុន្តែនៅពេលមកដល់កម្ពុជា គាត់ត្រូវបានគេនាំទៅខេត្តកោះកុង ដើម្បីជួយថៅកែជនជាតិចិនក្នុងការទាក់ទងជាមួយបុគ្គលិកថៃផ្សេងទៀត ដែលធ្វើការនៅមជ្ឈមណ្ឌលទូរស័ព្ទ ដែលកំពុងល្បួងជនជាតិថៃឱ្យវិនិយោគលើរូបិយប័ណ្ណគ្រីបតូ ដោយសន្យាថានឹងទទួលបានប្រាក់ចំណេញខ្ពស់។ ក្រោយមកជនល្មើសនេះបានអះអាងថា ខ្លួនបានរត់គេចត្រឡប់ទៅប្រទេសថៃវិញ។

នគរបាលបាននិយាយថា ពួកគេបានទទួលព័ត៌មានពីជនជាតិថៃម្នាក់ ដែលត្រូវបានបញ្ចុះបញ្ចូលឱ្យធ្វើការនៅក្នុងមជ្ឈមណ្ឌលហៅទូរស័ព្ទដូចគ្នាថា ក្រុមជនខិលខូចបានបង្កើតប្រព័ន្ធផ្សព្វផ្សាយសង្គមក្លែងក្លាយសម្រាប់បុគ្គលិករបស់ពួកគេដោយបន្លំខ្លួនជាបុរសសង្ហា ឬជានារីដែលស្រស់ស្អាត ដើម្បីទាក់ទាញអ្នកនិយមលេងអ៊ីនធឺណិតផ្សេងទៀត។ នគរបាលបានលើកឡើងទៀតថា បន្ទាប់មកពួកគេនឹងធ្វើជាមិត្តជាមួយជនរងគ្រោះ ហើយបញ្ចុះបញ្ចូលពួកគេឱ្យវិនិយោគលើការជួញដូររូបិយប័ណ្ណឌីជីថល ដោយបន្ថែមថាក្រុមឆបោកក៏បានបង្កើតបណ្តាញក្លែងក្លាយដែលជនរងគ្រោះអាចពិនិត្យរាល់របាយការណ៍ហិរញ្ញវត្ថុ ដើម្បីបញ្ចុះបញ្ចូលពួកគេឱ្យវិនិយោគ។

## មនុស្ស ៧៩នាក់ បានស្លាប់ និងរាប់រយនាក់បាត់ខ្លួន ក្រោយទូកជនអន្តោប្រវេសន៍លិច ក្បែរឆ្នេរសមុទ្រក្រិក

https://www.btv.com.kh/article/24767 2023/06/15 09:44:47 am

អង្គភាពឆ្មាំល្បាតឆ្នេរក្រិកនិយាយថា មនុស្សយ៉ាងហោចណាស់៧៩នាក់ បានស្លាប់ ក្រោយទូកជនអន្តោប្រវេសន៍មួយគ្រឿងដឹកមនុស្សរាប់រយនាក់ បានក្រឡាប់លិចក្បែរឆ្នេរសមុទ្រប្រទេសក្រិក កាលពីព្រឹកថ្ងៃពុធ ខណៈមានក្តីបារម្ភថាចំនួនអ្នកស្លាប់អាចកើនឡើង និងរាប់រយនាក់កំពុងបាត់ខ្លួន។ ជនអន្តោប្របេសន៍សរុបចំនួន១០៤នាក់ ដែលធ្វើដំណើរតាមទូក ត្រូវបានសង្គ្រោះពីទឹក និងបានបញ្ជូនទៅកាន់ទីក្រុង កាឡាម៉ាតា (Kalamata)។

អភិបាលក្រុងនេះ លោក តាណាស៊ីស វ៉ាស៊ីសូផូឡូស (Thanasis Vasilopoulos) បាននិយាយកាលពីថ្ងៃពុធថា យោងតាមអ្វីដែលពួកគេបាននិយាយ គឺ មនុស្សអាយុចន្លោះពី១៦ ដល់៤១ឆ្នាំ ។ ពួកគេក៏បាននិយាយផងដែរថា មានស្ត្រី និងកុមារជាច្រើននៅលើទូកនោះ។ គេមិនច្បាស់ទេថា មនុស្សប៉ុន្មាននាក់នៅលើនាវានោះ នៅពេលបានលិច។ ក្រុមអ្នកនៅរស់រានមានជីវិតនិយាយថា អាចមានអ្នកដំណើរប្រមាណ៧៥០នាក់។

អ្នកនាំពាក្យអង្គភាពឆ្មាំល្បាតឆ្នេរក្រិក លោក នីកូឡូស អាឡិចស៊ីអូ (Nikolaos Alexiou) បានប្រាប់សារព័ត៌មាន ERT ថា ទូកនេសាទនេះ មានប្រវែងចន្លោះពី២៥ទៅ៣០ម៉ែត្រ ហើយផ្ទុកមនុស្សពេញ ។

អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) បានសរសេរលើបណ្តាញសង្គមធ្វីតទ័រថា ខ្លួនជឿថា មានមនុស្សជាង ៤០០នាក់ នៅលើទូកនោះ៕ អត្ថបទ៖ សុខមាន

## កិច្ចប្រជុំគណៈកម្មាធិការព្រំដែន ថ្នាក់ភូមិភាគ កម្ពុជា-ថៃ លើកទី២៩ ត្រូវបានបិទបញ្ចប់នៅសៀមរាប

http://nokorwatnews.com/archives/1010834 15/06/2023

ខេត្តសៀមរាប ៖ ថ្ងៃព្រហស្បតិ៍ ១២រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ កិច្ចប្រជុំគណៈកម្មាធិការព្រំដែនថ្នាក់ភូមិភាគ កម្ពុជា-ថៃ លើកទី២៩ រវាងយោធភូមិភាគទី៥ (កម្ពុជា) និងកងទ័ពភូមិភាគទី១(ថៃ) បានបិទកិច្ចប្រជុំនៅសៀមរាប ក្រោយពីបានប្រព្រឹត្តធ្វើឡើងអស់រយៈពេល២ថ្ងៃ គឺចាប់ពីថ្ងៃទី១៤ ដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០២៣ ស្ថិតនៅសណ្ឋាគារអង្គរមីរ៉ាខល ខេត្តសៀមរាប។

កិច្ចប្រជុំបានប្រព្រឹត្តទៅក្រោមអធិបតីភាព លោក ឧត្តមសេនីយ៍ឯក ឯក សំអួន មេបញ្ជាការរងកងទ័ពជើងគោក មេបញ្ជាការយោធភូមិភាគទី៥ ភាគីកម្ពុជា ឯភាគីថៃ ដឹកនាំដោយ លោក ឧត្តមសេនីយ៍ទោ ផាក់ណា ខ្វៃវបូតធុក មេបញ្ជាការកងទ័ពភូមិភាគទី១ ជាសហប្រធាននៃអង្គប្រជុំរួម។ ការប្រជុំនេះមានគោលបំណងដើម្បីពិភាក្សារកទិសដៅដោះស្រាយ និងរំលឹកឡើងវិញនូវភាពរីកចម្រើននៃការអភិវឌ្ឍន៍លើវិស័យផ្សេងៗ ពាក់ព័ន្ធទៅនឹងសម្ព័ន្ធភាពកងទ័ព និងសន្តិសុខតាមព្រំដែន ដោយពិចារណាក្នុងការកំណត់ទស្សនវិស័យក្នុងក្របខ័ណ្ឌគណៈកម្មាធិការព្រំដែនថ្នាក់ភូមិភាគ។

អង្គប្រជុំបានរំលឹកឡើងវិញ ពីលទ្ធផលនៃការប្រជុំគណៈកម្មាធិការព្រំដែនថ្នាក់ភូមិភាគ ថៃ-កម្ពុជា លើកទី២៨ រវាងយោធភូមិភាគទី៥ និងកងទ័ពភូមិភាគទី១ ដោយនាំលទ្ធផលនៃការប្រជុំដូចបានពោលខាងលើដើម្បីយកមកពិចារណា និងរៀបចំធ្វើកំណត់ហេតុរួមក្នុងការប្រជុំលើកនេះ។ ក្នុង

រយៈពេលពីរថ្ងៃនេះអង្គប្រជុំមានការពិភាក្សា និងផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមកពាក់ព័ន្ធនឹងបញ្ហាផ្សេងៗក្នុងក្របខ័ណ្ឌគណៈកម្មាធិការព្រំដែនថ្នាក់ភូមិភាគ(RBC) ក្រៅពីនេះភាគីទាំងពីរបានលើកសួយឲ្យមានការអនុវត្តន៍ទៅតាមអនុស្សារណៈនៃការយោគយល់គ្នាស្តីអំពីការត្រួតពិនិត្យ និងរៀបចំបោះបង្គោលសីមាព្រំដែន ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០០ មានប្រសិទ្ធភាពខ្ពស់។

ភាគីទាំងពីរបានឯកភាពរួមគ្នាឲ្យមានការប្រជុំពិភាក្សាដើម្បីកំណត់ទិសដៅ ក្នុងការទប់ស្កាត់ការលបលួចកសាងសំណង់ខុសច្បាប់ និងការចោលសំណល់រឹង បង្ហូរសំណល់រាវចូលអូរព្រំដែនកម្ពុជា-ថៃ ភាគីទាំងពីរបានឯកភាពគ្នា ស្នើឲ្យមានការដើរល្បាតដោយមានការទំនាក់ទំនងគ្នាតាមបណ្តោយព្រំដែន កិច្ចសហប្រតិបត្តិការល្បាត ដើម្បីទប់ស្កាត់ការលបលួចកាប់ឈើខុសច្បាប់ និងការប្រយុទ្ធប្រឆាំងការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែន តាមបរិវេណព្រំដែន ទាំងការល្បាតផ្លូវអាកាស តាមបណ្តោយព្រំដែនស្នើឲ្យមានការទំនាក់ទំនងជាមុនសិនមុននឹងមានការហោះហើរ។

អង្គប្រជុំបានឯកភាពរៀបចំការប្រជុំគណៈកម្មាធិការព្រំដែនថ្នាក់ភូមិភាគ ថៃ-កម្ពុជា លើកទី៣០ នៅព្រះរាជាណាចក្រថៃ សម្រាប់ការកំណត់ពេលវេលានិងទីកន្លែង នឹងមានការជូនដំណឹងតាមរយៈក្រុមលេខាភាគីទាំងពីរ។ កំណត់ហេតុរួមការប្រជុំគណៈកម្មាធិការព្រំដែនភូមិភាគកម្ពុជា-ថៃលើកទី២៩នេះ បានរៀបចំ និងចុះហត្ថលេខា នៅសណ្ឋាគារអង្គរមីរ៉ាខល ខេត្តសៀមរាប។ កិច្ចប្រជុំបានបញ្ចប់ក្រោមបរិយាកាសដ៏សែនរីករាយនិងស្និទ្ធស្នាលបំផុត និងបានជូនកាដូអនុស្សាវរីយ៍ទៅវិញទៅមកផងដែរ ៕

# ថ្ងៃទី២០ ខែ មិថុនា ឆ្នាំ២០២៣

## សមត្ថកិច្ចកម្ពុជា បន្តទទួលបានបណ្តឹង ០១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ១នាក់

https://freshnewsasia.com/index.php/en/localnews/295888-2023-06-16-09-33-23.html 2023-06-16 04:33pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១៤ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០១នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំ

ពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៩៤០ករណី មានមនុស្ស ២,៤០៧នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៩០៤សំណើ និងបិទសំណុំរឿង ៣០៣សំណើ (រកឃើញមនុស្ស ១,៤០១នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣៧នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣៦ករណី។

## របាយការណ៍អាមេរិក
## ស្តីពីការជួញដូរមនុស្សផ្តោតសំខាន់លើពលកម្មចាប់បង្ខំ និងការជួញដូរក្មេងប្រុស

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 16/06/2023 - 14:24

ក្រសួងការបរទេសអាមេរិកចេញផ្សាយរបាយការណ៍ស្តីពីការជួញដូរមនុស្ស ដោយផ្តោតទៅលើពលកម្មដោយចាប់បង្ខំ និងការជួញដូរក្មេងប្រុស ដែលបានកើនឡើងគួរឲ្យកត់សំគាល់នៅប៉ុន្មានឆ្នាំចុងក្រោយនេះ។ នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ចេញផ្សាយ កាលពីថ្ងៃព្រហស្បតិ៍ម្សិលមិញ ក្រសួងការបរទេសអាមេរិកបានបង្ហាញប្រទេសដែលឡើងចំណាត់ថ្នាក់ល្អ និងប្រទេសធ្លាក់ចំណាត់ថ្នាក់ ដោយសារមិនបានប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងការជួញដូរ។ កម្ពុជា ស្ថិតក្នុងចំណោមប្រទេសចំនួន ២៤ ដែលជាប់ចំណាត់ថ្នាក់ កម្រិតទី៣ ដែលជាចំណាត់ថ្នាក់ដ៏អាក្រក់បំផុតរបស់ក្រសួងការបរទេសអាមេរិក។ នៅក្នុងរបាយការណ៍ប្រចាំឆ្នាំស្តីពីការជួញដូរមនុស្សចេញផ្សាយកាលពីថ្ងៃព្រហស្បតិ៍ទី ១៥ មិថុនា ក្រសួងការបរទេសអាមេរិកបានគូសបញ្ជាក់ពីការកើនឡើងគួរឲ្យកត់សំគាល់ នៃពលកម្មដោយបង្ខំ ដែលមានជាប់ទាក់ទងនឹងជំងឺរាតត្បាតកូវីដ។

តាមរដ្ឋមន្ត្រីការបរទេសអាមេរិក លោកអង់តូនី ប្លីងកិន ដែលបានឡើងនិយាយនៅក្នុងឱកាសបង្ហាញរបាយការណ៍ កាលពីថ្ងៃម្សិលមិញ ពលកម្មដោយបង្ខំ បានកើនឡើងលឿនស្ទើរ នៅក្នុងពិភពលោក។ ជាក់ស្តែង ថៅកែរោងចក្រ ម្ចាស់ក្រុមហ៊ុនបានយកលេសវិបត្តិកូវីដ ដើម្បីកេងប្រវ័ញ្ចលើបុគ្គលិក កម្មករ តាមរយៈការទម្លាក់ កាត់បន្ថយប្រាក់ខែ និងចាប់បង្ខំឲ្យធ្វើការច្រើនម៉ោង។

លោកស្រី Cindy Dyer ប្រធានផ្នែកប្រយុទ្ធប្រឆាំងនឹងការជួញដូររបស់ក្រសួងការបទេសអាមេរិក បានបន្ថែមថា ពួកក្រុមឈ្មួញជួញដូរមនុស្សបានយកពាក្យដែលថា ពិភពលោកកំពុងជួបវិបត្តិ

សេដ្ឋកិច្ចដោយសារកូវីដ មនុស្សគ្មានការងារធ្វើច្រើន បូកផ្សំ ឬការរឹតត្បិតក្នុងការធ្វើដំណើរឆ្លងដែន ទៅឃោសនា ទាក់ទាញជនរងគ្រោះ។

តាមរបាយការណ៍របស់ក្រសួងការបរទេស មនុស្សប្រមាណ ២៧លាននាក់ រងគ្រោះដោយសារការជួញដូរមនុស្សនៅក្នុងពិភពលោក។ សម្រាប់រដ្ឋមន្ត្រីការបរទេសអាមេរិក នៅក្នុងចំណោមការជួញដូរមនុស្សជាទូទៅ អាមេរិកបានកត់សំគាល់ឃើញ ការជួញដូរមនុស្សក្នុងទម្រង់ថ្មី គឺការជួញដូរ បោកបញ្ឆោត តាមបច្ចេកវិទ្យា ប្រព័ន្ធអ៊ីនធ័រនែត ឬហៅថា SCAM។ ការជួញដូរមនុស្សទម្រង់ថ្មី កើនឡើងខ្លាំង នៅតាមបណ្ដាប្រទេសមួយចំនួន មិនថា នៅអាស៊ី អាហ្វ្រិក ដូចជានៅកម្ពុជា តួកគី ម៉ាឡេស៊ី ហ្គាណាជាដើម។ ក្រៅពីការជួញដូរមនុស្សតាមរយៈ ការឆបោកតាមប្រព័ន្ធអ៊ីនធ័រនែត ក្រសួងការបរទេសអាមេរិកបានផ្ដោតទៅលើករណីជួញដូរក្មេងប្រុស ដែលបានកើនឡើងប្រមាណ ៥០០% នៅប៉ុន្មានឆ្នាំមកនេះ។

**ហេតុអ្វីរបាយការណ៍របស់អាមេរិកនិយាយពីការជួញដូរក្មេងប្រុស?**

ដោយនិយាយយោងរបាយការណ៍របស់អង្គការសហប្រជាជាតិ ស្ដីពីការជួញដូរមនុស្សនៅក្នុងពិភពលោក ប្រមុខការបរទេសអាមេរិក លោកអង់តូនី ប៊្លីងកិន បានសង្កត់ធ្ងន់លើករណីក្មេងប្រុស ដែលរងគ្រោះ ដោយសារការជួញដូចមនុស្ស។ តាមលោកប៊្លីងកិន ចន្លោះឆ្នាំ ២០០៤ ដល់ឆ្នាំ ២០២០ ក្មេងប្រុសដែលត្រូវគេជួញដូរខុសច្បាប់ មានចំនួនច្រើនជាង ក្មេងស្រី ស្ត្រី ឬបុរស។ ប៉ុន្តែគ្រាន់តែថា គេមិនសូវលើកនិយាយច្រើន។

តាមការពន្យល់របស់អ្នកជំនាញអាមេរិក ដូចស្ត្រី និងកុមារ ក្មេងប្រុសរងគ្រោះដោយសារការជួញដូរផ្លូវភេទ និងពលកម្មបង្ខំ។ ប៉ុន្តែ គេមិនសូវលឺគេនិយាយពីករណីក្មេងប្រុសជាជនរងគ្រោះដោយសារការជួញដូរមនុស្ស ដោយសារតែទី១ ក្មេងប្រុសមិនសូវចេញមុខប្រាប់ស្វែងរកសេវាជំនួយ ដោយសារតែពួកគេអាចខ្មាស់ មិនហ៊ាននិយាយថា ពួកគេចាញ់បោកពួកឈ្មួញជួញដូរមនុស្ស។

ហេតុផលទី២ ដែលធ្វើឲ្យក្មេងប្រុស មិនសូវមានរូបភាពនៅក្នុងបញ្ជីក្រុមជនរងគ្រោះដោយសារការជួញដូរផ្លូវភេទ និងពលកម្មចាប់បង្ខំ គឺ ការខ្វះអង្គការ ស្ថាប័នដែលធ្វើការសម្រាប់ជនរងគ្រោះដែលជាក្មេងប្រុស។ គេឃើញជាទូទៅ គេឃើញមានអង្គការច្រើនដែលធ្វើការផ្ដល់ជំនួយដល់មនុស្សស្រី ឬកុមារដែលរងគ្រោះដោយសារការជួញដូរមនុស្ស ប៉ុន្តែ គេកម្រនឹងឃើញស្ថាប័នអង្គការណាដែលធ្វើការផ្ដោតពិសេសលើការជួញដូរក្មេងប្រុស។

**ប្រទេស២៤ស្ថិតនៅក្នុងចំណាត់ថ្នាក់កម្រិតទី ៣ ចំណែក វៀតណាម ម៉ាឡេស៊ីត្រូវអាមេរិកដំឡើងចំណាត់ថ្នាក់ទៅកម្រិតទី២**

នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ មានប្រទេស២៤ដែលធ្លាក់ក្នុងចំណាត់ថ្នាក់កម្រិតទី ៣ ដែលជាកម្រិតអាក្រក់ជាងគេ ក្នុងនោះ មានចិន ភូមា រុស្ស៊ី កូរ៉េខាងជើង បេឡារុស អាល់ហ្សេរី ឆាត និងអាហ្វហ្កានីស្ថានជាដើម។ តាមការពន្យល់របស់លោកស្រី Cindy Dyer ចិនជាប់ចំណាត់កម្រិតទី៣ ដោយសារចិននៅតែបន្តអនុវត្តនយោបាយ ឬទម្រង់ជួញដូរមនុស្ស ជាពិសេសក្នុងរូបភាព ជាការងារចាប់បង្ខំដូចនៅខេត្តស៊ីនជាំងជាដើម។

របាយការណ៍របស់អាមេរិកបានដំឡើងចំណាត់ថ្នាក់របស់ប្រទេសដែលអាមេរិកកត់សំគាល់ឃើញថា បានធ្វើការប្រសើរឡើងនៅក្នុងរឿងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ដូចករណីប្រទេសវៀតណាម ម៉ាឡេស៊ី និងព្រុយណេ ដែលត្រូវបានដកចេញពី កម្រិតទី៣ ទៅនៅកម្រិតទី២ វិញ។ ប្រទេសដែលស្ថិតនៅក្នុងចំណាត់ថ្នាក់អាក្រក់ កម្រិតទី៣ នៅក្នុងរបាយការណ៍អាមេរិកស្តីពីរឿងជួញដូរមនុស្ស ត្រូវប្រឈមនឹងការជាប់ទណ្ឌកម្មរបស់អាមេរិក ការដាក់ពិន័យ មិនឲ្យចូលទឹកដីអាមេរិក ឬការកាត់បន្ថយជំនួយរបស់អាមេរិក។

### កម្ពុជានៅតែជាប់ចំណាត់ថ្នាក់កម្រិតទី៣របស់អាមេរិក

នៅក្នុងរបាយការណ៍ស្តីពីការជួញដូរមនុស្ស កម្ពុជានៅតែបន្តជាប់ក្នុងចំណាត់ថ្នាក់ កម្រិតទី ៣ ពោលគឺ២ឆ្នាំ ជាប់គ្នា បន្ទាប់ពីធ្លាក់ចំណាត់ថ្នាក់ ពីកម្រិតទី២ មកទី៣ កាលពីឆ្នាំ មុន។ បើតាមរបាយការណ៍របស់ក្រសួងការបរទេសអាមេរិក កម្ពុជានៅជាប់ក្នុងកម្រិតទី៣ ដោយសារតែកម្ពុជាមិនបានគោរពពេញលេញ តាមបទដ្ឋានអប្បបរមា ក្នុងការលុបបំបាត់ចោលការជួញដូរមនុស្ស ហើយមិនបានបង្កើនការប្រឹងប្រែង ច្រើនគួរឲ្យកត់សំគាល់ នៅក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។ អំពើពុករលួយ និងនិទណ្ឌភាពរបស់មន្ត្រីដែលអាចជាប់ពាក់ព័ន្ធនឹងការជួញដូរមនុស្សនៅកម្ពុជា ជាបញ្ហាសំខាន់ ដែលរបាយការណ៍រំលេចសរសេរច្រើន។ ជាថ្មីម្តងទៀត កម្ពុជា ត្រូវបានរបាយការណ៍អាមេរិកចាត់ទុកថា ត្រូវបានក្រុមជួញដូរមនុស្ស ប្រើប្រាស់ជាកន្លែងបោកបញ្ឆោតតាមប្រព័ន្ធអ៊ីនធ័រនែត ឬហៅថា SCAM។ ជនបរទេស និងជនជាតិខ្មែរក្នុងស្រុកត្រូវបានក្រុមឈ្មួញជួញដូរមនុស្ស ដែលជាប់ពាក់ព័ន្ធនឹងក្រុមហ៊ុនចិន បោកបញ្ឆោតឲ្យធ្វើការនៅតាមអគារក្នុងប្រទេសកម្ពុជា រហូតដល់មានសេចក្តីរាយការណ៍ពីការចាប់បង្ខាំងទុក មិនឲ្យមានសេរីភាព ការធ្វើទារុណកម្ម និងការជំរិតទារប្រាក់ជាដើម។ នៅត្រង់ចំណុចនេះ រដ្ឋមន្ត្រីការបរទេសអាមេរិកកាលពីថ្ងៃព្រហស្បតិ៍ ម្សិលមិញ បានផ្តល់រង្វាន់ដល់អ្នកកាសែតកម្ពុជាម្នាក់ គឺលោកម៉ិច ដារ៉ា ដែលយកចិត្តទុកដាក់ សរសេរអត្ថបទស៊ើបអង្កេតស្តីពីបណ្តាញជួញដូរមនុស្ស តាមរយៈប្រព័ន្ធអ៊ីនធ័រនែត។

# សមត្ថកិច្ចថៃចាប់ពលករខ្មែរ១០៩នាក់ចោទប្រកាន់ពីការលួចធ្វើការខុសច្បាប់

https://www.rfa.org/khmer/news/human-rights/11-cambodian-workers-arrested-by-thai-police-06162023043945.html *ដោយ សេក បណ្ឌិត*2023.06.16

*សមត្ថកិច្ចថៃចាប់ពលករខ្មែរ៩នាក់ និងកុមារតាមឪពុកម្ដាយពីរនាក់នៅការដ្ឋានសំណង់មួយនៅទីក្រុងបាងកក*(Bangkok) *ប្រទេសថៃ* (Thailand) *ដោយចោទប្រកាន់ថា ធ្វើការខុសច្បាប់នៅប្រទេសនេះ។ សាច់ញាតិអ្នកជាប់ឃុំស្នើទៅស្ថានទូតខ្មែរប្រចាំប្រទេសថៃ ជួយអន្តរាគមន៍ ដើម្បីអាចឱ្យពលករទាំងនោះបាននៅក្រៅឃុំ។ សមត្ថកិច្ចថៃកំពុងឃុំពលករធ្វើការងារផ្នែកសំណង់ទាំង៩នាក់ និងកុមារតាមម្ដាយពីរនាក់ នៅមន្ទីរឃុំខ្លួនមួយកន្លែងនៅទីក្រុងបាងកក ប្រទេសថៃ។ សាច់ញាតិពលករជាប់ឃុំឱ្យដឹងថា សមត្ថកិច្ចថៃ តម្រូវក្រុមពលករបង់ប្រាក់ក្នុងម្នាក់ៗជិត៥០០ដុល្លារ ទើបអាចនៅក្រៅឃុំបាន តែក្រុមពលរដ្ឋគ្មានប្រាក់បង់ឱ្យសមត្ថកិច្ចថៃឡើយ។*

*លោកស្រី រី ស្រីយ័ន្ត ជាពលករធ្វើសំណង់នៅប្រទេសថៃ ដែលសាច់ញាតិរបស់លោកស្រីត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួន ប្រាប់វិទ្យុអាស៊ីសេរីថ្ងៃទី១៥ ខែមិថុនា ថា សមត្ថកិច្ចថៃ បានចុះទៅត្រួតពិនិត្យនៅការដ្ឋានសំណង់មួយកន្លែង និងរកបានរកឃើញមានពលករខ្មែរ៩នាក់ ក្នុងនោះស្រី៥នាក់ និងប្រុស ៤គ្មានឯកសារគ្រប់គ្រាន់។ លោកស្រីឱ្យដឹងទៀតថា សមត្ថកិច្ចថៃក្រៅពីចាប់ពលករខ្មែរទាំង៩នាក់នោះ ក៏មានកុមារតាមម្ដាយពីរនាក់ម្នាក់អាយុ៤ឆ្នាំ និងម្នាក់ទៀតអាយុជាង១ឆ្នាំក៏ត្រូវបានសមត្ថកិច្ចនាំខ្លួនទៅជាមួយម្ដាយយកទៅឃុំខ្លួនដែរ។ លោកស្រីបញ្ជាក់ថា ក្រុមពលករដែលសមត្ថកិច្ចចាប់ខ្លួនទាំងនោះត្រូវបានសមត្ថកិច្ចចោទប្រកាន់ថា ឯកសារពួកគាត់ផុតសុពលភាព និងធ្វើការខុសកន្លែង។ លោកស្រី រី ស្រីយ័ន្ត ប្រាប់ថា លោកស្រីត្រឹមបានទាក់ទងទៅប្អូនតាមទូរស័ព្ទ ដោយមិនហ៊ានទៅសួរសុខទុក្ខដល់កន្លែងឃុំខ្លួនទេ ព្រោះលោកស្រីពេលនេះក៏មិនទាន់មានឯកសារការងារគ្រប់គ្រាន់ផងដែរ។*

*លោកស្រី រី ស្រីយ័ន្ត៖ «អ្នកដែលប័ណ្ណមានប៉ាស្ព័រ(លិខិតឆ្លងដែន) មានថៅកែ ត្រឹមត្រូវគេហៅចេញ តែមិនទាន់ហៅឈ្មោះនោះគេសួរថា តើស្អីៗអត់ដល់ពេលយើងអត់ហើយ ថៅកែទៅអត់ទាន់ដូចថា និយាយកន្លែងចាប់អត់ទាន់ គេ(សមត្ថកិច្ចថៃ) ក៏ហៅឡើងឡានយកទៅឃុំនៅ (ប៉ូលិសអន្តោប្រវេសន៍ថៃ) ចង់ឱ្យស្រណោះក្មេង ក្មេងហ្នឹងអាតូចទើបមួយខួបបីខែ ដែលគេចាប់ទាំងម៉ែទាំងកូននោះគ្នាមិនស្រួលបួលទៀតគ្នាគ្រុនទៀត»។ ពលករទាំង៩នាក់ និងកុមារតាមម្ដាយពីរនាក់ ត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួននៅក្នុងទីក្រុងបាងកក ពេលពួកគាត់កំពុងធ្វើការ កាលពីថ្ងៃទី១២ ខែមិថុនា។*

*លោកស្រី រី ស្រីយ័ន្ត ឱ្យដឹងដែរថា កាលពីថ្ងៃទី១៣ ខែមិថុនា ប្អូនស្រីរបស់លោកស្រីបានទូរស័ព្ទពីពន្ធនាគារមកថា សមត្ថកិច្ចថៃបង្គាប់ឱ្យក្រុមពលករ បង់ប្រាក់ម្នាក់ៗចំនួន១ម៉ឺន៤ពាន់បុដិត*

៥០០ដុល្លារ ទើបអនុញ្ញាតឱ្យមានសេរីភាពវិញ ប៉ុន្តែ ភ្លាមៗនោះលោកស្រីរកប្រាក់មិនបានទេ។ លោកស្រីបន្តទៀតថា នៅពេលគ្មានប្រាក់បង់ឱ្យសមត្ថកិច្ចថៃ ដូច្នេះ សមត្ថកិច្ចថៃបានបញ្ជូនក្រុមពលករទាំងនោះទៅតុលាការ ហើយពេលនេះតុលាការសម្រេចឃុំខ្លួនក្រុមពលករឱ្យជាប់ឃុំម្នាក់ៗចំនួន២៨ថ្ងៃ។ លោកស្រីក៏ព្យាយាមទាក់ទងទៅថៅកែជនជាតិថៃដែលគ្រប់គ្រងក្រុមពលករដែរ តែថៅកែថៃ ប្រាប់លោកស្រីវិញ ពេលនេះគេមិនអាចជួយអ្វីបានទេ ព្រោះសំណុំរឿងនេះបានចូលតុលាការទៅហើយ។ ស្ត្រីពលកររូបនេះ ស្នើទៅមន្ត្រីស្ថានទូតខ្មែរប្រចាំប្រទេសថៃ ជួយអន្តរាគមន៍ដល់ពលករឬក៏ជួយអន្តរាគមន៍ជួយឱ្យក្មេងៗពីរនាក់ដែលកំពុងជាប់ឃុំជាមួយម្ដាយអាចនៅក្រៅ។

លោកស្រី រី ស្រីយ័ន្តៈ «មានម៉ូតូដែលគាត់ទិញឱ្យឪគាត់ជិះនេះ ឱ្យយកទៅលក់សិន យកលុយមកលោះប្រពន្ធគាត់គាត់ស្រណោះប្រពន្ធកូន ចង់ឱ្យប្រពន្ធកូនចេញទៅមុន បើចំពោះរូបគាត់បើមិនមានលុយហើយ ក៏ជាប់ប៉ុណ្ណាក៏ជាប់ទៅតាមដំណើរ ដល់ពេលខ្ញុំទទួលទៅហើយ ខ្ញុំក៏បានម៉ែគាត់ តែគាត់ថា ឱ្យទៅរកលុយឯណា ព្រោះយើងមិនមានលុយជាប់ខ្លួនម៉ូតូក៏មិនលក់ថ្ងៃនេះបានថ្ងៃនេះទេបង ហើយគេពេលតែម្សិលមិញគេចាំយកលុយយើងបើថា ម្សិលមិញឱ្យមិនលុយគេទេ គេបញ្ជូនចូលគុកហើយ»។

ទាក់ទងរឿងរឿងនេះ វិទ្យុអាស៊ីសេរីមិនអាចសុំការអត្ថាធិប្បាយពីមន្ត្រីអនុព័ន្ធការងារនៃស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ លោក ឈឹម វិបុល អ្នកនាំពាក្យក្រសួងការបរទេស លោក អាន សុខខឿន និងប្រធានអង្គភាពអ្នកនាំពាក្យរដ្ឋាភិបាល លោក ផៃ ស៊ីផាន បានទេនៅថ្ងៃទី១៥ ខែមិថុនា។

មន្ត្រីផ្នែកការពារសិទ្ធិពលករចំណាកស្រុក នៃអង្គការសង់ត្រាល់ (CENTRAL) ប្រចាំនៅប្រទេសថៃ លោក លឹង សុផុន ដែលតាមដានដំណើររឿងនេះ យល់ថា ប្រសិនមន្ត្រីស្ថានទូត ឬថៅកែរបស់ពលករទាំងនោះចេញមុខជានាទាន់ពេល គឺសមត្ថកិច្ចមិនបញ្ជូនសំណុំរឿងនេះទៅតុលាការទេ។ លោក លឹង សុផុន លើកឡើងទៀតថា ពលករដែលធ្វើការខុសច្បាប់ នៅប្រទេសថៃ គឺប្រឈមនឹងត្រូវសមត្ថកិច្ចចាប់ខ្លួនគ្រប់ពេល ព្រោះនៅរយៈពេលចុងក្រោយនេះ អាជ្ញាធរថៃ កំពុងរឹតបន្តឹងច្បាប់លើពលករបរទេស។ អ្នកការពារសិទ្ធិពលកររូបនេះ ប្រាប់មូលហេតុដែលពលករមួយចំនួនបង្ខំចិត្តធ្វើការខុសច្បាប់នៅប្រទេសថៃ ព្រោះការបំពេញឯកសារមានការយឺតយ៉ាវ និងថ្លៃធ្វើឯកសារមានតម្លៃខ្ពស់ដែលមានតម្លៃចាប់ពី ៣០០ដុល្លារ ទៅ៥០០ដុល្លារ ឬជិត១ពាន់ដុល្លារ។

លោក លឹង សុផុនៈ «បងប្អូនពលករគាត់ត្អូញអំពីវីសា(ទិដ្ឋាការ)ថ្លៃ ហើយគាត់មិនទាន់មានលុយគ្រប់គ្រាន់ ដើម្បីឱ្យថៅកែដំណើរការឯកសារ ហើយកន្លែងខ្លះថៅកែជួយចេញថ្លៃឯកសារមុនទៅ គាត់ក៏ឆាប់បានឯកសារត្រឹមត្រូវតាមច្បាប់ទៅ តែកន្លែងខ្លះគេរង់ចាំកាត់លុយពីពលករឱ្យគ្រប់ចំនួនសិន បើគេធ្វើឯកសារឱ្យ ហើយកន្លែងខ្លះដល់ទៅ៤០ថ្ងៃជាង ពីរខែជាងអីអ៊ីចឹងទៅ ហើយពេល

កំពុងរង់ចាំ ដែលមានបញ្ហាប្រឈមក្នុងការចាប់»។ អង្គការសង់ត្រាល់ រកឃើញថា គិតត្រឹមខែមីនា មកដល់រយៈពេលចុងក្រោយនេះ ពលករខ្មែរជិត១ពាន់នាក់ ត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួនដោយអ្នកខ្លះលួចឆ្លងដែនខុសច្បាប់មកធ្វើការនៅប្រទេសថៃ និងពលករផ្សេងទៀត ធ្វើការគ្មានឯកសារគ្រប់គ្រាន់។

## ឯកឧត្តម ជា សុផារ៉ា ណែនាំឲ្យក្រុមការងារជួយសម្រួលមធ្យោបាយធ្វើដំណើរដល់ពលរដ្ឋចំណាកស្រុកពេលមកបោះឆ្នោត

https://www.btv.com.kh/article/24907 2023/06/18 09:37:23 am

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ជា សុផារ៉ា សមាជិកគណៈអចិន្ត្រៃយ៍ នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាអនុប្រធានទី១ ក្រុមការងារគណបក្សចុះមូលដ្ឋានខេត្តត្បូងឃ្មុំ បានណែនាំដល់ក្រុមការងារគណបក្សមូលដ្ឋានទាំងអស់ជួយសម្រួលមធ្យោបាយធ្វើដំណើររបស់បងប្អូនប្រជាពលរដ្ឋខ្មែរធ្វើចំណាកស្រុក ពេលដែលពួកគាត់មកធ្វើការបោះឆ្នោតនាពេលខាងមុខនេះ។ ក្នុងឱកាសជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ ជាសមាជិកគណបក្សប្រជាជនកម្ពុជាមកពី ឃុំប៉ុីសចំនួន ៤១២០នាក់ និងឃុំរកាខ្នុរ៥៥២៣នាក់ ក្នុងស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ នាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៣នេះ ឯកឧត្តម ជា សុផារ៉ា បានលើកឡើងថា «ដើម្បីឲ្យកាន់តែមានជំនឿជឿជាក់ និងភាពកក់ក្តៅនៅក្នុងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ដែលនឹងប្រព្រឹត្តិទៅនាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ខាងមុខនេះ សូមក្រុមការងារគ្រប់លំដាប់ថ្នាក់ទាំងអស់ក្នុងស្រុកក្រូចឆ្មារ ក៏ដូចជាមូលដ្ឋានឃុំប៉ុីស១ និងឃុំរកាខ្នុរត្រូវពិនិត្យមើលអ្នកដែលអវត្តមាននៅក្នុងការបោះឆ្នោតកន្លងមកតាមរយៈការធ្វើចំណាកស្រុករកការងារធ្វើនៅក្នុងប្រទេស ដោយត្រូវទំនាក់ទំនងទៅពួកគាត់ដោយផ្ទាល់ ដើម្បីជំរុញឲ្យពួកគាត់បានមកចូលរួមបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជាឲ្យបានគ្រប់ៗគ្នា ដោយក្រុមការងារត្រូវជួយសម្រួលមធ្យោបាយធ្វើដំណើរ និងរាល់ការចំណាយផ្សេងៗដល់ពួកគាត់ ដើម្បីឲ្យពួកគាត់បានមកដល់ទីតាំងការិយាល័យបោះឆ្នោត និងនៅពេលពួកគាត់ត្រឡប់ទៅវិញផងដែរ»។

ជាមួយនិងការជួបសំណេះសំណាលក្នុងឱកាសនោះដែរ ឯកឧត្តម ជា សុផារ៉ា ក៏បានសំណូមពរបន្ថែមទៀត ដល់ប្រជាពលរដ្ឋជាសមាជិកគណបក្សប្រជាជនកម្ពុជា ដែលមានមូលដ្ឋានក្នុងឃុំប៉ុីស១ និងឃុំរកាខ្នុរ ក្នុងស្រុកក្រូចឆ្មារ ធ្វើយ៉ាងណាក្នុងសមាជិកម្នាក់ត្រូវឱ្យបានសំឡេងគាំទ្រគណបក្សប្រជាជនកម្ពុជាមួយសន្លឹកនៅក្នុងការបោះឆ្នោតនាពេលខាងមុខ ពីព្រោះកត្តាដែលធ្វើឲ្យគណបក្សប្រជាជនកម្ពុជាទទួលបានជ័យជំនះ គឺពិតជាមិនអាចកាត់ផ្តាច់ពីការចូលរួមចំណែកដ៏ធំធេងពី

សំណាក់ក្រុមការងារគ្រប់លំដាប់ថ្នាក់របស់គណបក្ស ក៏ដូចជាសមាជិកសមាជិកាគណបក្សប្រជាជនកម្ពុជាទាំងអស់ ដែលបានលះបង់ទាំងកម្លាំងកាយចិត្តមិនខ្លាចនឿយហត់ ទើបអាចទទួលបានលទ្ធផលដ៏គាប់ប្រសើរ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ និងស្នើដល់អ្នកដែលធ្លាប់វង្វេងផ្លូវយល់ខុសហើយបោះឆ្នោតគាំទ្រគណបក្សផ្សេងនៅក្នុងឃុំប៉ឺស១ និងឃុំរកាខ្នុរនោះ ឱ្យវិលត្រឡប់ងាកមកដើរលើផ្លូវត្រឹមត្រូវវិញ ដោយចូលរួមបោះឆ្នោតគាំទ្រដល់គណបក្សប្រជាជនកម្ពុជាឱ្យបានគ្រប់ៗគ្នានៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រខាងមុខ និងគូសឲ្យចំគណបក្សប្រជាជនកម្ពុជាដែលមានលំដាប់លេខរៀងទី១៨ លើសន្លឹកឆ្នោត។ យ៉ាងណាក៏ដោយនៅក្នុងពិធីសំណេះសំណាលនោះឯកឧត្តម ជា សុផារ៉ា ក៏បានថ្លែងអំណរគុណដល់ប្រជាពលរដ្ឋទាំងខ្មែរ និងឥស្លាមនៅឃុំប៉ឺស១ និងឃុំរកាខ្នុរ ដែលបានផ្តល់ការគាំទ្រដល់គណបក្សប្រជាជនកម្ពុជាចាប់តាំងពីក្រោយថ្ងៃរំដោះ ៧មករាឆ្នាំ១៩៧៩ រហូតមកដល់បច្ចុប្បន្ននេះផងដែរ។ អត្ថបទ៖ បាន ចក់

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ០១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៨នាក់

https://freshnewsasia.com/index.php/en/localnews/296177-2023-06-18-12-29-14.html 2023-06-18 07:29pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១៦ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០៨នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៣ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៩៤១ករណី មានមនុស្ស ២,៤១១នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៩០២សំណើ និងបិទសំណុំរឿង ៣០៣សំណើ (រកឃើញមនុស្ស ១,៤០១នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣៧នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣៧ករណី។

# បាគីស្ថានចាប់ខ្លួនមេខ្លោង
# ជួញដូរមនុស្ស សង្ស័យពាក់ព័ន្ធករណីលិចទូកជនភៀសខ្លួននៅក្រិក

https://www.rfi.fr/km/ref=tgi ចុះផ្សាយនៅថ្ងៃ៖ 18/06/2023 - 17:13

នៅថ្ងៃអាទិត្យ ទី១៨មិថុនា រដ្ឋាភិបាលបាគីស្ថាន បានប្រកាសពីការចាប់ឃុំខ្លួន មនុស្ស ១០ នាក់ ដែលសង្ស័យមានជាប់ពាក់ព័ន្ធករណីជួញដូរមនុស្ស ហើយនិងករណីលិចទូកជនភៀសខ្លួនស្លាប់មនុស្សនិងបាត់ខ្លួនរាប់សិបនាក់ នៅប្រទេសក្រិក។ ក្នុងចំណោមជនភៀសខ្លួនស្លាប់បាត់បង់ជីវិត ជិត៨០ ដែលរកឃើញសាកសព គឺ យ៉ាងហោច មានជនជាតិបាគីស្ថាន ជាង១០នាក់។ ការចាប់ខ្លួនមេខ្លោងជួញដូរមនុស្សនៅពេលនេះ គឺបន្ទាប់ពី នាយករដ្ឋមន្ត្រីប៉ាគីស្ថាន បានចេញបញ្ជាឲ្យរៃកមុខជនល្មើសពាក់ព័ន្ធ ក្នុងការបោកជនអន្តោប្រវេសន៍ ហើយនិងត្រូវអូស ក ពួកគេ ទៅផ្តន្ទាទោសឲ្យធ្ងន់ធ្ងរ។ នេះបើតាមខុទ្ទកាល័យនាយករដ្ឋមន្ត្រីប៉ាគីស្ថាន។

ទូកដឹកជនភៀសខ្លួន លិចនៅសមុទ្រ ប្រទេសក្រិក មានផ្ទុះមនុស្ស យ៉ាងហោច ចន្លោះពី៤០០ ទៅ៧៥០នាក់។ គេរកឃើញសាកសព ជិត ៨០ នាក់ ហើយមនុស្សផ្សេងទៀត កំពុងបន្តបាត់ខ្លួន។ អាជ្ញាធរក្រិក ក៏គ្មានសង្ឃឹមថានឹងរកឃើញមនុស្សនៅមានជីវិតនោះឡើយ។ នៅកន្លែងសមុទ្រកើតហេតុ មានជនភៀសខ្លួន ជាង១២០នាក់ រស់រានមានជីវិត ដែលក្នុងនោះ ស្ថានទូតប៉ាគីស្ថានប្រចាំប្រទេសក្រិច បានបញ្ជាក់ថា ពលរដ្ឋរបស់ខ្លួន ជាង១០នាក់ បានរួចផុតពីចង្កូមមច្ចុរាជ។ អាជ្ញាធរប៉ាគីស្ថាន ពុំបានបញ្ជាក់ពីចំនួនជនភៀសខ្លួន ថាមានប្រហែលប៉ុន្មាននាក់ នៅលើទូកលិចនោះឡើយ។ ក៏ប៉ុន្តែ ប្រភពពីអ្នកគ្រប់ជនអន្តោប្រវេសន៍ដែលសុំលាក់ឈ្មោះ បានទម្លាយឲ្យដឹងថា យ៉ាងហោច ក៏មានជនជាតិប៉ាគីស្ថាន ប្រមាណជា ២០០ នាក់ដែរ នៅលើទូកលិចកាលពីថ្ងៃពុធ ពីថ្ងៃទី១៤មិថុនា ។ តាមតម្រុយពីអ្នករួចជីវិតពីស្លាប់នៅហេតុការណ៍លិចទូកនៅក្រិក ទើប អាជ្ញាធរប៉ាគីស្ថាន ធ្វើប្រតិបត្តិការចាប់ខ្លួនមេខ្យល់និងមេខ្លោងជួញដូរមនុស្ស ចំនួន ១០ នាក់។ ៩នាក់ ត្រូវចាប់ខ្លួន នៅតំបន់កាស្មៀរ ហើយម្នាក់ទៀត ចាប់ខ្លួនបាន នៅក្រុង Gujrat ប៉ែកខាងជើងនៃប្រទេស។ នាយរដ្ឋមន្ត្រីប៉ាគីស្ថាន Shehbaz Sharif បានចាត់ទុកថា អំពើជួញដូរមនុស្ស ជាឧក្រិដ្ឋកម្មគួរឲ្យស្អប់ខ្ពើម និងត្រូវដាក់ទោសទណ្ឌកម្មឲ្យធ្ងន់បំផុត។

នៅបាគីស្ថាន ជនភៀសខ្លួនភាគច្រើន ធ្វើចំណាកស្រុកចេញពីប៉ែកខាងកើត និងខាងជើងនៃផ្ទៃប្រទេស។ ពួកគេធ្វើដំណើរ ខុសច្បាប់ក្តី និងស្របច្បាប់ក្តី ចាកចេញទៅ អ៊ីរ៉ង់ លីប៊ី តួកគី ក្រិក និងប្រទេសគោលដៅផ្សេងទៀតនៅអឺរ៉ុប។ ក្នុងមួយឆ្នាំៗ មានយុវជនរាប់សិបពាន់នាក់ បង្ខំចិត្តចាកចោលស្រុកកំណើតដើម្បីស្វែងរកលំនឹងជីវិតថ្មី បើទោះបីជាដឹងពីការប្រឈមមុខប្រថុយប្រថាននឹងគ្រោះថ្នាក់ស្លាប់ជីវិត។

ពីបុរីវ៉ាទីកង់ នៅក្នុងពិធីសាសនាកាតូលិក ថ្ងៃអាទិត្យ សម្តេចប៉ាបមានបន្ទូលសោកស្តាយចំពោះព្រឹត្តិការណ៍លិចទូកជនភៀសខ្លួននៅក្រិច និងថ្ងៃឯក្តីឈឺចាប់ ហើយទ្រង់អំពាវនាវឲ្យរកចំណាត់ការទប់ស្កាត់សោកនាដកម្មបែបនេះ កុំឲ្យកើតជាថ្មី។ នៅប្រទេសបារាំង រដ្ឋមន្ត្រីក្រសួងការងារ Olivier Dussopt ក្រៅពីថ្លែងក្តីសោកស្តាយ គឺបានលើកឡើងគាំទ្រគម្រោងព្រាងច្បាប់អន្តោប្រវេសន៍របស់ខ្លួន ថា ប្រទេសបារាំង បើគ្មានជនភៀសខ្លួនបរទេស ធ្វើការទេ ក៏បារាំង មិនអាចដើរទៅមុខដែរ ពិសេសវិស័យភោជនីយដ្ឋាននិងកិច្ចការងារតាមផ្ទះ ដែលមានជនបរទេសធ្វើការ ដល់ទៅ ២៥% ឯណោះ ៕

# ថ្ងៃទី២១ ខែ មិថុនា ឆ្នាំ២០២៣

## មានការអំពាវនាវសុំឱ្យជួយនាំបុរសជនជាតិអាហ្វ្រិកខាងត្បូង ដែលចាញ់បោកគេទៅធ្វើការងារនៅប្រទេសថៃត្រឡប់ទៅផ្ទះវិញ ដែលបច្ចុប្បន្នបុរសនេះកំពុងស្ថិតនៅកម្ពុជា

https://www.khmertimeskh.com/ Khmer Times June 19, 2023

បុរសអាយុ២៩ ឆ្នាំរូបនេះបានចាកចេញពីប្រទេសអាហ្វ្រិកខាងត្បូងទៅធ្វើការនៅប្រទេសថៃ ប៉ុន្តែជាក់ស្តែងការងារនេះជាការងារបោកប្រាស់។បច្ចុប្បន្ន ក្រុមគ្រួសាររបស់គាត់កំពុងអង្វរសុំជំនួយដើម្បីនាំគាត់ត្រឡប់មកវិញខណៈដែលគាត់កំពុងជាប់នៅក្នុងប្រទេសកម្ពុជា។

ក្រុមគ្រួសាររបស់ Xolani Sidwell Fongo បាននិយាយថា ពួកគេបារម្ភចំពោះជីវិតរបស់គាត់ ហើយបានស្វះស្វែងសុំជំនួយពីគ្រប់បណ្តាញការទូតដើម្បីនាំគាត់ត្រឡប់មកវិញ។ «បន្ទាប់ពីអង្គការ IOL បានចុះផ្សាយរឿងរបស់គាត់ ប្រព័ន្ធផ្សព្វផ្សាយបានយកបញ្ហានេះផ្សព្វផ្សាយបន្ត ហើយយើងជឿថាឥឡូវនេះគាត់បានក្លាយជាគោលដៅ និងមិនមានសុវត្ថិភាពទៀតទេ។ យើងត្រូវការជំនួយដើម្បីយកគាត់មកវិញ»។

Fongo បានចាកចេញពីប្រទេសអាហ្វ្រិកខាងត្បូងក្នុងខែវិច្ឆិកា ឆ្នាំ២០២២បន្ទាប់ពីបានទទួលអ៊ីមែលពីបុរសម្នាក់ដែលមានឈ្មោះថា John Thomas ដោយបានអះអាងថាខ្លួនជាអ្នកជ្រើសរើសបុគ្គលិកសម្រាប់ក្រុមហ៊ុន Huilong Technology ដែលជាក្រុមហ៊ុនទីផ្សាររបស់ចិនមានមូលដ្ឋាននៅក្នុងប្រទេសថៃ។គាត់ត្រូវបានគេផ្តល់ការងារឱ្យធ្វើការជាអ្នកឯកទេសពិនិត្យអតិថិជននៅប្រទេសថៃ។ គាត់ត្រូវបានគេនាំទៅប្រទេសមីយ៉ាន់ម៉ាដោយខុសច្បាប់ ហើយនៅពេលដែលគាត់ទៅដល់ទីនោះ គាត់បាននិយាយថាគាត់ត្រូវបានគេបង្ខំឱ្យធ្វើការខុសច្បាប់ដែលផ្តោតលើបុរសមានទ្រព្យសម្បត្តិរស់

នៅសហរដ្ឋអាមេរិក។ គាត់បានចាកចេញពីប្រទេសមីយ៉ាន់ម៉ា ហើយទទួលបានការងារមួយទៀតនៅកម្ពុជា ដែលការងារនេះជាការងារបោកប្រាស់។

Neo Tsoai សមាជិកសហគមន៍ដែលទទួលបន្ទុករៃអង្គាសប្រាក់សម្រាប់នាំយកFongo ត្រលប់មកវិញបាននិយាយថាគាត់បានឃើញការអង្វររបស់ Fongo នៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមហើយបានសម្រេចចិត្តជួយ។ "Xolani គឺជាមនុស្សចេះដាក់ខ្លួន ស្មោះត្រង់ និងឧស្សាហ៍ព្យាយាម។ នោះហើយជាមូលហេតុដែលយើងត្រូវជួយគាត់ យើងត្រូវយល់ថាការធ្វើជាជនអន្តោប្រវេសន៍នៅបរទេសគឺពិបាកមួយកម្រិតទៅហើយ ឥឡូវនេះគាត់ជាជនខុសច្បាប់ទៀត ដូច្នេះវាកាន់តែមិនងាយស្រួល។

Tsoai បានបន្ថែមថា រហូតមកដល់ពេលនេះ ពួកគេបានរៃអង្គាសប្រាក់បានជាង R ១៥ ០០០ ហើយយើងនៅតែត្រូវការប្រាក់បន្ថែមទៀត ដើម្បីចំណាយលើការស្នាក់នៅលើសថ្ងៃរបស់ Fongo ។ គាត់បាននិយាយថា ការស្នាក់នៅលើសថ្ងៃត្រូវគិតប្រាក់ចំនួន ១០ដុល្លារ ក្នុងមួយថ្ងៃ ហើយ Fongo បានស្នាក់នៅលើសចំនួន៧១ថ្ងៃ ដែលយើងត្រូវការប្រាក់រហូតដល់ R១៤ ០០០។ គាត់បានបន្តថា "យើងអំពាវនាវដល់ប្រជាជនអាហ្វ្រិកខាងត្បូងទាំងអស់ឱ្យចូលរួមវិភាគទានជួយនាំFongo មកវិញ" ។ IOL.co.za

## មានករណី
## ស្ត្រីជនជាតិអាហ្វ្រិកមួយទៀតកំពុងស្ថិតនៅកម្ពុជា បន្ទាប់ពីចាញ់បោកការងារក្លែងក្លាយ

https://www.khmertimeskh.com/501310479/ Khmer Times June 19, 2023

អ្នកនាំពាក្យក្រសួងទំនាក់ទំនងអន្តរជាតិ និងសហប្រតិបត្តិការ (Dirco) លោក Clayson Monyela បានសរសេរនៅលើបណ្តាញសង្គម Twitter កាលពីសប្តាហ៍មុនដើម្បីរំលឹកជនជាតិអាហ្វ្រិកខាងត្បូងអំពីការផ្តល់ការងារក្លែងក្លាយនៅក្រៅប្រទេស។ ស្ត្រីរូបនេះទំនងកំពុងជាប់ក្នុងប្រទេសកម្ពុជាបន្ទាប់ពីធ្លាក់ខ្លួនរងគ្រោះដោយសារការចាញ់បោកការងារនៅបរទេស។

នេះជាការឆ្លើយតបទៅនឹងករណីរបស់ Zolani Fongo អាយុ២៩ឆ្នាំ មកពី Theunissen ដែលបានធ្វើដំណើរទៅប្រទេសថៃកាលពីខែវិច្ឆិកាឆ្នាំមុនដើម្បីធ្វើការជាអ្នកបញ្ចូលទិន្នន័យប៉ុន្តែជាក់ស្តែងត្រូវបានបញ្ជូនទៅប្រទេសមីយ៉ាន់ម៉ា។ បច្ចុប្បន្ននេះ គាត់កំពុងជាប់នៅកម្ពុជាដោយគ្មានថវិកាត្រឡប់ទៅផ្ទះវិញ។ Monyela បានបន្តថា ករណីនេះស្រដៀងទៅនឹងករណីមួយផ្សេងទៀតដែលពាក់ព័ន្ធនឹងស្ត្រីវ័យក្មេងមកពី Limpopo។

មិត្តភ័ក្តិរបស់ Fongo ដែលមានឈ្មោះ Palesa Moeti បាននិយាយថា ម្តាយរបស់គាត់បានព្រួយបារម្ភយ៉ាងខ្លាំង។ "ពួកគេពិតជាពិបាកចិត្ត ហើយម្តាយរបស់គាត់ថែមទាំងជំពាក់បំណុលគេ

ច្រើន ដើម្បីយកលុយជួយផ្គត់ផ្គង់ការស្នាក់នៅ និងអាហាររបស់គាត់នៅបរទេស ដូច្នេះពួកគេមិនមានលទ្ធភាពទិញសំបុត្រយន្តហោះឱ្យគាត់ទេ" ។

Moeti បាននិយាយថា ដំបូងឡើយ សាច់ញាតិរបស់ Fongo មានការភ័យខ្លាចថា ពួកគេនឹងលែងបានឃើញគាត់ទៀតហើយ។ ឥឡូវនេះពួកគេបានផ្ញើរអែផ្ដាសប្រាក់បានប្រហែល R៣០,០០០ ហើយ។ "ដូច្នេះខ្ញុំមានអារម្មណ៍ល្អប្រសើរជាងមុនហើយម្ដាយរបស់គាត់ក៏មានអារម្មណ៍ធូរស្រាលច្រើនដែរ"។ Moeti មានអារម្មណ៍រំជួលចិត្តនៅពេលគេសួរថា តើនាងចង់និយាយអ្វីទៅកាន់Fongo។ "យើងនឹងធ្វើឱ្យប្រាកដថាគាត់អាចត្រឡប់មកផ្ទះវិញដោយសុវត្ថិភាព ហើយយើងនៅតែបន្តរអែផ្ដាសប្រាក់ ហើយយើងនឹងមិនឈប់ទាល់តែគាត់អាចត្រឡប់មកផ្ទះវិញបាន យើងស្រឡាញ់គាត់ខ្លាំង"។ ពួកគេសង្ឃឹមថានឹងមានគាត់នឹងមកដល់ផ្ទះវិញនៅថ្ងៃអង្គារឬថ្ងៃពុធខាងមុខ។ EWNEyewitness News ZA

## ស្ត្រីពលករម្នាក់នៅប្រទេសថៃប្រឹងរកប្រាក់ឱ្យកូនទៅរៀន ទោះបីប្ដីកំពុងជាប់ពន្ធនាគារ

https://www.rfa.org/khmer/news/social-economy/a-female-worker-works-hard-to-earn-money-for-her-children-while-her-husband-is-in-prison-in-thailand-06182023055308.html ដោយ សេក បណ្ឌិត2023.06.18

ស្ត្រីពលករខ្មែរមួយរូបធ្វើកម្មករក្នុងចំការកៅស៊ូប្រទេសថៃ ធ្វើការលក់កម្លាំងស៊ីឈ្នួលរកប្រាក់ឱ្យកូនស្រីពីរនាក់ បន្តការសិក្សានៅប្រទេសថៃ បើទោះជាប្ដីរបស់ខ្លួនកំពុងជាប់ពន្ធនាគារនៅប្រទេសនេះ ទាំងអយុត្តិធម៌ជាង ១ឆ្នាំហើយក្ដី។ តើស្ត្រីពលករខ្មែរតស៊ូជំនះឧបសគ្គអ្វីខ្លះនៅប្រទេសថៃ? ជាកម្មករធ្វើការក្នុងចំការកៅស៊ូ បានប្រាក់កម្រៃ ២៧០បាត ឬជាង ៧ដុល្លារក្នុងមួយថ្ងៃ លោកស្រី ជ័យ មុំ រកប្រាក់ចំណូល ការចំណាយស្មើរស្មើគ្នា ដែលធ្វើឱ្យស្ត្រីរូបនេះ ត្រូវធ្វើការផងពីមួយខែទៅមួយខែគ្មានថ្ងៃសម្រាក ដើម្បីបានប្រាក់ទិញអង្ករ ទិញម្ហូប ឱ្យប្រាក់ឱ្យកូនស្រីពីរនាក់ទៅរៀន និងផ្ញើប្រាក់ខ្លះទៀត ឱ្យប្ដីនៅពន្ធនាគារទៀតផង។ មានរាងតូចល្អិត តែចិត្តធំ ស្ត្រីពលករ ជ័យ មុំ អាយុ ៤០ឆ្នាំ មានកូនស្រីពីរ ម្នាក់រៀនថ្នាក់ទី៥ ម្នាក់ទៀតរៀនថ្នាក់ទី៦ នៅប្រទេសថៃ។

លោកស្រី ជ័យ មុំ៖ «ពីរបីថ្ងៃទិញ (ទិញអង្ករ) មួយរយ បីបួនដប់ថ្ងៃខ្ញុំទិញមួយរយ ខ្ញុំអត់មានប្រាក់ បើខ្ញុំមានលុយខ្ញុំទិញមួយបេ (មួយបាវ) ហូបបានយូរ មួយរយបានតែបួនគីឡូកន្លះ អត់បានប្រាំគីឡូទេ។ រៀន សាំងម៉ូតូ អង្ករហូប ខោសអាវ សៀវភៅកូនរៀន ទិញមួយសព្វ។ ខោអាវសុទ្ធតែទិញមិនមែនគ្រូចែកឱ្យទេ មួយឆ្នាំបានតែកំប្លេ បួនកំប្លេ ទិញខ្លួនឯងចំណាយទាំងអស់។ នេះបើឈុតនេះវិញ ឈុតជាតិហ្នឹងមួយឈុតហ្នឹង ១ពាន់ជាង (ប្រាក់បាត) ១ពាន់ ៣រយ។ សរុបទាំងស្បែកជើង ១ពាន់ ៥រយ។ កូនខ្ញុំចូលថ្ងៃទី១៦ ខែ៥ (ខែឧសភា) ខ្ញុំខ្ចីលុយគេ ៣ពាន់»។

ជាងមួយឆ្នាំមកនេះ លោកស្រី ជ័យ មុំ ត្រូវរកប្រាក់តែម្នាក់ឯង នៅក្នុងចម្ការកៅស៊ូ មួយកន្លែងក្នុងខេត្តឈុនបុរី (Chunbori) ប្រទេសថៃ (Thailand) លោកស្រីនៅកន្លែងកែច្នៃឈើកៅស៊ូជាមួយស្ត្រីពលករខ្មែរពីរនាក់បីទៀត ក្រោមការគ្រប់គ្រងរបស់មេការជនជាតិថៃ។ ការងារនេះ បើលោកស្រីធ្វើការទើបបានប្រាក់ហើយក្នុងមួយសប្ដាហ៍បានប្រាក់ជិត១.២០០ (មួយពាន់ពីររយ) បាត។ លោកស្រី ជ័យ មុំ៖ «តស៊ូហ្នឹងហើយ គ្រុនអីខ្ញុំមិនដែលឈប់ទេ ខ្ញុំទៅទាំងគ្រុនធ្វើការ។ បើខ្ញុំឈប់ អត់អីហូប។ ខ្ញុំធ្វើការមិនដែលបានឈប់ទេ។ ចេះតែទៅបន្តិចៗ ខ្ញុំលំបាក។ បើថា ធ្វើបានលុយ បើអត់ធ្វើគឺអត់បាន។ ខ្ញុំបើក (បើកប្រាក់ឈ្នួល) ខ្ញុំបើកមកទិញអង្ករទិញអី កូនរៀនហ្នឹង»។

ពលករខ្មែរនៅទីនេះ ថៅកែអនុញ្ញាតឱ្យស្នាក់នៅក្នុងបរិវេណចំការ ដោយគេសង់បន្ទប់ជាប់ៗគ្នា ធ្វើពីឈើក្រាលបេតុងស៊ីម៉ង់ត៍។ បើទោះជាលោកស្រី ជ័យ មុំ ធ្វើការមួយថ្ងៃបានប្រាក់តែជិត៣០០បាតក្ដី លោកស្រីត្រូវចំណាយប្រាក់ជិត ១០០បាត ឱ្យកូនស្រីទាំងពីរនាក់របស់ខ្លួនទៅរៀន ដែលប្រាក់នោះសម្រាប់ចំណាយលើការហូបចំណី និងថ្លៃទិញឯកសារ។ ការចំណាយនេះ មិនទាន់រាប់បញ្ចូលការចំណាយលើថ្លៃម្ហូបអាហារប្រចាំថ្ងៃផង។

លោកស្រី ជ័យ មុំ រៀបរាប់ប្រាប់វិទ្យុអាស៊ីសេរីដឹងថា គ្រួសារលោកស្រីសព្វថ្ងៃត្រឹមហូបឱ្យឆ្អែតក្រពះ ប៉ុណ្ណោះ ព្រោះគ្មានប្រាក់ទិញអាហារឆ្ងាញ់ ហូបឡើយ។ លោកស្រីឱ្យដឹងទៀតថា ថ្ងៃខ្លះអត់លុយឱ្យកូនទៅសាលា លោកស្រីត្រូវដើរខ្ចីលុយអ្នកជិតខាង។ លោកស្រី ជ័យ មុំ៖ «អត់ប្ដីទៅយើងយ៉ាប់ យើងហូបខ្វះ ហូបមិនបានឆ្ងាញ់ ពេលប្ដីនៅខ្ញុំហូបបានឆ្ងាញ់ ពេលខ្វះខាតខ្ញុំរត់រកញាតិជិតខាង ខ្ញុំស្រណោះកូន ធ្វើម៉េចកូនអត់ដឹងអី ដឹងតែឆ្អែតៗ ខ្ញុំលំបាក បានកូនរៀនទៅ បានការងារធ្វើបានល្អ។ ដូចខ្ញុំយ៉ាប់ណាស់ ប្រថុយឱ្យកូនរៀន»។

ជីវិតគ្រួសារលោកស្រី ជ័យ មុំ ទន្ទឹមនឹងជួបការលំបាកផ្នែកជីវភាព លោកស្រីក៏ជួបរឿងអយុត្តិធម៌មួយទៀតដែរ ដោយប្ដីលោកស្រី ពេលនេះកំពុងឃុំក្នុងពន្ធនាគារប្រទេសថៃ ទាំងអយុត្តិធម៌អស់រយៈពេលជាង ១ឆ្នាំមកហើយ ព្រោះថៅកែមុនរបស់លោកស្រី ដែលជាថៅកែចម្ការដូងប្រេង បានចោទប្រកាន់ថា ប្ដីលោកស្រីបានលួចដូងប្រេងរបស់គេយកទៅលក់។

លោកស្រី ជ័យ មុំ រំលឹកថា កាលពីខែកុម្ភៈឆ្នាំ២០២២ មេការជនជាតិថៃ ដែលគ្រប់គ្រងចម្ការការដូងប្រេងនោះ បានចោទប្រកាន់ថា ប្ដីលោកស្រី និងពលករខ្មែរម្នាក់ទៀតថា លួចដូងប្រេងប្រមាណ ១តោន យកទៅលក់ ហើយថៅកែថៃម្ចាស់ចម្ការ ក៏ជឿតាមសំដីរបស់មេការថៃ និងបានប្ដឹងសមត្ថកិច្ចថៃ ឱ្យចាប់ប្ដីលោកស្រី និងពលករខ្មែរម្នាក់យកទៅឃុំ។ លោកស្រីបញ្ជាក់ថា នៅពេលសាកសួរនោះ សមត្ថកិច្ចថៃរកមិនឃើញភស្តុតាងថា ប្ដីលោកស្រីលួចដូងប្រេងទេ ហើយប្ដីលោកស្រីក៏មិនបានសារភាពដែរ។

ទោះបែបនេះលោកស្រីថា ប៉ូលិសថៃបានសម្មុតប្តីលោកស្រី និងពលករម្នាក់ទៀតឱ្យសារភាព ហើយប៉ូលិសថៃបានកុហកថា បើពួកគាត់សារភាពនឹងបានរួចខ្លួន ហើយក្រោយមក ពលករខ្មែរម្នាក់ដែលសមត្ថកិច្ចចាប់ខ្លួនជាមួយប្តីលោកស្រីនោះបានសារភាព តែសមត្ថកិច្ចថៃមិនបានដោះលែងដូចការសន្យាទេ ហើយបានបញ្ជូនសំណុំរឿងនេះទៅតុលាការ ហើយតុលាការថៃសម្រេចចោទប្រកាន់និងឃុំខ្លួនពួកគាត់ម្នាក់ៗ ឱ្យជាប់ឃុំរយៈ ១៨ខែ។ លោកស្រី ជ័យ មុំ៖ «ប្តីខ្ញុំថា ចតមកបើថា ខ្ញុំយកមែន ចតមកបង្ហាញប៉ូលិសមកថា ខ្ញុំយកមែន ខ្ញុំសារភាពបើខ្ញុំមិនបានយកផង? ប្តីខ្ញុំទៅដល់តុលាការអត់សារភាពទេ។ អាមួយហ្នឹងសារភាពអាជូនប្តីខ្ញុំហ្នឹង សារភាព។ វាថា វាយកមែន។ វាខ្លាចគេវាយ ខ្លាចគេវាយ ខ្លាចគេធ្វើបាប ដូចថា បើប្រាប់គេ គេលែង ដល់ពេលប្រាប់ទៅគេអត់លែងឯណា ប្រាប់ទៅគេដាក់ (ដាក់ឃុំ) ១៨ខែពេញប៊ឹប»។

លោក ម៉េត បូលី ប្តីរបស់លោកស្រី ជ័យ មុំ ពលករខ្មែរធ្វើការនៅប្រទេសថៃ ដែលកំពុងជាប់ពន្ធនាគារនៅប្រទេសថៃ។ រូបៈ ពលរដ្ឋផ្តល់ឱ្យប្តីរបស់លោកស្រី ជ័យ មុំ ឈ្មោះ ម៉េត បូលី អាយុ ៣៩ឆ្នាំ ជាកម្មករបេះដូងប្រេង។ លោកជាមនុស្សស្លូតបូត មិនចេះផឹកស្រាជក់បារី ឬលេងល្បែងទេ ហើយក៏មិនចេះនិយាយភាសាថៃដែរ។

លោកស្រី ជ័យ មុំ រំលឹកថា កាលពីសមត្ថកិច្ចចាប់ប្តីលោកស្រីថ្មីៗ នោះ លោកស្រីបានហៅទូរស័ព្ទទៅមន្ត្រីស្ថានទូតខ្មែរប្រចាំប្រទេសថៃ ស្ទើររាល់ថ្ងៃ តែខាងស្ថានទូតមិនដែលទទួលទូរស័ព្ទ ឬហៅទូរស័ព្ទត្រឡប់មកវិញទេ ហើយជាងមួយឆ្នាំមកនេះ ក៏មិនដែលមានមន្ត្រីស្ថានទូតខ្មែររូបណាមកសួរនាំលោកស្រីដែរ។ នៅពេលប្តីដែលជាជនបង្គោលជាប់ឃុំ ការរកប្រាក់ផ្គត់ផ្គង់ក្នុងគ្រួសារ ក៏មិនបានល្អដូចគ្រួសារគេដែលមានប្តីប្រពន្ធនៅជុំគ្នាដែរ។ កូនស្រីរបស់ស្ត្រីពលកររូបនេះ មិនសូវមានអាហារហូបចុកគ្រប់គ្រាន់ ឬមានអាហារមានសារជាតិចិញ្ចឹមទទួលទានទេ។ ពួកគេទាំងពីរនាក់មានទឹកមុខស្លេកស្លាំង។

កំពុងអានសំបុត្រ ឪពុកផ្ញើមកពីពន្ធនាគារ កុមារី ឡី វិច្ឆិកា អាយុ ១៤ឆ្នាំ កំពុងរៀនថ្នាក់ទី៦ នៅប្រទេសថៃ នាងជាសិស្សពូកែក្នុងថ្នាក់ ដោយរៀនបានចំណាត់ថ្នាក់លេខ២ ប្រចាំឆ្នាំ។ កុមារ ឡី វិច្ឆិកា ចេះនិយាយ ចេះអានភាសាថៃ យ៉ាងស្ទាត់ ហើយនាងអាចអានសំបុត្ររបស់ឪពុក ដែលសរសេរជាភាសាថៃ មកជាភាសាខ្មែរបានភ្លាមៗ ផងដែរ។ កុមារី ឡី វិច្ឆិកា អានសំបុត្រ៖ «ប៉ាថា ម៉េចហើយ សុខសប្បាយ ឬអត់ ជិតចូលខែភ្លៀងហើយ ប៉ាបារម្ភ។ មើលម៉ែផង ឱ្យម៉ែយកលុយមកឱ្យប៉ាផង ប៉ាយកទៅបង់ឱ្យប៉ូលិសថៃ ថ្ងៃដែលគេលែងប៉ាមក។ ចាំប៉ាទៅឱ្យគេ។ បាន ឬមិនបាន ប្រាប់ប៉ាផង»។

កុមារ ឡី វិច្ឆិកា មិនជឿថា ឪពុករបស់នាងលួចដូងប្រេងគេ ដូចការចោទប្រកាន់ឡើយ ឪពុកនាងជាមនុស្សឧស្សាហ៍ ចៅកែប្រើឱ្យធ្វើអ្វីគាត់មិនដែលប្រកែកឡើយ ណាមួយទៀតឪពុកប្អូនស្រីមិនចេះបើកឡាន មិនចេះភាសាថៃ តើធ្វើដូចម្ដេចអាចយកដូងប្រេងនោះទៅលក់កើត?។ បើទោះជាស្ថានភាពគ្រួសារ កំពុងជួបការលំបាក ឃើញម្ដាយធ្វើការហត់រកប្រាក់តែឯង នៅពេលទំនេរពីការរៀនសូត្រ កុមារ ឡី វិច្ឆិកា តែងតែជួយបោកខោអាវ លាងចាន និងជួយធ្វើការងារផ្ទះម្ដាយ។ កុមារ ឡី វិច្ឆិកា ថា នាងប្រឹងប្រែងរៀនសូត្រ ព្រោះរំពឹងថា ពេលខ្លួនធំដឹងក្ដី រៀបចប់អាចរកការងារល្អបានធ្វើបានប្រាក់ខែខ្ពស់ ដើម្បីយកប្រាក់នោះមកជួយឪពុកម្ដាយវិញ។

កុមារី ឡី វិច្ឆិកា៖ «ចង់រៀនទៅមុខទៀត ចង់ប្រឡងឱ្យចប់ រៀនបញ្ចប់ បានការធ្វើល្អ យកលុយឱ្យម៉ែច្រើនៗ។ ពេលអត់ប៉ាទៅម៉ែពិបាក ម៉ែមើលថែពួកខ្ញុំពីរនាក់ ខ្ញុំអត់សូវជួយម៉ែរកលុយបានទេ។ ពេលមានប៉ា អត់ខ្វះលុយទេ តែអត់មានប៉ាខ្វះលុយ ពេលទៅមើលប៉ា ម៉ែដើរខ្ចីលុយគេសិន»។

ទាក់ទងរឿងរឿងនេះ វិទ្យុអាស៊ីសេរីមិនអាចសុំការអត្ថាធិប្បាយពីមន្ត្រីអនុព័ន្ធការងារនៃស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ លោក ឈឹម វិបុល អ្នកនាំពាក្យក្រសួងការបរទេស លោក អាន សុខខឿន និងប្រធានអង្គភាពអ្នកនាំពាក្យរដ្ឋាភិបាល លោក ផៃ ស៊ីផាន បានទេ នៅថ្ងៃទី១៧ ខែមិថុនា។

មន្ត្រីផ្នែកការពារសិទ្ធិពលករចំណាកស្រុក នៃអង្គការសង់ត្រាល់ (CENTRAL) ប្រចាំនៅប្រទេសថៃ លោក លឹង សុផុន ប្រាប់ថា ទម្រាំលោកបានដឹង ករណីចោទប្រកាន់ប្ដីលោកស្រី ជ័យ មុំ គឺយឺតពេលទៅហើយ តុលាការថៃបានសម្រេចចោទប្រកាន់លើប្ដីលោកស្រី ជ័យ មុំ ទៅហើយ។ មន្ត្រីសង្គមស៊ីវិលការពារសិទ្ធិពលរដ្ឋរូបនេះថា ប្រសិនបើស្ថានទូតខ្មែរប្រចាំប្រទេសថៃ ជួយតាមដាន និងស៊ើបអង្កេត ឬផ្ដល់ជំនួយផ្នែកផ្លូវច្បាប់ លើរឿងនេះទាន់ពេល ក្រុមពលករដែលកំពុងជាប់ឃុំទាំងនេះ ទំនងរួចផុតការចោទប្រកាន់ ព្រោះលោកសង្កេតឃើញថា សំណុំរឿងនេះមានភាពអយុត្តិធម៌លើក្រុមពលករខ្មែរ។ លោក លឹង សុផុន ដែលតាមដានដំណើររឿងនេះ បន្តទៀតថា ការប្រឹងប្រែងតស៊ូរបស់លោកស្រី ជ័យ មុំ ដែលមិនបោះបង់ក្ដីសង្ឃឹម ប្រឹងធ្វើការរកប្រាក់ឱ្យកូនស្រីទាំងពីរនាក់ អាចបន្តការសិក្សា គឺជាគំរូល្អ និងជាការលះបង់ដ៏ធំធេងរបស់ស្ត្រីពលកររូបនេះ។

លោក លឹង សុផុន៖ «យើងដឹងស្រាប់ហើយថា ជីវភាពគាត់លំបាក ហើយណាមួយទៀតគាត់ក៏លើកចិត្តខ្លួនឯង បានកូនរៀន ហើយណាមួយទៀត ខ្ញុំបានសួរគាត់ផ្ទាល់ដែរថា ប្ដីបានផ្ញើលិខិតពីគុក ដើម្បីលើកទឹកចិត្តជំរុញឱ្យកូន ឱ្យប្រពន្ធចេះតស៊ូក្នុងជីវិតអ៊ីចឹងណ៎ា! ខ្ញុំគិតថា ជារឿងប្រសើរដែរ សម្រាប់គាត់ណ៎ា! តែជារឿងអយុត្តិធម៌មួយ ដែលគាត់មានបញ្ហាប្រឈមបែបហ្នឹង ហើយអត់ទាន់មានស្ថាប័នពាក់ព័ន្ធណាមកជួយតាមដាន»។ កាលពីពេលថ្មីៗ លោក លឹង សុផុន បានយកស្បៀងអាហារជូនគ្រួសារ លោកស្រី ជ័យ មុំ ដើម្បី ដោះទ័លក្នុងគ្រាលំបាកនេះ។

ប្តីលោកស្រី ជ័យ មុំ ដែលបានជាប់ឃុំចំនួន ១៨ខែមកហើយ នឹងត្រូវអនុវត្តទោសចប់ នៅថ្ងៃទី២៣ ខែសីហា ខាងមុខ។ លោកស្រី ជ័យ មុំ ឱ្យដឹងថានៅពេលដោះលែង សមត្ថកិច្ចថៃបានបង្គាប់លោកស្រីបង់ប្រាក់ឱ្យគេចំនួន ១ម៉ឺនបាត ឬប្រមាណ ៣០០ដុល្លារ ទើបសមត្ថកិច្ចអាចដោះលែងឱ្យនៅប្រទេសថៃ បើមិនដូច្នេះទេ គេនឹងបញ្ជូនទៅខ្មែរវិញ។ លោកស្រីត្អូញត្អែរថា លោកស្រីគ្មានប្រាក់១ម៉ឺនបាតបង់ឱ្យប៉ូលិសថៃទេ។ បើទោះជាលោកស្រីគ្មានប្រាក់បង់ឱ្យសមត្ថកិច្ចថៃក្តី នៅថ្ងៃប៉ូលិសថៃដោះលែងប្តី លោកស្រីនឹងជិះម៉ូតូទៅចាំប្តីនៅមុខពន្ធនាគារ ដើម្បីបានឃើញមុខប្តី និងរង់ចាំមើលថាតើសមត្ថកិច្ចថៃ នឹងបញ្ជូនប្តីលោកស្រីយកទៅណាទៀត៕

## ពលករខ្មែរមួយចំនួនរស់នៅកូរ៉េខាងត្បូងខុសច្បាប់ ប្រឈមនឹងបញ្ហាលំបាកជាច្រើន

https://www.rfa.org/khmer/news/human-rights/some-cambodian-workers-in-s-korea-facing-many-difficulties-due-to-illegal-stay-06192023093741.html ដោយ សន ចាន់រដ្ឋា2023.06.19

ពលករខ្មែរមួយចំនួនរស់នៅប្រទេសកូរ៉េខាងត្បូងដោយខុសច្បាប់ កំពុងប្រឈមនឹងបញ្ហាលំបាកជាច្រើន ដូចជា ការស្វែងរកការងារ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ជីវភាពខ្វះខាត និងការតាមចាប់ខ្លួនពីអាជ្ញាធរកូរ៉េ។ ពួកគាត់អះអាងថា មូលហេតុដែលពួកគាត់ក្លាយជាពលកររស់នៅខុសច្បាប់បែបនេះ គឺដោយសារតែថៅកែជនជាតិកូរ៉េធ្វើបាប និងរំលោភសិទ្ធិការងារ ដូច្នេះពួកគាត់បង្ខំចិត្តរត់ចេញពីកន្លែងការងារ។ មន្ត្រីឃ្លាំមើលសិទ្ធិការងារ យល់ឃើញថា មន្ត្រីស្ថានទូតគួរតែយកចិត្តទុកដាក់ដោះស្រាយបញ្ហាទាំងនេះ ដើម្បីធានាដល់ការរស់នៅដល់ពលករខ្មែរ។

ថ្ងៃចុងសប្តាហ៍មានពលករមួយចំនួនសម្រាកពីការងារ រីករាយជាមួយមិត្តភ័ក្តិក្រុមគ្រួសារ និងអ្នកខ្លះទៀតកំពុងធ្វើការថែមម៉ោង ដើម្បីទទួលបានប្រាក់ផ្គត់ផ្គង់ជីវភាពគ្រួសារ។ ទិដ្ឋភាពនៅរដូវក្តៅប្រទេសកូរ៉េខាងត្បូងមិនខុសគ្នាពីកម្ពុជានោះទេ ដែលរដូវក្តៅគឺមានសីតុណ្ហភាពចន្លោះពី ៣៤អង្សា ដល់ ៣៧អង្សា ដែលពលករខ្មែរមួយចំនួនកំពុងមមាញឹកធ្វើការងារក្នុងវិស័យកសិកម្មមានដំណាំចម្រុះជាច្រើនប្រភេទ។ ប៉ុន្តែផ្ទុយពីការមមាញឹកនេះ ពលករខ្មែរមួយចំនួនរស់នៅដោយខុសច្បាប់នៅប្រទេសកូរ៉េជួបជីវភាពខ្វះខាតព្រោះគ្មានការងារធ្វើ និងប្រឈមការចាប់ខ្លួនពីសំណាក់អាជ្ញាធរកូរ៉េដោយសារពួកគាត់បានរត់ចេញពីកន្លែងការងារដោយពុំទាន់បញ្ចប់កិច្ចសន្យា។

ពលការិនីធ្វើការងារនៅកូរ៉េរយៈពេល៣ឆ្នាំផ្នែកកសិឧស្សាហកម្ម កញ្ញា ហួន គន្ធា បានបញ្ជាក់ប្រាប់ពីមូលហេតុនៃការរស់នៅដោយខុសច្បាប់ក្នុងប្រទេសកូរ៉េថា ដោយសារតែថៅកែជនជាតិកូរ៉េ បង្ខំឱ្យពលករខ្មែរធ្វើការលើសម៉ោងគ្មានថ្ងៃឈប់សម្រាកត្រឹមត្រូវ និងទទួលបានប្រាក់ខែ

តិចតួច និងការរំលោភសិទ្ធិការងារ។ កញ្ញាបន្តថា កញ្ញាត្រូវរកការងារក្រៅម៉ោងធ្វើបន្ថែមដោយសារតែប្រាក់ខែទាបមិនអាចទ្រទ្រង់ជីវភាពគ្រួសារបានគ្រប់គ្រាន់។ លើសពីនេះស្ត្រីមួយចំនួនត្រូវបានថៅកែកូរ៉េរំលោភបំពានរាងកាយរហូតដល់មានផ្ទៃពោះ និងបង្ខំឱ្យរំលូតកូនចេញក៏មាន បញ្ហាទាំងអស់ធ្វើឱ្យពលករខ្មែរមួយចំនួនមិនអាចស៊ូទ្រាំក៏សម្រេចចិត្តរត់ចេញពីកន្លែងធ្វើការងារ។

កញ្ញា ហួន គន្ធា៖ «ឃើញគឺអត់ច្រើនករណីទេ ទាល់តែរបស់ហ្នឹងគឺជាគេផុសក្នុងក្ដាំងខ្លាំងទើបចុះអន្តរាគមន៍ចំពោះស្ថានទូត នៅស្រុកខ្មែរចំពោះល្មមយើងត្រូវដោះស្រាយ អ្នកខ្លះទៅគឺគាត់ពិបាកណាស់ដោយសារពួកគាត់អត់ចេះកូរ៉េត្រូវជួលមេធាវី ត្រូវជួលអ្នកបកប្រែហើយខ្មែរយើងខ្មែរស្រឡាញ់ខ្មែរណាស់ប៉ុន្តែករណីបកប្រែតែមួយម៉ាត់ពីរម៉ាត់ទារលុយគ្នារាប់រយដុល្លារ ប៉ុន្តែករណីនៅស្ថានទូតទាល់តែករណីហ្នឹងយើងផុសក្នុងក្ដាំងពេញហ្នឹង»។

កញ្ញា ហួន គន្ធា បញ្ជាក់ថា ច្បាប់ការងារនៅប្រទេសកូរ៉េ នៅពេលពលកររត់ចេញពីកន្លែងការងារ ដោយមិនទាន់បញ្ចប់កិច្ចសន្យា ពួកគាត់នឹងក្លាយជាពលករខុសច្បាប់គ្មានសិទ្ធិវិលត្រឡប់ទៅប្រទេសស្រុកកំណើតវិញឡើយ។ កញ្ញាបន្តថា កញ្ញាមានបញ្ហាសុខភាពដោយសារអាកាសធាតុត្រជាក់ខ្លាំង និងក្ដៅខ្លាំងនៅរដូវក្ដៅ ធ្វើឱ្យចង្កេះ ម្រាមដៃ ឡើងហើមឈឺចុកចាប់ខ្លាំង ហើយបញ្ហានេះ ធ្វើឱ្យជនបរទេសម្នាក់ដែលធ្វើការជាមួយកញ្ញា កាត់ដៃម្ខាងចោលទៀតផង ដោយសារឆ្លងមេរោគ។

ដោយឡែកពលករកូរ៉េធ្វើការនៅខេត្តក្វាងជូជំ (Gwangju) លោក នួន កែវស៊ីដា ថ្លែងថា លោកជាពលករខុសច្បាប់ ដោយសារលោករត់ចេញពីកន្លែងការងារពីព្រោះ លោករងសម្ពាធច្រើនកំឡុងពេលធ្វើការងារ និងកន្លែងរស់នៅតូចចង្អៀតគ្មានអនាម័យ។ លោកបន្តថា លោកជួបផលវិបាកច្រើនក្នុងជីវភាពរស់នៅរយៈពេល ១០ឆ្នាំមកនេះ គឺត្រូវរត់គេចពីប៉ូលិសអន្តោប្រវេសន៍នៅពេលអាជ្ញាធរកូរ៉េចុះមកត្រួតពិនិត្យកន្លែងធ្វើការ រស់នៅលាក់ពួនដូចជាអ្នកទោស និងគ្មានសិទ្ធិដើរហើរដោយសេរីនោះទេ ជាពិសេស ត្រូវតឹងតៀតក្នុងការចាយវាយថែមទៀត។

លោក នួន កែវស៊ីដា៖ «ពេលមួយនោះគឺ ខ្ញុំកំពុងតែធ្វើការមេការឱ្យខ្ញុំរត់ទៅក្នុងបន្ទប់មួយសំងំឱ្យស្ងៀម ពីព្រោះប៉ូលិសគេចូលមកឆែកមាន ព្រោះយើងជាជនអន្តោប្រវេសន៍ខុសច្បាប់អ៊ីចឹងហើយគឺរងហានិភ័យច្រើនណាស់មិនថានៅក្នុងរោងចក្រ មិនថានៅទីសាធារណៈ ឬក៏ផ្សារ ឬក៏កន្លែងយើងដើរកម្សាន្តអាចមានរងហានិភ័យ។ បង។ ប៉ូលិសយើងដើរមកឆែកជួនកាលឃាត់ងាយរងនូវបញ្ហាហ្នឹងច្រើនដែរ»។

លោក នួន កែវស៊ីដា ថា លោកចង់ត្រឡប់ទៅស្រុកខ្មែរពីព្រោះនឹកផ្ទះ និងបងប្អូនឪពុកម្ដាយប៉ុន្តែដោយសារពេលត្រឡប់ទៅវិញ មិនដឹងរកការងារអ្វីធ្វើ ម្យ៉ាងគ្រួសារក៏មានជីវភាពខ្វះខាត

ហើយកម្ពុជាក៏ពុំមានទីផ្សារការងារ។ កត្តាដែលជំរុញឱ្យពលករខ្មែរចំណាកស្រុកមកប្រទេសកូរ៉េ ដើម្បីរកការងារធ្វើ គឺជីវភាពខ្វះខាត ធ្វើស្រែចម្ការបានផលតែគ្មានទីផ្សារ គ្មានការងារក្នុងស្រុក និង ជំពាក់បំណុលធនាគារជាដើម។

ក្រៅពីធ្វើការខុសច្បាប់ ពលករខ្មែរ ក៏ប្រឈមនឹងបញ្ហាច្រើនយ៉ាង ដូចជា ថៅកែកេងប្រវ័ញ្ច កម្លាំងពលកម្ម បង្ខំឱ្យធ្វើការហួសកម្លាំង ប្រើហិង្សាលើរាងកាយ ប្រមាថមើលងាយ និងបើកប្រាក់ខែ ឱ្យមិនទៀងទាត់ជាដើម។ ពួកគាត់មិនដែលបានទទួលយុត្តិធម៌នោះទេ នៅពេលពួកគាត់ទៅប្ដឹងអំពី ការរំលោភសិទ្ធិការងារពីសំណាក់ថៅកែកូរ៉េ។ ចំណែកឯស្ថានទូតខ្មែរមិនដែលចុះមកអន្តរាគមន៍ ជួយដោះស្រាយឱ្យពលករ និងចុះត្រួតពិនិត្យពីស្ថានភាពរស់នៅរបស់ពលករនោះទេ ហើយ ជួនកាលមានការរើសអើងថែមទៀត ប្រសិនបើពលករខ្មែររូបណាគាំទ្រសកម្មជនសង្គម ឬគាំទ្រ គណបក្សនយោបាយដែលខ្លួនពេញចិត្ត។

វិទ្យុអាស៊ីសេរីមិនអាចទាក់ទងស្ថានទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េ និងអ្នកនាំពាក្យក្រសួង ការងារ លោក ហេង សួរ ដើម្បីសុំអត្ថាធិប្បាយជុំវិញបញ្ហានេះបានទេ នៅថ្ងៃទី១៨ មិថុនា។

ទាក់ទិនបញ្ហានេះប្រធានផ្នែកប្រឆាំងការជួញដូរមនុស្ស និងទេសន្តរប្រវេសន៍នៃអង្គការសង់ ត្រាល់ (Central) លោក ឌី ថេហូយ៉ា មានប្រសាសន៍ថា មន្ត្រីស្ថានទូតកម្ពុជាប្រចាំប្រទេសកូរ៉េគួរតែ ជួយដោះស្រាយបញ្ហាឱ្យពលករដែលត្រូវការជំនួយ ហើយប្រសិនបើមន្ត្រីស្ថានទូត និងក្រសួងពាក់ ព័ន្ធមិនចុះត្រួតពិនិត្យលើបញ្ហារំលោភសិទ្ធិការងារទេអ្នកដែលរងគ្រោះគឺពលករខ្មែរ។ លោកបន្តថា មន្ត្រីស្ថានទូតគួរតែធ្វើការបម្រើពលរដ្ឋមិនមែនបម្រើបក្សនោះទេ បើទោះបីជាពលករគាំទ្រគណ បក្សណានោះគឺជាសិទ្ធិរបស់ពួកគាត់មន្ត្រីស្ថានទូតមិនត្រូវមានការរើសអើង ឬប្រកាន់និន្នាការ នយោបាយនោះទេ។

លោក ឌី ថេហូយ៉ា៖ «ស្ថានទូតនៅប្រចាំប្រទេសកូរ៉េហ្នឹងត្រូវយកចិត្តទុកដាក់ក្នុងការការពារ ផលប្រយោជន៍របស់ប្រជាពលរដ្ឋខ្លួនឯងទី១។ ទី២ សូមធ្វើការជាអ្នកបម្រើរាស្ត្រមិនមែនធ្វើការបម្រើ និន្នាការគណបក្សនយោបាយទេ បម្រើរាស្ត្រ បម្រើជាតិ។ ទី៣ ធ្វើយ៉ាងណា ដើម្បីឱ្យប្រជាពលរដ្ឋ របស់ខ្លួនហ្នឹង ទទួលបានភាពស្របច្បាប់ការរស់រានមានជីវិតស្មើមុខស្មើមាត់ដូចគេដូចឯង ដូច ប្រទេសកូរ៉េ»។

បើទោះជាពលករខ្មែររងការរំលោភសិទ្ធិការងារបែបណាក្ដី ក៏លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនដែលខ្វាយខ្វល់ពីសុខទុក្ខ ជួយដោះស្រាយ និងបង្កើនការងារនៅក្នុងស្រុកឡើយ ផ្ទុយវិញ លោក ហ៊ុន សែន ថែមទាំងជំរុញឱ្យពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេសថែមទៀត។ ជាក់ស្ដែង កាលពីថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២ ក្នុងជំនួបជាមួយប្រធានាធិបតីកូរ៉េខាងត្បូងលោក មូន ចេអ៊ី

ន (Moon Jae-In) លោក ហ៊ុន សែន បែរជាស្នើឱ្យកូរ៉េបន្តបង្កើនចំនួននាំពលករខ្មែរទៅធ្វើការនៅប្រទេសកូរ៉េបន្ថែមទៀត។ លោក ហ៊ុន សែន មានមោទនភាព ដែលពលករខ្មែរចំណាកស្រុកទៅកូរ៉េអាចរកចំណូលបានខ្ពស់ និងបង្កើនចំណូលជាតិ ប៉ុន្តែ លោក ហ៊ុន សែន ភ្លេចគិតថា ពលករខ្មែរមួយចំនួនកំពុងរងទុក្ខវេទនាដោយសារការរំលោភសិទ្ធិការងារពីថៅកែជនជាតិកូរ៉េ និងការមិនអើពើជួយដោះស្រាយពីរដ្ឋាភិបាលកម្ពុជា។

ក្រុមពលករជំរុញឱ្យក្រសួងពាក់ព័ន្ធបង្កើនការងារនៅក្នុងស្រុក និងរកទីផ្សារលក់ចេញកសិផល ដើម្បីឱ្យពួកគាត់អាចមានឱកាសធ្វើការនៅក្នុងស្រុកដោយពុំបាច់ចំណាកស្រុក ហើយរងការមើលងាយ និងរំលោភសិទ្ធិការងារពីថៅកែបរទេស៕

# ថ្ងៃទី២២ ខែ មិថុនា ឆ្នាំ២០២៣

## មន្ត្រី៖ រាជរដ្ឋាភិបាល ខិតខំប្រឹងប្រែងយ៉ាងសកម្ម ក្នុងការដោះស្រាយបញ្ហាកេងប្រវ័ញ្ច និងការរំលោភបំពានលើកុមារ

https://freshnewsasia.com/index.php/en/localnews/296444-2023-06-21-03-29-08.html 2023-06-21 10:29am

**(ភ្នំពេញ)៖** រាជរដ្ឋាភិបាលកម្ពុជា បានខិតខំប្រឹងប្រែងយ៉ាងសកម្ម ក្នុងការដោះស្រាយបញ្ហាកេងប្រវ័ញ្ច និងការរំលោភបំពានលើកុមារ។ នេះបើតាមលោក យ៉ែម ច័ន្ទណារុំ អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៃក្រសួងមហាផ្ទៃ។

លោកបានថ្លែងបែបនេះ ពេលតំណាងលោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស បើកសិក្ខាសាលាពិគ្រោះយោបល់ និងផ្ទៀងផ្ទាត់របាយការណ៍សិក្សាវិភាគពីស្ថានភាពការកេងប្រវ័ញ្ចលើកុមារនៅកម្ពុជា នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ នៅភោជនីយដ្ឋានទន្លេបាសាក់ ២ ជាមួយអង្គការ Terre des Hommes ។ បើតាមលោក យ៉ែម ច័ន្ទណារុំ ក្នុងការដោះស្រាយបញ្ហាកេងប្រវ័ញ្ច និងការរំលោភបំពានលើកុមារ រាជរដ្ឋាភិបាលបានបង្កើតផែនការសកម្មភាពជាតិជាច្រើនដើម្បីកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារជាដើម។

លោកស្រី ប៊ូស្រា ហ្ស៊ីលហ្វីកា នាយិកាប្រចាំតំបន់អាស៊ីនៅអង្គការ Terre des Hommes បានលើកឡើងថា បញ្ហាកេងប្រវ័ញ្ចតាមរូបភាពនានាចំពោះកុមារនៅកម្ពុជាបានធ្លាក់ចុះ។ លោកស្រី

*បានបន្តថា ទោះធ្លាក់ចុះក៏ពិតមែន ប៉ុន្តែវានៅតែមានការព្រួយបារម្ភនៅឡើយ ដូច្នេះទាមទារឲ្យភាគីពាក់ព័ន្ធទាំងអស់រួមគ្នាដោះស្រាយបន្ថែមទៀត ដើម្បីធ្វើយ៉ាងណាកាត់បន្ថយការរំលោភបំពានចំពោះកុមារ ដែលជាជនរងគ្រោះ។*

*នៅក្នុងអង្គសិក្ខាសាលានេះ ភាគីរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល បានសន្យាថា ពួកគេនឹងខិតខំចាប់ដៃគ្នាបន្ថែមទៀត ដើម្បីដោះស្រាយ និងការពារកុមារឲ្យរួចផុតពីការរំលោភបំពាន ខណៈភាគីទាំងពីរបានលើកឡើងថា ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមរយៈទេសចរណ៍បានធ្លាក់ចុះ ប៉ុន្តែភាគីពាក់ព័ន្ធនៅបារម្ភចំពោះការកេងប្រវ័ញ្ច និងរំលោភបំពានតាម រយៈប្រព័ន្ធអនឡាញ៕*

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ៤ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ១០នាក់

https://freshnewsasia.com/index.php/en/localnews/296504-2023-06-21-09-16-10.html 2023-06-21 04:16pm

***(ភ្នំពេញ)៖*** *គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១៩ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៤ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ១០នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។* ***បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ រួមមាន៖***

*១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៩៥១ករណី មានមនុស្ស ២,៤២៨នាក់*

*២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៩០៩សំណើ និងបិទសំណុំរឿង ៣០៤សំណើ (រកឃើញមនុស្ស ១,៤០៦នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣៧នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)*

*៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៤២ករណី៕*

# ក្រសួងការបរទេសអាមេរិកដាក់ចំណាត់ថ្នាក់កម្ពុជាអាក្រក់បំផុតនៃអំពើជួញដូរមនុស្ស

https://www.rfa.org/khmer/news/human-rights/us-released-report-about-trafficking-in-cambodia-increasing-in-2023-06172023034834.html *ដោយ សេក បណ្ឌិត* 2023.06.17

*ក្រសួងការបរទេសអាមេរិកចេញផ្សាយ របាយការណ៍ ស្ដីពីការជួញដូរមនុស្ស ប្រចាំឆ្នាំ ២០២៣ នៅថ្ងៃទី១៦ ខែមិថុនា ដោយបង្ហាញថា ស្ថានភាពនៃអំពើជួញដូរមនុស្សនៅកម្ពុជាគ្មានភាពល្អប្រសើរឡើយ។ ក្រសួងការបរទេសអាមេរិក បន្តរក្សាចំណាត់ថ្នាក់កម្ពុជានៅកម្រិតទី៣ ដូចកាលឆ្នាំកន្លងទៅដដែល។*

របាយការណ៍ស្ដីពីការជួញដូរមនុស្សប្រចាំឆ្នាំ២០២៣ របស់ក្រសួងការបរទេសអាមេរិកលើកឡើងថា រដ្ឋាភិបាលឯកបក្សរបស់លោក ហ៊ុន សែន មិនបានបំពេញតាមស្ដង់ដារអប្បបរមាក្នុងការលុបបំបាត់ការជួញដូរមនុស្ស និងពុំបានខិតខំប្រឹងប្រែងឱ្យបានខ្លាំងក្លាក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សនោះទេ សូម្បីតែអំឡុងពេលមានការរីករាលដាលជំងឺកូវីដ-១៩ ក៏ដោយ។

អាមេរិករកឃើញថា អំពើពុករលួយនៃមន្ត្រីជាន់ខ្ពស់នៅកម្ពុជានៅតែបន្តរីករាលដាលដែលជាហេតុរាំងដល់ការអនុវត្តច្បាប់លើក្រុមឧក្រិដ្ឋជន ដែលបានប្រព្រឹត្តអំពើជួញដូរមនុស្សនៅកម្ពុជា។ របាយការណ៍បញ្ជាក់ថា អាជ្ញាធរកម្ពុជាពុំបានបើកការស៊ើបអង្កេត ឬនាំយកមន្ត្រីដែលជាប់ពាក់ព័ន្ធនឹងបទឧក្រិដ្ឋផ្អែកតាមសេចក្ដីរាយការណ៍គួរឱ្យជឿទុកចិត្ត ជាពិសេសនៅពេលដែលពាក់ព័ន្ធនឹងក្រុមអាជីវករអសីលធម៌ ដែលបានបង្ខំឱ្យបុរស ស្ត្រី និងកុមាររាប់ពាន់នាក់នៅទូទាំងប្រទេសកម្ពុជាធ្លាក់ចូលក្នុងការជួញដូរមនុស្សក្នុងវិស័យសេវាកម្មកម្សាន្ត ឡូតដ្ឋ និងប្រតិបត្តិការបែបឆបោកនៅលើប្រព័ន្ធអ៊ីនធឺណិត ជាដើម។ លើសពីនេះ អាមេរិករកឃើញថា រដ្ឋាភិបាលកម្ពុជាបានបរាជ័យជាបន្តបន្ទាប់ក្នុងការត្រួតពិនិត្យ ឬផ្ដល់យុត្តិធម៌ក្នុងឧក្រិដ្ឋកម្មជួញដូរសម្រាប់ពលករបរទេសដែលត្រូវបានជួយសង្គ្រោះពីប្រតិបត្តិការឆបោកតាមអ៊ីនធឺណិត។

រយៈពេលពីរឆ្នាំចុងក្រោយនេះ អាមេរិកបានទម្លាក់ចំណាត់ថ្នាក់កម្ពុជានៅកម្រិតទី៣ ដែលមានន័យថា ស្ថានភាពនៃអំពើជួញដូរមនុស្សនៅកម្ពុជាមានលក្ខណៈអាក្រក់បំផុត និងពុំធ្លាប់មានទេចាប់តាំងពីឆ្នាំ២០១៥ មក។ ទន្ទឹមនឹងនេះ ស្របពេលកម្ពុជាស្ថិតក្នុងស្ថានភាពគួរឱ្យព្រួយបារម្ភ និងគ្មានការចាត់វិធានការឱ្យមានប្រសិទ្ធភាពនោះ កន្លងទៅស្ថាប័នអន្តរជាតិមួយចំនួនបានលាតត្រដាងថា ឧក្រិដ្ឋកម្មជួញដូរមនុស្ស និងអំពើឆបោកតាមប្រព័ន្ធអ៊ីនធឺណិតទ្រង់ទ្រាយធំប្រតិបត្តិការដោយក្រុមហ៊ុនចិនមួយចំនួននៅកម្ពុជាដំណើរការទៅបានដោយសេរី ដ្បិតមានមន្ត្រីឧកញ៉ាគ្រាក់ៗសិទ្ធស្នាលនឹងលោក ហ៊ុន សែន នៅកាងការពារពីក្រោយខ្នង។

កាលពីឆ្នាំ២០២២ សមត្ថកិច្ចកម្ពុជាបង្ក្រាបបានអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទជិត ២រយករណី (១៧៤) ឃាត់ខ្លួនជនសង្ស័យជាង ២រយនាក់ (២២៦) ក្នុងនោះមានជនបរទេសចំនួន ៣២នាក់បញ្ជូនទៅតុលាការ និងរំដោះជនរងគ្រោះបានជាង ៥រយនាក់ (៥៥២)។ ដោយឡែកចាប់តាំងពីខែសីហា ឆ្នាំ២០២២ មកដល់ខែមីនា ២០២៣ អ្នកពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សមានជនបរទេសជិត ៩រយនាក់ (៨៧១) មកពីបណ្ដាប្រទេសចំនួន ១២ប្រទេសផ្សេងៗគ្នា ហើយក្នុងនោះមានមនុស្សជិត ២រយនាក់ (១៦២) សមត្ថកិច្ចរកឃើញថា មានជាប់ពាក់ព័ន្ធនឹងអំពើរត់ពន្ធ និងជួញដូរមនុស្ស ខណៈមនុស្ស ៨០នាក់ទៀតត្រូវបានបញ្ជូនទៅតុលាការពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសជួញដូរមនុស្ស។

វិទ្យុអាស៊ីសេរីមិនអាចទាក់ទងអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកស្រី ជូ ប៊ុនអេង ដើម្បីសាកសួរជុំវិញរឿងនេះបានទេនៅថ្ងៃទី១៦ ខែមិថុនា។ ប៉ុន្តែ កន្លងមកមន្ត្រីជាន់ខ្ពស់កម្ពុជា រួមទាំងលោក ស ខេង ផងអះអាងថា កម្ពុជាតែងប្ដេជ្ញាចិត្តក្នុងការប្រយុទ្ធប្រឆាំង និងបង្កើនកិច្ចសហប្រតិបត្តិការជាមួយបណ្ដាប្រទេសក្នុងតំបន់ និងអន្តរជាតិ ដើម្បីទប់ស្កាត់លុបបំបាត់អំពើជួញដូរមនុស្សនៅកម្ពុជា។

អ្នកឃ្លាំមើលលើកឡើងថា របាយការណ៍របស់ក្រសួងការបរទេសអាមេរិកឆ្លុះបញ្ចាំងការពិតដ្បិតបទល្មើសនៃអំពើជួញដូរមនុស្សនៅកម្ពុជានៅតែបន្តកើតមានច្រើន។

នាយកទទួលបន្ទុកកិច្ចការទូទៅនៃអង្គការលីកាដូ (LICADHO) លោក អំ សំអាត សោកស្ដាយដែលអាមេរិកបន្តទម្លាក់ចំណាត់ថ្នាក់កម្ពុជាមកកម្រិតទី៣ ដែលមានន័យថា ស្ថានភាពនៃអំពើជួញដូរមនុស្សនៅកម្ពុជាពុំទាន់មានភាពល្អប្រសើរឡើយ។ លោកថា រដ្ឋាភិបាលកម្ពុជាគួរតែត្រួតពិនិត្យបោសសម្អាតលើមន្ត្រីពុករលួយ និងបង្ហាញឆន្ទៈពិតប្រាកដក្នុងការស៊ើបអង្កេតមន្ត្រីអ្នកមានអំណាចប្រសិនបើរកឃើញថា ពួកគេមានជាប់ពាក់ព័ន្ធនឹងអំពើជួញដូរគឺត្រូវអនុវត្តតាមច្បាប់ ដើម្បីស្ដារមុខមាត់កម្ពុជា។

លោក អំ សំអាត ៖ «ម្យ៉ាងទៀតកាលណាប្រទេសកម្ពុជាយើងជាប់ការវាយតម្លៃរបស់សហរដ្ឋអាមេរិក លើចំណាត់ថ្នាក់លេខ៣ អ៊ីចឹងក៏មិនមានផលល្អអីប៉ុន្មានដែរ សម្រាប់កម្ពុជាយើង។ ការជួញដូរមនុស្សហ្នឹង កាលណានៅតែបន្តកើតឡើង ឬក៏គេរកឃើញថា នៅតែកើតឡើងច្រើន វាប៉ះពាល់ច្រើនទាក់ទង ការវិនិយោគ ទាក់ទងសន្តិសុខសុវត្ថិភាព ពីព្រោះក្រុមឧក្រិដ្ឋជនការជួញដូរតែងតែបង្កធ្វើឱ្យប៉ះពាល់ជាហូរហែ អាហ្នឹងគឺវាប៉ះពាល់មុខមាត់ និងស្ថានភាពនៃប្រទេសកម្ពុជាយើងទាក់ទងលើការវិនិយោគជាដើម»។

*អ្នកវិភាគ និងអ្នកតាមដានស្ថានការណ៍នយោបាយមួយចំនួនលើកឡើងថា មូលហេតុដែលរដ្ឋាភិបាលគ្មានឆន្ទៈក្នុងការស៊ើបអង្កេត និងគ្មានការចាត់វិធានការលើក្រុមអ្នកមានលុយមានអំណាចមួយចំនួនដែលមានងារជាឧកញ៉ា និងឯកឧត្តមដែលអាចមានជាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សនៅកម្ពុជា ដ្បិតក្រុមមនុស្សទាំងនោះគឺពួកគេតែងតែបម្រើ និងផ្តល់ផលប្រយោជន៍ដល់រដ្ឋាភិបាលលោក ហ៊ុន សែន និងក្រុមគ្រួសារត្រកូល«ហ៊ុន»។*

# ថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ២០២៣

## សមត្ថកិច្ចកម្ពុជា

## បន្តទទួលបានបណ្តឹង ៤ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ១៩នាក់

https://freshnewsasia.com/index.php/en/localnews/296550-2023-06-22-02-21-06.html 2023-06-22 09:21am

***(ភ្នំពេញ)៖*** *គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី២០ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៤ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ១៩នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន* Fresh News*។* ***បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣ រួមមាន៖***

***១៖*** *សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៩៥៥ករណី មានមនុស្ស ២,៤៤៧នាក់*

***២៖*** *បានស្រាវជ្រាវស៊ើបអង្កេតបឋម ៩១១សំណើ និងបិទសំណុំរឿង ៣០៥សំណើ (រកឃើញមនុស្ស ១,៤១៤នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣៧នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)*

***៣៖*** *កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៤៤ករណី។*

# ក្រសួងការងារប្រកាសឲ្យពលករខ្មែរជំនាញផ្នែកគោជនីយដ្ឋាន ប្រញាប់ដាក់ពាក្យធ្វើតេស្ត ដើម្បីបានទៅធ្វើការនៅជប៉ុន

https://www.kampucheathmey.com/local-news/532027 *ថ្ងៃព្រហស្បតិ៍ ២២ មិថុនា ២០២៣*

*ដោយ* Sokhom Khon

*ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រកាសឲ្យពលករខ្មែរជំនាញផ្នែកការងារនៅគោជនីយដ្ឋានទាំងអស់ប្រញាប់មកដាក់ពាក្យធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុនដើម្បីបានទៅធ្វើការនៅប្រទេសជប៉ុនទទួលបានបទពិសោធន៍ការងារល្អៗ និងទទួលបានប្រាក់ខែខ្ពស់ ។*

*លោកបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឲ្យដឹងនៅក្នុងសេចក្តីជូនដំណឹងមួយទើបទទួលបាននៅថ្ងៃទី២២មិថុនានេះថា អង្គភាពទទួលបន្ទុកការធ្វើតេស្តភាសាជប៉ុន និងតេស្តជំនាញនឹងរៀបចំការធ្វើតេស្តភាសា និងតេស្តជំនាញផ្នែកការងារនៅគោជនីយដ្ឋានតាមរយៈប្រព័ន្ធកុំព្យូទ័រ។ លោករដ្ឋមន្ត្រីបានបន្តថា ការធ្វើតេស្តភាសាជប៉ុន និងតេស្តជំនាញនេះនឹងប្រព្រឹត្តិទៅនៅវិទ្យាស្ថានអភិវឌ្ឍន៍វិស័យអប់រំដែលមានអាសយដ្ឋាននៅសង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ក្នុងតម្លៃធ្វើតេស្តចំនួន៣៣ដុល្លារអាមេរិក ដោយកាលបរិច្ឆេទនៃការធ្វើតេស្តរួមមានថ្ងៃទី៦,៧,១៤,១៥,និង៣០ ខែកក្កដា។ ថ្ងៃទី១,៥,៦,២១,២២,២៥ដល់២៧ ខែសីហា និងថ្ងៃទី១,៣,១១,១២កញ្ញា ឆ្នាំ២០២៣។*

*លោករដ្ឋមន្ត្រីបានបន្តទៀតថា ចំពោះការចុះឈ្មោះធ្វើតេស្តភាសាជប៉ុន និងតេស្តជំនាញបេក្ខជនត្រូវមានអាយុចាប់ពី១៧ឆ្នាំឡើងទៅដោយមិនគិតពីកម្រិតវប្បធម៌ឡើយ និងត្រូវភ្ជាប់មកជាមួយនូវឯកសារមួយចំនួនដូចជាលិខិតឆ្លងដែនឬប័ណ្ណបើកបរ។ ពិន្ទុធ្វើតេស្តជាប់ជាស្ថាពរចាប់ពី៦០%ឡើងទៅ ហើយចំនួនបេក្ខជនដែលអាចទទួលសម្រាប់ការស្នើសុំធ្វើតេស្តបាន៥០នាក់ក្នុង១ខែ។*

*យោងតាមក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានឱ្យដឹងថាបច្ចុប្បន្នកម្ពុជាមានពលករខ្មែរទៅធ្វើការនៅប្រទេសជប៉ុនចំនួន៤៩៧៣៨នាក់ភាគច្រើនជាកម្មសិក្សាការី។ ចំណែកពលករជំនាញមានប្រមាណពី១០០ទៅ២០០នាក់ប៉ុណ្ណោះដោយពួកគេទៅធ្វើការលើផ្នែកការវេខ្ចប់សំណង់ចំណីអាហារ សេវាកម្មសណ្ឋាគារគោជនីដ្ឋានកសិកម្មដាំដុះ និងចិញ្ចឹមសត្វ។ អត្ថបទ៖ សំអឿន*

**សាច់ញាតិខកចិត្តនឹង**
**មន្ត្រីស្ថានទូតខ្មែរនៅថៃមិនជួយអន្តរាគមន៍ដល់ពលករខ្មែរចំនួន៩នាក់**

https://www.rfa.org/khmer/news/human-rights/workers-relatives-upset-with-cambodian-embassy-officials-for-not-intervening-in-nine-cambodian-workers-arrested-by-thai-authorities-06222023045644.html *ដោយ នៅ វណ្ណារិន*2023.06.22

*សាច់ញាតិពលករខកចិត្តនឹងមន្ត្រីស្ថានទូតខ្មែរនៅថៃ ដែលមិនជួយអន្តរាគមន៍ទៅអាជ្ញាធរថៃករណីចាប់ខ្លួនពលករចំនួន៩នាក់ បើទោះជាពួកគាត់ព្យាយាមទាក់ទងសុំឱ្យមានការជួយកិច្ចអន្តរាគមន៍ក្ដី។មន្ត្រីសង្គមស៊ីវិលការពារសិទ្ធិពលករលើកឡើងថា ករណីនេះមិនមែនជាទី១ទេដែលមន្ត្រីស្ថានទូតខ្មែរប្រចាំប្រទេសថៃខកខានជួយពលករខ្មែរនៅពេលជួបទុក្ខលំបាកឬត្រូវសមត្ថកិច្ចថៃចាប់ខ្លួន។ ជិតពីរសប្ដាហ៍ហើយបន្ទាប់សមត្ថកិច្ចថៃចាប់ពលករខ្មែរ៩នាក់ហើយសាច់ញាតិពលករទាំងនោះនៅមិនទាន់ទទួលការឆ្លើយតបណាមួយពីមន្ត្រីស្ថានទូតខ្មែរប្រចាំប្រទេសថៃ ដើម្បីធ្វើកិច្ចអន្តរាគមន៍ជួយពួកគាត់បាននៅឡើយ។*

*លោកស្រី រី ស្រីយ័ន្ត ជាពលករធ្វើសំណង់នៅប្រទេសថៃដែលមានសាច់ញាតិត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួនប្រាប់វិទ្យុអាស៊ីសេរីថ្ងៃទី២១ ខែមិថុនា ថា លោកស្រីបានទូរស័ព្ទទៅមន្ត្រីស្ថានទូតខ្មែរប្រចាំប្រទេសថៃ ស្ទើររាល់ថ្ងៃចាប់តាំងពីសមត្ថកិច្ចថៃចាប់ខ្លួន សាច់ញាតិលោកស្រីរហូតមកដល់ពេលនេះ តែមិនទទួលបានការឆ្លើយតបឡើយ។ លោកស្រីយល់ថា ប្រសិនបើករណីនេះមន្ត្រីស្ថានទូតជួយអន្តរាគមន៍ទាន់ពេលទំនងជាសមត្ថកិច្ចថៃ មិនបញ្ជូនករណីនេះទៅកាត់ក្ដីដល់តុលាការនោះឡើយ។ លោកស្រីសោកស្ដាយដែលមន្ត្រីស្ថានទូតខ្មែរប្រចាំប្រទេសថៃ មិនជួយពលករដែលជួបទុក្ខបាននៅឡើយ។*

*លោកស្រី រី ស្រីយ័ន្ត៖ «ទាក់ទងទៅនេះ(ស្ថានទូតខ្មែរប្រចាំប្រទេសថៃ)ខ្ញុំចង់ឱ្យបងប្អូននៅខ្មែរអស់ចិត្តកុំឱ្យថា មើលបងប្អូនមានរឿងហើយក៏មិនជួយតែបើខ្ញុំព្យាយាមហើយ តែគេមិនបានតបខ្ញុំក៏មិនដឹងធ្វើម៉េច? ខ្ញុំព្យាយាមទាក់ទងតាមលេខគេឱ្យមកហើយ តែគេអន្តរាគមន៍មកយើងផងថារឿងរ៉ាវបានយ៉ាងម៉េចៗទេពេលនេះមានតែអស់សង្ឃឹមហើយព្រោះមនុស្សអីមនុស្សចូលគុកហើយ»។ លោកស្រី រី ស្រីយ័ន្ត ឱ្យដឹងទៀតថា សមត្ថកិច្ចបានបញ្ជូនពលករទាំង៩នាក់ទៅកាត់ក្ដី ឬជំនុំជម្រះក្ដីនៅតុលាការប្រទេសថៃរួចហើយ កាលពីថ្ងៃទី១៤ខែមិថុនា។ លោកស្រីបន្តថា មុនពេលសមត្ថកិច្ចថៃបញ្ជូនសំណុំរឿងនេះទៅតុលាការ សមត្ថកិច្ចថៃបង្គាប់ឱ្យពលករទាំងនោះបង់ប្រាក់ក្នុងម្នាក់ចំនួន១.៤០០០បាត ឬជាង៥០០ដុល្លារជាថ្នូរនឹងដោះលែងនៅក្រៅឃុំ។*

សមត្ថកិច្ចថៃនៅទីក្រុងបាងកក (Bangkok) កាលពីថ្ងៃទី១២ ខែមិថុនា បានចុះឆែកឆេរនិង ចាប់ខ្លួនពលករខ្មែរចំនួន ៩នាក់នៅការដ្ឋានសំណង់មួយកន្លែងក្រោយរកឃើញថា ពួកគេគ្មានឯក សារធ្វើការគ្រប់គ្រាន់ហើយសមត្ថកិច្ចថៃក៏បានយកទាំងកុមារតាមម្ដាយពីរនាក់ ម្នាក់អាយុ ៤ឆ្នាំ និង ម្នាក់ទៀតអាយុជាង១ឆ្នាំទៅឃុំខ្លួនជាមួយម្ដាយផងដែរ។ លោកស្រី រី ស្រីយ័ន្ត ប្រាប់ថា មូលហេតុ ដែលសមត្ថកិច្ចថៃចុះចាប់ពលករខ្មែរដូច្នេះព្រោះមានជនជាតិថៃប្ដឹងសមត្ថកិច្ចថៃថា មានពលករខ្មែរ លួចធ្វើការខុសច្បាប់។

ទាក់ទងរឿងរឿងនេះ វិទ្យុអាស៊ីសេរីមិនអាចសុំការអត្ថាធិប្បាយពីមន្ត្រីអនុព័ន្ធការងារនៃស្ថាន ទូតកម្ពុជាប្រចាំប្រទេសថៃលោក ឈឹម វិបុល អ្នកនាំពាក្យក្រសួងការបរទេស លោក អាន សុខខឿន និងប្រធានអង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលលោក ផៃ ស៊ីផាន បានទេនៅថ្ងៃទី២១ ខែមិថុនា។

ចំណែកអ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាលោក សុខ ឥសាន យល់ថា ការងារចំបង របស់មន្ត្រីស្ថានទូតខ្មែរនៅក្រៅប្រទេស គឺជួយដោះស្រាយបញ្ហារបស់ពលករ។ លោក សុខ ឥសាន ឆ្លើយជំនួសមន្ត្រីស្ថានទូតខ្មែរប្រចាំប្រទេសថៃថា ករណីមន្ត្រីស្ថានទូតបានទទួលទូរស័ព្ទរបស់ក្រុម ពលករអាចមកពីមន្ត្រីស្ថានទូតមានការងារច្រើនដែលត្រូវបំពេញ ឬក៏មកពីពលករខ្មែរនៅប្រទេស ថៃចុចលេខទូរស័ព្ទខុស។ អ្នកនាំពាក្យគណបក្សកាន់អំណាចរូបនេះប្រាប់ទៅក្រុមពលករថាបើ ពិបាកទាក់ទងមន្ត្រីស្ថានទូតតាមប្រព័ន្ធទូរស័ព្ទ ពលករគួរធ្វើដំណើរទៅដល់មុខស្ថានទូតតែម្ដង ដើម្បីសុំការអន្តរាគមន៍។

លោក សុខ ឥសាន៖ «ឥឡូវថ្ងៃក្រោយមិនបាច់ចុកតេឡេហ្វូន(ទូរស័ព្ទ)ជិះតាក់ស៊ីទៅចូល ស្ថានទូតម្ដងទៅ បានដឹងច្បាស់ហើយមកសួរខ្ញុំនៅភ្នំពេញខ្ញុំក៏អត់ដឹងឆ្លើយអីច្បាស់លាស់ដែរ ឱ្យដើរ ទៅស្ថានទូតទៅ សួរនាំគេទៅ ហើយនៅព្រំដែនគេមានអគ្គកុងស៊ុលដែរតាស គេប្រចាំនៅហ្នឹងដើម្បី ជួយដោះស្រាយបងប្អូន»។

បើទោះជាមន្ត្រីបក្សកាន់អំណាចអះអាងបែបនេះក្ដីតែក្រុមពលករនិងអ្នកការពារសិទ្ធិពលករ រិះគន់ថាមន្ត្រីស្ថានទូតខ្មែរប្រចាំប្រទេសថៃមិនសូវយកចិត្តទុកដាក់ជួយដោះស្រាយបញ្ហារបស់ពល ករទេ តែបើការងារពង្រឹងបក្សគឺមន្ត្រីស្ថានទូតធ្វើការងារនេះយ៉ាងសកម្មតែម្ដង។

មន្ត្រីផ្នែកការពារសិទ្ធិពលករចំណាកស្រុក នៃអង្គការសង់ត្រាល់ (CENTRAL) ប្រចាំនៅ ប្រទេសថៃលោក លឹង សុផុន លើកឡើងថា តួនាទីរបស់មន្ត្រីស្ថានទូតនៅប្រទេសថៃមានសារៈ សំខាន់ណាស់ព្រោះប្រទេសថៃមានពលករជិត ២លាននាក់កំពុងធ្វើការងារនៅប្រទេសថៃ។ លោក លឹង សុផុន សង្កេតឃើញទៀតថា ពលករខ្មែរភាគច្រើនដែលស្នើទៅមន្ត្រីស្ថានទូតឱ្យជួយកន្ទង់ កន្ទង់មកគឺមិនសូវទទួលបានការឆ្លើយតបវិញនោះទេ។ អ្នកការពារសិទ្ធិពលកររូបនេះថា ភាពមិន

អើពើពីទុក្ខលំបាករបស់ពលករពីសំណាក់មន្ត្រីស្ថានទូតខ្មែរបែបនេះ នឹងធ្វើឱ្យពលករអស់ជំនឿនលើស្ថានទូតខ្មែរប្រចាំប្រទេសថៃ។

មន្ត្រីផ្នែកការពារសិទ្ធិពលករចំណាកស្រុកនៃអង្គការសង់ត្រាល់ (CENTRAL) ប្រចាំនៅប្រទេសថៃលោក លឹង សុផុន។ រូបៈ ពលរដ្ឋផ្តល់ឱ្យលោក លឹង សុផុនៈ «ស្ថានទូតអីយើងគួរតែជួយពួកគាត់ (ពលករ) ធ្វើយ៉ាងណាយើងតាមដានពួកគាត់មានទោស ដោយសារអីបានជាគេចាប់គាត់ដាក់គុកពលករហៅទៅហើយ តែយើង(ស្ថានទូត)មិនលើកទូរស័ព្ទពួកគាត់អ៊ីចឹង មានតែប្រជាពលរដ្ឋរិះគន់ហើយថា យើងមកធ្វើដើម្បីប្រជាពលរដ្ឋថាយើងមកធ្វើការដើម្បីប្រជាពលរដ្ឋ ប៉ុន្តែប្រជាពលរដ្ឋមានបញ្ហាយើងមិនអើពើអ៊ីចឹងជារឿងមិនល្អទេ»។ លោក លឹង សុផុន ឱ្យដឹងដែរថា ប៉ុន្មានខែចុងក្រោយមានពលករខ្មែរជាង១ពាន់នាក់ហើយ ដែលត្រូវសមត្ថកិច្ចចាប់ខ្លួន ព្រោះករណីគ្មានឯកសារធ្វើការងារគ្រប់គ្រាន់។ អង្គការសង់ត្រាល់រកឃើញថា ពលករខ្មែរភាគច្រើនដែលសមត្ថកិច្ចថៃចាប់ខ្លួននោះពួកគាត់ត្រូវបានរងការធ្វើទុក្ខទោសទារុណកម្ម និងជាប់ឃុំក្នុងបន្ទប់តូចចង្អៀត ហើយក៏មានករណីខ្លះទៀតត្រូវបានសមត្ថកិច្ចថៃដាក់ខ្នោះប្រៀបដូចឧក្រិដ្ឋជន៕

# ថ្ងៃទី២៦ ខែ មិថុនា ឆ្នាំ២០២៣

## គ្រោះថ្នាក់ក្រឡាប់ឡាន

## បានធ្វើអោយពលករខ្មែរ ២នាក់ស្លាប់ និងអ្នកផ្សេងទៀតរងរបួស

https://www.khmertimeskh.com/501313279/ Khmer Times June 23, 2023

រថយន្តមួយគ្រឿងបើកបុកនិងក្រឡាប់ផ្ងារដើង បណ្តាលឲ្យបុរស២នាក់ស្លាប់ និងមានអ្នករបួសជាច្រើននាក់នៅវេលាម៉ោង២៣និង៣០នាទីម្សិលមិញ។ លោកវរសេនីយ៍ទោ Worachai Sukying ប្រចាំប៉ុស្តិ៍នគរបាល Klong Luang ក្នុងខេត្ត Pathum Thani ទទួលបានដំណឹងអំពីកន្លែងកើតហេតុដែលមានជនរងគ្រោះជាពលករខ្មែរចំណាកស្រុក។

សមត្ថកិច្ចបានប្រទះឃើញរថយន្ត Mitsubishi ពណ៌ទឹកប្រាក់ ក្រឡាប់ផ្ងារជើងឡើងលើដោយរងការខូចខាតយ៉ាងដំណំ។ បំណែកឡាន និងរបស់របរផ្ទាល់ខ្លួនត្រូវបានធ្លាក់រាយប៉ាយនៅជុំវិញរថយន្ត ហើយមានអ្នករងរបួសជាច្រើននាក់ដោយក្នុងនោះមានបុរស៦នាក់ និងស្ត្រី ២នាក់ផងដែរ។ បុរស២នាក់ដែលបានស្លាប់នៅកន្លែងកើតហេតុដែរគឺជាជនជាតិខ្មែរ ។ រថយន្តដឹកទំនិញបានរេចង្កូតធ្លាក់ផ្លូវបានក្រឡាប់ផ្ងារជើង និងបណ្តាលឲ្យអ្នករួមដំណើរទាំង៨នាក់ដែលជិះពីក្រោយរថយន្តបានខ្ទាតចេញ។

*ក្រុមអ្នកជួយសង្គ្រោះមកពីមូលនិធិ Ruam Katanyu បានជួយ និងដឹកអ្នករបួសភ្លាមៗទៅកាន់មន្ទីរពេទ្យ Thammasat University និងកន្លែងសង្គ្រោះនៅជិតផ្សេងទៀតៗ ដោយឡែក អ្នកបើកបរជាបុរសជនជាតិខ្មែរត្រូវបានគេដឹកយកទៅសង្គ្រោះនៅមន្ទីរពេទ្យ Sam Khok។ នឹងមានការស៊ើបសួរបន្ថែម រួមទាំងការធ្វើកោសល្យវិច័យដើម្បីកំណត់ពីមូលហេតុនៃគ្រោះថ្នាក់ និងចាត់ការទៅតាមផ្លូវច្បាប់ ចំណែកយករថយន្ត ដែលរងការខូចខាតក៏បានយកចេញពីកន្លែងកើតហេតុផងដែរ។ សាកសព ត្រូវបានប្រគល់ទៅឱ្យមូលនិធិ Ruam Katanyu ដើម្បីយកទៅធ្វើកោសល្យវិច្ច័យនៅមន្ទីរពេទ្យសាកលវិទ្យាល័យ Thammasat។ ក្រុមគ្រួសារសពនឹងត្រូវបានជូនដំណឹងដើម្បីយកសពមកគោរពវិញ្ញាណក្ខន្ធជាលើកចុងក្រោយ។ The thiager*

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ៤ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៥នាក់

https://freshnewsasia.com/index.php/en/localnews/296717-2023-06-23-08-20-49.html 2023-06-23 03:20pm

***(ភ្នំពេញ)៖*** *គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី២១ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៤ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០៥នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។* ***បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ រួមមាន៖***

*១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៩៥៨ករណី មានមនុស្ស ២,៤៥១នាក់*

*២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៩១១សំណើ និងបិទសំណុំរឿង ៣០៥សំណើ (រកឃើញមនុស្ស ១,៤១៤នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣៧នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)*

*៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៤៨ករណី។*

## ម៉ាឡេស៊ី ចោទប្រកាន់ពលរដ្ឋថៃ៤នាក់ ក្រោយការរកឃើញផ្នូរសពជាច្រើន រួមជាមួយជំរំរត់ពន្ធមនុស្ស នៅតាមព្រំដែន

https://freshnewsasia.com/index.php/en/internationalnews/296736-2023-06-23-09-57-42.html

2023-06-23 04:57pm

**(គួឡាឡាំពួ)៖** ពលរដ្ឋថៃចំនួន ៤នាក់ត្រូវបានចោទប្រកាន់ នៅក្រោមច្បាប់ប្រឆាំងការជួញដូរមនុស្សរបស់ម៉ាឡេស៊ី ក្រោយពីផ្នូរសាកសពទ្រង់ទ្រាយធំ ព្រមទាំងជំរំខុសច្បាប់សម្រាប់ជនភៀសខ្លួន ត្រូវបានរកឃើញនៅក្នុងតំបន់ព្រៃភ្នំដាច់ស្រយាល តាមព្រំដែនម៉ាឡេស៊ី-ថៃ កាលពីជាង៨ឆ្នាំមុនៗ នេះបើយោងតាមការចេញផ្សាយដោយទីភ្នាក់ងារសារព័ត៌មាន AFP នៅថ្ងៃសុក្រ ទី២៣ ខែមិថុនា ឆ្នាំ២០២៣។

បុរសដែលមានអាយុចន្លោះពី ៣០ឆ្នាំ ដល់ ៥៨ឆ្នាំ បានទៅដល់តុលាការទីក្រុងកាងហ្គា (Kangar) នៃរដ្ឋពែលីស (Perlis) ភាគខាងជើងប្រទេសម៉ាឡេស៊ីនៅថ្ងៃសុក្រនេះ។ ក្រោយមក អ្នកបកប្រែក្នុងតុលាការបានអានការចោទប្រកាន់ពួកគេ ដែលពាក់ព័ន្ធទៅនឹងការជួញដូរជនជាតិមីយ៉ាន់ម៉ាពីរនាក់។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃម៉ាឡេស៊ី លោក សៃហ្វ៊ូតឌីន ណាស៊ូសិន អ៊ីម៉េល (Saifuddin Nasution Ismail) បានឲ្យដឹងថា ជនជាតិថៃទាំង ៤នាក់ត្រូវបានធ្វើបត្យាប័នកាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍នេះ ហើយពួកគេស្ថិតក្នុងចំណោមមនុស្ស ១០នាក់ដែលម៉ាឡេស៊ីបានស្វែងរកការធ្វើបត្យាប័ននៅក្នុងឆ្នាំ ២០១៧។

គួរបញ្ជាក់ថា ថៃ និងម៉ាឡេស៊ីបានបើកការស៊ើបអង្កេតរួមគ្នាលើការសាងសង់ជំរុំបែបនេះ ហើយកន្លងមកថៃធ្លាប់បានកាត់ទោស ជនជាប់ចោទចំនួន ៦២នាក់ក្នុងនោះមានមន្ត្រីរដ្ឋាភិបាល ៩នាក់ជុំវិញការស្លាប់ និងការជួញដូរជនជាតិរ៉ូហ៊ីងយ៉ា និងបង់ក្លាដែសទៅកាន់ប្រទេសម៉ាឡេស៊ី តាមរយៈប្រទេសថៃកាលពីឆ្នាំ ២០១៧៕

## បុរសអាហ្វ្រិកខាងត្បូង ដែលជាប់គាំងនៅកម្ពុជា ក្រោយបោកប្រាស់ការងារនៅថៃ បានត្រឡប់ទៅផ្ទះវិញ

https://www.khmertimeskh.com/501313669/ June 24, 2023

បន្ទាប់ពីជាប់គាំងរយៈពេលប្រាំពីរខែដ៏លំបាក នៅអាស៊ីអាគ្នេយ៍ Xolani Fongo ដែលជាបុរសជនជាតិអាហ្វ្រិកខាងត្បូងដែលបានជួបរឿងស៊ីយពីការបោកប្រាស់ការងារនៅក្នុងប្រទេសកម្ពុជា និងប្រទេសថៃនោះ បានមកជួបជុំគ្រួសាររបស់គាត់វិញនៅក្រុង Masilo Theunissen ខេត្ត Free State។

បុរសវ័យ២៩ ឆ្នាំរូបនេះបានអង្វរសុំជំនួយជាសាធារណៈបន្ទាប់ពីប្រើអស់លទ្ធភាពទាក់ទងបណ្ដាញការទូតនានា។ គាត់បានចុះចតនៅអាកាសយានដ្ឋានអន្តរជាតិ OR Tambo នៅរសៀលថ្ងៃពុធ។ Fongo បាននិយាយទៅកាន់សមាជិកគ្រួសារ និងសមាជិកសហគមន៍ដែលទទួលស្វាគមន៍គាត់នៅអាកាសយានដ្ឋានដោយពោរពេញដោយក្ដីរំភើបក្រៃលែង។"ខ្ញុំចង់អរគុណអ្នកគ្រប់គ្នា។ ខ្ញុំសប្បាយចិត្តនឹងក្ដីស្រលាញ់ និងការគាំទ្រដែលអ្នកបានបង្ហាញខ្ញុំ។ មានថ្ងៃមួយដែលខ្ញុំគិតថា ខ្ញុំមិនអាចត្រលប់មកផ្ទះវិញទេ។

គាត់បាននិយាយថា៖ «ពេលខ្លះខ្ញុំយំម្នាក់ឯង ហើយអធិស្ឋានដល់ព្រះអង្គឲ្យលោកបើកផ្លូវឲ្យខ្ញុំត្រឡប់មកផ្ទះវិញ»។ Fongo បានចាកចេញពីអាហ្វ្រិកខាងត្បូង កាលពីខែវិច្ឆិកាឆ្នាំមុន បន្ទាប់ពីទទួលបានអ៊ីមែលពីបុរសម្នាក់ដែលប្រាប់អត្តសញ្ញាណថាឈ្មោះ John Thomas ដោយអះអាងថាជាអ្នកជ្រើសរើសបុគ្គលិកសម្រាប់ក្រុមហ៊ុន Huilong Technology ដែលជាក្រុមហ៊ុនទីផ្សារចិនដែលសន្មត់ថាមានមូលដ្ឋាននៅក្នុងប្រទេសថៃ។ គាត់ត្រូវបានផ្ដល់ការងារជាអ្នកឯកទេសពិនិត្យអតិថិជននៅប្រទេសថៃ។ អ្នកបោកប្រាស់នោះ បានផ្ដល់ការងារដល់គាត់ដោយអះអាងថាបានឃើញប្រវត្តិរូបរបស់គាត់នៅលើ Pnet ។ នៅពេលដែល Fongo មកដល់ប្រទេសថៃ ទើបគាត់ដឹងថាមានអ្វីមួយខុសប្រក្រតី។ គាត់ត្រូវបានគេនាំទៅប្រទេសមីយ៉ាន់ម៉ាដោយខុសច្បាប់ ហើយនៅពេលដែលគាត់ទៅដល់ទីនោះ គាត់បាននិយាយថាគាត់ត្រូវបានគេបង្ខំឱ្យធ្វើការនៅក្នុងគម្រោងបោកប្រាស់ដែលពាក់ព័ន្ធនឹងការតម្រង់គោលដៅមនុស្សមានទ្រព្យសម្បត្តិនៅសហរដ្ឋអាមេរិក។ គាត់បានចាកចេញពីប្រទេសមីយ៉ាន់ម៉ា បន្ទាប់ពីទទួលបានការងារមួយផ្សេងទៀតនៅកម្ពុជា ហើយវាក៏ក្លាយជាការបោកប្រាស់មួយទៀត។

Neo Tsoai សមាជិកសហគមន៍ដែលទទួលខុសត្រូវលើគំនិតផ្ដួចផ្ដើមរៃអង្គាសថវិកាសម្រាប់ការត្រឡប់មកវិញប្រកបដោយសុវត្ថិភាពរបស់ Fongo បាននិយាយថាគាត់ដឹងគុណចំពោះការគាំទ្រដែលពួកគេទទួលបានពីសាធារណៈជន។ Tsoai បាននិយាយថាពួកគេរៃអង្គាសប្រាក់បានជាង ៤០,០០០រ៉ង់ (40,000R) ក្នុងមួយសប្ដាហ៍។ "តំបន់ ANC Lejweleputswa ដឹកនាំដោយប្រធាន Xolile Toki បានសន្យាផ្ដល់២០,០០០រ៉ង់ (20, 000 R) ដើម្បីជួយឱ្យបានធាប់គ្រប់។ "លុយនោះគឺសម្រាប់ទិញសំបុត្រយន្តហោះរបស់គាត់ ហើយយើងក៏ត្រូវចំណាយលើការស្នាក់នៅលើសរបស់គាត់ផងដែរ ពីព្រោះទិដ្ឋាការរបស់គាត់ផុតកំណត់តាំងពីខែមីនា។ យើងក៏ត្រូវចំណាយលើការចំណាយផ្សេងទៀតរួមទាំងគយនៅប្រទេសថៃផងដែរ»។ បន្ទាប់ពីជាប់គាំងនៅអាស៊ីបូព៌ាអស់រយៈពេល៧ខែ Xolani Fongo ដែលជាប់គាំងក្នុងប្រទេសកម្ពុជាបន្ទាប់ពីចាកចេញពីអាហ្វ្រិកខាងត្បូង ពេលទទួល

បានការផ្តល់ការងារនៅក្នុងប្រទេសថៃដែលប្រែទៅជាការបោកប្រាស់នោះទីបំផុតបានជួបជុំគ្រួសាររបស់គាត់វិញ។

Tsoai បានបន្ថែមថា នេះនឹងមិនអាចទៅរួចនោះទេ បើគ្មានការអន្តរាគមន៍ពីសាធារណៈជន។ គាត់បាននិយាយថា "យើងសូមអរគុណចំពោះទឹកចិត្តសប្បុរសដែលបានឱ្យ Xolani អាចត្រលប់មកវិញ... អ្នកមិនអាចឈ្នះតែម្នាក់ឯងបានទេ ក្នុងជីវិត អ្នកមិនអាចឈ្នះតែម្នាក់ឯង អ្នកត្រូវការព្រះ ហើយអ្នកត្រូវការមនុស្ស។ Tsoai បាននិយាយថាសមត្ថភាពដែលនៅសល់នឹងយកទៅជួយគ្រួសាររបស់ Fongo ។"នេះបានជួយផ្គត់ផ្គង់ជីវភាពរបស់ពួកគេ និងបិទគម្លាត និងលាងជម្រះទុក្ខវេទនា"។ ទន្ទឹមនឹងនេះ គ្រួសាររបស់ Fongo បានស្នើសុំឯកជនភាព ហើយបាននិយាយថា គាត់នៅតែមានការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរចំពោះរឿងសោកសៅនេះ នឹងត្រូវការការប្រឹក្សាផ្លូវចិត្ត។ lol.co.za

# ថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ២០២៣

## រាជរដ្ឋាភិបាលថៃ និងកម្ពុជា

## ព្រមព្រៀងគ្នាសម្រួលការបន្តបណ្ណការងារសម្រាប់ពលករចំណាកស្រុក

https://sbm.news/articles/6497b0098c9050bca6333d8f ដោយ Nary Vann ចុះផ្សាយថ្ងៃ 8/6/2023

ប្រទេសថៃ និងកម្ពុជា បានឈានដល់កិច្ចព្រមព្រៀងមួយ ដើម្បីបង្កើនភាពងាយស្រួលសម្រាប់ពលករកម្ពុជាចំណាកស្រុកជាង៤ម៉ឺននាក់ ដែលស្នើសុំបន្តបណ្ណការងាររបស់ពួកគេ។

លោក ផៃរុច ចុតជីកាសាធីន (Pairoj Chotikasathien) អគ្គនាយកនៃនាយកដ្ឋានការងារថៃ បានឱ្យដឹងថា កិច្ចព្រមព្រៀងនេះត្រូវបានសម្រេចនៅក្នុងកិច្ចប្រជុំរវាងអាជ្ញាធរការងារថៃ និងសមភាគីកម្ពុជា ក្នុងក្តីសង្ឃឹមថានឹងបន្ធូរបន្ថយកង្វះកម្លាំងពលកម្ម។ ពលករចំណាកស្រុកជាច្រើនបានត្រឡប់ទៅប្រទេសកំណើតវិញក្នុងអំឡុងពេលជំងឺរាតត្បាតកូវីដ១៩ ខណៈដែលតម្រូវការសម្រាប់ពលករចំណាកស្រុកបានកើនឡើងយ៉ាងឆាប់រហ័សចាប់តាំងពីជំងឺនេះបានធូរស្រាលវិញ។ ក្រោមអនុស្សរណៈនៃការយោគយល់គ្នា (MoU) នាពេលបច្ចុប្បន្ន ដែលអនុញ្ញាតឱ្យពលករខ្មែរទៅធ្វើការដោយស្របច្បាប់ក្នុងប្រទេសថៃរយៈពេល៤ឆ្នាំ បណ្ណការងារដែលកាន់កាប់ដោយពលករទាំងនេះបានចាប់ផ្តើមផុតកំណត់នៅចន្លោះខែមករាឆ្នាំមុន រហូតដល់ថ្ងៃទី៣១ ខែកក្កដាខាងមុខនេះ។ ដូច្នេះពួកគេត្រូវតែធ្វើបណ្ណការងារ និងឯកសារផ្សេងទៀតពាក់ព័ន្ធផ្សេងទៀតជាថ្មី ដើម្បីត្រឡប់ទៅធ្វើការនៅប្រទេសថៃ ឬបន្តរស់នៅ និងធ្វើការនៅក្នុងប្រទេសថៃ ប្រសិនបើពួកគេនៅតែនៅក្នុងប្រទេសថៃនៅឡើយ។

លោក ផៃរុច បានថ្លែងយ៉ាងដូច្នេះថា៖ «កម្មករកម្ពុជាទាំងនេះនឹងរួចផុតពីលក្ខខណ្ឌទូទៅក្នុងការរង់ចាំរយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃដែលបណ្ណការងាររបស់ពួកគេផុតកំណត់ រហូតដល់ពួកគេត្រូវបានអនុញ្ញាតឱ្យស្នើសុំបណ្ណការងារឡើងវិញ។ ដំណើរការទាំងមូលនៃការស្នើសុំនេះ នឹងត្រូវធ្វើឡើងតាមប្រព័ន្ធអ៊ីនធឺណិត ដើម្បីបង្កើនភាពងាយស្រួលសម្រាប់កម្មករ»។ បន្ថែមលើនោះ ភាគីថៃស្នើឱ្យអាជ្ញាធរការងារកម្ពុជាពន្លឿនឯកសារបញ្ជាក់ព័ត៌មានផ្ទាល់ខ្លួនរបស់កម្មករ។ លោក ផៃរុច បានបន្តថា ករណីនេះទាក់ទងនឹងអ្នកដែលត្រូវបានអនុញ្ញាតឱ្យស្នាក់នៅរហូតដល់ថ្ងៃទី ៣១ ខែកក្កដា តាមសេចក្ដីសម្រេចរបស់គណៈរដ្ឋមន្ត្រីដែលបានអនុម័តកាលពីថ្ងៃទី ៧ ខែកុម្ភៈ ដូច្នេះពួកគេនឹងមិនបាត់បង់ប្រាក់ប្រយោជន៍ជនអន្តោប្រវេសន៍ និងកម្មករ នៅពេលដែលសេចក្ដីសម្រេចនេះផុតកំណត់។ ដោយឡែក ភាគីកម្ពុជាបានស្នើសុំបញ្ចុះតម្លៃទិដ្ឋាការពី ២០០០បាត មកនៅត្រឹម ៥០០បាត ដែលនឹងត្រូវបញ្ជូនទៅកាន់គណៈរដ្ឋមន្ត្រីថ្មី។
កិច្ចព្រមព្រៀងស្រដៀងគ្នានេះក៏ត្រូវបានសម្រេចនៅក្នុងកិច្ចប្រជុំរវាងអាជ្ញាធរការងារថៃ និងសមភាគីមីយ៉ាន់ម៉ាផងដែរ។ ពលករចំណាកស្រុកមីយ៉ាន់ម៉ាក៏នឹងត្រូវបានលើកលែងពីច្បាប់រង់ចាំរយៈពេល៣០ថ្ងៃ ហើយនឹងអាចស្នើសុំឡើងវិញភ្លាមៗសម្រាប់បណ្ណការងារ នៅពេលដែលបណ្ណការងារបច្ចុប្បន្នរបស់ពួកគេជិតផុតកំណត់។ ភាគីមីយ៉ាន់ម៉ាក៏បានស្វែងរកការបញ្ចុះតម្លៃលើថ្លៃទិដ្ឋាការផងដែរ៕

## ឧត្តមសេនីយ៍ឯក ឌី វិជ្ជា ជួបពិភាក្សាការងារជាមួយមន្ត្រីជាន់ខ្ពស់ក្រសួងសន្តិសុខសាធារណៈចិន ពង្រឹងកិច្ចសហប្រតិបត្តិការ ជាពិសេសការងារប្រយុទ្ធប្រឆាំងបទល្មើស

https://freshnewsasia.com/index.php/en/localnews/297125-2023-06-26-08-18-23.html 2023-06-26 03:18pm

**(ភ្នំពេញ)៖** ឧត្តមសេនីយ៍ឯក ឌី វិជ្ជា អគ្គស្នងការរងនគរបាលជាតិ និងជាប្រធាននាយកដ្ឋានកណ្ដាលសន្តិសុខ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣នេះ បានជួបពិភាក្សាការងារជាមួយ លោក NIU Haifeng អគ្គនាយករង ទទួលការងារសហប្រតិបត្តិការអន្តរជាតិ គណៈប្រតិភូក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាមានិតចិន នៅអគ្គស្នងការដ្ឋាននគរបាលជាតិ។

មន្ត្រីនគរបាលជាន់ខ្ពស់ បានប្រាប់អង្គភាពព័ត៌មាន Fresh News ថា គោលបំណង នៃការអញ្ជើញមកបំពេញទស្សនកិច្ចការងាររបស់គណៈប្រតិភូក្រសួងសន្តិសុខចិន នាពេលនេះ គឺអនុវត្តទៅតាមផែនការសហប្រតិបត្តិការ របស់ក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងសន្តិសុខចិន និងដើម្បីធ្វើការពិភាក្សាផ្លាស់ប្ដូរយោបល់បំពេញបន្ថែមលើដំណើរការ នៃកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់

ពិសេសកិច្ចសហការប្រយុទ្ធប្រឆាំងបទល្មើស តាមរយៈការិយាល័យសម្របសម្រួលអនុវត្តច្បាប់ រួមទាំងការជំរុញការសាងសង់អគារទីបញ្ជាការនគរបាលជាតិ។

**មន្ត្រីនគរបាលជាន់ខ្ពស់ កម្ពុជា-ចិន ក៏បានឯកភាពគ្នាលើការងារមួយចំនួនរួមមាន៖**

***ទី១៖** បន្តពង្រឹងអនុវត្តកិច្ចសហការស្របតាមខ្លឹមសារដូចមានចែងក្នុងផែនការក្រសួងទាំងពីរ

***ទី២៖** កោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះលទ្ធផល នៃកិច្ចសហការអនុវត្តច្បាប់ដែលភាគីកម្ពុជា-ចិនសម្រេចបាន និងបានខិតខំរិះរកវិធីសាស្ត្រស្របតាមគោលការណ៍ច្បាប់ និងបទបញ្ញត្តិនៃប្រទេសនីមួយៗ ដើម្បីដោះស្រាយ រាល់បញ្ហាប្រឈមដែលកើតឡើងក្នុងអំឡុងពេលប្រតិបត្តិការ

***ទី៣៖** ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងបទល្មើស តាមរយៈយន្តការការិយាល័យសម្របសម្រួល ភាគីទាំងពីរឯកភាពប្រកាន់ខ្ជាប់នូវស្មារតីលើកកម្ពស់កិច្ចសហប្រតិបត្តិការ ការផ្លាស់ប្តូរព័ត៌មានទាន់ពេល និងការគោរពអធិបតេយ្យភាពគ្នា ដូចមានកំណត់ក្នុងខ្លឹមសារនៃ MoU និងផែនការសហប្រតិបត្តិការក្រសួងទាំងពីរ។ ដើម្បីបង្កើនប្រសិទ្ធភាពលើកិច្ចការនេះ ភាគីទាំងពីរពិនិត្យលទ្ធភាពបង្កើតជា SOP រួមគ្នាមួយ ដែលជាផែនទីបង្ហាញផ្លូវក្នុងការចាត់តាំងកិច្ចប្រតិបត្តិការ។

***ទី៤៖** គាំទ្រចំពោះគំនិតផ្តួចផ្តើមសម្រាប់បើកវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលា ដើម្បីកសាងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ បម្រើឲ្យកិច្ចប្រតិបត្តិការរវាងភាគីទាំងពីរ។ ភាគីចិនបានបញ្ជាក់អំពីការខិតខំដោះស្រាយសំណូមពរកម្ពុជា ពាក់ព័ន្ធ និងការគាំទ្រជាមធ្យោបាយ ឧបករណ៍សម្ភារបច្ចេកទេស បម្រើឲ្យកិច្ចប្រតិបត្តិការរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់ ទៅតាមដំណាក់កាល និងស្ថានភាពជាក់ស្តែង។

***ទី៥៖** គាំទ្រឲ្យក្រុមជំនាញបច្ចេកទេសរបស់ភាគីទាំងពីរ ជួបពិភាក្សាគ្នាឲ្យបានញឹកញាប់ពាក់ព័ន្ធនឹងគម្រោងសាងសង់ទីបញ្ជាការនគរបាលជាតិដើម្បីជំរុញដំណើរការសាងសង់ឲ្យបានឆាប់រហ័ស៕

## ថៃចាត់វិធានការក្តៅ គ្មានយោគយល់ទេ! ចុះចាប់ជនចំណាកស្រុក ភូមា ខ្មែរ ឡាវ វៀតណាម ដែលមករកស៊ីលក់ដូរសូម្បីតាមរទេះ ដោយចោទថា ដណ្តើម មុខរបរជនជាតិខ្លួន

https://cen.com.kh/archives/672121.html Posted ByLeng KhunJune 26, 2023

ពិតជាមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង នៅពេលដែលបានឃើញមន្ត្រីអន្តោប្រវេសន៍ថៃ បានចាត់វិធានការក្តៅគគុក ចុះចាប់ និងបិទហាងរកស៊ី រួមទាំងការលក់ដូររកំប៉ិចកំប៉ុក នៅតាមដងផ្លូវ ពីសំណាក់ជនចំណាកស្រុកជិតខាង ក្រោយមន្ត្រីទាំងនោះ បានរកឃើញតាមរយៈការចែករំលែកនៅលើបណ្តាញសង្គម។ នេះបើយោងតាមប្រភពពីសារព័ត៌មាន khaosod បានចុះផ្សាយនៅឲ្យដឹងថា នៅពាក់កណ្តាលយប់ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣ ក្រុមមន្ត្រីអន្តោប្រវេសន៍ថៃ ដែលទទួលបន្ទុកតំបន់បាងកក បានចុះបោសសម្អាតជនបរទេសដែលល្មើសនឹងច្បាប់ស្តីពីអន្តោប្រវេសន៍ និងច្បាប់ស្តី

ពីជនបរទេសរស់នៅក្នុងប្រទេសណាមួយ បានធ្វើការយ៉ាងក្ដៅគគុក នៅតំបន់គោលដៅផ្លូវដើរជុំវិញ Sukhumvit រហូតដល់ Asoke។ ជាលទ្ធផល ជនជាតិមីយ៉ាន់ម៉ាចំនួន ៩ នាក់ ជនជាតិខ្មែរ ២ នាក់ ជនជាតិឡាវម្នាក់ ជនជាតិវៀតណាមម្នាក់ និងជនមិនបានចុះបញ្ជីម្នាក់ ត្រូវបានចាប់ខ្លួន ដោយចោទប្រកាន់ពីបទទទួលជនបរទេស ចូលធ្វើការដោយគ្មានការអនុញ្ញាត។ ចំណែកមនុស្ស២ នាក់ទៀតត្រូវបានអនុញ្ញាត សរុបទាំងអស់ ១៦ នាក់។

លោកឧត្ដមសេនីយឯក គី យ៉ាណាន់ បានថ្លែងឲ្យដឹងថា បន្ទាប់ពីបណ្ដាញសង្គមបានចុះផ្សាយអំពីជនបរទេសរត់ពន្ធទំនិញ រួមទាំងការបើកតូបលក់ដូរម្ហូបអាហារ និងភេសជ្ជៈ មកលួច « ដង្ហើម» មុខរបររបស់ជនជាតិថៃ ជាពិសេសនៅក្នុងសង្កាត់ពាណិជ្ជកម្មដ៏សំខាន់នោះ កម្លាំងអន្តោប្រវេសន៍១បានចល័តកម្លាំង ដោយបានចុះទៅចាប់ជនបរទេសទាំងនោះ ខណៈពួកគេកំពុងដើរលក់អាហារ និងសម្លៀកបំពាក់ ដោយប្រើរទេះចល័ត និងតូបបណ្ដោះអាសន្ន ខ្លះឃើញមន្ត្រីរត់គេចខ្លួនបាត់ បន្សល់ទុកសម្ភារជួញដូរ។ លោក គី យ៉ាណាន់ បានបញ្ជាក់បន្ថែមថា ក្នុងចំណោមអ្នកដែលត្រូវបានចាប់ខ្លួនមួយចំនួន មិនអាចបង្ហាញឯកសារលិខិតឆ្លងដែន និងលិខិតអនុញ្ញាតការងារជូនអធិការបានទេ។ អ្នកខ្លះមានលិខិតឆ្លងដែន ប៉ុន្តែការអនុញ្ញាតរបស់ពួកគេបានផុតកំណត់ហើយ ឬត្រូវបានផ្ដល់ការលើកលែងទិដ្ឋាការក្នុងការធ្វើដំណើរក្នុងគោលបំណងទេសចរណ៍។ រក្សាសិទ្ធិដោយ៖ លឹម ហុង

## ថៃយល់ព្រមបន្តសុពលភាពលិខិតអនុញ្ញាតការងារសម្រាប់ពលករកម្ពុជាជិត ៤ 0000នាក់

https://www.khmertimeskh.com/501314795/ Manoj Mathew / Khmer Times June 27, 2023

ប្រទេសថៃ បានយល់ព្រមបន្តសុពលភាពលើលិខិតអនុញ្ញាតការងារ ដល់ពលករចំណាកស្រុកខ្មែរជិត៤ម៉ឺននាក់ ដោយនាំឲ្យមានក្ដីសង្ឃឹមដល់គ្រួសាររបស់ពួកគេ។

យោងតាមសារព័ត៌មានថៃ មន្ត្រីនាយកដ្ឋានការងារ នៃប្រទេសទាំងពីរបានព្រមព្រៀងដើម្បីជួយសម្រួលបន្តប័ណ្ណការងាររបស់ពលករចំណាកស្រុក។ ពលករនឹងទទួលបានការអនុញ្ញាតឱ្យដាក់ពាក្យសុំបន្តតាមអុ៊ីនធឺណិត ដើម្បីធ្វើឱ្យដំណើរការកាន់តែលឿន និងមិនមានការរំខាន។ ដកស្រង់សម្ដីលោក Pairoj Chotikasathien អគ្គនាយកនៃនាយកដ្ឋានការងារថៃ ពីកាសែតបាងកកប៉ុស្តិ៍ មានប្រសាសន៍ថា ពលករនឹងត្រូវបានលើកលែងពីតម្រូវការធម្មតានៃការរង់ចាំយ៉ាងតិច ៣0 ថ្ងៃ បន្ទាប់ពីការផុតកំណត់នៃការអនុញ្ញាតការងារសម្រាប់ការដាក់ពាក្យសុំបន្ត។

យោងតាមរបាយការណ៍ ប័ណ្ណការងារទាំងនេះតាម កិច្ចព្រមព្រៀង MoU បច្ចុប្បន្នសម្រាប់រយៈពេល ៤ឆ្នាំនឹងផុតកំណត់នៅចន្លោះខែមករាឆ្នាំមុនដល់ថ្ងៃទី ៣១ ខែកក្កដា។ កិច្ចព្រមព្រៀងថ្មី

រវាងប្រទេសទាំងពីរនឹងជួយដល់ពលករដែលនៅបន្តការងារនៅក្នុងប្រទេសថៃ ដើម្បីបន្តនៅក្នុងប្រទេស ហើយអ្នកដែលត្រឡប់មកកម្ពុជាវិញឥឡូវអាចត្រឡប់ទៅវិញបាន។ យោងតាមរបាយការណ៍ក្រសួងការងារបានឲ្យដឹងថា មានពលករសរុបចំនួន ១,៣ លាននាក់ចាកចេញពីកម្ពុជាទៅធ្វើការនៅក្រៅប្រទេស ក្នុងនោះ ១,២ លាននាក់ ធ្វើការនៅប្រទេសថៃ អាចរកប្រាក់ចំណូលជាមធ្យម ៤០០ដុល្លារក្នុងមួយខែ។ ក្នុងនោះផងដែរ មានពលករកម្ពុជាចំនួន៤៩,០០០នាក់ធ្វើការនៅកូរ៉េខាងត្បូង ២២,០០០នាក់នៅម៉ាឡេស៊ី និង ១៩,០០០ នាក់នៅជប៉ុន។ ពលករទាំងនោះអាចរកប្រាក់ចំណូលជាមធ្យម ១,៥០០ ដុល្លារនៅកូរ៉េ ប្រហែល ១,៤០០ដុល្លារនៅជប៉ុន និង ប្រហែល ៣០០ ដុល្លារនៅប្រទេសម៉ាឡេស៊ីផងដែរ។

រដ្ឋមន្ត្រីក្រសួងការងារ លោក អ៊ិត សំហេង មានប្រសាសន៍កាលពីពេលថ្មីៗនេះថា ពលករកម្ពុជាផ្ញើប្រាក់មកស្រុកកំណើតជិត ២,៧ ពាន់លានដុល្លារក្នុងមួយឆ្នាំ ដែលជាសញ្ញាចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ៕ ប្រែសម្រួលដោយៈ សុ ជាតា

## **អ្នកឃ្លាំមើលរិះគន់ថា កម្ពុជាកំពុងក្លាយជាកន្លែងឧក្រិដ្ឋជនប្រតិបត្តិការឆបោកតាមប្រព័ន្ធអ៊ីនធឺណិត**

https://www.rfa.org/khmer/news/social-economy/police-crack-down-chineses-networks-for-hacking-many-telegrams-to-defraud-06252023090112.html ដោយ សេក បណ្ឌិត2023.06.25

អ្នកវិភាគនយោបាយ និងអ្នកជំនាញផ្នែកសន្តិសុខឌីជីថល (Digital) ព្រួយបារម្ភចំពោះការកើនឡើងនៃក្រុមចោរព័ត៌មានវិទ្យា ឬហេកគ័រ (Hackers) លួចយកទិន្នន័យនៅតាមបណ្ដាញសង្គមនានារបស់ប្រជាពលរដ្ឋប្រព្រឹត្តទង្វើទុច្ចរិត និងឆបោកទឹកប្រាក់តាមប្រព័ន្ធអ៊ីនធឺណិត(Internet)។ ក្ដីបារម្ភរបស់មន្ត្រីសង្គមស៊ីវិល និងអ្នកជំនាញបែបនេះ ធ្វើឡើងបន្ទាប់ពីកម្លាំងកងរាជអាវុធហត្ថរាជធានីភ្នំពេញបង្ក្រាបបានក្រុមចោរព័ត៌មានវិទ្យាចិន ៤នាក់ និងខ្មែរម្នាក់ដែលតែងតែលួចចូលគណនីតេឡេក្រាម (Telegram) ជនរងគ្រោះដើម្បីឆបោកប្រាក់។

អ្នកជំនាញសន្តិសុខផ្នែកឌីជីថល ព្រមានចំពោះអ្នកប្រើប្រាស់ប្រព័ន្ធបណ្ដាញសង្គម ជាពិសេសលើកម្មវិធីតេឡេក្រាម ឱ្យប្រុងប្រយ័ត្នខ្ពស់ចំពោះជនខិលខូច ដែលព្យាយាមលួចយកគណនីតេឡេក្រាម។ អ្នកប្រឹក្សាផ្នែកសន្តិសុខឌីជីថល លោក ង៉ែត ម៉ូសេ លើកឡើងនៅក្នុងទំព័រហ្វេសប៊ុករបស់លោកថា អ្នកប្រើប្រាស់កម្មវិធីតេឡេក្រាមពុំគួររក្សាឯកសារ ឬទិន្នន័យសំខាន់ៗក្នុងកម្មវិធីមួយនេះឡើយ។ លោកបន្តថា អ្នកប្រើប្រាស់បណ្ដាញសង្គមមួយនេះគួរបង្កើនការប្រុងប្រយ័ត្នខ្ពស់ នៅពេលមានការទាមទារលេខកូដសម្ងាត់ពីជនណាម្នាក់ដើម្បីចូលកម្មវិធីមួយនេះ។ លោក ង៉ែត ម៉ូសេ

៖ «ដោយសារតែការលួចហ្នឹងគេត្រូវការលេខកូដទេ លេខកូដ ៤-៥ ខ្ទង់ហ្នឹង ដែលគេផ្ញើទៅតេឡេក្រាម។ អ៊ីចឹង ប្រសិនបើយើងអត់ឱ្យលេខកូដហ្នឹងទៅឱ្យគេទេ មានន័យថា យើងអាចរួចខ្លួន។ ខ្លះគេឱ្យទៅគេមាន (two Factor) បើកវាពិបាកយក។ អ៊ីចឹងបើទោះបីជាយើងដឹងថា វិធីសាស្ត្រគេលួចហ្នឹង យើងកុំឱ្យលេខតេឡេក្រាម ៥ខ្ទង់ផ្ញើមកហ្នឹង កុំថតអេក្រង់ (screenshot) ឬមានការខលមកយើង ដើម្បីឱ្យលេខកូដទៅមនុស្សមួយចំនួនបញ្ឆោត ដើម្បីឱ្យបានលេខកូដអីហ្នឹង ហើយយើងអត់ឱ្យលេខកូដទៅវិញហ្នឹង ទោះបីយើងអត់មាន (two Factor) ក្តីក៏គេពិបាកនឹងយកដែរ។ [ជនឆបោក] ងាយស្រួល បើសិនជាគាត់ [ជនរងគ្រោះ] យល់ច្រឡំថា ជនឆបោកជាមិត្តភក្តិមែនឱ្យលេខកូដ អាហ្នឹងគឺស្រួលយកបានហើយ។ អ៊ីចឹងអាស្រ័យលក្ខខណ្ឌខ្ញុំបាននិយាយមិញ»។

ចំណែក អ្នកវិភាគនយោបាយ លោក គឹម សុខ លើកឡើងថា មិនមែនតែសន្តិសុខផ្នែកឌីជីថលរបស់ប្រជាពលរដ្ឋកំពុងរងការវាយប្រហារពីក្រុមចោរព័ត៌មានវិទ្យាចិននោះតែ ប៉ុន្តែសន្តិសុខជាតិ ឬទិន្នន័យនានារបស់រដ្ឋាភិបាលឯកបក្សខ្លួនឯងក៏អាចនឹងត្រូវងាយប្រឈមក្រុមហ៊ុនចិនមួយចំនួនគ្រប់គ្រងដែរ ខណៈកន្លងទៅកម្ពុជាបានចុះកិច្ចពង្រឹងកិច្ចសហប្រតិបត្តិផ្នែកវិស័យឌីជីថលជាមួយក្រុមហ៊ុនចិនស្អិតល្មួត។ លោកថា ក្រុមអ្នកជំនាញសន្តិសុខផ្នែកឌីជីថលក្រោមការដឹកនាំដោយលោក ហ៊ុន សែន ពុំមានសមត្ថភាពដល់ក្រុមអ្នកជំនាញសន្តិសុខផ្នែកឌីជីថលចិនដែលមកពង្រីកវិសាលភាពនៅកម្ពុជាឡើយ។

លោក គឹម សុខ៖ «សន្តិសុខជាតិខ្មែរយើងស្ថិតក្នុងកណ្តាប់ដៃក្រុមហ៊ុនចិន និងបណ្តាញវៀតណាមតែម្តង។ វៀតណាមគ្រប់គ្រងប្រព័ន្ធគមនាគមន៍ អាកាសចរណ៍ ក្រុមហ៊ុនទូរស័ព្ទ និងផ្នែកសំខាន់នៃក្រសួងការពារជាតិ ក្រសួងមហាផ្ទៃនៃរដ្ឋាភិបាលកម្ពុជា ដែលវៀតណាមហ្នឹងគេបង្កប់មនុស្សរបស់គេតាំងពីឆ្នាំ១៩៧៩ មកចេះទាំងខ្មែរច្បាស់ទៀតផង។ ចិនវិញមែនទែនទៅស្ទើរតែមិនចាំបាច់ទៅហែកចូលប្រព័ន្ធទិន្នន័យរបស់រដ្ឋាភិបាលលោក ហ៊ុន សែន ផង។ ប្រព័ន្ធទិន្នន័យរបស់រដ្ឋាភិបាលលោក ហ៊ុន សែន គ្រប់គ្រងដោយក្រុមហ៊ុនចិនតែម្តង។ ហេតុដូច្នេះ ប្រព័ន្ធសន្តិសុខជាតិរបស់យើងស្ថិតក្នុងគ្រោះថ្នាក់ធំណាស់»។

ប្រតិកម្មរបស់អ្នកជំនាញ និងអ្នកវិភាគនេះធ្វើឡើងបន្ទាប់ពីកងកម្លាំងរាជអាវុធហត្ថរាជធានីភ្នំពេញកាលពីថ្ងៃទី១៩ ខែមិថុនា បង្ក្រាបបានជនសង្ស័យជនជាតិចិនចំនួន ៤នាក់ និងខ្មែរម្នាក់ពាក់ព័ន្ធសកម្មភាពលួចចូលទិន្នន័យបណ្តាញសង្គម ឬហែកចូលកម្មវិធីតេឡេក្រាមមនុស្សជាច្រើន ដើម្បីប្រើប្រាស់បន្តឆបោកប្រាក់។

ទាក់ទងនឹងរឿងនេះ អ្នកនាំពាក្យកងរាជអាវុធហត្ថលើផ្ទៃប្រទេស លោក អេង ហ៊ី ប្រាប់វិទ្យុអាស៊ីសេរីយ៉ាងខ្លីថា ជនសង្ស័យទាំង ៥នាក់អាវុធហត្ថរាជធានីភ្នំពេញបានកសាងសំណុំរឿងបញ្ជូន

ទៅតុលាការហើយ ប៉ុន្តែលោកថា មិនទាន់ទទួលរបាយការណ៍នៃការសម្រេចរបស់អយ្យការសម្រេចចោទប្រកាន់លើជនសង្ស័យទាំងនោះបែបណានោះទេ។ លោក អេង ហ៊ុះ «គាត់ [តំណាងអយ្យការ] ធ្វើក្នុងនីតិវិធីខ្ញុំទាន់ដឹងថា ដល់ណាៗទេ គ្រាន់ថា ឯកសារយើងធ្វើទៅតាមនីតិវិធីហើយបាទ រឿងការស៊ើបអង្កេតគេអត់មានរាយការណ៍មកទេ។ ពេលបង្ក្រាបហើយអ៊ីចឹងខាងកងកម្លាំងរាជអាវុធហត្ថអំពាវនាវឱ្យសាធារណជនអំពីការបោកអំពាវនាវឱ្យប្រជាជនយើងហ្នឹងប្រុងប្រយ័ត្នទៅពេលទទួលបានពីសារមួយទៅសារមួយសូមឱ្យប្រុងប្រយ័ត្នមែនទែន»។

ទំព័រហ្វេសប៊ុកកងកម្លាំងរាជអាវុធហត្ថរាជធានីភ្នំពេញបញ្ជាក់ថា នារយៈពេលចុងក្រោយនេះ ករណីក្រុមចោរព័ត៌មានវិទ្យា ឬហែកគ័របានលួចចូលកម្មវិធីតេលេក្រាម ដែលធ្វើឱ្យជនរងគ្រោះជាច្រើននាក់ បានចាញ់បោកបញ្ឆោតក្រុមហែកគ័ររាប់ម៉ឺនដុល្លារ។ ប្រភពដដែលឱ្យដឹងថា ទម្រង់ឆបោកទឹកប្រាក់របស់ក្រុមចោរព័ត៌មានវិទ្យាទាំងនោះ គឺនៅពេលពួកគេបានលួចចូលកម្មវិធីតេឡេក្រាមជនរងគ្រោះណាម្នាក់គ្រប់គ្រងនៅក្នុងដៃ ពួកគេប្រើប្រាស់គណនីបណ្តាញតេឡេក្រាមនោះដើម្បីបន្តឆាតសុំខ្ចីលុយមិត្តភក្តិ សាច់ញាតិ និងបងប្អូនជនរងគ្រោះ។

អាវុធហត្ថរាជធានីភ្នំពេញអំពាវនាវ ដល់ប្រជាពលរដ្ឋមិនត្រូវចូលមើលតំណលីង (Link) ឬ App ណាមួយគ្មានច្បាស់លាស់ ដែលបានផ្ញើចូលតាមរយៈកម្មវិធី SMS WhatsApp Telegram Line ឬ Messenger ដើម្បីចៀសវាងអំពីការទាមទារឱ្យបង្ហាញទិន្នន័យបណ្តាញសង្គមផ្ទាល់ខ្លួន ឬភ្ជាប់ទិន្នន័យធនាគារតាមរយៈតំណលីងគ្មានប្រភពច្បាស់លាស់នោះ ដែលអាចតម្រូវឱ្យមានការទូទាត់ប្រាក់ភ្លាមៗ។

អ្នកវិភាគនយោបាយលោក គឹម សុខ ពិនិត្យឃើញថា ការបង្ក្រាបបានក្រុមព័ត៌មានវិទ្យា ឬហែកគ័រទាំង ៩នាក់នោះ អាចជាក្រុមមនុស្សដែលមានទំនាក់ទំនងជាមួយមនុស្សដែលមានឥទ្ធិពលក្នុងជួរគណបក្សប្រជាជនកម្ពុជា ដើម្បីប្រើជំនាញបែបទំនើបកេងប្រវ័ញ្ចកម្លាំងញើសឈាមប្រជាពលរដ្ឋខ្មែរ។

ពាក់ព័ន្ធនឹងក្រុមចោរព័ត៌មានវិទ្យានេះដែរ កាលពីខែឧសភា ឆ្នាំ២០២០ ក្រសួងយុត្តិធម៌អាមេរិកបានរកឃើញចោរព័ត៌មានវិទ្យា ឬហែកគ័រ ជនជាតិចិន ៤នាក់ បានលួចយកទិន្នន័យពាក់ព័ន្ធនឹងយកទិន្នន័យទន្លេមេគង្គពីក្រសួងការបរទេសកម្ពុជា នៅមុនកិច្ចប្រជុំកំពូលមេគង្គ-ឡានឆាង កាលពីដើមឆ្នាំ២០១៨។ ប៉ុន្តែ ស្ថានទូតចិនបដិសេធជុំវិញរឿងនេះ។ ក្រៅពីនេះ ការស៊ើបអង្កេតផ្ទៃក្នុងមួយរបស់ក្រុមហ៊ុនហ្វេសប៊ុក (Facebook) កាលពីខែមេសា ឆ្នាំ២០២១ រកឃើញថា ក្រុមចោរព័ត៌មានវិទ្យា ឬហែកគ័រដែលសង្ស័យជារួមថា ជាប់ពាក់ព័ន្ធជាមួយភ្នាក់ងារស៊ើបការណ៍សម្ងាត់របស់រដ្ឋចិនបានធ្វើការវាយប្រហារ «ជាប្រចាំ» និង «យូរអង្វែង» ទៅលើក្រុមមន្ត្រីនៃគណបក្សសង្គ្រោះជាតិ៕

# ថ្ងៃទី២៨ ខែ មិថុនា ឆ្នាំ២០២៣

## អាជ្ញាធរហ្វីលីពីន ឃាត់ខ្លួនមនុស្សជាង ២,៧០០នាក់ដែលចម្រុះជាតិសាសន៍ ក្នុងការវាយឆ្មក់បង្ក្រាបបទឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត និងការជួញដូរមនុស្ស

https://freshnewsasia.com/index.php/en/internationalnews/297321-2023-06-27-14-25-57.html

2023-06-27 09:25pm

**(ម៉ានីល)៖** អាជ្ញាធរហ្វីលីពីនបាឃាត់ខ្លួនមនុស្សជាង ២,៧០០នាក់ កំលុងពេលវាយឆ្មក់លើអគារជាច្រើនក្នុងទីក្រុងម៉ានីល ជាកន្លែងដែលជនរងគ្រោះនៃការជួញដូរ ត្រូវបានបោកបញ្ឆោតឱ្យធ្វើការឱ្យគេហទំព័រហ្គេមអនឡាញក្លែងក្លាយ និងក្រុមឧក្រិដ្ឋកម្មតាមអ៊ីនធឺណិតផ្សេងទៀត។ នេះបើយោងតាមការចេញផ្សាយដោយ ទីភ្នាក់ងារសារព័ត៌មាន AFP នៅថ្ងៃអង្គារ ទី២៧ ខែមិថុនា ឆ្នាំ ២០២៣។

ជនជាតិចិន ឥណ្ឌូណេស៊ី វៀតណាម សិង្ហបុរី ម៉ាឡេស៊ី ប៉ាគីស្ថាន កាមេរូន ស៊ូដង់ មីយ៉ាន់ម៉ា និងហ្វីលីពីន ស្ថិតក្នុងចំណោមមនុស្ស ដែលត្រូវបានរកឃើញនៅខាងក្នុងបរិវេណមួយក្នុងរដ្ឋធានីហ្វីលីពីនកាលពីយប់ថ្ងៃចន្ទ។

លោកស្រី Michelle Sabino អ្នកនាំពាក្យរបស់អង្គភាពប្រឆាំងឧក្រិដ្ឋកម្មតាមអ៊ីនធឺណិតបាននិយាយថា អាជ្ញាធរកំពុងសួរចម្លើយអ្នកជាប់ឃុំចំនួន ២,៧២៤នាក់ ដើម្បីកំណត់ថានរណាជាជនរងគ្រោះ ហើយនរណាជាជនសង្ស័យ។ក្នុងចំណោមពួកគេមានជាង ១,៥០០នាក់ជាជនជាតិហ្វីលីពីន។ ការព្រួយបារម្ភជាអន្តរជាតិបាន និងកំពុងកើនឡើង ជុំវិញការបោកបញ្ឆោតតាមអ៊ីនធឺណិតនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលជារឿយៗជនរងគ្រោះនៃការជួញដូរ ដែលត្រូវបានបោកបញ្ឆោត ឬបង្ខិតបង្ខំឱ្យលើកកម្ពស់ការវិនិយោគគ្រីបតូក្លែងក្លាយ។ លោកស្រី Sabino បាននិយាយថា ជនរងគ្រោះបានទទួលយកការងារដែលបានបង្ហោះនៅលើហ្វេសប៊ុក ដើម្បីធ្វើការនៅក្នុងប្រទេសហ្វីលីពីន «ដើម្បីស្វែងរកអ្នកលេង» សម្រាប់ហ្គេមអនឡាញ៕

# កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆមាសទី១
# ឆ្នាំ២០២៣ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស !

https://www.information.gov.kh/articles/108066 *ចេញផ្សាយ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០២៣*

*សៀមរាប៖ គ ខ ប ជ ខេត្តសៀមរាប នៅរសៀលថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣នេះ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប គ ខ ប ជ បានរៀបចំកិច្ចជុំប្រចាំឆមាសទី១ ក្រោមអធិបតីភាព លោកស្រី យូ សុភា អភិបាលរងខេត្ត ជាប្រធានលេខាធិការដ្ឋាន គ ខ ប ជ តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការ គ ខ ប ជ ព្រមទាំងមានការអញ្ជើញចូលរួមពីតំណាងមន្ទីរ អង្គភាព រដ្ឋបាលក្រុង ស្រុក និងអង្គការដៃគូជាតិ អន្តរជាតិ សរុប ៩៩នាក់ បានអញ្ជើញចូលរួម។*

*លោកស្រី យូ សុភា អភិបាលរងខេត្ត ជាប្រធានលេខាធិការដ្ឋាន គ ខ ប ជ មានប្រសាសន៍ក្នុងកិច្ចប្រជុំបានពិនិត្យនិងពិភាក្សាតាមរបៀបវារៈរួមមាន៖*

*១. ពិនិត្យលើសេចក្តីរបាយការណ៍លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំឆមាសទី១ ឆ្នាំ២០២៣។*

*២. ពិនិត្យនិងពិភាក្សាលើបញ្ហាប្រឈម ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយបានផ្តោតសំខាន់នៅក្នុងកិច្ចប្រជុំកាលពីខែឧសភា ដោយស្ថាប័នពាក់ព័ន្ធធ្វើបច្ចុប្បន្នភាពដូចជា ករណីជនជាតិចិន ស្នើសុំរៀបអាពាហ៍ពិពាហ៍ ជាមួយស្ត្រីខ្មែរ (នៅឃុំខ្នងភ្នំ ស្រុកស្វាយលើ) ដោយករណីនេះ ជនជាតិចិនបានស្នើសុំបែបបទពីស្ថានទូតរួចហើយ និងបាននឹងកំពុងរៀបចំឯកសារ ដើម្បីស្នើសុំទៅក្រសួងមហាផ្ទៃបន្ត។ ការតាមដានត្រួតពិនិត្យលើស្ត្រីរងគ្រោះដោយករណីរៀបការផ្ទុយពីធម្មៈ ដែលបានធ្វើសមាហរណកម្មត្រឡប់ទៅមូលដ្ឋានវិញ ចំនួន ០២នាក់ នៅស្រុកវ៉ារិន ដោយទទួលបានការគាំទ្រទៅលើរៀនជំនាញវិជ្ជាជីវៈ (ផ្នែកសាឡន) មានការគាំទ្រដោយអង្គការមូលនិធិអេ២១។*

*លោកស្រី បានបន្តទៀតថា កន្លងមកខាងមន្ទីរកិច្ចការនារីខេត្ត ស្នងការនគរបាលខេត្ត និងអង្គការ* APLE *បានធ្វើបច្ចុប្បន្នភាពអំពីករណីដែលសង្ស័យទទួលរងការរំលោភបំពានតាមប្រព័ន្ធអនឡាញ បានធ្វើការចុះប្រឹក្សាយោបល់ផ្នែកផ្លូវចិត្ត និងផ្នែកច្បាប់ជូនកុមារីជាអនីតិជន ដែលមានទំនាក់ទំនងជាមួយជនបរទេស ហើយមានការរំលោភបំពានតាមអនឡាញ។ ចំពោះលេខាធិការដ្ឋាន គ.ខ.ប.ជ រដ្ឋបាលស្រុកពួក ស្នងការនគរបាលខេត្ត និងអង្គការ* A21 *យើងបានធ្វើបច្ចុប្បន្នភាពលើករណីអតីតពលករនៅភូមិព្រៃជ្រូក ឃុំកែវពណ៌ ស្រុកពួក ដោយបានធ្វើការចុះប្រឹក្សាយោបល់ និងធ្វើសម្ភាសន៍ ដើម្បីកំណត់អត្តសញ្ញាណ ព្រមទាំងបាននាំយកថវិកា និងសម្ភារៈប្រើប្រាស់ គ្រឿង*

ឧបភោគបរិភោគមួយចំនួន របស់លេខាធិការដ្ឋាន គ.ខ.ប.ជ រដ្ឋបាលស្រុកពួក និងអង្គការមូលនិធិ អេ២១ ជូនពួកគាត់ផងដែរ។

បន្ថែមពីនោះ អង្គប្រជុំក៏បានលើកឡើងអំពីបញ្ហាប្រឈមថ្មីមួយចំនួន យកមកពិភាក្សារួមមានៈ ករណីក្រុមហ៊ុនឯកជនមួយបានស្នើឱ្យអាជ្ញាធរឃុំ ធ្វើការបញ្ជាក់លម្អិតអំពីទំនាក់ទំនងរវាងប្រជាពលរដ្ឋចំនួន ០៣នាក់ និងអ្នកដែលបានយកទៅចិញ្ចឹម (ជាជាមេគ្រួសាររបស់ពលរដ្ឋទាំង ០៣នាក់ខាងលើ) ដើម្បីនាំយកចេញទៅធ្វើការនៅប្រទេសជប៉ុន។ ករណីខាងលើនេះជំនាញសមត្ថកិច្ចនឹងធ្វើការស្រាវជ្រាវបន្ត ព្រោះវាអាចជាករណីពាក់ព័ន្ធនឹងការជួញដូរកម្លាំងពលកម្ម។

ការជំរុញ និងពង្រឹងទៅលើការចុះអធិការកិច្ច នៅតាមមណ្ឌលថែទាំជំនួស នៅក្នុងខេត្តសៀមរាប និងបានពិភាក្សាទៅលើករណីកុមារអាយុ ២ខែកន្លះ ពុំមានទឹកដោះគោប៉ៅ ដោយសារក្រោយពីសម្រាលរួចម្តាយបានទុកចោលនៅជាមួយឪពុកក្រីក្រ (ឪពុកពុំមានលទ្ធភាពទិញទឹកដោះគោ) ករណីអាជ្ញាធរបានដោះស្រាយជូនមួយចំនួនដែរ ប៉ុន្តែមិនគ្រប់គ្រាន់ ទើបស្នើឱ្យមានការជួយគាំទ្របន្ថែមពីដៃគូ (ករណីនេះ មានការសន្យាជួយគាំទ្របានមួយចំនួន ពីអង្គការមេត្រីអន្តរជាតិ)។

នៅក្នុងកិច្ចប្រជុំនេះផងដែរ ក៏មានការផ្សព្វផ្សាយជូនអំពីវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដោយឥតគិតថ្លៃជូនដល់ពលករ ដែលបានវិលត្រឡប់មកពីធ្វើការនៅក្រៅប្រទេសវិញ ដែលគាំទ្រដោយអង្គការ IOM នៅវិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរខេត្តសៀមរាបជាដើម៕ ដោយៈ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយៈ ធូ កុសល

## ថៃព្រមសម្រួលលក្ខខណ្ឌ
## បន្តសុពលភាពលិខិតអនុញ្ញាតធ្វើការរបស់ពលករចំណាកស្រុកខ្មែរជិត៤ម៉ឺននាក់

https://www.rfi.fr/km/B?ref=tgi ចុះផ្សាយនៅថ្ងៃ៖ 27/06/2023 - 08:00

កម្ពុជានិងថៃ បានសម្រេចកិច្ចព្រមព្រៀងមួយ ដើម្បីសម្រួលលក្ខខណ្ឌស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតឱ្យធ្វើការដល់ពលករចំណាកស្រុកខ្មែរនៅប្រទេសថៃប្រមាណជាង៤ម៉ឺននាក់ ដែលនឹងផុតសុពលភាពកំណត់ នៅថ្ងៃទី៣១ខែកក្កដាខាងមុខនេះ។ តាមការបញ្ជាក់ពីអាជ្ញាធរថៃ កិច្ចព្រមព្រៀងនេះធ្វើឡើងដោយសារតែបច្ចុប្បន្ននេះ ថៃកំពុងខ្វះពលករបម្រើការងារយ៉ាងខ្លាំង។ អង្គការសង្គ្រោះ យល់ថា កិច្ចព្រមព្រៀងថ្មីនេះ នឹងកាន់តែមានប្រសិទ្ធភាពបម្រើប្រយោជន៍ពលករខ្មែរ ប្រសិនបើស្ថានទូតខ្មែរនៅថៃបង្កើនការជួយសម្រួលឯកសារការងារមួយចំនួនឱ្យលឿនជាងពេលបច្ចុប្បន្ន។

តបតាមការស្នើពីកម្ពុជា រដ្ឋាភិបាលថៃបានយល់ព្រមសម្រួលលក្ខខណ្ឌ ស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតធ្វើការដល់ពលករចំណាកស្រុកខ្មែរ ជាង៤ម៉ឺននាក់ដែលកំពុងអស់សុពលភាពនៅចុងខែកក្កដាខាងមុខ។ នេះបើតាមការចុះផ្សាយរបស់កាសែតបាំងកកប៉ុស្តិ៍របស់ថៃកាលពីថ្ងៃទី២៩មិថុនាកន្លងទៅ។

តាមការចុះផ្សាយរបស់បាំងកកប៉ុស្តិ៍ អគ្គនាយកនៃអគ្គនាយកដ្ឋានការងាររបស់ប្រទេសថៃ លោក ផៃរ៉ូច្ន ចុទីកាសាធៀន (Pairoj Chotikasathien) លើកឡើងថា ការព្រមព្រៀងនេះត្រូវបានធ្វើឡើងនៅក្នុងកិច្ចប្រជុំមួយរវាងអាជ្ញាធរផ្នែកការងាររបស់ថៃ និងកម្ពុជា ដើម្បីជួយសម្រួលដល់បញ្ហាខ្វះខាតពលករបរទេសនៅក្នុងប្រទេសថៃនៅពេលនេះ។ តាមរយៈកិច្ចព្រមព្រៀងនេះ ពលករចំណាកស្រុកខ្មែរក្នុងប្រទេសថៃ នឹងមិនចាំបាច់រង់ចាំដល់ទៅ៣០ថ្ងៃ គិតចាប់ពីថ្ងៃផុតកំណត់សុពលភាពនៃលិខិតអនុញ្ញាតឱ្យធ្វើការ ទើបអាចដាក់ពាក្យស្នើសុំឡើងវិញ ឬបន្តសុពលភាពដូចតាមលក្ខខណ្ឌទូទៅនោះទេ។ ហើយដំណើរការទាំងមូលនៃការដាក់ពាក្យស្នើសុំបន្តសុពលភាពនៃលិខិតអនុញ្ញាតឱ្យធ្វើការនេះ នឹងត្រូវធ្វើឡើងតាមប្រព័ន្ធអនឡាញ ដើម្បីផ្តល់ភាពងាយស្រួលដល់ពលករចំណាកស្រុកខ្មែរ។

គួរដឹងថា ក្រោមអនុស្សរណៈនៃការយោគយល់គ្នា (MOU) បច្ចុប្បន្នរវាងកម្ពុជា និងថៃ អនុញ្ញាតឱ្យពលករចំណាកស្រុកខ្មែរធ្វើការដោយស្របច្បាប់ក្នុងប្រទេសថៃរយៈពេល ៤ឆ្នាំ ដែលលិខិតអនុញ្ញាតឱ្យធ្វើការរបស់ពលករចំណាកស្រុកខ្មែរទាំងជាង៤ម៉ឺននាក់ខាងលើ នឹងត្រូវផុតកំណត់ក្នុងចន្លោះចាប់ពីខែមករា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣១ ខែកក្កដា ខាងមុខនេះ។

តាមរយៈវិទ្យុបារាំងអន្តរជាតិនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ លោក មឿន តុលា នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL) យល់ថា ជារឿងល្អដែលថៃយល់ព្រមសម្រួលលក្ខខណ្ឌសុពលភាពលិខិតអនុញ្ញាតធ្វើការរបស់ពលករខ្មែរ ប៉ុន្តែលោកនៅមានក្តីបារម្ភជុំវិញសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាអនឡាញរបស់ពួកគេ។ សម្រាប់លោក មឿន តុលា កិច្ចព្រមព្រៀងថ្មីនេះ អាចកាន់តែមានប្រសិទ្ធភាពបម្រើប្រយោជន៍ពលករខ្មែរ ប្រសិនបើស្ថានទូតខ្មែរនៅថៃ បង្កើនការគាំពារពលករខ្មែរ តាមរយៈការពន្លឿនដំណើរការធ្វើឯកសារការងារ ខណៈដារឿយៗ ពលករខ្មែរតែងត្អូញត្អែរពីភាពយឺតយ៉ាវ ក្នុងការរត់ឯកសារនៅស្ថានទូត ក៏ដូចជាការត្អូញត្អែរពីការចំណាយច្រើននៅពេលបន្តសុពលភាពការងាររបស់ពួកគេជាដើម។ គួរជម្រាបថា ក្នុងចំណោមពលករខ្មែរនៅក្រៅប្រទេសសរុប ១.៣លាននាក់បច្ចុប្បន្ននេះ គឺមាន១.២លាននាក់ កំពុងបម្រើការងារនៅប្រទេសថៃ៕

# ថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ២០២៣

## អង្គការសង្គមស៊ីវិលចំនួន ៤ ស្នើឱ្យរដ្ឋាភិបាលបញ្ឈប់ការបើកសុំកូនអន្តរប្រទេសឡើងវិញ ខណៈក្រសួងថាមិនទាន់មានការស្នើសុំកូនពីកម្ពុជានោះឡើយ

https://www.postkhmer.com/national/2023-06-28-1815-251801.html *ជា សុខនី* I Publication date 28 June 2023 I 18:15 ICT

***ភ្នំពេញ:*** *អង្គការសង្គមស៊ីវិលចំនួន ៤ បានស្នើឱ្យរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអ៊ីតាលី បញ្ឈប់នូវការបើកសុំកូនអន្តរប្រទេសឡើងវិញ តែរាជរដ្ឋាភិបាលកម្ពុជា គួរតែផ្តោតការយកចិត្តទុកដាក់លើការបង្កើនលទ្ធភាពទទួលបានការការពារ និងការគាំទ្រសង្គមរបស់គ្រួសារ ព្រមទាំងពង្រឹងប្រព័ន្ធថែទាំតាមគ្រួសារក្នុងស្រុកឱ្យបានខ្លាំង ក៏ដូចជាកសាងសមត្ថភាពអ្នកធ្វើកិច្ចការសង្គមទាំងអ្នកថ្មី និងអ្នកចាស់ ។*

*ការស្នើនេះ ត្រូវបានធ្វើឡើងតាមរយៈសេចក្តីថ្លែងការណ៍រួមមួយស្តីពី៖ ប្រទេសកម្ពុជា និងអ៊ីតាលី មិនគួរណែនាំការសុំកូនអន្តរប្រទេសទេ កាលពីថ្ងៃទី២៨ ខែមិថុនា ដែលអង្គការសង្គមស៊ីវិលទាំង ៤ នោះមាន មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា* (CCHR) *សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា* (ADHOC) *សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្សលីកាដូ* (LICADHO) *និង*Intercountry Adoptee Voices (ICAV)*។*

*សេចក្តីថ្លែងការណ៍បានលើកឡើងថា៖ «យើងខ្ញុំ ជាអង្គការសង្គមស៊ីវិល សូមស្នើសុំឱ្យរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអ៊ីតាលី បញ្ឈប់នូវការបើកសុំកូនអន្តរប្រទេសឡើងវិញ។ ប្រទេសកម្ពុជា មិនបានអនុម័តកិច្ចគាំពារ ដែលនឹងការពារអត្ថប្រយោជន៍ល្អបំផុតរបស់កុមារ ឬទប់ស្កាត់ការកើតឡើងវិញ នូវការក្លែងបន្លំ និងអំពើពុករលួយធ្ងន់ធ្ងរ ដែលបានកត់សម្គាល់នៅក្នុងការសុំកូនអន្តរប្រទេសដែលកើតមានពីអតីតកាល» ។ ប្រទេសជាច្រើន បានហាមឃាត់ការសុំកូនអន្តរប្រទេសពីប្រទេសកម្ពុជាពេញ១ទសវត្សរ៍ឆ្នាំ២០០០ បន្ទាប់ពីមានភស្តុតាងជាច្រើននៃការអនុវត្តដែលប្រាសចាកពីច្បាប់ និងគ្មានសីលធម៌ នេះរួមបញ្ចូលទាំងអាជ្ញាធរ និងបុគ្គលិកមណ្ឌលកុមារកំព្រា ដែលក្លែងបន្លំឯកសារប្រកាសថា កុមារមួយចំនួនជាក្មេងកំព្រា ឬជាក្មេងគេបោះបង់ចោល ដោយជាទូទៅមានការផ្លាស់ប្តូរឈ្មោះ និងថ្ងៃខែ ឆ្នាំកំណើតរបស់ពួកគេ។*

*អង្គការសង្គមស៊ីវិលចំនួន ៤ បានបញ្ជាក់ថា កុមារត្រូវបានគេសុំយកទៅចិញ្ចឹមនៅក្រៅប្រទេស ដោយពុំមានការយល់ព្រម ឬដឹងឮពីឪពុកម្តាយរបស់ពួកគេ។ ជាលទ្ធផល ប្រទេសកម្ពុជាខ្លួនឯងផ្ទាល់ បានផ្អាកការសុំកូនអន្តរប្រទេសនៅក្នុងឆ្នាំ២០០៩។*

យោងតាមសេចក្តីថ្លែងការណ៍រួមដដែលនេះបានលើកឡើងថា ប្រទេសកម្ពុជា និងអ៊ីតាលី បានជំរុញឱ្យមានការបើកការសុំកូនអន្តរប្រទេសឡើងវិញ ដែលគណៈប្រតិភូមកពីគណៈកម្មាធិការសុំកូនអន្តរប្រទេសនៃប្រទេសអ៊ីតាលី បានជួបជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កាលពីអំឡុង ខែឧសភា ឆ្នាំ២០២៣។

យោងតាមការរាយការណ៍ របស់គណៈកម្មាធិការសុំកូនអន្តរប្រទេសអ៊ីតាលី កាលពីថ្ងៃទី១៧ ខែឧសភា បានឱ្យដឹងថា កាលពីថ្ងៃទី១ ដល់ទី៦ ខែឧសភា គណៈប្រតិភូមកពីគណៈកម្មាធិការសុំកូនអន្តរប្រទេស(CAI)បានមកប្រទេសកម្ពុជា ក្នុងគោលបំណងបន្តកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរកម្ពុជាសម្រាប់ការសុំកូនអន្តរជាតិ (ICAA) និងពិនិត្យពីស្ថានភាពនៃដំណើរការនៃនីតិវិធីការទទួលស្គាល់ឡើងវិញនៃស្ថាប័នដែលមានការអនុញ្ញាតពីប្រទេសអ៊ីតាលី (EEAA)។

គណៈកម្មាធិការសុំកូនអន្តរប្រទេសអ៊ីតាលី បានបញ្ជាក់ថា៖ «ប្រទេសកម្ពុជានឹងរៀបចំជាផ្លូវការនូវបញ្ជីឈ្មោះកុមារដែលគ្រប់លក្ខខណ្ឌក្នុងការសុំកូន ប្រហែលជាក្នុងខែមិថុនា ឆ្នាំ២០២៣។ កុមារ២នាក់ក្នុងចំណោមក្នាក់ងារមួយ ត្រូវបានរំពឹងថា នឹងត្រូវផ្គូផ្គងជាមួយគ្រួសារជនជាតិអ៊ីតាលី ត្រឹមដំណាច់ឆ្នាំនេះ ហើយគណៈប្រតិភូប្រទេសកម្ពុជា ត្រូវបានអញ្ជើញទៅកាន់ប្រទេសអ៊ីតាលី នៅឆ្នាំ២០២៤ ដើម្បីបន្តតាមដានកូនចិញ្ចឹមទាំងនោះ»។

សេចក្តីថ្លែងការណ៍រួមនេះ បានបញ្ជាក់ថា៖ «ការបើកឱ្យមានការសុំកូនអន្តរប្រទេសឡើងវិញ ដោយប្រថុយប្រថាន និងខ្វះការទទួលខុសត្រូវច្បាស់លាស់នេះ គឺជាការប្រឆាំងនឹងការអនុវត្តច្បាប់ជាតិ និងអន្តរជាតិ។ ច្បាប់ជាតិ និងអន្តរជាតិកំណត់ថា ការសុំកូនអន្តរប្រទេស គួរតែធ្វើឡើងបន្ទាប់ពីការប្រើប្រាស់រួចហើយនូវគ្រប់មធ្យោបាយថែទាំកុមារតាមគ្រួសារនៅក្នុងប្រទេសកំណើតរបស់ពួកគេ»។ ប្រភពដដែលបន្តថា៖ «រាជរដ្ឋាភិបាលកម្ពុជា គួរតែផ្តោតការយកចិត្តទុកដាក់លើការបង្កើនលទ្ធភាពទទួលបានការការពារ និងការគាំទ្រសង្គមរបស់គ្រួសារ ព្រមទាំងពង្រឹងប្រព័ន្ធថែទាំតាមគ្រួសារក្នុងស្រុកឱ្យបានខ្លាំងក៏ដូចជាកសាងសមត្ថភាពអ្នកធ្វើកិច្ចការសង្គមទាំងអ្នកថ្មីនិងអ្នកចាស់»។ ជាមួយគ្នានេះ ក្រុមអង្គការសង្គមស៊ីវិលចំនួន៤ បានបង្ហាញនូវក្តីសង្ឃឹមដែរថា រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអ៊ីតាលី អាចបញ្ឈប់ជាបន្ទាន់នូវការបើកសុំកូនអន្តរប្រទេសឡើងវិញ ដើម្បីធានាថាគ្មានកុមារ និងគ្រួសារប្រជាពលរដ្ឋខ្មែរណាមួយ ត្រូវបែកចេញពីគ្នាម្តងទៀត។

ទាក់ទងនឹងការលើកឡើងរបស់ក្រុមអង្គការសង្គមស៊ីវិលចំនួន៤នេះ លោក តូច ចាន់នី អ្នកនាំពាក្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានប្រាប់ឱ្យដឹងថា ក្រសួងមិនទាន់បានឃើញនូវសេចក្តីថ្លែងការណ៍ជាផ្លូវការរបស់ក្រុមអង្គការសង្គមស៊ីវិលទាំងនោះនៅឡើយទេ។ ប៉ុន្តែអ្វីដែលអង្គការទាំងនោះ បានស្នើសុំបញ្ឈប់នូវការបើកសុំកូនអន្តរប្រទេសរវាងកម្ពុជាជាមួយអ៊ីតាលី

*លោកបានបញ្ជាក់ថា រហូតមកដល់ពេលនេះក្រសួងមិនទាន់បានទទួលនូវការសុំកូនណាម្នាក់ឡើយ ជាមួយប្រទេសអុីតាលី ក្រោយពេលដែលក្រសួងបើកឱ្យមានការសុំកូន ប៉ុន្តែក្រសួងក៏មិនទាន់បាន ដំណើរការអ្វីទាំងអស់នោះទេ ពីព្រោះក្រសួងកំពុងត្រូវការរៀបចំនីតិវិធី និងរៀបចំឯកសារឱ្យបាន ត្រឹមត្រូវគ្រប់គ្រាន់ផងដែរ។*

*ក្រៅពីនេះទៀត លោកថា ក្រសួងក៏មិនអាចធ្វើតាមអ្វីដែលក្រុមអង្គការសង្គមស៊ីវិលទាំងនោះ ស្នើដែរ ព្រោះក្រសួងធ្វើការទៅតាមគោលការណ៍ ទៅតាមច្បាប់ ទៅតាមគោលនយោបាយរបស់រាជ រដ្ឋាភិបាល ពិសេសកម្ពុជាក៏មានច្បាប់ អនុសញ្ញាអន្តរជាតិស្តីពីសុំកូនអន្តរជាតិជាច្រើនដែរ។ លោក តូច ចាន់នី បានថ្លែងថា៖ «ខ្ញុំដូចអត់យល់រឿងសង្គមស៊ីវិលទាំងប៉ុន្មាន វាចេះតែបារម្ភអ៊ីចឹង ហើយ មកដល់ពេលនេះមិនទាន់មានការសុំកូនណាមួយ ហើយក៏មិនទាន់អ្នកណាដាក់ពាក្យសុំកូនដែរ។ យើងគ្រាន់តែធ្វើការរៀបចំ យើងបើកមែន ប៉ុន្តែយើងរៀបចំឱ្យមានភ្នាក់ងារសុំកូនអន្តរប្រទេសគឺ ពាក់ព័ន្ធនឹងអុីតាលី គឺអុីតាលីត្រូវស្នើសុំមកតាមរយៈភ្នាក់ងារសុំកូន ហើយបើពាក់ព័ន្ធសហរដ្ឋអា មេរិក សហរដ្ឋអាមេរិកត្រូវស្នើមកភ្នាក់ងារដែរ»។ លោកបានបន្ថែមថា ដូច្នេះក្រសួងមិនទាន់ទទួល បានពាក្យស្នើសុំកូនណាមួយពីអន្តរប្រទេសនោះទេ ហើយក្រសួងក៏ធ្វើតែតាមគោលការណ៍ និង គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាតែប៉ុណ្ណោះ៕*